# ប្រជុំក្រមងអត្ថបទ

## ស្តីអំពី

## ព្រះពុទ្ធសាសនា

រៀបរៀងដោយ

**សមណនិស្សិត និងនិស្សិតខ្មែរ**

*បោះពុម្ពលើកទី ១*

ចំនួន .................

ការផ្សាយរបស់

**សមាគមសមណនិស្សិតខ្មែរ**

*ទីក្រុងយ៉ាំងហ្គូន សហភាពមីយ៉ាន់ម៉ា*

**ព.ស ២៥៥៣**

## មាតិកាធម៌

ទំព័រ

និវេទនកថា ............................................................... ក

ឈ្មោះគម្ពីរអក្សរសង្ខេប ............................................... ឃ

សេចក្ដីផ្ដើម ............................................................... ង

ឧទ្ទិសកថា ................................................................... ឈ

កាតព្វកិច្ចរបស់មាតាបិតា ............................................... ១

ភិក្ខុ ស៊ុយ សុវណ្ណ

ការងាររបស់វិញ្ញាណទាំងប្រាំមួយ ................................... ១៣

ភិក្ខុ មួន វិចិត្រ

ដំណើរនៃជីវិត ............................................................ ២១

ភិក្ខុ ឡេង ប៊ុននាង

ជ្រុងមួយនៃពុទ្ធសាសនា ................................................ ៣១

សាមណេរ ថុង ត្រាកន

អបាយមុខ ៤ ប្រការ ..................................................... ៣៧

ភិក្ខុ ង៉ាន ភាគ

គុណភាពនៃជីវិត .......................................................... ៤៩

ភិក្ខុ អ៊ុំ សត្ថា

ភាពប្រសើរជាងគេរបស់មនុស្ស ..................................... ៥៣

សាមណេរ ជិន ម៉ៅ

ព្រះសង្ឃខ្មែរ ................................................................ ៦៣

ភិក្ខុ វ៉ា ចន្ទ័ប៊ន់

មនុស្សជាអ្វី ................................................................ ៧៩

សាមណេរ ផ្លិច មាស

គោលព្រះពុទ្ធសាសនា ៣ យ៉ាង ...................................... ៩៣

លោក ព្រុំ ស៊ីណា

ការងារប្រាំប្រការដែលត្រូវបំពេញសន្សឹមៗ ..................... ១០១

លោក ម៉ៅ ស៊ីថា

គន្លឹះមូលដ្ឋានគ្រឹះដើម្បីជោគជ័យក្នុងវិថីជីវិត .................... ១១១

សាមណេរ កាឡាន ម៉េងហុង

សាសនាគួរជឿ ........................................................... ១២៣

ភិក្ខុ លាង សារ៉យ

លោកសណ្ឋានកថា ....................................................... ១៣៣

សាមណេរ សុខ ធាវី

លក្ខណៈសំខាន់ ៤ យ៉ាង ក្នុងការយល់អំពីព្រះនិព្វាន ........... ១៤៧
ភិក្ខុ ឈុំ ឆន
នវទស្សនៈ ..................................................................... ១៧៣
ភិក្ខុ សឿង វុទ្ធី
សេចក្ដីសន្និដ្ឋានរួម

## សួនកំណាព្យ

យុវ៉ន និងសង្គម ........................................................ ១៧៣
សាមណេរ កាឡាន ម៉េងហុង
តណ្ហាទាសៈ .............................................................. ១៧៦
សាមណេរ កាឡាន ម៉េងហុង
គុណធម៌របស់ពុកម៉ែ .................................................. ១៨០
ភិក្ខុ ស៊ុយ សុវណ្ណ
ល្បែងបួនប្រការ ........................................................ ១៨៧
ភិក្ខុ ង៉ាន ភាគ
សន្តានចិត្តម៉ែ ............................................................ ១៨៨
ភិក្ខុ ស៊ុយ សុវណ្ណ
យោងសេចក្ដី
គន្ថនិទ្ទេស

# និវេទនកថា

ខ្ញុំព្រះករុណាអាត្មាភាពទាំងអស់អង្គ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះលោកអ្នកអានទាំងអស់ដែលតែងតែគាំទ្រនូវស្នាដៃ ដែលជាសមិទ្ធិផលរបស់សមណនិស្សិតខ្មែរនៅសហភាព-មីយ៉ាន់ម៉ា។ ជាពិសេស ខ្ញុំព្រះករុណាអាត្មាភាពទាំងអស់អង្គ សូមថ្លែងអំណរគុណ និងការដឹងគុណ យ៉ាងជ្រាលជ្រៅបំផុតចំពោះ ៖

១-សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្រ្តីនៃរាជរដ្ឋាភិបាលកម្ពុជា ដែលសម្តេចតែងតែយកចិត្តទុក-ដាក់ ក្នុងការឧបត្ថម្ភសមណនិស្សិតខ្មែរឱ្យបានសិក្សានៅសហភាព-មីយ៉ាន់ម៉ាគ្រប់ជំនាន់។

២-ឯកឧត្តម **ឆួង ងឹន** ឯកអគ្គរាជទូតខ្មែរ ប្រចាំសហ-ភាពមីយ៉ាន់ម៉ា និងលោកជំទាវ ព្រមទាំងសហការី ដែលបានចូលរួមចំណែកឧបត្ថម្ភសមណនិស្សិតខ្មែរយើង ទាំងផ្នែកស្មារតី និងបច្ច័យបួនជារៀងរាល់ឆ្នាំ ស្របតាមពិធីបុណ្យធំៗ តាមប្រពៃណីទំនៀមទម្លាប់របស់ព្រះពុទ្ធសាសនាយើង។

៣- អ្នកស្រី **ឌួត គន្ធា** ទីប្រឹក្សាស្ថានទូត, លោក **ទ៉ិត ណារិទ្ធ** លេខាស្ថានទូត នៃឯកអគ្គរាជទូតខ្មែរ ប្រចាំសហភាព



មីយ៉ាន់ម៉ា និងក្រុមគ្រួសារ ដែលតែងតែឧបត្ថម្ភបច្ច័យបួនដល់សមណនិស្សិតខ្មែរ។

៤- ញោមស្រី **គី សុភា** និង ញោមប្រុស **ម៉ែរត វ៉ាន់ក្ងុល** ព្រមទាំងបុត្រា ដែលតែងតែឧបត្ថម្ភចង្ហាន់ដល់សមណនិស្សិតខ្មែរ ជារៀងរាល់ថ្ងៃពុធ និងសម្ភារៈប្រើប្រាស់ផ្សេងៗ។

៥-ឧបាសក **ម៉ៅ វ៉ាន** និង ឧបាសិកា **ឆន់ សំបូរ** អតីតទីប្រឹក្សាឯកអគ្គរាជទូតខ្មែរ ប្រចាំសហភាពមីយ៉ាន់ម៉ា ដែលតែងតែ ឧបត្ថម្ភទាំងអាមិសទាន និងធម្មទាន មានប្រគេនចង្ហាន់ជារៀងរាល់ថ្ងៃសៅរ៍ និងជាវព្រះត្រៃបិដកជាភាសាអង់គ្លេស ដល់សមណនិស្សិតខ្មែរគ្រប់ព្រះអង្គ។

៦-ឧបាសក **លឹម ហ៊ុយគាង** និងឧបាសិកា **ហេង នាង** នៅប្រទេសកាណាដា ដែលតែងតែបរិច្ចាគបច្ច័យ ជួយបោះពុម្ពសៀវភៅរបស់សមាគមសមណនិស្សិតខ្មែរជារៀងរាល់ឆ្នាំ។

៧- ញោម មហាឧបាសិកា **ភាំង ឃ្លិចណៃ** ព្រមទាំងក្រុមគ្រួសារដែលតែងតែឧបត្ថម្ភបច្ច័យបួន ដល់សមាគមសមណ-និស្សិតខ្មែរជារៀងរាល់ឆ្នាំ។

៨- ញោម **គីម មួយ** ដែលតែងតែមានសទ្ធាជ្រះថ្លាបវារណាបច្ច័យបួន ដល់សមាគមសមណនិស្សិតខ្មែរ។

*៩-ព្រះសង្ឃ គណៈកម្មាធិការ សីលវន្ត សីលវតី ឧបាសក ឧបាសិកា និងពុទ្ធបរិស័ទនៅពុទ្ធមណ្ឌលវិបស្សនាធុរៈ នៃព្រះរាជាណាចក្រកម្ពុជា* ដែលតែងតែជួយផ្គត់ផ្គង់សម្ភារៈប្រើប្រាស់ក្នុងសមាគម គ្រឿងបរិភោគ និងបច្ច័យបួនដល់សមណនិស្សិតខ្មែរ ជារឿយៗ។

លើសពីនេះទៅទៀត ខ្ញុំព្រះករុណាអាត្មាភាពទាំងអស់អង្គ សូមថ្លែងអំណរគុណ និងសូមសម្ដែងនូវ កតញ្ញូតាធម៌ដ៏ជ្រាលជ្រៅបំផុត ចំពោះព្រះតេជគុណគ្រប់ព្រះអង្គ និងញាតិញោមពុទ្ធបរិស័ទទាំងក្នុង និង ក្រៅប្រទេស ដែលតែងតែជួយលើកទឹកចិត្តមានការឧបត្ថម្ភបច្ច័យបួនដល់ព្រះសង្ឃ និងការបោះពុម្ពសៀវភៅ របស់សមាគមសមណនិស្សិតខ្មែរជារៀងរាល់ឆ្នាំ។

ជាទីបញ្ចប់ ខ្ញុំព្រះករុណាអាត្មាភាពទាំងអស់អង្គ សូមប្រគេនពរ និង ជូនពរដល់ព្រះតេជគុណ ញាតិញោម ពុទ្ធបរិស័ទទាំងក្នុង និងក្រៅ ប្រទេសឱ្យជួបប្រទះនឹងពុទ្ធពរបួនប្រការគឺៈ អាយុ វណ្ណៈ សុខៈ និង ពលៈ កុំបីអាក់ខានឡើយ។

# ឈ្មោះគម្ពីរអក្សរសង្ខេប

| | | |
|---|---|---|
| - អង្គ. អដ្ឋក. | = | អង្គុត្តរនិកាយ អដ្ឋកនិបាត |
| - អង្គ. តិក. | = | អង្គុត្តរនិកាយ តិកនិបាត |
| - អាគត. | = | អាគតដ្ឋានដូចគ្នា |
| - ខុ. ធ. | = | ខុទ្ទកនិកាយ ធម្មបទ |
| - ខុ. មហា. | = | ខុទ្ទកនិកាយ មហានិទ្ទេស |
| - ទី. បា. | = | ទីឃនិកាយ បាដិកវគ្គ |
| - ប. ធម្ម. | = | បទានុក្រមធម្មបទ |
| - វិ. ចុល្ល. | = | វិន័យបិដក ចុល្លវគ្គ |
| - វិនយ. អ. | = | វិនយ អដ្ឋកថា (សមន្តបាសាទិកា) |

# សេចក្តីផ្តើម

នៅប្រទេសកម្ពុជានាយុគសម័យនេះ គម្ពីរក្បួនច្បាប់ផ្នែកព្រះពុទ្ធសាសនា គឺជាតម្រូវការដ៏ចាំបាច់មួយ សម្រាប់ការស្រាវជ្រាវ, ការអប់រំសីលធម៌, ការពង្រីកពុទ្ធិ, ការឈ្វេងយល់ពីមាគ៌ាជីវិតឱ្យបានត្រឹមត្រូវ, ការរស់នៅប្រកបដោយភាពថ្លៃថ្នូរក្នុងសង្គម ក៏ដូចជាការសិក្សាជាទូទៅ នៅតាមគ្រឹះស្ថាននានាដែលមិនអាចខ្វះបាន។

ដើម្បីបំពេញតាមតម្រូវការ នៃការអភិវឌ្ឍធនធានមនុស្ស សមណនិស្សិត និងនិស្សិតខ្មែរគ្រប់ព្រះអង្គ គ្រប់រូប នៅទីក្រុងយ៉ាំងហ្គូន សហភាពមីយ៉ាន់ម៉ា ដែលកំពុងស្នាក់សិក្សា នៅសាកលវិទ្យាល័យពុទ្ធសាសនទូតថេរវាទអន្តរជាតិ ផ្នែកព្រះពុទ្ធសាសនា បានឆ្លៀតឱកាសដ៏មមាញឹក ពីការសិក្សាក្រេបជញ្ជក់យកនូវចំណេះដឹងជាសាកលនេះ ចូលរួមបញ្ចេញស្នាដៃនានា ទៅតាមសមត្ថភាពជាក់ស្តែងដែលខ្លួនមាន ដើម្បីប្រមូលចងក្រងឱ្យកើតបានជាសៀវភៅនេះឡើង ប្រយោជន៍ដើម្បីផ្សព្វផ្សាយវប្បធម៌ព្រះពុទ្ធសាសនា ដល់បណ្ឌាបញ្ញវន្ត ក៏ដូចជាពុទ្ធបរិស័ទទូទៅ ក្នុងន័យជួយពង្រីង និង



ពង្រីកស្មារតី ចំណេះដឹងបន្ថែមទៀត។ សព្វថ្ងៃនេះ គម្ពីរក្បួនខ្នាតផ្នែកព្រះពុទ្ធសាសនា នៅបណ្តាប្រទេស អ្នកកាន់ព្រះពុទ្ធសាសនាដូចគ្នា គេមានសំបូរបែបណាស់។ ដោយឡែក ប្រទេសខ្មែរដ៏អភ័ព្វរបស់យើង ពុំសូវមានច្រើនឡើយ ក្រៅពីគម្ពីរធម៌អាថ៌ដែលបានបន្សល់ទុកពីយុគសម័យ សម្តេចព្រះសង្ឃរាជ ព្រះមហាសុមេធាធិបតី **ជួន ណាត** (ជោតញ្ញាណោ)។ ប៉ុន្តែ យើងក៏គួរមានមោទនភាពផងដែរ ចំពោះស្នាដៃបញ្ញវន្តជំនាន់ថ្មី ដែលកំពុងរីកចម្រើនយ៉ាងផុសផុល បានស្ថាបនាក្បួនច្បាប់នានា ទាំងផ្នែកពុទ្ធចក្រ និងអាណាចក្រ។ ទន្ទឹមនឹងនេះ សមណនិស្សិត និងនិស្សិតខ្មែររបស់យើង នៅសហភាពមីយ៉ាន់ម៉ា (ភូមា) បាននឹងកំពុងរួមសាមគ្គីគ្នាបង្កើតកម្រងអត្ថបទជារៀងរាល់ឆ្នាំ ដោយបានដាក់វេនគ្នា ជាភាសាខ្មែរមួយឆ្នាំ ជាភាសាអង់គ្លេសមួយឆ្នាំ រួចបោះពុម្ពចែកជាធម្មទានទូទៅ។ វណ្ណកម្ម ដែលកើតឡើងដោយសេចក្តីព្យាយាមរបស់សមណនិស្សិត និងនិស្សិតខ្មែរ នៅសហភាពមីយ៉ាន់ម៉ានេះ បានបោះពុម្ពផ្សាយចំនួនប្រាំបីជំនាន់រួចមកហើយ ប៉ុន្តែចំណងជើងសៀវភៅត្រូវបានរក្សានៅដដែល ទាំងភាសាខ្មែរ និងភាសាអង់គ្លេស។ រីឯកម្រងអត្ថបទ អត្ថន័យ អត្ថរស ខ្លឹមសារ ដែលមាននៅក្នុងវណ្ណកម្មនេះ មិនដូចគ្នាទេ ពីមួយជំនាន់ ទៅមួយជំនាន់។ សមណនិស្សិត

យើង បានព្យាយាមប្រឹងប្រែងកែតម្រូវ ធ្វើយ៉ាងណាឱ្យកម្រងអត្ថបទកាន់តែប្រសើរ និងងាយស្រួលដល់សិក្ខាកាម អ្នកស្នេហាការសិក្សាស្រាវជ្រាវទាំងឡាយ ។ ជាក់ស្ដែង វណ្ណកម្មដែលកំពុងស្ថិតក្នុងដៃលោកអ្នកអាននេះ គឺរឹងរឹតតែធ្វើឱ្យមានភាពងាយស្រួលជាងបណ្ដាជំនាន់មុនៗទាំងអស់ ។ នៅក្នុងវណ្ណកម្មនេះ មានចង្អុលបង្ហាញពីឈ្មោះគម្ពីរ ភាគ ទំព័រ អ្នកនិពន្ធ អ្នករៀបរៀង ឬអ្នកបកប្រែយ៉ាងជាក់ច្បាស់ ដើម្បីឱ្យលោកអ្នកអាន អ្នកសិក្សាទាំងឡាយងាយស្រួលក្នុងការរកប្រភពអត្ថបទ និងសិក្សាស្រាវជ្រាវបន្ថែមទៀតទៅលើអត្ថបទនីមួយៗ ។ ចំណែកឯអក្ខរាវិរុទ្ធវិញ សមណនិស្សិត និងនិស្សិតខ្មែរយើងបានឯកភាពគ្នា យកតាម *វចនានុក្រមខ្មែររបស់សម្ដេចព្រះសង្ឃរាជ* **ជួន ណាត** *ជោតញ្ញាណោ* ទាំងស្រុង ដោយមិនបានសរសេរតាមយុគសម័យថ្មីឡើយ ព្រោះវាអាចធ្វើឱ្យកូនខ្មែរទាំងឡាយ ចងចាំនូវបិតាដែលជាអ្នកបង្កើតនូវអក្សរសាស្ត្រជាតិរបស់ខ្លួន នាំគ្នារឹងរឹតតែគោរពស្រឡាញ់ដឹងគុណលោក ព្រមទាំងនាំគ្នាជួយថែរក្សាកេរមរតកនេះ ឱ្យគង់វង្សជាអមតៈ ។

ប៉ុន្តែទោះបីជា ខិតខំប្រឹងប្រែងរៀបចំកែសម្រួលយ៉ាងណា ក៏ខ្ញុំព្រះករុណាអាត្មាភាពទាំងអស់អង្គ មិនបានគិតថា វណ្ណកម្មនេះត្រឹម



ត្រូវឥតខ្ចោះនោះឡើយ ។ ខុស និងត្រូវតែងតែធ្វើដំណើរតាមក្រោយជានិច្ច គ្រាន់តែថា មានច្រើន ហើយនិងតិចប៉ុណ្ណោះ ។

អាស្រ័យហេតុនេះ ខ្ញុំព្រះករុណាអាត្មាភាពទាំងអស់អង្គ សូមអភ័យទោសទុកជាមុនចំពោះលោកអ្នកអានទាំងឡាយ ប្រសិនបើមានការខុសឆ្គង ឬខ្វះចន្លោះ សេចក្ដីដោយអចេតនាណាមួយនោះ ។ ជាមួយគ្នានេះដែរ ខ្ញុំព្រះករុណាអាត្មាភាពទាំងអស់អង្គ ក៏សូមរង់ចាំទទួលស្វាគមន៍ ចំពោះការរិះគន់ស្ថាបនាកែលំអពីសំណាក់ លោកអ្នកអានគ្រប់មជ្ឈដ្ឋាន ដោយសេចក្ដីសោមនស្សរីករាយ ។

សូមអំពើល្អ តាមជួយថែរក្សាអស់លោកអ្នកគ្រប់ ពេលវេលាកុំបីឃ្លៀងឃ្លាតឡើយ ។

សមណនិស្សិត និងនិស្សិតខ្មែរ
ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩
សាកលវិទ្យាល័យពុទ្ធសាសនាទូតថេរវាទអន្តរជាតិ
ទីក្រុងយ៉ាំងហ្គូន, សហភាពមីយ៉ាន់ម៉ា

# ឧទ្ទិសកថា

ខ្ញុំព្រះករុណាអាត្មាភាព ជាសមណនិស្សិតធម្មទូតខ្មែរ ដែលកំពុងស្នាក់សិក្សា នៅសាកលវិទ្យាល័យពុទ្ធសាសនទូតថេរវាទអន្តរ-ជាតិ នៃសហភាពមីយ៉ាន់ម៉ា (ភូមា) ទាំងអស់ សូមឧទ្ទិសកុសលផលបុណ្យ ដែលកើតអំពីការព្យាយាមចងក្រងសៀវភៅ "ប្រជុំកម្រងអត្ថបទស្តីអំពីព្រះពុទ្ធសាសនា" ជំនាន់ទី៩ ដើម្បីជាប្រយោជន៍ដល់ជនជាច្រើន ដើម្បីសេចក្តីសុខចម្រើនដល់មនុស្ស និងទេវតាទាំងឡាយ និងដើម្បីសន្តិភាពដល់ពិភពលោកទាំងមូលនេះ ប្រគេនថ្វាយ និងជូនចំពោះ អតីតវិញ្ញូសមណនិស្សិត, ព្រះមហាវិរក្សត្រ, វិរបុរស, និងកវីបណ្ឌិតខ្មែរ ជំនាន់មុន ដូចជា:-

-សម្តេចព្រះសង្ឃរាជ ព្រះមហាសុមេធាធិបតី **ជួន ណាត** (ជោតញ្ញាណោ)

-ព្រះភិក្ខុ **ហួត តាត** សម្តេចព្រះសង្ឃរាជពីឆ្នាំ ១៩៦៩-១៩៧៥

-ព្រះភិក្ខុ **អ៊ុំ ស៊ូ** (ព្រះឧត្តមមុនី)

-ព្រះភិក្ខុ **លី ឯម** (សម្តេចព្រះធម្មលិខិត)



-ព្រះភិក្ខុ **ប៉ាង ខាត់** (វីរិយបណ្ឌិតោ)

-ព្រះភិក្ខុ **ខៀវ ជុំ** (ធម្មបាលោ)

-ព្រះភិក្ខុ **សេក នាង** (សារញ្ញាណោ)

-ព្រះភិក្ខុ **ស៊ុខ ស៊ីវ** (ព្រះបាឡាត់ឧត្តមលិខិត សិទ្ធត្ថោ)

-ព្រះភិក្ខុ **ប៊ុន សម្អាង**

-ព្រះភិក្ខុ **ស៊ូ ហាយ** ជាដើម។

សូមប្រគេន និងជូនបុណ្យកុសលនេះ ចំពោះព្រះសង្ឃ និងញាតិញោមក្នុងនិងក្រៅប្រទេសទាំងអស់ ដែលបានជួយឧបត្ថម្ភ ដល់សមាគមសមណនិស្សិតខ្មែរយើង ជារៀងរាល់ឆ្នាំ។ សូមព្រះតេជ-គុណ និងញាតិញោមជាបុព្វការីទាំងអស់ មេត្តាទទួលយកនូវមគ្គ-ផលកុសលនៃធម្មទាននេះ តាមសេចក្តីពេញចិត្តចុះ ហើយសូមព្រះតេជគុណ និងញាតិញោមទាំងអស់ ជួបប្រទះតែនឹងសេចក្តីសុខសេចក្តីចម្រើនជាភិយ្យោភាពតរៀងទៅ កុំបីឃ្លៀងឃ្លាតក្លាយជាបការៈដទៃឡើយ។

# កាតព្វកិច្ចរបស់មាតាបិតា

*ដោយភិក្ខុ* **ស៊ុយ សុវណ្ណ** (ថ្នាក់បរិញ្ញាបត្រ)

មាតាបិតាមានតួនាទីយ៉ាងសំខាន់បំផុត ក្នុងការចិញ្ចឹមបីបាច់ថែរក្សា អប់រំទូន្មានប្រៀនប្រដៅកូនរបស់ខ្លួន ឱ្យក្លាយជាពលរដ្ឋល្អក្នុងសង្គម ទោះបីជាស្ថិតនៅក្នុងកាលៈទេសៈណាក៏ដោយ។ កូនដែលកើតមកហើយ គឺពិតជាត្រូវការ ការយកចិត្តទុកដាក់មើលការខុស-ត្រូវពីមាតាបិតា មិនថាពួកគេរស់នៅទីណានោះទេ។ ទាក់ទិននឹងតួនាទីរបស់មាតាបិតា ខ្ញុំសូមលើកយកអត្ថបទមួយស្តីពី "កាតព្វកិច្ចរបស់មាតាបិតា" តាមដំបូន្មានរបស់ព្រះសម្មាសម្ពុទ្ធ ជាម្ចាស់នៃយើង មករៀបរាប់នៅក្នុងសៀវភៅ "ប្រជុំកម្រងអត្ថបទ ស្តីអំពីព្រះពុទ្ធសាសនា" នាឆ្នាំសិក្សា ២០០៩ នេះ។

ឥឡូវនេះ យើងត្រូវឈ្វេងយល់ពីពាក្យ "មាតា" និងពាក្យ "បិតា" ជាមុនសិន។ "មាតា" ជាភាសាបាលី តាមវេយ្យាករណ៍បាលី "មាតា" មកពី "មាន ធាតុ បូកនិង រាតុ បច្ច័យ" ដូចមានវិគ្គហៈថា "បុត្តំ មានេតីតិ = មាតា, មានន័យថាៈ "ស្ត្រីអ្នករាប់-អាននូវកូន" ឬម្យ៉ាងទៀត "មាតា" មកពីពាក្យ "បា ធាតុ បូកនិង រាតុ បច្ច័យ (បា ប្តូរទៅជា ម)" មានវិគ្គហៈថា "បុត្តំ បាតីតិ= មាតា



មានន័យថា "ស្ត្រីអ្នកថែរក្សានូវកូន"។[១] រីឯពាក្យថា "បិតា" វិញក៏ជាភាសាបាលី ដែលមកពី "បា ធាតុ បូកនិង រិតុ បច្ច័យ" មានវិគ្គហៈថា "បុត្តំ បាតិ រក្ខតីតិ= បិតា មានន័យថា "(បុរស) អ្នករក្សានូវកូន"។[២]

តាមសេចក្តីពន្យល់នៃពាក្យ "មាតាបិតា" ខាងលើនេះ យើងពិតជាអាចយល់បានថា មាតាបិតាមានទំនួលខុសត្រូវចំពោះមនុស្សទាំងឡាយ និងចិញ្ចឹមបីបាច់កូនផ្ទាល់របស់ខ្លួន។ ប្រសិនបើកូននោះកើតមកមានកំលាំងមាំមួនល្អ, សុខភាពល្អ, និងជាពលរដ្ឋល្អ វាជាលទ្ធផលនៃការប្រឹងប្រែងរបស់យើង ជាមាតាបិតាខ្លួនឯង។ ប្រ-សិនបើ កូននោះធំពេញវ័យក្លាយជាជនល្មើស មាតាបិតាក៏ត្រូវតែចេញមុខទទួលខុសត្រូវចំពោះបញ្ហានេះដែរ។ សូមកុំស្តីបន្ទោសអ្នកដទៃឱ្យសោះ។ ក្នុងនាមជាមាតាបិតា វាជាកាតព្វកិច្ចរបស់ខ្លួន ក្នុងការណែនាំកូនឱ្យដើរតាមផ្លូវត្រូវ។

កូននៅក្នុងវ័យភ្លើតភ្លើន (ឈាមរាវ) ពួកគេត្រូវការសេចក្តីស្រឡាញ់ថ្នាក់ថ្នម, ថែរក្សា, និងការយកចិត្តទុកដាក់ពីមាតាបិតា។ ប្រសិនបើ មិនមានសេចក្តីស្រឡាញ់ និងការណែនាំរបស់មាតាបិតាទេ កូននឹងត្រូវជួបឧបសគ្គ ហើយនឹងយល់ថា ពិភពលោកនេះជាកន្លែងដែលធ្វើឱ្យឡប់ស្មារតីក្នុងការរស់នៅ។ ទោះជាយ៉ាងណា ការ

បង្ហាញនូវសេចក្ដីស្រឡាញ់, ការថែទាំ, និងការយកចិត្តទុកដាក់របស់មាតាបិតា មិនមែនមានន័យថា ត្រូវតែបំពេញបំណងគ្រប់ការទាមទាររបស់កូន ឬក៏ហេតុផលណាផ្សេងនោះឡើយ។ ការថ្នាក់ថ្នមកូនហួសហេតុពេក នឹងធ្វើឱ្យកូនទទម្រើស។ ក្នុងការបង្ហាញនូវសេចក្ដីស្រឡាញ់ និងការថ្នាក់ថ្នម មាតាគួរគប្បីតឹងរ៉ឹង និងរឹងមាំចំពោះការច្រឡោតខឹងរបស់កូន។ ការតឹងរ៉ឹង និងរឹងមាំនេះមិនមែនមានន័យថា ជាការគំរោះគំរើយដាក់កូននោះទេ។ ចូរបង្ហាញនូវសេចក្ដីស្រឡាញ់ ប្រកបព្រមដោយវិន័យ ពេលនោះកូនអាចយល់បាន។ ជាអកុសល ក្នុងចំណោមមាតាបិតាសព្វថ្ងៃនេះ សេចក្ដីស្រឡាញ់របស់មាតាបិតាមានតិចតួចណាស់។ ការឈ្លក់វង្វេងទៅនឹងសម្ភារៈនិយម ជាហេតុធ្វើឱ្យមាតាទាំងឡាយចូលរួមជាមួយស្វាមីរបស់ពួកគេ, ចំណាយពេលវេលាធ្វើការងារនៅការិយាល័យ និងហាង ច្រើនជាងចំណាយពេលវេលានៅផ្ទះថែរក្សាកូន។ កូនត្រូវទុកផ្ញើនឹងញាតិ ឬអ្នកបម្រើ ជាហេតុធ្វើឱ្យពួកគេខ្វះភាពកកក្ដៅ បដិសេធនូវសេចក្ដីស្រឡាញ់ និងការថែរក្សាដោយមាតាបិតា។ មាតាដែលមានការសោកស្ដាយ អំពីភាពខ្វះការយកចិត្តទុកដាក់របស់ខ្លួនចំពោះកូន បានព្យាយាមផ្គាប់ផ្គុនកូន ដោយឱ្យវត្ថុគ្រប់បែបយ៉ាងតាមការទាមទាររបស់កូន។ ទង្វើបែបនេះហើយ ដែលធ្វើឱ្យកូន



ទទម្រើស។ ការឱ្យរបស់លេងទាំងឡាយដល់កូន មានដូចជា រថក្រោះ, កាំភ្លើងម៉ាស៊ីន, កាំភ្លើងខ្លី, ដាវ, និងការលួងចិត្ត យ៉ាងហ្នឹង គឺមិនមែនជាចិត្តសាស្ត្រដ៏ល្អទេ។ ពួកគេកំពុងតែបង្រៀនកូនពីការបំផ្លិចបំផ្លាញវិញ មិនមែនជាការបង្រៀនអំពីការធ្វើល្អ, សេចក្ដីករុណា, និងការជួយសង្គ្រោះនោះទេ។ ការមើលកូនជាមួយនឹងរបស់លេងបែបនេះ គឺមិនមែនជាការជំនួសសេចក្ដីស្រឡាញ់ និងការយកចិត្តទុកដាក់របស់មាតានោះឡើយ។ សេចក្ដីស្រឡាញ់ និងការណែនាំរបស់មាតាបិតាគ្មានន័យ ដូច្នេះមិនមានអ្វីគួរឱ្យភ្ញាក់ផ្អើលទេ ប្រសិនបើកូននោះពេញវ័យឡើងក្លាយជាក្មេងពាល។ ដូច្នេះ តើត្រូវស្ដីបន្ទោសនរណា? ពិតជាត្រូវស្ដីបន្ទោសមាតាបិតា។ ជាពិសេសទៅទៀត មាតាធ្វើការពេញមួយថ្ងៃ នៅក្នុងការិយាល័យ ហើយត្រូវធ្វើការងារផ្ទះជាច្រើន ពិតជាមិនអាចរកពេលសម្រាប់កូនដែលកំពុងតែត្រូវការសេចក្ដីស្រឡាញ់ ថ្នាក់ថ្នមរបស់គាត់។ ក្នុងការដណ្ដើមសិទ្ធិស្មើគ្នា ស្ត្រីភាគច្រើនទំនងជាគិតថា ដំណោះស្រាយគឺដើម្បីប្រកួតប្រជែងជាមួយបុរសនៅខាងក្រៅផ្ទះ។ ស្ត្រីជំពូកនេះ គួរគប្បីផ្ដល់ដំបូន្មានកុំឱ្យមានកូនចៅអី។ វាជាភាពអាត្មានិយមបំផុត ដែលបង្កើតកូនមកនៅក្នុងលោកនេះ ហើយបោះបង់គ្នាចោល។ អ្នកត្រូវតែទទួលខុសត្រូវចំពោះអ្វីដែលអ្នកកសាង ពោលគឺអ្នកត្រូវទទួល

ខុសត្រូវក្នុងការមើលថែកូន មិនមែនបំពេញបំណងត្រឹមតែសម្ភារៈប៉ុណ្ណោះទេ ប៉ុន្តែសំខាន់ជាងនោះទៅទៀត គឺផ្នែកស្មារតី និងចិត្តសាស្ត្រ, ការអប់រំទូន្មានពីសីលធម៌។ ការផ្តល់សេចក្តីសុខផ្នែកសម្ភារៈ គឺជាជំហានទី២ ធៀបទៅនឹងការផ្តល់នូវសេចក្តីស្រឡាញ់ និងការយកចិត្តទុកដាក់ថែរក្សា។ យើងដឹងហើយថា មនុស្សជាច្រើនក្នុងគ្រួសារក្រីក្រ ដែលបានចិញ្ចឹមកូនរបស់គេបានល្អ ដោយសេចក្តីស្រឡាញ់ច្រើន។ រីឯគ្រួសារអ្នកមានវិញ បានផ្តល់នូវសេចក្តីសុខខាងសម្ភារៈដល់កូនរបស់គេ ប៉ុន្តែសេចក្តីស្រឡាញ់គ្មានខ្លឹមសារបែបនេះ បានធ្វើឱ្យកូនទាំងនេះពេញវ័យឡើងគ្មានស្មារតី និងសីលធម៌សោះឡើយ។

ស្ត្រីមួយចំនួនទៀតគិតថា ការអប់រំពួកគេឱ្យផ្តោតអារម្មណ៍តែកិច្ចការគ្រួសារ គឺថោកទាប ហើយអភិរក្សនិយមពេក។ ជាការពិតហើយដែលថា កាលពីអតីតកាល គេចាត់ទុកស្ត្រីយ៉ាងអន់បំផុត ប៉ុន្តែរឿងនេះ គឺដោយសារតែភាពអវិជ្ជារបស់បុរស ច្រើនជាងភាពទន់ខ្សោយជាប់មកជាមួយ ក្នុងការមានទស្សនៈស្ត្រីមានតួនាទីត្រឹមតែថែកូន។ ពាក្យសំស្ក្រឹត "គ្រុហិនិ" មានន័យថា "មេផ្ទះ"។ តាមពិតមិនមែនសំដៅថា ស្ត្រីគឺជាហីនភេទទេ។ ផ្ទុយទៅវិញ វាមានន័យថា ការបែងចែកតួនាទីសម្រាប់បុរស និងស្ត្រី។ នៅក្នុងប្រទេស



ជប៉ុន ស្វាមីមួយចំនួនប្រគល់លុយទាំងអស់ទៅប្រពន្ធដែលជាអ្នកគ្រប់គ្រងកិច្ចការផ្ទះ។ បញ្ហានេះធ្វើឱ្យបុរសនៅទំនេរពីការគិតទៅលើអ្វីដែលគាត់ត្រូវធ្វើយ៉ាងពិសេស។ ដោយសារគ្រួសារនីមួយៗយល់ច្បាស់ពីតួនាទីរបស់ខ្លួន ហេតុនេះមិនមានការឈ្លោះប្រកែកទាស់ទែងគ្នាកើតឡើង ហើយបរិយាកាសក្នុងគ្រួសារក៏ប្រកបតែសន្តិភាព សុភមង្គល ជាកន្លែងកូនចៅពេញវ័យ ក្លាយជាពលរដ្ឋល្អមនុស្សល្អក្នុងសង្គម។

តាមពិតស្វាមីត្រូវតែយល់ថា ភរិយារបស់ខ្លួនថែរក្សាកូនបានល្អ, ត្រូវសុំយោបល់នាងលើការសម្រេចចិត្តគ្រួសារ, សមល្មមមានសេរីភាព ក្នុងការអភិវឌ្ឍបុគ្គលិកលក្ខណៈរបស់នាង ដើម្បីមានពេលទំនេរពីការតាមរកចំណូលរបស់នាងជាដើម។ ក្នុងករណីនេះ ស្វាមី និងភរិយាមានទំនួលខុសត្រូវស្មើគ្នា ចំពោះកិច្ចការងារគ្រួសាររបស់ខ្លួន ហើយមិនមែនជាការប្រកួតប្រជែងគ្នាទេ។

មាតាគួរគប្បីថ្លឹងថ្លែងដោយប្រុងប្រយ័ត្នថា តើនាងគួរបន្តជាមាតាធ្វើការងារ ឬក៏ជាមេផ្ទះដែលផ្តល់នូវសេចក្តីស្រឡាញ់ និងការថែរក្សាចំពោះសុខុមាលភាពកូនរបស់នាងដែលធំពេញវ័យ។ ដោយឡែកមាតាសម័យទំនើបខ្លះ កំពុងតែហុចកាំភ្លើង និងឧបករណ៍សម្លាប់ដទៃទៀត ពេលពួកគេឱបក្រសោបស្រឡាញ់កូនរបស់ពួក-

តេ ហើយហ្វឹកហាត់ពួកគេឱ្យក្លាយជាមនុស្សល្អ និងជាពលរដ្ឋគោរពច្បាប់។ ការជំនួសបំបៅកូននឹងទឹកដោះសុទ្ធ ដោយទឹកដោះកំប៉ុងក៏ជាហេតុមួយផ្សេងទៀត សម្រាប់ការកាត់បន្ថយសេចក្តីស្រឡាញ់រវាងម្តាយនិងកូនដែរ។ រហូតមកដល់ពេលនេះ នៅពេលមាតាធ្លាប់បំបៅកូនដោយទឹកដោះខ្លួន និងក្រសោបឱបកូនដោយរង្វង់ដៃ សេចក្តីស្រឡាញ់រវាងមាតានិងកូន គឺមានទំហំធំធេងណាស់ ហើយឥទ្ធិពលមាតាមានទៅលើកូនសម្រាប់ក្លាយជាពលរដ្ឋល្អ ក៏រឹងរឹតតែមានច្រើនទៅទៀត។ ស្ថិតនៅក្នុងកាលៈទេសៈបែបនេះ សេចក្តី-ស្រឡាញ់កូន, ភាពស្និទ្ធស្នាលគ្រួសារ និងការគោរព មិនមានការផ្លាស់ប្តូរទេ។ លក្ខណៈប្រពៃណីទាំងនេះ គឺសម្រាប់អំពើល្អ និងសេចក្តីល្អរបស់កូន។ វាអាស្រ័យទៅលើមាតាបិតាប៉ុណ្ណោះ ជាពិ-សេស មាតាផ្តល់ដល់ពួកគេ។ មាតាមានទំនួលខុសត្រូវចំពោះកូនទាំងល្អទាំងចចេសរឹងរូស។ មាតាអាចកាត់បន្ថយនូវការប្រព្រឹត្តិបទល្មើសរបស់កូន។ នៅក្នុងកម្រិតខ្ពស់នៃការគិត មាតាបិតាអាចឃើញបញ្ហាតាមសភាវៈរបស់វា មិនមែនដូចរូបខ្លួនឡើយ។ បន្ទាប់-មក មាតាបិតាដឹងថា ខ្លួនជាមនុស្សដែលត្រូវទទួលខុសត្រូវគ្រប់អ្វីៗទាំងអស់។[៣]

និយាយរួមទៅ មាតាបិតាដែលបានបង្កើតកូនមកហើយត្រូវតែ



យកគុណធម៌ប្រាំប្រការមកអនុវត្តក្នុងជីវិតប្រចាំថ្ងៃ ដើម្បីបំពេញកាតព្វកិច្ច និងតួនាទីជាមាតាបិតាដ៏ល្អនៅក្នុងសង្គម។

គុណធម៌ទាំង ៥ ប្រការនោះ,[៤] គឺ ÷

១- បាបា និវារេន្តិ - ហាមកូនមិនឱ្យធ្វើអំពើអាក្រក់,

២- កល្យាណេ និវេសេន្តិ - ទូន្មានកូនឱ្យតាំងនៅក្នុងសេចក្តីល្អ,

៣- សិប្បំ សិក្ខាបេន្តិ - ឱ្យកូនសិក្សានូវសិល្បវិជ្ជា,

៤- បតិរូបេន ទារេន សំយោជេន្តិ -រៀបចំកូនឱ្យមានគូស្រករតាមសមគួរ,

៥- សមយេ ទាយជ្ជំ និយ្យាទេន្តិ - ត្រូវចែករំលែកទ្រព្យសម្បត្តិតាមលទ្ធភាព

ទី១ :- មាតាបិតាត្រូវតែទទួលខុសត្រូវ ក្នុងការអប់រំកូនរបស់ខ្លួន ឱ្យចៀសផុតពីអំពើអាក្រក់គ្រប់យ៉ាង។ នេះជាកាតព្វកិច្ចសំខាន់បំផុតរបស់ឪពុកម្តាយ នាសម័យទំនើបនេះ។ ដើម្បីឱ្យកូនគ្រប់រូបចៀសផុតពីសេចក្តីសោកសៅនៅក្នុងជីវិត ដាច់ខាតមាតាបិតាត្រូវតែហាមកូនៗ កុំឱ្យប្រព្រឹត្តនូវអំពើទុច្ចរិតទាំងឡាយ មានការបៀតបៀនកាប់សម្លាប់ជីវិតសត្វ ការលួចទ្រព្យអ្នកដទៃ ការសេពគប់

បាបមិត្តជាដើម។ ទង្វើអាក្រក់ទាំងនេះ នឹងនាំឱ្យកូនវិនាសអន្តរាយក្នុងឆាកជីវិតពិតប្រាកដ។

ទី២ :- មាតាបិតាត្រូវទូន្មានអប់រំកូន ឱ្យប្រព្រឹត្តធ្វើតែអំពើល្អ ដោយផ្តល់នូវសេចក្តីស្រឡាញ់របស់ខ្លួន ចំពោះកូនប្រកបដោយព្រហ្មវិហារធម៌មាន មេត្តា ករុណា មុទិតា និងឧបេក្ខា។ អំពើល្អនឹងនាំឱ្យកូនៗជួបប្រទះតែសេចក្តីសុខចម្រើនក្នុងជីវិត។ ដូច្នេះ ឪពុក-ម្តាយគ្រប់រូបគួរគប្បីទូន្មានកូនឱ្យធ្វើតែអំពើសុចរិត។ ម្យ៉ាងទៀត នៅក្នុងសម័យទំនើបនេះ ការសេពគប់ជាមួយជនជាបណ្ឌិត គឺជាធាតុចាំបាច់បំផុត ដើម្បីនាំកូនៗឱ្យក្លាយជាមនុស្សល្អនៅក្នុងសង្គម។

ទី៣ :- មាតាបិតាត្រូវតែទទួលខុសត្រូវ ចំពោះការសិក្សារបស់កូន មិនថាស្ថិតនៅក្នុងស្ថានភាពបែបណានោះឡើយ។ មាតាបិតាមួយចំនួន កើតវិប្បដិសារីចំពោះទង្វើរបស់ខ្លួន ដោយសារតែសេចក្តីធ្វេសប្រហែស ក្នុងការនាំកូនទៅសាលារៀន។ មានពាក្យស្លោកមួយឃ្លាដែលយើងគប្បីដឹងគ្រប់គ្នា ÷

"មនុស្សប្រើប្រាក់ត្រជាក់ក្សេមក្សាន្ត ប្រាក់ប្រើមនុស្សបានទុក្ខក្តៅក្រហាយ
ជនជាបណ្ឌិតតែងគិតវែងឆ្ងាយ ច្រើនតែឱ្យតម្លៃទៅលើមនុស្ស"។

ការឱ្យតម្លៃទៅលើមនុស្សក្នុងទីនេះ គឺសំដៅលើការឱ្យតម្លៃលើការសិក្សារបស់មនុស្ស ឬការអប់រំធនធានមនុស្ស។ អ្នកប្រាជ្ញ



ទាំងឡាយតែងតែឱ្យតម្លៃអ្នកសិក្សារៀនសូត្រ ព្រោះពួកគាត់គិតឃើញថា ប្រទេសទាំងឡាយ ដែលអាចអភិវឌ្ឍរីកចម្រើនរុងរឿងបាន និងក្លាយជាអច្ឆរិយប្រទេស ក៏ដោយសារអ្នកចេះដែរ មិនមែនគេយកមនុស្សល្ងង់ខ្លៅ អប្បបញ្ញាទៅដឹកនាំប្រទេសឱ្យជឿនលឿននោះឡើយ។ សូមជ្រាបថា មិនមែនគ្រាន់តែបង្កើតកូនចៅឱ្យបានច្រើន ហៅថា បង្កើតធនធានមនុស្សទេ។ ធនធានមនុស្សបែបនេះមិនអាចញ៉ាំងគ្រួសារ ឬប្រទេសជាតិឱ្យរីកចម្រើនបានឡើយ។ ការបង្កើតធនធានមនុស្សយ៉ាងហ្នឹង មិនមានប្រយោជន៍ទេ វាបានត្រឹម-តែធ្វើឱ្យគ្រួសារ ឬប្រទេសជាតិ វឹកវរ ចលាចល ជ្រួលច្របល់ទ្វេឡើងប៉ុណ្ណោះ។ ជាការពិត ប្រសិនបើមាតាបិតាអាចផ្តល់នូវការសិក្សាអប់រំដ៏ល្អដល់កូន មាតាបិតាពិតជាមិនលំបាកក្នុងការជេរស្តីកូន ឱ្យដើរផ្លូវត្រូវនោះឡើយ។

ទី៤ :- មាតាបិតាត្រូវរៀបចំគូស្រករឱ្យកូន សមស្របទៅនឹងត្រកូលរបស់ខ្លួន ទៅតាមកាលៈទេសៈ និងសម័យកាល។ រឿងនេះត្រូវតែយល់ស្របគ្នា រវាងភាគីទាំងសងខាង (មាតាបិតា និងកូន)។ មាតាបិតាមិនត្រូវគំរាមកំហែងកូន ឱ្យដើរតាមការយល់ឃើញរបស់ខ្លួនទេ ប៉ុន្តែ ក៏មិនត្រូវបណ្តែតបណ្តោយឱ្យកូនធ្វើតាមអំពើចិត្តនោះដែរ។ យើងធ្លាប់ឃើញករណីនេះច្រើនរាប់មិនអស់ នៅក្នុងសង្គម

ខ្មែរ ហេតុដូច្នេះ មាតាបិតាគប្បីឈ្វេងយល់ឱ្យបានច្រើន ពីការទំនាក់ទំនងរបស់កូន មុននឹងឈានដល់ថ្ងៃមង្គលការ ដើម្បីចៀសវាងពីបញ្ហាទាំងឡាយ ដែលនឹងអាចកើតមានឡើង ក្រោយពេលរៀបការ ។

ទី៥ :- មាតាបិតាត្រូវចែកកេរមតិក ដល់កូនតាមលទ្ធភាពដែលខ្លួនអាចធ្វើទៅបាន ។ បន្ទាប់ពីរៀបចំកូនឱ្យមានគូស្រករហើយ មាតាបិតា ក៏មិនត្រូវធ្វើព្រងើយកន្តើយ ចំពោះកូននោះឡើយ ។ ទោះបីជាយើងមិនមានអ្វីឱ្យដល់កូនចៅរបស់ខ្លួន តែការជួយលើកទឹកចិត្ត និងការផ្តល់យោបល់ដល់កូន គឺពិតជាសំខាន់ណាស់ ។

ដូច្នេះ ក្នុងនាមជាមាតាបិតារបស់បុត្រប្រុសស្រី មាតាបិតាត្រូវតែរែកពុនគ្រប់បែបយ៉ាង និងគ្រប់ស្ថានភាព ។ ការទទួលខុសត្រូវចំពោះវាសនាអនាគតរបស់កូន គឺជាកាតព្វកិច្ចរបស់មាតាបិតាគ្រប់រូប ។ សូមមាតាបិតាគ្រប់រូបកុំធ្វេសប្រហែសឱ្យសោះ ។

# ការងាររបស់វិញ្ញាណទាំងប្រាំមួយ

*ដោយភិក្ខុ* **មួន វចិត្រ** (ថ្នាក់បរិញ្ញាបត្រ)

សម្រាប់មនុស្សម្នាក់ មានផ្ទុកនូវគំនរនៃធម្មជាតិប្រាំប្រការ គឺ *រូប វេទនា សញ្ញា សង្ខារ* និង *វិញ្ញាណ* ។ ក្នុងគំនរទាំងប្រាំនេះ មានចរន្តនៃវិញ្ញាណទាំងប្រាំមួយរត់ជានិច្ច លើកលែងតែពេលសម្រាកក្នុងដំណេក។ វិញ្ញាណទាំងប្រាំមួយនោះ ធ្វើការជាមួយភ្នែក, ត្រចៀក, ច្រមុះ, អណ្តាត, កាយ និងហទយវត្ថុ ឬថា ការ-ឃើញ ឬមើល, ការស្តាប់ ឬឮ, ការហិត ឬធុំ, ការបរិភោគ, ការ-ពាល់ និងការគិត។ តើយើងគួរប្រើវិញ្ញាណទាំងប្រាំមួយនោះដោយរបៀបណា?

## ការឃើញ ឬការមើល

នៅជុំវិញខ្លួនយើងមានកម្មវត្ថុ (អារម្មណ៍) ច្រើនជារបស់ចក្ខុ-វិញ្ញាណអាចគេចាត់ទុកជា វត្ថុគួរមើល និងវត្ថុមិនគួរមើល ឬ វត្ថុនាំមកនូវប្រយោជន៍ និងវត្ថុនាំមកនូវបញ្ហា។ តើការមើលនូវអ្វីខ្លះដែលចាត់ទុកថា ការគួរមើល?

ការព្យាយាមមើលនូវអ្វីដែលខ្លួនធ្វើខុស, ការទទួលបានចំណេះអ្វីខ្លះ និងមានអ្វីខ្លះទៀតដែលត្រូវធ្វើបន្ថែម, ការងារដែលចិត្តរបស់



ខ្លួនកំពុងធ្វើការ, សភាពប្រែប្រួលនៃសុខភាពផ្លូវកាយ និងផ្លូវចិត្ត, កិច្ចការដែលនឹងត្រូវធ្វើក្នុងថ្ងៃស្អែក, អំពើរបស់ខ្លួនអាចប៉ះពាល់អ្នកដទៃឬទេ, ក្នុងពេលមួយថ្ងៃ តើយើងបានធ្វើអ្វីខ្លះ (បុគ្គលគួរធ្វើអ្វីមួយដែលជាប្រយោជន៍ឧបត្ថម្ភកាយ និងចិត្ត ក្នុងរយៈមួយថ្ងៃ), សម្តីរបស់ខ្លួនអាចធ្វើឱ្យជនដទៃកើតទុក្ខឬទេ ប្រសិនបើអាត្មាអញនិយាយចេញ, អ្វី១ខាងក្រៅ (ទំនៀមរបស់មនុស្ស, សត្វ, វត្ថុ) អាចជាគ្រូបង្រៀនរបស់យើង ដែលបង្ហាញនូវឧទាហរណ៍ជាក់ស្តែងក្នុងជីវិតប្រចាំថ្ងៃ ឱ្យឃើញនូវផ្លូវខុស និងត្រូវ។ វត្ថុបីយ៉ាងគួរតែមើលឱ្យឃើញគឺ វិធីសាស្ត្រប្រើសម្តី, កាលៈទេសៈ និងបុគ្គល ដែលជាគ្រឿងកំណត់សម្រាប់ហេតុ គួរនិយាយ និងមិនគួរនិយាយ ត្បិតការស្គាល់ហេតុពិត អាចរក្សានូវរសនៃសម្តីបាន។ម្យ៉ាងទៀត ក្នុងពុទ្ធសាសនា អ្វីទាំងពួងគួរតែត្រូវបានគេមើលនឹងបញ្ញា ព្រោះការពិ-ចារណារមែងនាំមកនូវហេតុ និងផល ចំណែកសភាពរាយមាយរមែងនាំមកនូវភាពតានតឹងនៃផ្លូវចិត្ត។

វត្ថុដែលនាំមកនូវទុក្ខ, ជម្លោះ, កំហុសរបស់អ្នកដទៃ, អ្វីជាហេតុនាំឱ្យកើតសេចក្តីច្រណែន, អ្វីជាហេតុនាំមកនូវកំហឹង, អ្វីជាហេតុនាំមកនូវអធម្មរាគ, អ្វីជាហេតុនាំទៅរកការយល់ខុស, អ្វីជាហេតុនាំឱ្យកើតនូវសេចក្តីល្ងង់ជាដើម អាចគេចាត់ជាវត្ថុដែលមិនគួរ

មើល។

**ការស្តាប់ ឬត្រចៀក**

ការស្តាប់ក៏ជាអំពើមួយកើតជាមួយនឹងចេតនាផងដែរ, កម្មវត្ថុនៃសោតវិញ្ញាណ ក៏ត្រូវបានគេចាត់ទុកជាវត្ថុគួរស្តាប់ និងមិនគួរស្តាប់។ ធម្មជាតិទាំងពីរនេះ រមែងនាំមកនូវអារម្មណ៍ជាទីស្រឡាញ់ និង អារម្មណ៍មិនជាទីស្រឡាញ់។ ចុះអារម្មណ៍អ្វីខ្លះដែលគួរស្តាប់?

កម្មវត្ថុដែលគួរស្តាប់ គឺជាការពោលដែលនាំមកនូវចំណេះដឹង, ភាពសប្បាយក្នុងសាមគ្គី, សេចក្តីប្រាថ្នាតិច, សេចក្តីត្រេកអរក្នុងអំពើល្អ, ការគាំទ្រនូវក្រុមបណ្ឌិត, ការបង្កើននូវសេចក្តីព្យាយាមក្នុងកិច្ចការងារ, ការសិក្សា និងការអនុវត្ត។ ចំណែកខាងកម្មវត្ថុដែលមិនគួរស្តាប់បានដល់ កិរិយាពោលពាក្យរោយរាយ, កិរិយារិះគន់ដល់គ្នានិងគ្នា ឬការញុះញង់, ការជេរប្រទេច ឬពាក្យទ្រគោះបោះបោក, ការនិយាយកុហក, ការនិយាយពាក្យមិនពីរោះរបស់ជនដទៃ ទាំងមកកាន់ខ្លួន និងអ្នកដទៃ (ត្រង់ចំនុចនេះហើយដែលជាទីផ្តើមនៃជម្លោះ និងជាទីរលត់ទៅនៃបញ្ហារវាងគ្នានិងគ្នា), ការនិយាយពីរឿងអាស្រូវរបស់ជនដទៃ, ពីសេចក្តីស្នេហារបស់បុរស និងនារី ឯ-ណោះ ឬថា អ្វីដែលមិនគួរស្តាប់អាចសំដៅដល់អត្ថន័យផ្ទុយពីអារ-



ម្មណ៍ ដែលគួរស្តាប់ក៏បានដែរ។ ធម្មជាតិនៃការស្តាប់ ពិតជាអាចនាំទៅរកទំនោរមានចេតនាខាងការប្រព្រឹត្តិអាក្រក់ និងល្អ ព្រោះហេតុនោះព្រះពុទ្ធជាម្ចាស់ ទ្រង់ដាស់រំឭកណាស់ពីការស្តាប់ (សុត-មយបញ្ញា)។ ដូច្នេះ បុគ្គលគួរទាញប្រយោជន៍ពីការងារនៃត្រចៀករបស់ខ្លួន មិនគួរប្រើការស្តាប់ដើម្បីជួបប្រទះនូវបញ្ហាផ្សេងៗ-ឡើយ។

**ការហិត ឬច្រមុះ**

ការហិត គឺអំពើដែលកើតឡើងដោយមានចេតនា ទើបអាចដឹងក្លិនបាន នេះខ្ញុំនឹងពោលដល់ទំនាក់ទំនងទៅនឹងសុខភាពរបស់រាងកាយ។ បើបុគ្គលហិតនូវរបស់ដែលមិនគួរហិត មានវត្ថុដែលផ្ទុកនូវសារធាតុគីមី ដូចជាថ្នាំដែលសម្រាប់ព្យាបាលជម្ងឺផ្នែកអវយវៈខាងក្រៅ, ថ្នាំញៀនផ្សេងៗ ឬផ្សែងពុលទាំងឡាយក្នុងបរិយាកាសជាដើម ទាំងនេះសុទ្ធតែធ្វើឱ្យប៉ះពាល់ដល់សួត និងប្រព័ន្ធផ្លូវ-ដង្ហើម។ ព្រោះបើបុគ្គលចង់ពិសោធនូវវត្ថុអ្វីមួយ តាមរយៈការ-ហិត គួរតែឈ្វេងយល់ជាមុនសិន។ ពុំនោះទេ ព្រោះតែការហិតបុគ្គលអាចទទួលយកនូវជម្ងឺមួយដោយមិនដឹងខ្លួន ត្រង់នេះអ្នកអានគួរសិក្សាបន្ថែមទៀត ទាក់ទងទៅនឹងបញ្ហាសុខភាព។ ត្បិតជម្ងឺឆ្លង

ឬការបង្កជម្ងឺអាចកើតតាមរយៈការដកដង្ហើម និងពិតជាមិនអាចមើលឃើញនឹងភ្នែកបានឡើយ, ដូច្នេះការហិតក៏ជាអំពើដែលគួរ និងមិនគួរដែរ។ ចំណែកខាងព្រះធម៌ ការហិត ឬធុំក្លិនត្រូវប្រព្រឹត្តទៅជាមួយសតិដឹង ដើម្បីកំណត់នូវនាមធម៌ និងរូបធម៌។

## ការបរិភោគ

ការបរិភោគពិតជាការងារដ៏សំខាន់បំផុតសម្រាប់ជីវិត ដើម្បីបន្តនូវចរន្តនៃជីវិត, ប៉ុន្តែមិនមែនកើតមកដើម្បីការងារបរិភោគឡើយ ត្បិតការងារបរិភោគតែម្យ៉ាង មិនអាចធ្វើឱ្យចិត្តបរិសុទ្ធបានទេ។ ព្រោះហេតុនោះ បុគ្គលត្រូវប្រើប្រយោជន៍នៃចំណីអាហារជាគ្រឿងឧបត្ថម្ភដល់សរីរាង្គ ដើម្បីការងារដែលមានប្រយោជន៍។ ទំនៀមនៃការបរិភោគ និងចំណីអាហារគួរតែត្រូវបានគេសិក្សាឱ្យច្បាស់លាស់ តើអ្វីដែលធ្វើឱ្យប៉ះពាល់ដល់សុខភាព និងអ្វីដែលផ្តល់ប្រយោជន៍ដល់សុខភាព ដូចជាការបរិភោគសាច់ដែលចម្អិនមិនដល់កម្រិតដែលមេរោគស្លាប់, បន្លែលាងមិនជ្រះល្អ, ការបរិភោគមិនទៀងពេល, ការបរិភោគមិនប្រមាណនឹងទំហំក្រពះ (ន ភោជនេ មត្តញ្ញុតា), ការបរិភោគទឹកឆៅ, ការបរិភោគចំណីមានលាយជាតិគីមីជាដើម។ ព្រះពុទ្ធជាម្ចាស់ទ្រង់មិនអនុញ្ញាតឱ្យបព្វជិតឆាន់សាច់



ស្រស់, បន្លែស្រស់ ត្រង់ចំនុចនេះ បើតាមការស្រាវជ្រាវរបស់អ្នកវិទ្យាសាស្ត្រ សាច់ស្រស់អាចមានផ្ទុកមេរោគ ពងព្រូន និងតេនញ៉ា ចំណែកបន្លែស្រស់ក៏អាចមានអតិសុខុមប្រាណនានា ដែលមិនអាចមើលឃើញនឹងភ្នែកបាន ទាំងនេះអាចបណ្តាលឱ្យមានជម្ងឺផ្សេងៗ ដូចជា ការរាករូស, គ្រុនពោះវៀន, ក្អកជាដើម។ ចំណែកខាងព្រះធម៌ ការបរិភោគត្រូវប្រព្រឹត្តទៅជាមួយសតិដឹង ដើម្បីកំណត់នូវនាមធម៌ និងរូបធម៌។

## ការពោល ឬការកាន់

ជាទូទៅអំពើនៃផ្លូវកាយ ត្រូវបានគេវាយតម្លៃដល់ផ្លូវចិត្តផងដែរ។ វត្ថុដែលកាន់អាចនាំមកនូវសេចក្តីអាក្រក់ និងសេចក្តីល្អ។ ទម្លាប់លួចរបស់ជនដទៃ, ការកាប់សម្លាប់, ការប្រព្រឹត្តិមិនប្រក្រតីជាមួយនឹងភរិយាអ្នកដទៃ និងការងារធ្វើខ្វះការពិចារណាជាមុន និងគ្មានសតិដឹងរមែងនាំមកនូវសេចក្តីអាក្រក់ និងផលអាក្រក់។ ការកាន់ដែលនាំមកនូវសេចក្តីល្អ គឺជាការងារដែលធ្វើដោយបញ្ញា។ ព្រះពុទ្ធជាម្ចាស់ទ្រង់លើកតម្កើងបញ្ញា និងមនសិការៈ (ការធ្វើទុកក្នុងចិត្ត) ផ្តោតទៅនឹងការងារនានា។

**ការគិត**

គំនិតដែលលេចចេញឡើងពីការងាររបស់ចិត្ត រមែងប្រកបដោយចេតនា។ សកម្មភាពនៃការគិត ពិតជាមានកម្លាំងខ្លាំងណាស់ជះទៅលើប្រព័ន្ធសរីរាង្គ ប្រសិនបើគំនិតល្អ រមែងធ្វើឱ្យប្រព័ន្ធរាងកាយរត់ស្រួលនិងមានសុខភាពល្អ ដូចជា ទឹកមុខស្រស់បស់ សម្តីពីរោះ បរិភោគបាយបាន, ទទួលដំណេកស្ងប់ស្រួលជាដើម។ ផ្ទុយទៅវិញ ការគិតអាក្រក់រមែងធ្វើឱ្យប្រព័ន្ធរាងកាយរត់មិនស្រួល ដូចជា ការស្ទះល្បឿនឈាមរត់ ដែលអាចបណ្តាលឱ្យសន្លប់ ឬ ធ្លាយសរសៃខួរក្បាលជាដើម។ សកម្មភាពគិត ត្រូវការថាមពលរាងកាយច្រើន បុគ្គលខ្លួនឯងអាចពិសោធដឹងត្រង់ចំនុចនេះ នៅពេលដែលខ្លួនប្រើការគិតខ្លាំង។ ព្រះពុទ្ធជាម្ចាស់ទ្រង់ឱ្យប្រើចិត្តធ្វើការ ដើម្បីបង្កើនសមត្ថភាពបញ្ញា (ចិន្តាមយបញ្ញា)។

នៅជុំវិញខ្លួនយើង អ្វីៗទាំងពួងនឹងអាចក្លាយជាកម្មវត្ថុសម្រាប់ចម្រើននូវគុណជាតិល្អៗ នៅក្នុងខ្លួនយើង ពោលគឺ យើងអាចបង្រៀនចិត្តយើង ឱ្យចេះអត់ធ្មត់នឹងអារម្មណ៍មិនជាទីគាប់ចិត្ត, ជាជំនួសចម្រើននូវគុណជាតិនៃមេត្តា ឱ្យប្រព្រឹត្តទៅក្នុងឥរិយាបថដេក, ដើរ, ឈរ និងអង្គុយ ឆ្ពោះទៅរកជនទាំងឡាយដែលនៅជុំវិញខ្លួនយើង និងសត្វទាំងពួង, នៅពេលដែលយើងឃើញជនដទៃកើតទុក្ខ នោះហើយជាពេល ដែលយើងគួរបណ្តុះនូវគុណជាតិនៃសេចក្តីអាណិតអាសូរ, នៅពេលឃើញអ្នកដទៃបានលាភសក្ការៈ យើងគួរចម្រើននូវគុណជាតិនៃមុទិតា (សភាពទន់ភ្លន់នៃចិត្តទោរទន់ទៅរកអ្នកដទៃ), នៅពេលដែលយើងក្លាយជាអ្នកកាត់ក្តី ឬជាមេចំណែកទៅលើអ្វីមួយ នៅពេលនោះ យើងគួរចម្រើននូវគុណជាតិឧបេក្ខា (សភាពនៃសេចក្តីស្រឡាញ់ស្មើ)។ ទាំងនេះជាគុណជាតិដែលយើងគួរចម្រើនដល់សត្វ និងជនទាំងឡាយ ទាំងនៅក្បែរយើង និងទូទៅ ដែលជាគ្រឿងឧបត្ថម្ភដល់សុខភាពផ្លូវចិត្តរបស់ខ្លួនផ្ទាល់។



បើយើងឆ្លាតក្នុងការប្រើភ្នែក, ត្រចៀក, ច្រមុះ, អណ្តាត, កាយ និងហទយវត្ថុ ឱ្យធ្វើការត្រឹមត្រូវ យើងអាចចៀសផុតពីបញ្ហាផ្សេងៗបានប្រហែល ៧៩ ភាគរយក្នុងជីវិត ចំណែក ២១ ភាគរយទៀត ជាចំណែកនៃកម្លាំងកម្ម ដែលមិនអាចហាមឃាត់បាន។ ទីនេះអ្នកសរសេរមិនអាចផ្តល់នូវសេចក្តីពិស្តារ នៃការងារវិញ្ញាណទាំងប្រាំមួយបានឡើយ ត្បិតសំនេរមានកំណត់។

# ដំណើរនៃជីវិត

*ដោយភិក្ខុ* **ឡេង ម៉ុននាង** (ថ្នាក់ឱប្ចម)

យើងបានដឹងគ្រប់គ្នាហើយថា សេចក្តីទុក្ខគឺជាធាតុមួយដែលបុគ្គលគ្រប់រូប មួយណាក៏ដូចជាមួយណាគ្មានចង់ជួប គ្មានចង់បានសោះ ឯចំណែកសេចក្តីសុខវិញ កុំថាឡើយច្រើន សូម្បីបន្តិចបន្តួចក៏ប្រាថ្នាចង់បាន បើបានមកហើយមិនចង់ឱ្យបាត់បង់ទៅវិញទេ ប៉ុន្តែគេមិនសូវបានជួបតាមសេចក្តីត្រូវការរបស់ខ្លួនឡើយ។ តើព្រោះហេតុអ្វី? ព្រោះសេចក្តីសុខកើតមកអំពីហេតុ គឺធ្វើបុណ្យទាន ឯចំណែកសេចក្តីទុក្ខកើតមកអំពីហេតុ គឺធ្វើបាប។ មនុស្សខ្លះតែងយល់ច្រឡំថា សេចក្តីសុខ និងទុក្ខកើតមកអំពីព្រះអាទិទេព ជាអ្នកកំណត់ជាអ្នកផ្តល់ឱ្យ ហើយមើលមិនឃើញនូវសមត្ថភាពរបស់ខ្លួន តែព្រះសម្មាសម្ពុទ្ធទ្រង់មិនបានចាត់ទុកថា ធាតុទាំងឡាយពីរនេះ គឺសុខ, ទុក្ខ កើតមកអំពីទង្វើរបស់ព្រះអាទិទេពម្តងណាសោះឡើយ គឺកើតមកតែអំពីទង្វើរបស់ខ្លួនជាអ្នកសាងហ្នឹងឯង។[៥]

ដើម្បីអប់រំពន្យល់ដល់សត្វទាំងឡាយ ឱ្យជឿជាក់លើសមត្ថភាពខ្លួនឯង ចេះទទួលខុសត្រូវចំពោះទង្វើដែលខ្លួនបានធ្វើហើយពិសេសត្រូវខិតខំលះបង់ចោលនូវទង្វើអាក្រក់ ហើយចាប់យកនូវ



ទង្វើល្អដើម្បីរកឱ្យឃើញពិតប្រាកដនូវតម្លៃនៃសុភមង្គល ដែលអាចមាននៅក្នុងជីវិតបច្ចុប្បន្ន និងជីវិតឯលោកខាងមុខ។[៦]

អាស្រ័យដោយសង្ខារធម៌ទាំងឡាយ តាក់តែងឱ្យមានផ្លាស់ប្តូរប្រែប្រួលពីភាពដើមទៅរកភាពថ្មី គឺចាប់តាំងពីការយោនយកកំណើត រហូតដល់ដំណាក់កាលចុងក្រោយនៃជីវិត គឺសេចក្តីស្លាប់។

ជាក់ស្តែងកាលនៅជាកុមារភាព អ្នកដ៏មានគុណទាំងពីរ គឺមាតាបិតាបានរៀបចំជីវិតឱ្យកូន ដឹកដៃកូនទៅសាលា ដើម្បីសិក្សានូវមុខវិជ្ជាផ្លូវលោក ផ្លូវធម៌ ក្នុងគោលបំណងឱ្យកូនមានចំណេះដឹងប្រាសចាកនូវអវិជ្ជា។ មិនយូរប៉ុន្មានក៏បានបដិវត្តជីវិតក្លាយមកជាយុវជន-យុវតី។

ភាពជាយុវជន-យុវតី មានកម្លាំងមាំមួនក្នុងការប្រឈមមុខទៅនឹងការងារប្រកបមុខរបរចិញ្ចឹមជីវិត ដូចជាកសិកម្ម ពាណិជ្ជកម្ម អាជីវកម្ម និងការងារផ្សេងៗទៀត ទៅតាមសេចក្តីពេញចិត្ត និងជំនាញពីធម្មជាតិរបស់ខ្លួន។ ក្រោយមកមាតាបិតារៀបចំឱ្យមានប្តីប្រពន្ធ បង្កើតបានជាក្រុមគ្រួសារមួយ។ កាលបើមានប្តីប្រពន្ធហើយអាស្រ័យមកពីអវិជ្ជា និងតណ្ហា ជាអ្នកដឹកនាំសត្វបង្កើតបានជាកូនចៅ ហើយក៏ក្លាយទៅជាឪពុកម្តាយរបស់កូន។ ដូច្នេះត្រូវមានកាតព្វកិច្ចទទួលបន្ទុក គឺចិញ្ចឹមកូន ផ្តល់នូវសេចក្តីសុខចម្រើនដល់កូន។

ភាពជាម្ដាយឪពុកមិនយូរប៉ុន្មាន ក៏បំពាក់ស័ក្ដិមួយទៀត ហៅ-ថា តាយាយ របស់គេតែម្ដង បន្ទាប់មកក៏បានបំពាក់ស័ក្ដិមួយទៀត គឺតាទួត យាយទួត។ ព្រោះហេតុអ្វី? អនិច្ចំជាអ្នកធ្វើឱ្យប្រែប្រួល វាមិនគ្រាន់តែញ៉ាំងជីវិតមនុស្សឱ្យប្រែប្រួលប៉ុណ្ណោះទេ សូម្បីតែទឹក ដី ភ្លើង ខ្យល់ ទាំងរូបធម៌ និងអរូបធម៌ទាំងឡាយក៏ប្រែប្រួលគ្មានអ្វីសល់ដែរ។ ការប្រែប្រួលនេះគឺមានគ្រប់ពេលវេលាទាំងអស់ គ្មានពេលវេលាណាមួយដែលមិនប្រែប្រួលទេ ចំពោះការប្រែប្រួលខ្លះយើងចាប់អារម្មណ៍ ហើយអាចមើលឃើញបាន ឯចំណែកការប្រែ-ប្រួលខ្លះទៀត យើងចាប់អារម្មណ៍ហើយក៏មិនអាចមើលឃើញតែប៉ុណ្ណោះ។ តាមពិតទោះជា យើងចាប់អារម្មណ៍ក្ដី មិនចាប់អារម្មណ៍ក្ដី មើលឃើញក្ដី មិនឃើញក្ដី ក៏ការប្រែប្រួលនេះ នៅតែបន្តសកម្ម-ភាពរបស់ខ្លួនឥតត្រឡប់ក្រោយឡើយ។

តើមកអំពីមូលហេតុអ្វីទៅ? គឺមកតែពីអនិច្ចំញ៉ាំងជីវិតឱ្យប្រែ-ប្រួលផ្លាស់ប្ដូរឥតស្រាកស្រាន្ត។[៧] ជីវិតត្រូវឆ្លងកាត់នូវឧបសគ្គរាប់មិនអស់ជារឿយៗ បន្តិចរឿងនេះបន្តិចរឿងនោះ ដោយច្រើនគឺបញ្ហាតាមផ្លូវចិត្តហ្នឹងឯង បើយើងមិនមានធម៌សម្រាប់ដោះស្រាយទេនោះ វារមែងមានការលំបាកតានតឹងក្នុងជីវិតយ៉ាងពិតប្រាកដ ហើយវាអាចគ្របសង្កត់ចិត្តរបស់យើងបានយូរទៀតផង។ រឿងរ៉ាវ



ផ្សេងៗក្នុងជីវិតជាវិបត្តិក្ដី ជាឧបសគ្គក្ដី វានៅតែកើតមានជាធម្មតា ព្រោះតែមិនមានសេចក្ដីយល់ដឹងពិតនៃជីវិត។[៨]

ជីវិតមនុស្សយើងគ្រប់រូបតែងជួបប្រទះនឹងឧបសគ្គ ការលំបាកតិច ឬច្រើនជារឿងធម្មតា។ ដើម្បីទ្រទ្រង់ជីវិត យើងចាំបាច់ត្រូវប្រើប្រាស់ភាពក្លាហានដើម្បីតស៊ូនឹងឧបសគ្គ បើពុំនោះយើងនឹងក្លាយទៅជាមនុស្សបរាជ័យ ដោយសារតែមិនអាចពុះពារឆ្លងកាត់ឧបសគ្គទាំងនោះបាន។ ជីវិតមនុស្សគឺបែបនេះ ផ្លូវដែលយើងដើរមិនមែនសុទ្ធតែត្រង់រាបស្មើរហូតនោះទេ ជាញឹកញាប់ណាស់ដែលយើងត្រូវដើរលើផ្លូវក្រឡិកក្រឡុកខ្ពស់ទាបបត់បែន បើយើងពុំមានសេចក្ដីក្លាហាន និងពុះពារទម្លុះទម្លាយទេនោះ វានឹងត្រូវឧបសគ្គមករារាំង ធ្វើឱ្យយើងទៅមុខមិនរួច មិនអាចដើរទៅដល់គោលដៅបាន។[៩]

ដូច្នេះ ជីវិតវាលំបាកក្នុងការរស់នៅណាស់ ព្រោះជីវិតឆ្លងកាត់ឧបសគ្គរាប់មិនអស់ រាប់ម៉ឺនជំពូក។ មនុស្សសត្វទាំងអស់ស្រឡាញ់ជីវិតជាងអ្វីៗទាំងអស់ ទើបបានជាមានពុទ្ធដីកាសម្ដែងថា៖

“នត្ថិ អត្តសមំ បេមំ ស្រឡាញ់អ្វីស្មើដោយខ្លួនមិនមានឡើយ”។

ក្នុងការរស់នៅ ជីវិតត្រូវទាមទារអ្វីៗគ្រប់បែបយ៉ាង ដើម្បីឱ្យរស់សុខស្រួល ហើយបរិបូរដោយបច្ច័យទាំងឡាយបួន មានអនា-

ម័យល្អ មានសុជីវធម៌ល្អ ដើម្បីឈ្វេងយល់ពីការរស់នៅឱ្យបានច្បាស់លាស់ ។[១០]

តាមសភាវៈពិត ពេលវេលាដែលកន្លងផុតទៅរហូតឥតទាន់វិលថ្ងៃត្រឡប់ឡើយ ចំណែកអាយុជីវិតរបស់យើងក៏ចេះតែកន្លងទៅឥតមានថ្ងៃវិលត្រឡប់ដែរ ។

តើមានអ្វីដែលទៀងទាត់ទេនៅលើលោកយើងនេះ? តាមពិតនោះគឺគ្មានទេ មានតែភាពមិនទៀងទេ ដែលវាទៀងទាត់ និងមិនផ្លាស់ប្តូរនោះ ។ ចំណុចនេះហើយ បានជាព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សម្តែង ដើម្បីជាគ្រឿងដាស់សតិសម្បជញ្ញៈ ដល់យើងគ្រប់គ្នាថា ÷

"យេ ច វុឌ្ឍា ច ទហរា យេ ច ពាលា ច បណ្ឌិតា
អឌ្ឍា ចេវ ទលិទ្ទា ច សព្វេ មច្ចុបរាយនោ"។

"សត្វទាំងឡាយឯណាទោះចាស់ក្តី ក្មេងក្តី ពាលក្តី បណ្ឌិតក្តី អ្នកមានទ្រព្យក្តី អ្នកខ្សត់ទ្រព្យក្តី សត្វទាំងឡាយនោះ សុទ្ធតែមានសេចក្តីស្លាប់នៅខាងមុខរង់ចាំទាំងអស់ មិនមានសត្វឯណានីមួយគេចអំពីសេចក្តីស្លាប់បានទេ ទោះបីខំប្រឹងរត់ទៅពួនក្នុងសមុទ្រក្តី កណ្តាលអាកាសក្តី ក្នុងរូងភ្នំក្តី ក៏មិនអាចរួចផុតពីសេចក្តីស្លាប់បានដែរ ពីព្រោះទីកន្លែងទាំងនោះមិនមាន



ដល់បុគ្គលនោះឡើយ"។

"អជ្ជេវ ចិត្តំ អាតប្បំ កោជញ្ញា មរណំ សុវេ
ន ហិ នោ សង្គរន្តេន មហាសេនេន មច្ចុនោ"។

"សេចក្តីព្យាយាមជាគ្រឿងដុតបំផ្លាញនូវកិលេស បុគ្គលត្រូវធ្វើទុកឱ្យហើយស្រេចក្នុងថ្ងៃនេះ នរណានឹងគប្បីដឹងថាសេចក្តីស្លាប់ត្រូវមកដល់ថ្ងៃស្អែក ព្រោះថាការដោះដៃឱ្យរួចអំពីសេចក្តីស្លាប់នេះ មិនមានឡើយ"។

"ន តត្ថ ហត្ថីនំ ភូមិ ន ថោកាំ ន បត្តិយា
ន ចាបិ មន្តយុទ្ធេន សក្កា ជេតុំ ធនេនវា"។

"សត្វទាំងឡាយមិនអាចប្រយុទ្ធប្រឆាំងជាមួយមច្ចុរាជបានឡើយ ព្រោះថាក្នុងសង្គ្រាមមច្ចុនេះ មិនមែនជាវិស័យភូមិនៃពលដំរីទាំងឡាយផង, មិនមែនជាវិស័យភូមិនៃពលរថផង, មិនមែនជាវិស័យភូមិនៃពលថ្មើរជើងផង បើទុកណាជានឹងតប្រយុទ្ធដោយប្រើមន្តអាគមក្តី ទ្រព្យក្តី ក៏មិនអាចឈ្នះបានឡើយ"។

"អច្ចេន្តិ កាលោ តរយន្តិ រត្តិយោ វយោ គុណោ
អនុបុព្វំ ជហន្តិ ឯតំ ភយំ មរណេ បេក្ខមានោ

**"បុញ្ញានិ កាយិរាថ សុខាវហានិ"។**

"កាលទាំងឡាយចេះតែកន្លងទៅ រាត្រីទាំងឡាយចេះតែឆ្លងផុតទៅ ជំនាញទាំងឡាយក៏ចេះតែរបេះខាត់ជាលំដាប់ទៅ កាលបើសាធុជនសម្លឹងឃើញនូវភ័យក្នុងសេចក្តីស្លាប់ដូច្នេះ គប្បីធ្វើនូវបុណ្យជាហេតុនាំមកនូវសេចក្តីសុខមកឱ្យ"។

**"ផលានមីវ បក្កានំ ចាតោ បតនតោ ភយំ**
**ឯវំ ជាតោ ន មច្ចានំ និច្ចំ មរតោ ភយំ"។**

"ផ្លែឈើទាំងឡាយទុំហើយ តែងភ័យអំពីកិរិយាជ្រុះចុះចាកដើមអំពីព្រលឹមយ៉ាងណាមិញ សត្វទាំងឡាយដែលកើតមក ហើយតែងភ័យអំពីកិរិយាស្លាប់ទៅក៏យ៉ាងនោះដែរ"។[១១]

ដើម្បីធ្វើជីវិតឱ្យមានប្រយោជន៍ត្រូវរស់នៅប្រកបដោយធម៌ គឺមេត្តា ករុណា មុទិតា និងឧបេក្ខា ប្រព្រឹត្តតាមពុទ្ធោវាទ រក្សាសីល ធ្វើសមាធិដែលនាំឱ្យកើតបញ្ញាទើបយើងអាចស្រង់ជីវិតរស់នៅរបស់យើងចាកចេញ ពីជីវិតអន្ធពាលបាន មិនធ្លាក់ចុះក្នុងជីវិតនៃមច្ចុរាជ។

ជីវិតមិនមែនថ្លៃថ្នូរដោយទ្រព្យ ដោយយសស័ក្តិ ដោយគោត្រត្រកូលឡើយ។ បុគ្គលរស់នៅអស់រយៈកាលមួយរយឆ្នាំ ក្នុងអំពើអយុត្តិធម៌ មិនថ្លៃថ្នូរស្មើដោយបុគ្គលរស់នៅក្នុងមួយថ្ងៃ ក្នុងអំពើ



យុត្តិធម៌។ បុគ្គលរស់នៅអស់រយៈកាលមួយរយឆ្នាំជាមួយសេចក្តីខ្ជិលច្រអូស មិនធ្វើការងារ មិនថ្លៃថ្នូរស្មើដោយបុគ្គលរស់នៅមួយថ្ងៃប្រកបដោយសេចក្តីចេះដឹង ស្គាល់ហេតុនៃសេចក្តីទុក្ខ។ បុគ្គលរស់នៅអស់រយៈកាលមួយរយឆ្នាំជាមួយនឹងតណ្ហា មិនថ្លៃថ្នូរស្មើដោយបុគ្គលរស់នៅមួយថ្ងៃជាមួយនឹងត្រៃលក្ខណ៍។

ជីវិតបម្រើកាម បម្រើតណ្ហា បម្រើសេចក្តីប្រាថ្នារបស់ខ្លួន ជាជីវិតសៅហ្មង ជាជីវិតទាសៈនៃសេចក្តីប្រាថ្នា ជាជីវិតទាសៈនៃសេចក្តីសប្បាយ។ របៀបរស់នៅដូច្នេះ ជារបៀបរស់នៅក្រោមបង្គាប់របស់ធម្មជាតិ រស់នៅដើម្បីសប្បាយ មិនមែនរស់នៅដើម្បីប្រយោជន៍លោក ប្រយោជន៍ធម៌ឡើយ។ ព្រះសាស្តារបស់យើងទ្រង់រើសរកផ្លូវរស់មួយថ្មីហៅថា÷

"រស់នៅដើម្បីរស់, រស់នៅត្រឹមតែរស់, រស់នៅដើម្បីការងារ, រស់នៅដើម្បីលោក, រស់នៅដើម្បីធម៌"។[១២]

ហេតុអ្វីបានជាព្រះអង្គសម្តែងដូច្នេះ? ពីព្រោះព្រះពុទ្ធអង្គមានបំណងអប់រំទូន្មានមនុស្សឱ្យមានសីលធម៌ក្នុងការរស់នៅ ទើបរកសេចក្តីសុខចម្រើនដោយពិតក្នុងការរស់។ ប្រសិនបើយើងរស់នៅប្រាសចាកសីលធម៌នោះ រកសេចក្តីសុខមិនឃើញឡើយ។

ពេលវេលាដែលកន្លងផុតទៅ រមែងនាំយកនូវអាយុជីវិតរបស់មនុស្សទៅជាមួយ ។ ដូច្នេះមនុស្សគ្រប់រូប យ៉ាងហោចណាស់ គួរតែធ្វើនូវអ្វីមួយឱ្យមានប្រយោជន៍ ទោះបីស្ថិតនៅក្នុងរយៈពេលខ្លីក៏ដោយ ។

# ជ្រុងមួយនៃពុទ្ធសាសនា

*ដោយសាមណេរ* **ថុង ត្រាគន** (ថ្នាក់ឌីប្លូម)

វានៅតែជាបញ្ហាចំពោះរឿងនេះដល់ពេលបច្ចុប្បន្ន។ តើអ្វីទៅជាដំណោះស្រាយ ចំពោះការវិភាគដ៏ត្រឹមត្រូវ? ដោយយោងទៅតាមព្រះពុទ្ធសាសនា ដែលព្រះពុទ្ធទ្រង់បានសម្តែងជាង ២៦ សតវត្សរ៍កន្លងមកហើយ ចំពោះនិគមមួយឈ្មោះកេសបុត្តរបស់ពួកក្សត្រិយ៍ ឈ្មោះកាលាមៈ។

សម័យមួយ ព្រះដ៏មានព្រះភាគទ្រង់ស្តេចយាងទៅកាន់ចារិកក្នុងកោសលជនបទជាមួយនឹងភិក្ខុសង្ឃច្រើន ក៏បានទៅដល់និគមឈ្មោះកេសបុត្តរបស់ពួកក្សត្រិយ៍ឈ្មោះកាលាមៈ។ ដោយបានឮដំណឹងថា ព្រះសមណគោតមជាសក្យបុត្រចេញពីសក្យត្រកូល ជាព្រះអរហត្តទ្រង់បរិបូណ៌ដោយ វិជ្ជា និងចរណៈ ជាសាស្តាចារ្យនៃមនុស្ស និងទេវតា ប្រកបដោយបញ្ញាដ៏ឧត្តមជាដើមនោះ។ លំដាប់នោះពួកកាលាមៈក្សត្រិយ៍ បានចូលទៅគាល់ព្រះដ៏មានព្រះភាគហើយក៏អង្គុយក្នុងទីដ៏សមគួរ។ លុះអង្គុយក្នុងទីដ៏សមគួរហើយក៏ក្រាបទូលព្រះដ៏មានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន មានសមណព្រាហ្មណ៍មួយពួកមកកាន់កេសបុត្តនិគម សមណ-



ព្រាហ្មណ៍នោះសម្តែងប្រកាន់នូវវាទៈរបស់ខ្លួនឯង បៀតបៀនមើលងាយ លើកទម្លាក់នូវវាទៈរបស់បុគ្គលដទៃ បពិត្រព្រះអង្គដ៏ចម្រើន មានសមណព្រាហ្មណ៍ដទៃមួយពួកទៀត មកកាន់កេសបុត្តនិគម សមណព្រាហ្មណ៍នោះ ក៏សម្តែងប្រកាសនូវវាទៈរបស់ខ្លួន បៀតបៀនមើលងាយ លើកទម្លាក់នូវវាទៈរបស់បុគ្គលដទៃដែរ បពិត្រព្រះអង្គដ៏ចម្រើន យើងមានសេចក្តីងឿងឆ្ងល់សង្ស័យពេកណាស់ ចុះបណ្តាសមណព្រាហ្មណ៍ដ៏ចម្រើនទាំងនេះ អ្នកណានិយាយពិត អ្នកណានិយាយកុហក។ ម្នាលកាលាមៈក្សត្រិយ៍ គួរអ្នកទាំងឡាយងឿងឆ្ងល់ដែរ។ ម្នាលកាលាមៈក្សត្រិយ៍ អ្នកចូរមក អ្នកចូរកុំប្រកាន់ដោយគ្រាន់តែឮតគ្នា កុំប្រកាន់តាមពាក្យបរម្បរា កុំប្រកាន់ដោយបានឮថាដូច្នេះ កុំប្រកាន់ដោយអាងក្បួនតម្រា កុំប្រកាន់តាមហេតុដែលត្រិះរិះ កុំប្រកាន់ដោយកាត់ដំរួយផ្សែផ្សំ កុំប្រកាន់ដោយគ្រាន់តែត្រិះរិះនូវអាការ កុំប្រកាន់ដោយសេចក្តីពេញចិត្តតាមការពិនិត្យសមនឹងសេចក្តីយល់ឃើញ កុំប្រកាន់ដោយយល់ថា មានសភាពគួរជឿ កុំប្រកាន់ដោយគិតថា សមណៈនេះជាគ្រូរបស់យើង ម្នាលកាលាមៈក្សត្រិយ៍ កាលណាអ្នកដឹងដោយខ្លួនឯងថា ធម៌ទាំងនេះជាអកុសល ប្រកបដោយទោស អ្នកប្រាជ្ញតិះដៀលធម៌ទាំងនេះ បុគ្គលបានសមាទានពេញលេញហើយ រមែងប្រព្រឹត្តទៅដើម្បីមិនជាប្រ-

យោជន៍ ដើម្បីសេចក្ដីទុក្ខ អ្នកទាំងឡាយត្រូវលះបង់ចោលចេញ។ ម្នាលកាលាមៈក្សត្រិយ៍ កាលណាអ្នកដឹងដោយខ្លួនឯងថា ធម៌ទាំងឡាយនេះជាកុសល ធម៌ទាំងឡាយនេះមិនមានទោស ធម៌ទាំងឡាយនេះ ដែលអ្នកប្រាជ្ញសរសើរ ធម៌ទាំងនេះដែលបុគ្គលសមាទានពេញលេញហើយ ប្រព្រឹត្តទៅដើម្បីជាប្រយោជន៍ ដើម្បីសេចក្ដីសុខ ម្នាលកាលាមៈក្សត្រិយ៍ អ្នកទាំងឡាយចូរដល់នូវធម៌ទាំងឡាយនោះចុះ។[(១៣)]

គួរដឹងថា ព្រះពុទ្ធសាសនាមិនមែនជាប្រព័ន្ធនៃជំនឿនោះទេ ឬក៏ការបូជានោះឡើយ តែជាជំនឿទុកចិត្ត ដោយហេតុផលដែលបានមកពីបញ្ញា ឬហៅតាមបាលីថា "សទ្ធា"។ រាល់ការបង្រៀនរបស់ព្រះពុទ្ធ គ្រប់គ្នាគឺមានសិទ្ធិសាកល្បង ដោយឆ្លងកាត់ការពិចារណាសិក្សាពិនិត្យ ហើយប្រតិបត្តិ នោះការពិតគឺអ្នក ជាអ្នកសម្រេចថាល្អឬយ៉ាងណា។ ព្រះពុទ្ធតែងទ្រង់សម្ដែងថា "ឯហិបស្សិកោ" ចូរមកសាកល្បងទៅ នោះអ្នកនឹងជាក់ច្បាស់មិនខាន ជាជំនួសឱ្យការជឿ ឬមិនជឿ។

ពុទ្ធសាសនិកគួរយល់ថា ព្រះពុទ្ធមិនមែនជាអាទិទេព ឬក៏អ្នកស្រង់នោះទេ ជាជំនួយគួរយល់ថា ទ្រង់ជាបរមសាស្ដាចារ្យ ឬក៏មគ្គុទ្ទេសក៏។



ដោយការប្រើប្រាជ្ញាពិចារណា ហើយប្រតិបត្តិមាគ៌ាដែលទ្រង់រកឃើញ នោះអ្នកនឹងអាចទៅដល់មគ្គផល ហើយនឹងនិព្វានដែលជាមោក្ខធម៌។ ព្រះពុទ្ធទ្រង់មិនដែលធានារ៉ាប់រងថា ដោយអានុភាព និងលាងបាបរបស់សត្វ ហើយបញ្ជូនទៅកាន់ឋានសួគ៌ ឬនិព្វាននោះ ដល់ម្ដងក៏ទេ ដោយពិតការរួចរំដោះ នោះជាសមិទ្ធផលនៃការប្រឹងប្រែងរបស់អ្នក។ តាមសេចក្ដីខាងលើនេះ គឺជាសេរីភាពដែលមនុស្សគួរតែមាននូវការទទួលខុសត្រូវលើខ្លួនឯង ជាជាងតែទៅលើអ្នកដទៃតែម្ខាង។

មានសាសនាជាច្រើន ដែលយកជំនឿជាកត្តាសំខាន់ តែចំពោះព្រះពុទ្ធសាសនាវិញ គន្លឹះដ៏សំខាន់គឺបញ្ញា។ វាមិនមែនជាការបដិសេធចំពោះជំនឿនោះទេ។ ប្រសិនបើជំនឿក្នុងទីនេះមានន័យថា "សទ្ធា" នោះ។

យើងហ៊ាននិយាយពីតំលៃនៃបញ្ញា ក្នុងព្រះពុទ្ធសាសនា ព្រោះដោយយោងទៅតាមពាក្យប្រៀនប្រដៅរបស់ព្រះសម្មាសម្ពុទ្ធ ដូចជាការសម្ដែងអំពីអរិយសច្ចៈបួន បដិច្ចសមុប្បាទជាដើម។

បច្ចុប្បន្ន ព្រះពុទ្ធសាសនាបានទទួលការនិយមយ៉ាងច្រើន ជាពិសេសនៅលោកខាងលិច។ យើងមានពុទ្ធសាសនិកអង់គ្លេស ពុទ្ធសាសនិកបារាំង ពុទ្ធសាសនិកអាមេរិកាំង និងពុទ្ធសាសនិកជាតិឯ

ទៀតជាច្រើន។ តើអ្វីដែលបណ្តាលឱ្យអ្នកទាំងឡាយនោះ ចាប់ចិត្ត លើព្រះពុទ្ធសាសនា? ភាពជឿនលឿន និងល្អិតល្អន់នៃការវិនិច្ឆ័យ ចំពោះព្រះធម៌ គេបានកោតសរសើរថា ព្រះពុទ្ធសាសនាមានភាព ប្រាកដនិយម ភាពជាក់ស្តែងចំពោះការពិចារណាបញ្ហា ហើយនិង ដំណោះស្រាយជាក់ស្តែង ដោយស្របទៅនឹងប្រយោជន៍និយម មិន ថានៅក្នុងទស្សនវិជ្ជា នយោបាយ ឬ សេដ្ឋកិច្ច។[១៤] អ្នកអាចអាន បាន ចំពោះការអះអាងនេះ នៅក្នុងចូឡមលុង្ក្យាសូត្រ ដែលសម្តែង អំពីបុរសអ្នកត្រូវរបួសដោយព្រួញ។ តែជាការគួរឱ្យសោកស្តាយ ណាស់ តម្លៃនៃព្រះពុទ្ធសាសនា នៅស្រុកខ្មែរយើង មិនថាមនុស្ស ចាស់ៗ សូម្បីក្មេងៗជាន់ក្រោយ បានចាត់ទុកពុទ្ធសាសនាគ្រាន់តែជា សាសនា ចាស់គំរឹលមួយ ដែលមិនសមហេតុផល ហើយសំបូរតែទៅ ដោយអប្បិយជំនឿ។ ទាំងការសិក្សា និងប្រតិបត្តិគឺស្ថិតនៅមាន កម្រិតនៅឡើយ។ នៅទីនេះប្រទេសភូមា គេមានសាកលវិទ្យាល័យ ៣ ទៅ ៤ កន្លែង សម្រាប់និស្សិតបរទេសសិក្សាព្រះធម៌ មណ្ឌល សមាធិមានពាសពេញប្រទេស ព្រះធម៌បានផ្សព្វផ្សាយជាភាសា ផ្សេងៗ មាន អង់គ្លេស បារាំង ចិន ជាដើម ទៅមនុស្សទាំងឡាយ នៅក្នុងសកលលោក។ សង្ឃឹមថា ថ្ងៃខាងមុខប្រទេសខ្មែរយើងគង់ បានរីកចម្រើន អាចធ្វើបានដូចគេដែរ។

# **អបាយមុខ ៤ ប្រការ**

*ដោយភិក្ខុ* **ចាន់ ភាគ** (ថ្នាក់ឱឬម)

ពាក្យថា "អបាយមុខ" ប្រែថា ប្រធាននៃសេចក្តីវិនាស ផ្លូវនៃសេចក្តីវិនាស ហេតុ ឬអំពើជាប្រធាន ឬជាផ្លូវនៃសេចក្តីវិនាស។ "អបាយមុខ" ជាពាក្យផ្ទុយគ្នានឹង "អាយមុខ" ដែលប្រែថា ប្រធាន ឬផ្លូវនៃសេចក្តីចម្រើនហ្នឹងឯង។

នៅក្នុងគម្ពីរសុត្តន្តបិដក អង្គុត្តរនិកាយ អដ្ឋកនិបាត ព្រះសម្មាសម្ពុទ្ធបរមគ្រូទ្រង់សម្តែងអំពីហេតុនាំឱ្យវិនាស ៤ ប្រការ ដោយប្រារព្ធនឹងព្រាហ្មណ៍ម្នាក់ឈ្មោះ ឧជ្ជយព្រាហ្មណ៍ដូច្នេះថា ÷

"ឯវំ សមុប្បន្នានំ ព្រាហ្មណ ភោគានំ ចត្តារិ
អបាយមុខានិ ហោន្តិ ឥត្ថីធុត្តោ សុរាធុត្តោ
អក្ខធុត្តោ បាបមិត្តោ បាបសហាយោ
បាបសម្បវង្កោ។

ប្រែថា "ម្នាលព្រាហ្មណ៍ កាលដែលភោគៈទាំងឡាយចម្រើនយ៉ាងនេះហើយ រមែងមានផ្លូវនៃសេចក្តីវិនាស៤ប្រការ គឺជាអ្នកលេងស្រី ១, លេងសុរា១, លេងល្បែងភ្នាល់១, មានមិត្តលាមក មានសម្លាញ់លាមក, សេពគប់នឹងបុគ្គលលាមក១"។[(១៥)]



តើ អបាយមុខទាំង ៤ ប្រការនេះ នាំឱ្យវិនាសដោយហេតុដូចម្តេចខ្លះ?

១- **ឥត្ថីធុត្តៈ** ភាពជាអ្នកលេងស្រី។ តាមធម្មតាបុរសដែលមានភរិយាហើយ មិនត្រេកអរនឹងភរិយារបស់ខ្លួនតែម្នាក់ឯងទេ ចេះតែមានចិត្តសាវ៉ា ជាប់ជំពាក់ទៅក្នុងស្រីនានា មិនដឹងថាខ្លួនធ្វើខុសច្បាប់ស្វាមី អាងតែខ្លួនឯងជាប្រុស ម្ល៉ោះហើយតាំងចិត្តខុសទាល់តែភ្លេចខ្លួនទៅជាជ្រុលជ្រប់ក្នុងស្រីទាំងឡាយ មិនរើសថា ស្រីល្អ ឬអាក្រក់ឡើយ ឱ្យតែឃើញស្រីចេះតែចង់ប្រាថ្នារួមបវេណីតែម្តង[(១៦)] សមដូចជាពាក្យកាព្យពោលថា ÷

"ឃើញស្រីស្រស់ស្រើបស្រាល ត្រេកត្រអាលឥតអៀនអង្គ
ពេញចិត្តចេះតែចង់ តែងតួខ្វង់បង់លុយកាក់។
បានឱបបីត្រកង ជម្ងឺឆ្លងក្តៅញញាក់
ស្រីមានផ្ទៃទាមទាក់ ប្រុសធ្លោយធ្លាក់អារកចោលការ"។[(១៧)]

មិនតែប៉ុណ្ណោះ ថែមទាំងមិនប្រាថ្នានឹងចិញ្ចឹមទុកជាភរិយាទៀតផង គឺគ្រាន់តែឱ្យបានសប្បាយមួយពេលមួយគ្រាតែប៉ុណ្ណោះ។ បើថ្ងៃណា វេលាណាមួយខ្លួនមិនបានទៅផ្តេកផ្តិតជាមួយស្រីនោះទេ ថ្ងៃនោះវេលានោះហាក់បីដូចជាខ្លួនជិតស្លាប់អ៊ីចឹង។[(១៨)] នេះជាលក្ខណៈ

របស់អ្នកលេងស្រី ភាសាបាលីហៅថា "ឥត្ថីធុត្តៈ" ហ្នឹងឯង ។

ជាការពិត បុគ្គលជាអ្នកលេងស្រី បើមានចិត្តដោតជាប់ គឺថា ចិត្តរបស់ខ្លួនជាប់ជំពាក់ទៅលើស្រីណា ដែលខ្លួនស្រឡាញ់ហើយ ពេញចិត្តហើយ ប្រាថ្នាហើយ ត្រូវតែខំទៅមករកស្រីនោះ ត្រូវតែ ចាយប្រាក់ ឬទិញសម្ភារៈផ្សេងៗដូចជាទូរស័ព្ទ ឡាន វីឡា ជាដើម ដើម្បីទំនុកបម្រុងបម្រើឱ្យស្រីនោះស្រឡាញ់ខ្លួន ឱ្យសមតាមបំណង ប្រាថ្នារបស់ខ្លួន ។ បើសេចក្ដីស្រឡាញ់នោះ រឹងរឹតតែដុះដាលខ្លាំង ឡើងៗ ទៅជានាំឱ្យរត់ចោលការងាររបស់ខ្លួនក៏មាន,[១៩] ត្រូវនឹង ពាក្យកាព្យថា ÷

"ត្រេកនឹងស្រី ត្រីនឹងស្រា ថាឈ្មើមឆ្ងាញ់
ក៏ស្រឡាញ់ កាញ់ស្រឡះ ខះខូចខួរ
ហិនហោចប្រាក់ ហាក់ហោចប្រាណ ខានតែងតួ
មុខមិនគួរ មួមិនគាប់ ងប់ងងុល ។
ប្រុសចេះដែរ ប្រែចេះដូច ខូចភ្លឺភ្លើ
ទៅលលើ ទើលលាក់ ខ្វាក់រុករុល
កែបន្លំ ខំដួសដុល ទោសវាជ្រុល
ទាល់វាជ្រាយ ធ្លាយធ្លុះធ្លោយ" ។[២០]

បើបុរសដែលមានភរិយាហើយ ជួនកាលនាំឱ្យមានការបែក-



បាក់គ្នា ឈ្លោះគ្នាក៏មាន ដោយសារតែខ្លួនទៅមានស្រីថ្មី សមដូច ពាក្យកាព្យពោលថា ÷

មានប្រពន្ធ គន់ឱ្យល្អិត ស្និទ្ធស្នេហ៍ស្នង
កុំកន្លង ប៉ងមានទៀត ឆ្លៀតលួចលាក់
បំណាច់ចេះ រិះឱ្យត្រូវ ផ្លូវជ្រៅរាក់
ក្រែងជំពាក់ ធ្លាក់មានពូជ ខូចដល់កូន ។
បើចំណង់ ចង់សប្បាយ ស្ដាយស្រីញី
កាលដើមទី ពីលីវស្អាត ឆ្លាតសណ្ដូន
លេងសើចផ្ទួន ខ្លួនទំនេរ គេចស្ងៀមស្ងួន
មានបងប្អូន កូនប្រពន្ធ ធ្ងន់គំនិត" ។[២១]

ម្យ៉ាងវិញទៀត បើស្រីនោះជាស្រីពេស្យារកស៊ីលក់ប្រពៃណី ផង ក៏អាចបណ្ដាលឱ្យកើតរោគឆ្លងផ្សេងៗ រហូតដល់អន្តរាយជីវិត ខ្លួនក៏មាន ពុំនោះសោត ដល់ប្រពន្ធកូនក៏មាន ។ លើសពីនេះទៅ ទៀត គឺថា បើជាស្រីមានស្វាមីគ្រប់គ្រងស្រាប់ផង ក៏អាចឱ្យកើត ជម្លោះវិវាទគ្នា រហូតដល់ជាប់គុកជាប់ច្រវាក់ ខ្ទោះឃ្នាងក៏មាន ។[២២]

សរុបសេចក្ដីទៅ ភាពជាអ្នកលេងស្រីឥតចម្រើនកើនយសសោះ ឡើយ ។ ព្រោះហេតុនោះបានជាព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ថាជា

អបាយមុខប្រការទីមួយ។

២- *សុរាធុត្តៈ* ភាពជាអ្នកលេងសុរា។ បុរស ឬស្រីជាអ្នកផឹកសុរាមេរ័យ គឺផឹកស្រវឹងបែបណាក៏ដោយ ឱ្យតែផឹកជាប់ជានិច្ចទៅ រហូតដល់រកមកទុកបម្រុងសម្រាប់ខ្លួនមិនឱ្យខ្វះផឹក។ គ្មានពេលស្វាង ដូចយ៉ាងគេហៅថា ផឹកងូត (លិចទាំងខ្លួន) ឬអ្នកធ្ងន់ក្នុងការផឹក ឈ្មោះថា ជាអ្នកលេងសុរា ឬអ្នកប្រមឹក។ មនុស្សអ្នកប្រមឹកនេះ មានប្រក្រតីផឹកជាប់ជានិច្ច ទាល់តែញៀន បើថ្ងៃណាមួយមិនបានផឹក ថ្ងៃនោះមានចិត្តក្ដៅក្រហាយ មិនសប្បាយចិត្តទាល់តែសោះ ចេះតែតឹងទ្រូង ច្របល់ចិត្តស្ទើរឆ្កួត ក្លាយទៅជាបុគ្គលឈ្មោះថា សុរុម្មត្តកោ បុគ្គលឆ្កួតព្រោះសុរា។ អ្នកផឹកខ្លះថា សុរានិងមេរ័យផឹករាល់ថ្ងៃ ដើម្បីកែរោគ។ តែខ្ញុំសូមកែសេចក្ដីថា សុរានិងមេរ័យផឹករាល់ថ្ងៃ វាយគ្នាតែញយ។

ជាការពិត មនុស្សប្រុស ឬស្រីជាអ្នកលេងសុរា កាលបើញៀនជាប់ទាល់ល្បីឈ្មោះថា អ្នកប្រមឹក ហើយត្រូវតែចំណាយប្រាក់ដើម្បីទិញស្រាផឹក កាលបើផឹកស្រាចូលទៅហើយ កិច្ចដែលមិនគួរនឹងធ្វើ ពាក្យសម្ដីដែលមិនគួរនឹងនិយាយ អ្នកប្រមឹកហ៊ានធ្វើ ហ៊ាននិយាយឥតខ្លាចឡើយ។ បើកាលណាអស់ប្រាក់ពីខ្លួន ក៏នាំឱ្យរកស៊ីផ្លូវទុច្ចរិតជាផ្លូវខុសគោលច្បាប់ សម្រាប់ប្រទេស ដូចជាធ្វើចោរប្លន់ លួចគេ



ដោយលបលាក់ជាដើម តមកក៏រត់ពួនលាក់ខ្លួននៅក្នុងព្រៃភ្នំក្រំថ្មឥតមានសេចក្ដីសប្បាយសោះ បើគេចាប់បានក៏ត្រូវគេឃុំឃាំង វាយដំ ដាក់ពិន័យ ខូចទាំងការងារ អាក្រក់ទាំងឈ្មោះ ខាតទាំងប្រាក់គ្មានចម្រើនសោះឡើយ។ អ្នកប្រមឹកបើជាអ្នកមិនធ្លាប់សម្លាប់សត្វក៏ទៅជាហ៊ានសម្លាប់ មិនធ្លាប់លួចបែរជាហ៊ានលួច។ រឿងនេះព្រោះសុរា ព្រះពុទ្ធទ្រង់ត្រាស់ថា "សុរាធុត្តៈ" ហ្នឹងឯង។ (២៣)

## ទោសផឹកសុរា ៦ ប្រការ

*១- សន្ទិដ្ឋិកា ធនជានី* នាំឱ្យវិនាសទ្រព្យនឹងឃើញទាន់ភ្នែក,

*២- កលហប្បវឌ្ឍនំ* នាំឱ្យចម្រើនខាងការឈ្លោះប្រកែក,

*៣- រោគានំ អាយតនំ* ជាហេតុនាំឱ្យកើតរោគច្រើនយ៉ាង,

*៤- អកិត្តិ សញ្ជននី* បណ្ដាលឱ្យខូចកេរ្ដិ៍ឈ្មោះ ឬឱ្យកើតគរហានិន្ទា,

*៥- ហិរិកោបិនទស្សនី* នាំឱ្យលេចកេរ្ដិ៍ខ្មាស និង

*៦- បញ្ញាយ ទុព្វលីករណី* ធ្វើប្រាជ្ញាឱ្យមានកំលាំងថយ (១៨)

៣- *អក្ខធុត្តៈ* ជាអ្នកលេងល្បែងភ្នាល់។ តាមធម្មតាល្បែង-ភ្នាល់មានច្រើនយ៉ាង ដូចជាល្បែងបៀរ ប៉ោងជាដើម រហូតដល់ទៅ

ល្បែងផ្សេងៗដែលមានស៊ីសង ដោយប្រាក់កាសបន្តិចបន្តួច ក៏ធ្លាក់ចុះក្នុងលក្ខណៈរបស់ល្បែងភ្នាល់ ឬអនុលោមទៅតាមល្បែងភ្នាល់ទាំងអស់។ មនុស្សប្រុសស្រីណាដែលប្រកាន់យកល្បែងភ្នាល់ ជាគ្រឿងចិញ្ចឹមជីវិតប្រចាំថ្ងៃ ឬជាអ្នករកស៊ីក្នុងការភ្នាល់ជាសំខាន់ ទើបចាត់ជាអ្នកភ្នាល់។

ជាការពិត មនុស្សជាអ្នកលេងល្បែងភ្នាល់ត្រូវតែហ៊ានលះបង់ចាយវាយទ្រព្យសម្បត្តិគ្រប់បែបយ៉ាង ក្នុងការលេងរបស់ខ្លួន។ បើជាការភ្នាល់ ជាល្បែងស៊ីសង មេតំបន់មិនបានអនុញ្ញាតក៏ត្រូវតែលេងដោយលួចលាក់ ដោយភ័យខ្លាច បើគេចាប់បានក៏ត្រូវជាប់ឃុំឃាំង ត្រូវជាប់ទោសនាំឱ្យខូចខាតប្រាក់មាសផង នាំឱ្យកើតពៀរផងសមដូចពុទ្ធតម្រាស់ថា ÷

ជយំ វេរំ បសវតិ អ្នកឈ្នះរមែងប្រទះនូវពៀរ, ទុក្ខំ សេតិ បរាជិតោ អ្នកចាញ់រមែងដេកកើតទុក្ខ ហើយធ្វើឱ្យចងពៀរនឹងគ្នាដោយគិតកែខ្លួនដើម្បីឱ្យបានឈ្នះលើអ្នកនោះវិញ ក្តៅក្រហាយទាំងផ្លូវកាយ ទាំងផ្លូវចិត្ត ឥតមានសេចក្តីសប្បាយរីករាយបន្តិចសោះឡើយ។ ព្រោះហេតុនោះ ទើបព្រះសមណគោត្តមត្រាស់ថា អក្ខធុត្តៈ ប្រការទីបី។ (២៥) សូមចាំថា ច្បាប់ល្បែង បើមិនចង់ឈ្នះ គឺមិនចាញ់ទេ។



## ទោសលេងល្បែងភ្នាល់ ៦ ប្រការ

*១-* ជយំ វេរំ បសវតិ អ្នកលេងឈ្នះរមែងធ្វើឱ្យអ្នកចាញ់រងវេរា,

*២-*ជនស្ស វិភេចតិ អ្នកលេងចាញ់រមែងសោកស្តាយទ្រព្យដែលវិនាសទៅ,

*៣-* សន្ទិដ្ឋិកោ ធនជានី សេចក្តីវិនាសទ្រព្យនឹងឃើញទាន់ភ្នែក,

*៤-*សភាគតស្ស វចនំ នរុហតិ ពាក្យរបស់អ្នកលេងល្បែងភ្នាល់ នឹងយកជាសាក្សី ជាបន្ទាល់ពិតមិនបាន,

*៥-*មិត្តមច្ចានំ បរិភូតោ ហោតិ ពួកមិត្តសំឡាញ់ដែលគេមិនលេងល្បែងភ្នាល់តែងមើលងាយ និង

*៦-*អាវាហវិវាហកានំ អបត្ថិកោ ហោតិ ពួកជនអ្នកធ្វើនូវអាវាហវិវាហមង្គលគេនឹងមិនត្រូវការឡើយ។ (២៦)

៤- ចាបមិត្តៈ សេពគប់មិត្តអាក្រក់។ អ្នកណាប្រព្រឹត្តអំពើអាក្រក់ ឬបាបកម្មដោយផ្លូវកាយ ផ្លូវវាចា និងផ្លូវចិត្ត ឬថាអ្នកណាប្រព្រឹត្តអំពើទុច្ចរិតដោយទ្វារទាំងបី គឺកាយទ្វារ វចីទ្វារ និងមនោទ្វារ អ្នកនោះឈ្មោះថា បុគ្គលអាក្រក់។ អ្នកណាបរិភោគជាមួយ ដេកជាមួយ លេងជាមួយនឹងមនុស្សអាក្រក់ជាប់ជានិច្ច ដោយភាពទុកចិត្ត

ស្និទ្ធស្នាលនឹងគ្នា អ្នកនោះឈ្មោះថា សេពគប់មនុស្សអាក្រក់ជាមិត្ត វៀរលែងតែអ្នកដែលជួបនឹងមនុស្សអាក្រក់ម្ដងម្កាលប៉ុណ្ណោះ។

តាមធម្មតាមនុស្សអ្នកធ្លាប់មាននិស្ស័យល្អ គឺថាខ្លួនធ្លាប់ប្រព្រឹត្តតែអំពើល្អដោយផ្លូវកាយ មានមិនសម្លាប់ជីវិតសត្វ មិនលួច ទ្រព្យគេ មិនប្រព្រឹត្តខុសក្នុងកាម ផ្លូវវាចាមាន មិនពោលពាក្យ កុហក ចាក់ដោត ទ្រគោះ រោយរាយឥតប្រយោជន៍ និងផ្លូវចិត្តមាន មិនមានចិត្តសម្លឹងរំពៃទៅលើទ្រព្យអ្នកដទៃ មិនព្យាបាទ និងមានសម្មាទិដ្ឋិ ដោយយល់ថា ឪពុកម្ដាយមានគុណជាដើម ប៉ុន្ដែបើកាលណាបានចូលទៅសេពគប់នឹងមនុស្សអាក្រក់ជាមិត្ត ជាសំឡាញ់ហើយ ទោះបីមនុស្សនោះធ្លាប់មាននិស្ស័យល្អយ៉ាងណាក៏ដោយ ក៏អាចធ្វើឱ្យមនុស្សនោះ ត្រឡប់ក្លាយទៅជាមនុស្សអាក្រក់ ជាមនុស្សថោកទាបឥតប្រាជ្ញា គួរឱ្យស្អប់ខ្ពើមទៅវិញបាន ព្រោះតាមធម្មតាមនុស្សដែលនៅរួមគ្នា ឬសមគំនិតឃុបឃិត ច្រឡូកច្រឡំជាមួយគ្នា អ្នកមានអធ្យាស្រ័យទន់ខ្សោយ តែងដេកដួលដោយអ្នកដែលមានអធ្យាស្រ័យរឹងប៉ឹង។ កុំថាឡើយមនុស្សដែលមានវិញ្ញាណគ្រប់គ្រង សូម្បីតែរុក្ខាលតាវល្លិដែលឥតមានវិញ្ញាណសោះ ក៏វាបណ្ដោយទៅតាមគ្នាដែរ ដោយសារតែមែក និងឫសវាព័ទ្ធព័ន្ធគ្នា ហើយយូរៗទៅរសរបស់ឈើប្រភេទខ្លះ ប្រែត្រឡប់ខុសពីប្រក្រតីដើមរបស់ខ្លួន



ក្លាយជារសរបស់ឈើមួយទៀត ដែលអាស្រ័យជាប់ជាមួយគ្នា ដូចវល្លិបណ្ដូលពេជ្រឡើងព័ទ្ធដើមស្វាយ ផ្លែស្វាយក៏ក្លាយជាមានរសល្វីងជូរចត់ទៅតាមវល្លិបណ្ដូលពេជ្រវិញ សមដូចជាសុភាសិតថា៖

"យំ វេ សេវតិ តាទិសោ" សេពគប់អ្នកណា ក៏ក្លាយខ្លួនដូចជាអ្នកនោះឯងហោង។ ទោះបីមនុស្សអាក្រក់មិនណែនាំ មិនប្រៀនប្រដៅឱ្យធ្វើអាក្រក់ក៏ដោយ ក៏យើងនៅតែធ្វើអាក្រក់កើត ព្រោះចិត្តធ្លាប់ស្និទ្ធស្នាលជាមួយគ្នា ធ្លាប់សេពគប់នោះជាហេតុ សូម្បីយើងមិនលួចគេសោះ បើយើងទៅសេពគប់នឹងអ្នកលួចគេហើយ មុខជានឹងល្បីឈ្មោះថាជាអ្នកលួចដូចគេដែរ។ ព្រោះអ្វី? ព្រោះហេតុតែមិត្តរបស់យើងជាអ្នកលួចគេ។ កាលបើយើងទៅសេពគប់នឹងអ្នកលួចគេហើយ បើគេចាប់ចោរនោះបានយកទៅដាក់គុក ដាក់ច្រវាក់ខ្នោះឃ្នាងនោះ យើងក៏នឹងត្រូវជាប់ឃុំឃាំង ឬជាប់គុកជាប់ច្រវាក់ដូចគេដែរ ព្រោះយើងជាបក្ខពួកជាមួយនឹងចោរ ពុំនោះសោតចោរនឹងឆ្លើយដាក់យើងថាលួចគេដែរ។[២៧] ម្យ៉ាងទៀត សូម្បីយើងមិនធ្លាប់វាយដំច្រំធាក់ មើលងាយមើលថោកអ្នកដទៃ មិនធ្លាប់ពោលពាក្យកុហកបោកបញ្ឆោតអ្នកដទៃ មិនធ្លាប់សេពសុរាមេរ័យ មិនធ្លាប់ប្រើប្រាស់គ្រឿងញៀនអាភៀនកញ្ឆាសោះ បើកាលណាយើងទៅសេពគប់ជាមួយមនុស្សអាក្រក់ជាមិត្រជាសំឡាញ់ហើយ ពេល

នោះខ្លួន យើងក៏នឹងក្លាយជាមនុស្សអាក្រក់ពុំខានឡើយ ។ ជាពិសេសយុវជនខ្មែរដែលធ្លាប់ជាមនុស្សល្អ ជាមនុស្សមានសីលធម៌ក្នុងខ្លួន ជាមនុស្សសុភាពរៀបរយ ជាកូនធ្លាប់ស្តាប់ដំបូន្មានឪពុកម្តាយ ជាសិស្សធ្លាប់មានវីរិយភាពក្នុងការសិក្សា ស្តាប់ដំបូន្មានគ្រូ តែបើទៅសេព-គប់ជាមួយនឹងមនុស្សអាក្រក់ជាមិត្រ មុខជាក្លាយជាមនុស្សអាក្រក់ពុំខានឡើយ ។

ដោយឃើញអំណាចឥទ្ធិពលនៃការសេពគប់មិត្តអាក្រក់ មានឥទ្ធិពលខ្លាំងក្លាដូច្នេះហើយ បានជាព្រះសមណគោត្តមបរមគ្រូទ្រង់ត្រាស់សម្តែងទុកក្នុងមង្គលសូត្រជាខាងដើមថា÷

"អសេវនា ច ពាលានំ បណ្ឌិតានញ្ច" ដែលមាន
សេចក្តីថា ឱ្យវៀរចាកការគប់រក ការសេពគប់បុគ្គលពាល
ហើយឱ្យគប់រកបុគ្គលជាបណ្ឌិតវិញ ។

មុននឹងយើងសេពគប់មិត្រ គឺយើងត្រូវសង្កេតមើលលក្ខណៈអត្តចរិតរបស់គេនោះឱ្យបានល្អិតល្អន់ជាទីបំផុតជាមុនសិន ទើបជាការប្រសើរ ពុំនោះទេនឹងនាំឱ្យវិនាសពុំខានឡើយ សមដូចពាក្យកាព្យពោលថា ÷

បើមានមិត្តគិតជាមុនសិន ជួនមានស័យហិនដោយសារវា



ដែលសង្វាតមកពេលយើងជា ពុំយល់ជាក់គ្រាដែលយើងក្រ ។
ដោយយល់ក្រែលរកតែលុយកាក់ តែងលេងកិច្ចធ្វើហាក់ស្មោះល្អ
ហេតុស្មានល្អិតថាយើងមិនក្រ យូរមកក្រោយវ័ណ្ឌកវេះបាត់ ។[២៨]

ព្រោះហេតុនោះ បានជាព្រះពុទ្ធសម្តែងថា ការសេពគប់មនុស្សអាក្រក់ជាមិត្រ ពិតជានាំឱ្យវិនាសប្រការទី៤ ។

សរុបសេចក្តីមក អបាយមុខទាំងបួនប្រការខាងលើនេះ បុគ្គលគ្រប់រូបគប្បីចៀសវាង ឱ្យបានទើបសេចក្តីចម្រើនកើនយសទ្រព្យសម្បត្តិ សំបូរមិត្រជាមនុស្សល្អ មករាប់រកយើងគ្រប់គ្រាគ្រប់ពេលវេលា ។ នោះជីវិតរបស់យើងនឹងមានភាពស្រស់ថ្លា រីករាយតាំងពីជាតិនេះ តទៅជាតិមុខ ពិតជាបានសុខហោង ។

# គុណភាពនៃជីវិត

*ដោយភិក្ខុ* **អ៊ុំ សត្ថា** (ថ្នាក់បរិញ្ញាបត្រ)

ក្នុងការរស់នៅ មនុស្សម្នាក់ៗតែងចង់បានអ្វីៗមកជារបស់ខ្លួន ឬប្រាថ្នាឱ្យខ្លួនមានទ្រព្យសម្បត្តិច្រើន យសស័ក្តិខ្ពង់ខ្ពស់ប្រពៃ សេចក្តីសុខផ្សេងៗ ដោយសង្ឃឹមថា សេចក្តីប្រាថ្នារបស់គេនឹងសម្រេចតាមបំណងក្នុងថ្ងៃណាមួយនាអនាគត។ បើគេមានតែសេចក្តីប្រាថ្នាមិនមានសេចក្តីព្យាយាមធ្វើកិច្ចការឱ្យបានទៀងទាត់ទេ សេចក្តីសង្ឃឹមនុ៎ះបានត្រឹមតែសង្ឃឹម ដោយគ្មានផ្លែផ្កាតាមបំណងឡើយ។ អ្នកមានបញ្ញាតែងតែប្រាថ្នាចង់បានអ្វីៗ ដែលសមនឹងសមត្ថភាពរបស់ខ្លួន ហើយក៏តាំងចិត្តព្យាយាមបំពេញយ៉ាងទៀងទាត់ តាម-លំដាប់រហូតដល់បានសម្រេចដូចបំណង។[២៩] ការតស៊ូដើម្បីគុណ-ភាពនៃជីវិត អ្នកត្រូវសិក្សាឱ្យយល់ច្បាស់ពីសម្បទាបួន ហើយត្រិះរិះពិចារណាឱ្យបានហ្មត់ចត់ ក្នុងការរៀបចំជីវិតបានត្រឹមត្រូវ ដើម្បីទទួលបាននូវគុណភាពនៃជីវិតនាពេលបច្ចុប្បន្ន និងអនាគត។

ធម៌ដែលជាហេតុឱ្យបានសម្រេចផលដូចសេចក្តីប្រាថ្នាបួនយ៉ាង

១- *សទ្ធាសម្បទា* យើងម្នាក់ៗត្រូវបំពេញជំនឿ ឱ្យមានក្នុងខ្លួនថា៖ មនុស្សលោកបានទទួលតំណែងខ្ពស់ទាបជាងគ្នា ឬមានភ័ព្វ-



វាសនាតិចច្រើនជាងគ្នាទៅអំពីកម្ម គឺការងារដែលខ្លួនធ្វើច្រើនតិច មិនមែនមកអំពីជំនួយរបស់ទេវតា តែទេវតាតែងតែជួយសង្គ្រោះមនុស្សអ្នកតស៊ូ អ្នកធ្វើការដោយត្រឹមត្រូវប្រាកដប្រជា។

១- *សីលសម្បទា* យើងត្រូវហាត់បំពេញសីល គឺធ្វើឱ្យខ្លួនមានចរិយាមារយាទល្អ វៀរចាកការជិះជាន់បៀតបៀនអ្នកដទៃ ដោយប្រើកម្លាំងណាមួយមាន កម្លាំងយសស័ក្តិ កម្លាំងទ្រព្យធន កម្លាំងអំណាចជាដើម។

២- *ចាគសម្បទា* ការបំពេញទាន គឺចាយទ្រព្យបូជា សាងសង្គ្រោះ ធ្វើអំណោយ ដូចជាបូជាមាតាបិតា សាងបុណ្យកុសល ឬសង្គ្រោះអ្នកក្រខ្សត់។

៣- *បញ្ញាសម្បទា* ការបំពេញបញ្ញាដោយពិចារណារកហេតុខុសត្រូវ ស្តាប់ច្រើន គិតច្រើន ស្រាវជ្រាវច្រើន កត់ត្រាច្រើន ព្រម-ទាំងរៀនច្រើន និងភាវនាធម៌សមថកម្មដ្ឋាន ឬចម្រើនវិបស្សនាជាដើម។[៣០]

ការប្រកួតប្រណាំងដើម្បីរស់នៅក្នុងបច្ចុប្បន្ន ដោយសិក្សាចំ-ណេះវិជ្ជា ដោយស្វែងរកទ្រព្យសម្បត្តិ ស្វែងរកយសស័ក្តិ ស្វែងរកភាពសរសើរ ស្វែងរកសុខ គួប្រកួតប្រណាំងត្រូវចៀសវាងឱ្យផុតពីការជិះជាន់ សង្កត់សង្កិនអ្នកដទៃ ផ្តួលជំហរអ្នកដទៃ ដោយពង្រឹង

ជំហរខ្លួនឯង ឱ្យអស់ពីកម្លាំងកាយ កម្លាំងចិត្ត និងកម្លាំងបញ្ញាយ៉ាងណា ការប្រកួតប្រណាំងដើម្បីរស់នៅក្នុងបរលោក ដោយបំពេញបុណ្យកុសល ក៏ត្រូវចៀសវាងឱ្យផុតពីការជិះជាន់សង្កត់សង្កិនអ្នកដទៃ យ៉ាងនោះដែរ។ អ្នកសាងបុណ្យកុសល និងសាងកេរ្តិ៍ឈ្មោះត្រូវនៅក្នុងឧត្តមគតិថា៖

"បុណ្យជាអំពើល្អ ជាសភាពស្អាតបរិសុទ្ធ ជាធមិសម្រាប់ដុសលាងចិត្តវិញ្ញាណឱ្យបានស្អាត ឱ្យហ្មត់ចត់ផូរផង់ កាលណាចិត្តស្អាតបរិសុទ្ធ និងមានសុគតិប្រព្រឹត្តទៅក្នុងលោកខាងមុខ"។ (៣១)

ដូច្នេះបុណ្យកុសលនេះ អ្នកណាគេមិនធ្វើ ខ្លួនយើងត្រូវធ្វើ គេធ្វើដោយយឺតយូរ យើងធ្វើឱ្យបានឆាប់រហ័ស ធ្វើដោយពេញចិត្ត ធ្វើដោយសេចក្តីឈ្លាសវៃ ដោយសំអាងយកច្បាប់ព្រះពុទ្ធ និងភាពថ្លៃថ្នូររបស់មនុស្សជាគោលគំនិត។ ការធ្វើបុណ្យកុសលជាអំពើសម្រេចអំពីចិត្ត មានចិត្តជាសភាពផ្តួចផ្តើម មានចិត្តជាសភាពខាត់រំលីងឱ្យថ្លាស្អាត ចិត្តស្អាត ចិត្តភ្លឺ ប្រាសចាកមន្ទិល ប្រាសចាកភាពងងឹត ជាចិត្តគួរដល់បុណ្យកុសល។

អ្នកធ្វើបុណ្យកុសលតែងមានចិត្តទៅលើបុណ្យកុសល និងកេរ្តិ៍-ឈ្មោះ ទៅក្នុងការអភិវឌ្ឍ ទៅក្នុងការស្តារមុខមាត់អ្នករងគ្រោះ



ព្រោះថាសេចក្តីល្អដែលបុគ្គលបានធ្វើហើយ ទោះជាមិនមានអ្នកណាដឹងឮ ក៏ខ្លួនអ្នកបានដឹងជាប្រាកដ ទោះជាមិនមានអ្នកណាប្រោសប្រាណ ក៏គង់មានព្រះពុទ្ធអង្គណាមួយ ឬទេវតាណាមួយ ព្រះអង្គនឹងប្រោសប្រាណជាមិនខាន។ កាលណាយើងបានធ្វើបុណ្យកុសលក្នុងឧត្តមគតិ ដូចបានពោលមកនេះ យើងនឹងបានភប់ប្រសព្វវាសនាខ្ពង់ខ្ពស់ ក្នុងអនាគតជាពុំខាន។ គប្បីចេះតែធ្វើអំពើល្អបោះទៅក្នុងសមុទ្រជាប្រក្រតីទៅ បើត្រីមិនដឹង ក៏ទេវតាដឹងដែរ។

យើងបានជួបការតស៊ូដើម្បីរស់នៅក្នុងលោកបច្ចុប្បន្ន និងលោកអនាគត ដែលមនុស្សនៅមានការតស៊ូមួយទៀត ដែលជាការតស៊ូធំបំផុតក្នុងនាមជាពុទ្ធមាមកជន គឺការប្រយុទ្ធនឹងការកើត ចាស់ ឈឺ ស្លាប់ ដែលមានអវិជ្ជានិងតណ្ហាជាមេដឹកនាំ ការតស៊ូនេះហៅថា ការតស៊ូខាងក្នុង គឺច្បាំងនឹងសេចក្តីល្ងង់ សេចក្តីលោភ សេចក្តីក្រោធ សេចក្តីសប្បាយបោកប្រាស់ សេចក្តីសប្បាយបន្លំ កាលណាយើងឈ្នះសេចក្តីសៅហ្មងរបស់ខ្លួន យើងនឹងឈ្នះការកើត ចាស់ ឈឺ ស្លាប់ ឈ្នះទុក្ខសោក ឈ្នះសេចក្តីព្រាត់ប្រាស ឈ្នះលោកដែលជាទីលំនៅនៃទុក្ខគ្រប់ជាន់ គ្រប់ជ្រុង ហើយយើងនឹងបានសម្រេចនូវគ្រប់បំណងមគ្គ ផល និងព្រះនិព្វាន។

# ភាពប្រសើរជាងគេរបស់មនុស្ស

*ដោយសាមណេរ* **ខិន ម៉ៅ** (ថ្នាក់ឌីប្លូម)

តួនាទីរបស់សាសនា គឺណែនាំមនុស្សឱ្យកាន់យកនូវគោលការណ៍សីលធម៌ ដើម្បីធ្វើជីវិតឱ្យប្រកបដោយសន្តិភាព និងដើម្បីទ្រទ្រង់សេចក្តីថ្លៃថ្នូររបស់មនុស្ស។ ផ្ទុយទៅវិញ បើការរស់នៅរបស់គេគ្រាន់តែដើម្បីទទួលបាននូវអាហារបរិភោគ ទីស្នាក់អាស្រ័យ សេចក្តីសុខក្នុងកាមគុណ ហើយចង់បាននូវសេចក្តីថ្លៃថ្នូរដែរនោះ ពិតជាមិនអាចទៅរួចទេ គេបានត្រឹមតែបន្ថោកបន្ទាបខ្លួនឯងតែប៉ុណ្ណោះ។ នៅពេលណាដែលជីវិតមនុស្សរស់នៅ បំពេញតែតម្រូវការសភាវគតិផ្ទាល់ខ្លួន ពេលនោះគ្មានអ្វីដែលត្រូវបង្ហាញថា គេជាមនុស្សឡើយ។ មនុស្សគ្រប់រូបមានការរស់នៅប្រកបដោយភាពខ្ពង់ខ្ពស់ ហើយមានសមត្ថភាពស្វែងរកនូវសច្ចភាពដោយខ្លួនឯងផ្ទាល់ សត្វមានជីវិតដទៃក្រៅពីមនុស្ស មិនអាចថ្លឹងថ្លែង និងស្វែងរកឃើញនូវសច្ចភាព ពោលគឺព្រះធម៌បានឡើយ ពីព្រោះបញ្ញារបស់សត្វទាំងនោះមានកម្រិតទាប ជាបញ្ញាបែបសភាវគតិ មិនអាចពិចារណានូវអ្វីដែលពិត អ្វីដែលមិនពិត និងអាក្រក់ល្អបានទេ។ ដូច្នេះ យើងអាចកត់សម្គាល់បានថា មនុស្សគឺជាសត្វតែមួយគត់ដែលអាច



ទទួលយកនូវទ្រឹស្តីនៃសាសនា ដែលមានអត្ថន័យដ៏ស៊ីជម្រៅ និងស្មុគស្មាញបាន។

សូម្បីតែទេវតា ឥន្ទព្រហ្មដែលមនុស្សនាំគ្នាគោរពបូជា ធ្វើនូវការបន់ស្រន់សូមនូវសេចក្តីសុខ សេចក្តីចម្រើន ក៏មានបញ្ញាខ្ពស់មិនដល់មនុស្សដែរ។ ហេតុនេះហើយបានជាពពួកទេវតាទាំងនោះ មិនអាចត្រាស់ដឹងជាព្រះពុទ្ធបាន មានតែមនុស្សទេ ដែលមានសក្តានុពល អាចចម្រើន និងអភិវឌ្ឍបញ្ញារបស់ខ្លួនឱ្យដល់កម្រិតខ្ពស់បំផុត ហើយឈានទៅចាប់យកនូវអនុត្តរសម្មាសម្ពោធិញ្ញាណបាន។

ដោយបញ្ញាសម្បទាដ៏ឈ្លាសវៃនេះ មនុស្សបានព្យាយាមឈ្វេងយល់អំពីជីវិតពិតរបស់គេ ហើយបានបង្កើតឡើងនូវក្រមសីលធម៌ដ៏មានសណ្តាប់ធ្នាប់ល្អមួយ ដែលធ្វើឱ្យគេក្លាយជាអរិយបុគ្គល និងជាអ្នកសមគួរដល់ការគោរព និងបូជា។ តើអ្វីជាគ្រឹះសីលធម៌របស់មនុស្ស? ដើម្បីឆ្លើយនឹងសំនួរនេះ ដំបូងយើងត្រូវសួរខ្លួនឯងថា តើពាក្យថា “មនុស្ស” មានន័យយ៉ាងណា?។

ភាសាបាលី និងសំស្ក្រឹតប្រើពាក្យថា “មនុស្ស” ឬ “មនុស្យ” នៅពេលគេពោលសំដៅទៅលើសត្វដែលមានបញ្ញាខ្ពស់។ ទន្ទឹមនឹងនេះដែរ ពាក្យថា “មែន” “Man” ក្នុងភាសាអង់គ្លេស ដែលក្លាយមកពីភាសាសំស្ក្រឹតថា “មនុ” “Manu” មានន័យថា គិត, ពិចារណា

(to think)។ ពាក្យថា "មែន" (man) នេះដែលក៏ក្លាយមកពីពាក្យបាលីថា "មន" (mana) មានន័យថា ចិត្ត, គំនិត (mind, consciousness)។ ដូច្នេះអ្នកដែលមានសតិ វីប្រាជ្ញាចេះពិចារណា ហៅថា "មែន" (Man) (មនុស្សប្រុស ឬបុរស)។ តាមពិតទៅពាក្យបុរសក្នុងទីនេះ គឺពោលសំដៅទៅលើមនុស្សជាតិទាំងអស់ ទាំងប្រុសទាំងស្រី។ ជាងនេះទៅទៀត ភាសាចិនបានឱ្យនិយមន័យពាក្យ "មនុស្ស" នេះថា "ជនអ្នកមានបេះដូងស្រឡាញ់ និងចង់បាននូវអំពើល្អ" ក្នុងបេះដូងមនុស្សពិតជាមាននូវសមានចិត្ត ការអាណិតអាសូរ សន្តោស ប្រោសប្រណី ហើយនឹងសេចក្តីស្មោះត្រង់ ប្រសិនបើ មិនមានលក្ខណសម្បត្តិទាំងនេះទេ អ្នកនោះមិនត្រូវបានគេចាត់ទុកថា ជាមនុស្សពិតប្រាកដឡើយ។ ទស្សនវិទូបស្ចិមប្រទេសបានឱ្យនិយមន័យពាក្យ "មនុស្ស" ថា "អ្នកដែលអាចប្រើបញ្ញាប្រកបដោយវិចារណញ្ញាណសមហេតុផល"។ មនុស្សគឺជាអ្នកមានហេតុផលច្បាស់លាស់ក្នុងទង្វើរបស់ខ្លួន រីឯសត្វដទៃប្រើតែសភាវគតិប៉ុណ្ណោះ ដើម្បីចិញ្ចឹមជីវិត ស្វែងរកសេចក្តីសប្បាយ និងការពារខ្លួនពីការបៀតបៀនពីសត្រូវ។

នៅពេលដែលចិត្តរបស់មនុស្សត្រូវបានអប់រំឱ្យល្អ ដោយលះបង់នូវគតិអាក្រក់ ហើយចម្រើនផ្សាយនូវមេត្តា ករុណា គេអាច



ទទួលបាននូវភាពស្ងប់ដែលនាំទៅរកសភាពបរិសុទ្ធនៃចិត្ត។ ដូច្នេះ គ្រឹះសីលធម៌របស់មនុស្ស គឺជាអ្វីដែលធ្វើទៅតាមអត្ថន័យនៃឈ្មោះរបស់ខ្លួន "មនុស្ស" ដែលជាពាក្យដាក់មកសម្រាប់ហៅពពួកសត្វថ្នាក់ខ្ពស់ ដោយបញ្ញា និងការប្រតិបត្តិ។ ម្យ៉ាងទៀតគ្រឹះសំខាន់នៃសីលធម៌ គឺស្ថិតនៅត្រង់ទង្វើដែលគប្បីចំពោះខ្លួនឯង មិនក្បត់នឹងឧត្តមគតិរបស់ខ្លួន ហើយជាទង្វើដែលមិនប្រព្រឹត្តទៅដើម្បីបៀតបៀនជិះជាន់ និងរំលោភបំពានអ្នកដទៃ។ ហើយមនុស្សជាសត្វប្រសើរជាងគេ ព្រោះជាអ្នកចេះអភិវឌ្ឍខ្លួន ពីទាបទៅខ្ពស់ ពីថោកទាបទៅថ្លៃថ្នូរ ពីមនុស្សទៅទេវតា និងពីសាមញ្ញជនទៅជាអរិយបុគ្គលបាន។

## សភាពនៃចិត្តរបស់មនុស្ស

ចិត្តរបស់មនុស្សមានឥទ្ធិពលអាចវិភាគ និងពិចារណារកឃើញនូវវត្ថុធាតុសំខាន់ៗ និងប្រព័ន្ធផ្សេងៗទៀតជាច្រើនដែលមាននៅក្នុងចក្រវាឡទាំងមូល។ ចិត្តនេះមានលក្ខណៈលឿនរហ័ស កើតឡើងហើយរលត់ទៅវិញភ្លាមៗ ដូចជាផ្លេកបន្ទោរ ហើយមិនចេះសម្រាកស្ងៀមឡើយ។ ចិត្តជាថាមពលដ៏ខ្លាំងអស្ចារ្យមួយ ដែលគ្មានថាមពលណាមកប្រៀបផ្ទឹមបាន ចិត្តជាប្រធាននៃធម្មជាតិទាំងអស់ វាជាធម្មជាតិដែលមានអំណាចខ្ពស់ដាច់គេ អ្វីៗគ្រប់បែបយ៉ាងគឺ

កើតឡើងអំពីចិត្ត។ ព្រះពុទ្ធទ្រង់ត្រាស់ថា÷

"តថាគតពិចារណារកមិនឃើញសោះ នូវថាមពលដ៏ខ្លាំងក្លាណាមួយដែលមានល្បឿនលឿនជាងចិត្តរបស់មនុស្ស"។

ចំពោះអ្នកដែលធ្លាប់សិក្សាវិទ្យាសាស្ត្រ ពិតជាបានដឹងហើយអំពីលក្ខណៈនៃអាតូម អាតូមអាចធ្វើចលនាបានរាប់លានដងក្នុងមួយវិនាទី។ នៅក្នុងចិត្តវិជ្ជាពុទ្ធសាសនានិយាយថា នៅពេលរូបរាងកាយធ្វើបំលាស់ប្តូរមួយដង ចិត្តបានផ្លាស់ប្តូរ ១៧ ដងរួចទៅហើយ។ ចិត្តរបស់យើងកើតហើយរលត់ទៅវិញលឿនជាងផ្លេកបន្ទោរ មួយពាន់ដង នេះគឺជាលក្ខណៈធម្មជាតិរបស់ចិត្ត។

ក្រៅពីនេះ ចិត្តមានទំនួលខុសត្រូវចំពោះអ្វីៗទាំងអស់ដែលកើតឡើងក្នុងលោក ព្រះពុទ្ធទ្រង់សម្តែងថា÷

"ចិត្តមានទំនួលខុសត្រូវ ចំពោះរឿងរ៉ាវទាំងអស់ទាំងអាក្រក់ ទាំងល្អ ដែលកើតមានក្នុងលោក"។

ហើយពាក្យមួយឃ្លាទៀតនិយាយថា÷

"បើអ្នកគិតបែបណា អ្នកនឹងធ្វើយ៉ាងនោះ អ្វីដែលអ្នកធ្វើ គឺជាលទ្ធផលនៃគំនិតរបស់អ្នក"។

គ្មាននរណាម្នាក់អាចគ្រប់គ្រងចិត្តរបស់អ្នកដទៃបានឡើយ តែ



នៅពេលដែលយើងអប់រំចិត្តរបស់យើងបាន យើងនឹងមានឥទ្ធិពលទៅលើអ្នកដទៃ។ ការរៀននូវចំណេះដឹងផ្នែកវិទ្យាសាស្ត្រអាចធ្វើឱ្យមនុស្សយកទៅប្រើប្រាស់ខុស ដោយសារគំនិតអាត្មានិយម។ម្យ៉ាងទៀត ចិត្តនេះក៏អាចត្រូវបានគេអប់រំទៅតាមគន្លងនៃព្រះធម៌ និងដំណើរប្រព្រឹត្តទៅនៃលោកធាតុផងដែរ។ ឧទាហរណ៍ថា យើងបានរកឃើញនូវថាមពលនៃសារធាតុមួយ ដោយការអប់រំចិត្តបានល្អ យើងអាចប្រើនូវថាមពលនោះ ដើម្បីស្ថាបនានូវសមិទ្ធផលយ៉ាងច្រើនដែលជាប្រយោជន៍ដល់មនុស្សជាតិ ផ្ទុយទៅវិញ បើចិត្តមិនត្រូវបានគ្រប់គ្រង និងបង្វឹកឱ្យបានល្អទេ យើងអាចផលិតនូវអាវុធប្រល័យលោក ដែលអាចបំផ្លាញនូវពិភពលោកទាំងមូល បង្កនូវគ្រោះមហន្តរាយដ៏ធំធេងមួយ មិនអាចស្មានបាន។

ស្ទើរតែគ្រប់វត្ថុ និងសត្វមានជីវិតទាំងអស់ ត្រូវវិនាសសាបសូន្យទៅបន្តិចម្តងៗ ដោយសារគំនិតអត្តទត្ថបុគ្គលរបស់មនុស្សដែលកើតពីចិត្តដែលមិនបានទូន្មានឱ្យបានត្រឹមត្រូវ។ មនុស្សនាំគ្នាបំពុលទឹក បំពុលខ្យល់ និងបំផ្លាញបរិស្ថាន ដោយនិយាយថា ពួកគេកំពុងអភិវឌ្ឍ តែតាមការពិត គឺជាការបង្ហិនបង្ហោច។

ក្នុងនាមជាមនុស្ស យើងត្រូវមានគោលការណ៍កំណត់ខ្លួនឯងថា អ្វីដែលយើងធ្វើជាទង្វើដែលមិនប្រព្រឹត្តទៅដើម្បីបំផ្លាញ គឺត្រូវប្រ-

ព្រឹត្តទៅដើម្បីជាប្រយោជន៏ដល់មនុស្សជាតិ ។

មានតែនៅពេលដែលចិត្តត្រូវបានគ្រប់គ្រង និងតម្រង់ទិសឱ្យបានល្អទេ ទើបផ្ដល់នូវប្រយោជន៏ដល់ខ្លួនឯងផង និងសង្គមផង ចិត្តដែលមិនបានគ្រប់គ្រង ធ្វើឱ្យកើតនូវកង្វល់ដល់ខ្លួនឯង និងអ្នកដទៃ។ រាល់គ្រោះមហន្តរាយទាំងអស់ក្នុងលោក គឺជាស្នាដៃរបស់អ្នកដែលមិនបានទូន្មានចិត្តឱ្យមានតុល្យភាព និងស្ងប់ស្ងៀម ។

## ចរិត ឬលក្ខណៈបីយ៉ាងក្នុងខ្លួនមនុស្ស

កើតជាមនុស្ស យើងទាំងអស់គ្នាមានចរិតបីយ៉ាងមកជាមួយ ចរិតជាសត្វ ចរិតជាមនុស្ស និងចរិតជាទេវតា។ នៅពេលដែលយើងកើតមក ចរិតទាំងនេះមានមកជាស្រេចក្នុងខ្លួនរបស់យើង យើងមិនចាំបាច់រង់ចាំទៅកើតក្នុងឋានទេវតា ឬនរកដើម្បីសោយសុខ និងទុក្ខវេទនានោះទេ ។

ដូចយើងដឹងហើយ ជាធម្មតាវិចារណញ្ញាណរបស់សត្វ គឺមានដែនកំណត់ ក្នុងនាមជាមនុស្សយើងអាចប្រើនូវបញ្ញាដើម្បីបង្ក្រាប ឬគ្រប់គ្រងចរិតជាសត្វរបស់យើងបាន បន្ទាប់មកយើងអនុវត្តនូវសភាពជាមនុស្សរបស់យើង ឱ្យឡើងទៅកាន់សភាពជាទេវតា ។

គ្រប់ពពួកសត្វក្រៅពីមនុស្ស គ្មានវិធីសាស្ត្រណាដើម្បីគ្រប់គ្រង



នូវវាសនាជាសត្វរបស់គេបានឡើយ ព្រោះគេត្រូវបានដឹកនាំដោយសភាវគតិតែម្យ៉ាងប៉ុណ្ណោះ ។ ចំណែកមនុស្សដោយប្រើប្រាជ្ញា វិភាគថ្លឹងថ្លែង យើងអាចដឹងនូវអ្វីដែលល្អ អ្វីដែលអាក្រក់ ហើយដឹងនូវអ្វីដែលឃោរឃៅ ដែលកំណាច និងប្រកបដោយគ្រោះថ្នាក់ ដឹងនូវអ្វីដែលល្អ ហើយមានប្រយោជន៏សម្រាប់ខ្លួនឯងផង និងអ្នកដទៃផង ។ អ៊ីចឹងហើយបានជាមនុស្សត្រូវបានគេចាត់ជាសត្វដែលមានឋានៈខ្ពស់ជាងសត្វណាៗទាំងអស់ ។

ដោយការកម្ចាត់បង់នូវចរិតជាសត្វរបស់យើង ហើយចម្រើននូវសេចក្ដីស្រឡាញ់ និងការអាណិតអាសូរ ធ្វើឱ្យការអត់ធ្មត់ ការអត់ឱនអធ្យាស្រ័យ ការយោគយល់គ្នា ការឯកភាពគ្នា សុឆន្ទៈ សីលធម៌ និងសុជីវធម៌កើតឡើង ហើយរីកដុះដាលក្នុងចិត្តរបស់យើង ។ ទាំងនោះ គឺជាលក្ខណសម្បត្តិរបស់មនុស្ស ។

បើធ្វើការពិចារណា ទៅលើពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ-យើងអាចដឹងថា គោលបំណងដ៏ចម្បងរបស់សាសនា គឺដើម្បីលើកស្ទួយ និងបណ្ដុះបណ្ដាលនូវគុណសម្បត្តិទាំងនោះឯង ។ ទោះបីជា-យ៉ាងណាក៏ដោយ យើងត្រូវដឹងថា គុណសម្បត្តិមួយចំនួនបានកើតមកជាមួយយើងតាំងពីកំណើត ហើយតាមពិតយើងនាំគ្នាចម្រើននូវលក្ខណសម្បត្តិទាំងនោះ តាំងពីមុនសាសនាចាប់កំណើតមកម្លេះ ។

ចិត្តរបស់មនុស្សមានសារៈសំខាន់ណាស់ អាចធ្វើឱ្យមនុស្សសោយសុខសម្បត្តិសួគ៌ទាំងមិនទាន់ស្លាប់បាន វាប្រៀបដូចជាម៉ាស៊ីនដ៏ស្មុគ-ស្មាញមួយ អាចបង្កើតនូវឋាននរកដ៏សែនអាក្រក់បំផុតផងដែរ ។ ចិត្តនេះឯងអាចធ្វើឱ្យមនុស្សកាប់សម្លាប់គ្នា ដោយអំណាចនៃសេចក្តីលោភ ការច្រណែនឈ្នានីស និងជួនកាលគ្រាន់តែដើម្បីកំសាន្ត-សប្បាយ ហើយមិនដែលចេះស្កប់ស្កល់ឡើយ នៅពេលដែលបំណងប្រាថ្នាមួយបានសម្រេច ភ្លាមៗនោះគេចាប់ផ្តើមចង់បាននូវវត្ថុមួយផ្សេងទៀត ជាលទ្ធផល សេចក្តីសុខ និងសុភមង្គលដែលកើតឡើងហើយក៏វិនាសទៅវិញ ហើយបុគ្គលនោះកម្រទទួលបាននូវសេចក្តីសុខណាស់ ។

មហាត្មៈគន្ធីបាននិយាយថា ÷ "ពិភពលោកមានរបស់គ្រប់យ៉ាងសម្រាប់តម្រូវការរបស់មនុស្ស គ្រប់គ្នា តែវត្ថុទាំងនោះមិនគ្រប់គ្រាន់ឡើយសម្រាប់មនុស្សតែម្នាក់ដែលមានសេចក្តីលោភ"។

មនុស្សក្នុងលោកដែលប្រកួតប្រជែងគ្នារាល់ថ្ងៃ គឺដោយសារតែសេចក្តីលោភ ចង់បានមិនចេះស្កប់ស្កល់នូវទ្រព្យសម្បត្តិ ឬទ្ធិអំណាចព្រមទាំងសេចក្តីសប្បាយក្នុងកាមគុណផងដែរ ។[(៣២)]

# ព្រះសង្ឃខ្មែរ

*ដោយភិក្ខុ* **ទ៉ា ចន្ទបិន់** ( ថ្នាក់ឱប្លួម)

រាល់ប្រទេស ឬលទ្ធិសាសនាក្នុងលោកទាំងអស់ សុទ្ធតែមានបាវចនាសម្រាប់សម្គាល់រៀងៗខ្លួន។ ចំណែកពាក្យថា "ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ" ក៏ជាបាវចនាដែលប្រើជាទូទៅក្នុងព្រះពុទ្ធសាសនាដែរ។

ព្រះពុទ្ធ គឺជាអ្នកដែលខំប្រឹងកសាងអភិនីហារធម៌ អស់រយៈពេលច្រើនអសង្ខេយ្យ រហូតបានត្រាស់ដឹងអរិយសច្ចធម៌ ចាក់ធ្លុះជ្រាបច្បាស់អំពីបញ្ហាជីវិត។ ព្រះធម៌ គឺជាមាគ៌ា ឬជាវិធីសាស្ត្រសម្រាប់ដោះស្រាយបញ្ហាទាំងអស់ក្នុងឆាកជីវិត។ ព្រះសង្ឃ គឺជាអ្នកសិក្សា និងប្រតិបត្តិតាមព្រះធម៌ ព្រមទាំងជាអ្នកជួយបង្ហាត់បង្រៀន ពន្យល់ណែនាំពុទ្ធសាសនិក ឱ្យស្គាល់អ្វីដែលត្រូវលះបង់ អ្វីដែលត្រូវបំពេញ និងអ្វីដែលត្រូវចម្រើនស្របតាមពុទ្ធោវាទ។

ព្រះពុទ្ធមុនបរិនិព្វាន បានផ្ញើសាសនានឹងព្រះសង្ឃ ឧបាសក ឧបាសិកា។ ព្រះសង្ឃ គឺជាអ្នកនៅកៀកកើយក្បែរព្រះរតនត្រៃជាងគ្រហស្ថ ព្រោះគ្រហស្ថជាប់រវល់ដោយគេហកិច្ច។ តាមការស្ដាប់ចាស់ព្រឹទ្ធាចារ្យមួយចំនួន ដែលនិយាយតគ្នាថា សម័យមុន ខ្មែរ-



យើងឱ្យតម្លៃ និងគោរពព្រះសង្ឃព្រមទាំងវត្តខ្លាំងណាស់ រហូតមានពាក្យមួយឃ្លាថា "ពាក្យសង្ឃ ពាក្យសត្យ" ដែលមានពុទ្ធសាសនិកខ្មែរទាំងក្មេង ទាំងចាស់ជឿយ៉ាងមុតមាំថា បើព្រះសង្ឃធ្វើអ្វី និយាយអ្វី សុទ្ធតែជាការពិត និងមានប្រយោជន៍ទាំងអស់។ ហេតុនេះ ព្រះសង្ឃដើរតួសំខាន់ណាស់ក្នុងសង្គមខ្មែរ ពេលខ្លះដើរតួជាគ្រូបង្រៀន ពុទ្ធសាសនិកខ្មែរជំនាន់ដើមតែងយកកូនចៅធ្វើព្រះសង្ឃ ដើម្បីសិក្សាវិជ្ជាផ្លូវលោក និងផ្លូវធម៌ ហើយខ្លះក៏បានបួសជាសាមណេរ ខ្លះឧបសម្បទាជាភិក្ខុ ហើយខ្លះទៀតធ្វើជាកូនសេក្ខលោក ជាការងាយស្រួលក្នុងការបំពេញវិជ្ជា។ ពេលខ្លះ ដើរតួជាតុលាការដោះស្រាយជម្លោះ ប្រសិនបើជាមានជម្លោះដោះស្រាយមិនចេញ អ្នកស្រុកតែងទៅសុំសេចក្ដីសន្តោសពីព្រះគ្រូចៅអធិការ ដើម្បីជួយដោះស្រាយឱ្យ។ ពេលខ្លះ ដើរតួជាអ្នកអភិវឌ្ឍ ដូចជាប្រមែប្រមូលពុទ្ធបរិស័ទ លើកផ្លូវ សង់វិហារ កុដិ សាលា អណ្តូង ជាដើម។ ពេលខ្លះ ដើរតួជាវេជ្ជបណ្ឌិតព្យាបាលជម្ងឺផ្លូវកាយ និងផ្លូវចិត្ត។ ទោះបីការផ្សំថ្នាំ ឬប្រាប់ថ្នាំដល់អ្នកជម្ងឺ មានការខុសទាស់នឹងព្រះវិន័យក៏ពិតមែន ប៉ុន្តែដោយទឹកចិត្តប្រកបដោយសេចក្ដីអាណិតអាសូរ ចំពោះសត្វដែលរងទុក្ខ ក៏លោកដាច់ចិត្តប្រាប់របៀបព្យាបាល ឬ ព្យាបាលដោយផ្ទាល់។ ការព្យាបាលដ៏អស្ចារ្យនិងត្រឹមត្រូវបំផុត-

នោះ គឺព្យាបាលជម្ងឺផ្លូវចិត្ត នៅពេលដែលពុទ្ធបរិស័ទមានទុក្ខព្រួយដោយសារព្រាត់ប្រាសអ្នកជាទីស្រលាញ់ ឬជួបគ្រោះវិបត្តិអ្វីមួយ ព្រះសង្ឃតែងជួយដោះស្រាយ ដោយយកព្រះធម៌ជាឱសថ ក្នុងការព្យាបាលឱ្យបានធូរស្បើយស្ញើយពីទុក្ខា។ ដោយសារតែវិស័យអប់រំ វិស័យសុខាភិបាល អំណាចតុលាការ និងការអភិវឌ្ឍនាសម័យនោះ នៅមានកម្រិតនៅឡើយ។

បច្ចុប្បន្ន ទោះបីវិស័យទាំងអស់នេះ មានការរីកចម្រើនលូត-លាស់យ៉ាងណាក៏ដោយ ក៏ព្រះសង្ឃនៅតែខិតខំបំពេញតួនាទីទាំងនោះដដែល។ អង្គខ្លះ លោកមានឆន្ទៈបានបង្កើតអង្គការ ឬសមាគមផ្សេងៗ ទាំងក្នុងនិងក្រៅប្រទេស ដើម្បីជួយអប់រំចរិយាធម៌ សីល-ធម៌ និងវិជ្ជាជីវៈ មានបង្រៀនកុំព្យូទ័រ ភាសាបរទេស ដោយឥតគិតថ្លៃជាដើម ជាការងាយស្រួលក្នុងការបំពេញសម្មាជីព និងជាពលរដ្ឋល្អក្នុងសង្គម។

មកដល់សម័យទំនើបនេះ មនុស្សមួយចំនួនតូច ហាក់ដូចជារសាយចិត្តឆ្ងាយចាកវត្តអារាម និងព្រះសង្ឃ ដោយសារតែឃើញ ឬឮអំពីការប្រព្រឹត្តិមិនគប្បីរបស់បុគ្គលមួយក្ដាប់តូចក្នុងសាសនា។ ជនអ្នករួមសាសនាជាទីស្រឡាញ់! ទោះបីព្រះសង្ឃអង្គខ្លះមានការប្រ-ព្រឹត្តិឆ្គាំឆ្គងខុសទាស់នឹងព្រះវិន័យតិចតួច ត្រូវគិតថា ធម្មតាបុថុជ្ជន



នៅមានកិលេសមិនទាន់លះ លែងអីនឹងមានខុស។ តែអង្គខ្លះជាកល្យាណបុថុជ្ជន បានព្យាយាមសង្រួមប្រព្រឹត្តទៅតាមសិក្ខាបទ ឯអង្គខ្លះក៏មានការប្រព្រឹត្តិមិនប្រសើរ អាស្រ័យទៅតាមនិស្ស័យចរិត និងកិលេសានុកិលេស ដែលសម្បយុត្តនៅក្នុងចិត្តលោក។ ស្របនឹងពាក្យចាស់បរមបុរាណថា "ដូងមួយធ្លាយ មានតក់មាននាឡិ" យ៉ាងណា ព្រះសង្ឃក៏ដូចគ្នា ឬអាចហៅម្យ៉ាងទៀតថា ធ្វើជាអ្នកកាត់ក្ដីលែងអីនឹងខុស ធ្វើជាអ្នកបួសលែងអីនឹងត្រូវអាបត្តិ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ យើងគប្បីយល់ថា អ្នកដែលធ្វើខុសនោះ គឺជារឿងបុគ្គល មិនមែនជារឿងរបស់សង្ឃទាំងមូលទេ។ ការគិតដូចនេះ ទើបត្រឹមត្រូវ។

បណ្ដាប្រទេស ដែលគោរពកាន់ព្រះពុទ្ធសាសនាថេរវាទ មានប្រទេសកម្ពុជា ថៃ ឡាវ ភូមា ស្រីលង្កា និងជាតិខ្លះទៀត នៅទ្វីបអាស៊ី និងអឺរ៉ុប សុទ្ធតែមានព្រះវិន័យរបស់ព្រះពុទ្ធជាគោលដូចគ្នា ខុសគ្នាតែត្រង់ការលើកយកមកប្រតិបត្តិ និងទំនៀមទម្លាប់ ពិធីកម្មនៃប្រទេសនីមួយៗប៉ុណ្ណោះ។

ឆ្លងតាមបទពិសោធន៍ ដែលមកស្នាក់នៅភូមាដើម្បីសិក្សាព្រះ-បរិយត្តិធម៌ និងតាមរយៈការសាកសួរសព្រហ្មចារីខ្លះ ដែលសិក្សានៅប្រទេសថៃ ព្រមទាំងបានឮសំដីរបស់ពុទ្ធសាសនិកមួយចំនួន

ឃើញថា ការអនុវត្តព្រះវិន័យនៅប្រទេសខ្លះ មានការធូរលុងជាងប្រទេសខ្មែរយើង។

ហេតុនេះហើយ នៅពេលពុទ្ធសាសនិកខ្មែរម្នាក់និយាយថា "ចាំនាំគ្នាទៅធ្វើបុណ្យនៅប្រទេសគេម្តង ក្រែងមានព្រះសង្ឃបរិសុទ្ធជាងព្រះសង្ឃខ្មែរ ព្រោះគេកាន់ព្រះពុទ្ធសាសនាជិតដល់"។ ពេលនោះឧបាសិកា ធន់ សំបូរ ដែលបានរស់នៅ និងធ្វើការនៅស្ថានទូតខ្មែរ ប្រចាំប្រទេសភូមារយៈពេល ៣ ឆ្នាំ ហើយគាត់និងគ្រួសារក៏ជាញោមឧបដ្ឋាកទំនុកបម្រុងទាំងកម្លាំងកាយ ចាវាចិត្ត និងបច្ច័យទាំងបួនដល់ព្រះសង្ឃខ្មែរ ដែលគង់នៅសិក្សាទីនេះដែរ បានតបទៅវិញថា "រកព្រះសង្ឃណាបរិសុទ្ធជាងព្រះសង្ឃខ្មែរគ្មានឡើយ"។ លើសពីនេះទៅទៀត មានជនជាតិភូមាម្នាក់ឈ្មោះលោក ស្វេហាន (Shwe Han) ដែលរស់នៅ និងធ្វើការស្ថានទូតភូមា ប្រចាំប្រទេសកម្ពុជារយៈពេលបីឆ្នាំ គាត់បាននិយាយជាមួយព្រះសង្ឃខ្មែរ គង់នៅភូមានេះថា គាត់មានសេចក្តីជ្រះថ្លាខ្លាំងណាស់ ចំពោះព្រះសង្ឃខ្មែរ ព្រោះគាត់មិនដែលឃើញព្រះសង្ឃដើរប្រសេចប្រសាច ខុសកាលវេលា គឺគាត់ជួបព្រះសង្ឃតែពេលទ្រង់និមន្តបិណ្ឌបាតប៉ុណ្ណោះ ជួនកាល ស្ទើរតែមិនជួបទៀតផង ហើយនៅពេលដែលគាត់ឡើងផ្សារទំនើបម្តងៗ គាត់មិនដែលឃើញព្រះសង្ឃឡើយ។ នេះជាលក្ខណៈ



ដែលផ្ទុយពីប្រទេសគាត់ ដែលគាត់តែងឃើញព្រះសង្ឃធ្វើនេះ ធ្វើនោះមិនសមរម្យ ស្រគត់ស្រគំ សង្រួមដូចព្រះសង្ឃខ្មែរ។ (តាមមតិអ្នកនិពន្ធយល់ថា ដោយសារប្រទេសរបស់គាត់មានព្រះសង្ឃច្រើនជាងខ្មែរហើយមើលទៅ បានជាគាត់ឧស្សាហ៍ជួបព្រះសង្ឃនោះ។ តាមស្ថិតិព្រះសង្ឃភូមាមានប្រហែល ៤ សែនអង្គ ក្នុងចំណោមប្រជាជន ៦២ លាននាក់ ឯព្រះសង្ឃខ្មែរយើងមានប្រហែលជា ៥ ម៉ឺនអង្គប៉ុណ្ណោះ។ ស្របគ្នានេះដែរ ទើបព្រះតេជគុណបណ្ឌិត ហុក សុវណ្ណ បានធ្វើសេចក្តីអំពាវនាវចំពោះព្រះសង្ឃខ្មែរ ដែលនិមន្តទៅសិក្សាពុទ្ធសាសនា នៅប្រទេសផ្សេងៗ គប្បីរក្សាលក្ខណៈជាព្រះសង្ឃខ្មែរ គឺបានន័យថា នាំគ្នាទៅសិក្សាយកចំណេះវិជ្ជាពីប្រទេសគេមក ប៉ុន្តែត្រូវរក្សាលក្ខណៈ និងតម្លៃជាព្រះសង្ឃខ្មែរ។[៣៣] ម្យ៉ាងវិញទៀត មុនពេលខ្ញុំរៀបនឹងនិមន្តមកសិក្សានៅទីនេះ ខ្ញុំនិងព្រះសង្ឃមួយអង្គទៀត បានចូលទៅថ្វាយបង្គំលាព្រះគ្រូចៅអធិការវត្តសុទស្សនារាម (ជ្រោយថ្ម) ព្រះនាមឧត្តមប្រិយ៍ជា អន ធាងអាន ជាវត្តដែលខ្ញុំបានស្នាក់នៅ ដើម្បីសិក្សាអស់ថេរវេលា ៥ វស្សា។ ពេលនោះព្រះគ្រូចៅអធិការបានឧបត្ថម្ភបច្ច័យជាសោហ៊ុយខ្លះ និងបានប្រគេនពរជ័យសិរីសួស្តី ព្រមទាំងផ្តល់ឱវាទដ៏ល្អ ដែលខ្ញុំទាំងពីររូបចាំមិនភ្លេច គឺព្រះតេជគុណបានមានថេរដីកាថា "ទៅរៀនស្រុក

គេ គប្បីយកសាច់ កុំយកសម្បកឱ្យសោះ”។ សាច់ទីនេះ ប្រៀបទៅនឹងចំណេះវិជ្ជា រីឯសម្បកប្រៀបទៅនឹងអរិយធម៌ វប្បធម៌របស់គេ។ លោកគ្រូចង់ទូន្មានថា ទៅរៀនប្រទេសគេ គប្បីយកតែចំណេះដឹងមកជួយអភិវឌ្ឍប្រទេសយើងបានហើយ កុំយកអរិយធម៌ វប្បធម៌គេមកសាបព្រោះលើទឹកដីយើងធ្វើអី ព្រោះប្រទេសយើងមានអរិយធម៌ វប្បធម៌ល្អបរិបូណ៌ គ្រប់គ្រាន់ហើយ។

ការរៀបរាប់មកនេះ មិនមែនក្នុងចេតនារិះគន់បន្ទុះបង្អាប់ប្រទេសគេទេ ហើយក៏មិនមែនថា គេមិនចេះវិន័យដែរ។ ប្រទេសភូមានេះ ភាគច្រើនសុទ្ធតែជាពហុស្សូត្រ បញ្ញវន្ត បណ្ឌិត ជួនកាលខ្ញុំនិយាយលេងជាមួយមិត្រភក្តិថា “នៅភូមាហ្នឹង ដើរមិនស្រួលជាន់បណ្ឌិតមិនដឹងខ្លួន”។ អ្នកខ្លះបញ្ចប់បណ្ឌិតក្នុងស្រុក ខ្លះក្រៅស្រុកនឹងមានឯកទេសផ្សេងៗគ្នា។ បណ្ឌិតខ្លះផ្នែកទស្សនវិជ្ជា ខ្លះផ្នែកវិទ្យាសាស្ត្រ និងខ្លះទៀតផ្នែកព្រះពុទ្ធសាសនា ដែលគួរឱ្យស្ងើចបំផុតនោះ នៅប្រទេសនេះ មានអ្នកចេះចាំអាចសូត្រព្រះត្រៃបិដកចប់រហូត ៧ អង្គ ដែលគង់នៅសព្វថ្ងៃនេះ។ សូមបញ្ជាក់ថា អង្គដទៃទៀតក៏មានការចេះចាំព្រះត្រៃបិដកនេះដែរ តែមិនទាន់ចាំបិដកទាំង ៣ គម្ពីរទេ គឺ អង្គខ្លះទ្រទ្រង់ព្រះវិន័យ អង្គខ្លះទ្រទ្រង់ព្រះសូត្រ អង្គខ្លះទ្រទ្រង់ ព្រះអភិធម្ម ហើយអង្គខ្លះទៀតទ្រទ្រង់បានពីរគម្ពីរ



ព្រះសូត្រ និងព្រះវិន័យ ឬព្រះវិន័យ និងព្រះអភិធម្ម ឬព្រះសូត្រ និងព្រះអភិធម្ម ជាដើម។

ដូច្នេះ ការប្រតិបត្តិព្រះពុទ្ធសាសនាមានការខ្វះខាត ដោយអន្លើៗដូចគ្នា មិនថាប្រទេសយើង ប្រទេសគេទេ។ តែនៅប្រទេសគេមិនឃើញចុះផ្សាយពតិមានអ្វី ដែលប៉ះពាល់ដល់ព្រះពុទ្ធសាសនាឡើយ ទោះបីព្រះសង្ឃធ្វើអ្វីខុសឆ្គងក៏ដោយ។ ចំណែកប្រទេសយើងវិញ សូម្បីតែបញ្ហាតិចតួច ក៏ចុះផ្សាយតាមកាសែត ទស្សនាវដ្ដី វិទ្យុ ទូរទស្សន៍ អ៊ីនធឺណែត ឬនិយាយតគ្នាពីមាត់មួយទៅមាត់មួយដែរ។ ការចុះផ្សាយធ្វើឱ្យប៉ះពាល់ខ្លាំងណាស់ដល់ព្រះពុទ្ធសាសនាមានដូចជា ÷

- ធ្វើអ្នកគ្មានសទ្ធា ឱ្យរឹងរឹតតែឃ្លាតឆ្ងាយពីព្រះពុទ្ធសាសនា និងនាំគ្នារិះគន់ហែកហួរពីទង្វើអាក្រក់ក្នុងព្រះពុទ្ធសាសនាថា ជាទង្វើពុទ្ធសាសនា តាមការពិតជាទង្វើបុគ្គលសោះ ហើយនាំគ្នាបែរទៅកាន់សាសនាដទៃ។
- ធ្វើអ្នកមានសទ្ធាឱ្យធ្លាក់ទឹកចិត្តក្នុងការបំពេញទង្វើល្អ។
- ជាចំណុចខ្សោយដែលសាសនាដទៃលើកឡើង ដើម្បីបង្អាប់ព្រះពុទ្ធសាសនាក្នុងការផ្សព្វផ្សាយសាសនារបស់ខ្លួន។
- ធ្វើអ្នកដែលខ្វះការអប់រំ បដិសេធចោលព្រះពុទ្ធសាសនា

ទាំងមិនបានសិក្សាឱ្យបានស៊ីជម្រៅ។

- បាត់បង់ធនធានព្រះសង្ឃ ដោយសារទៅណាមកណាក៏ឮគេនិយាយយ៉ាងនេះមួយ យ៉ាងនោះមួយ ពីចំណុចមិនល្អរបស់ព្រះសង្ឃ ជាហេតុឱ្យព្រះអង្គខ្លះលាសិក្ខាបទ។ ជួនកាលមានកុលបុត្រមួយចំនួនសូមមាតាបិតាទៅបួស មាតាបិតាមិនអនុញ្ញាតក៏មាន ដោយគិតថា ខ្លាចកូនគាត់ប្រព្រឹត្តមិនល្អ ហើយគេចុះកាសែត ផ្សាយតាមវិទ្យុ ទូរទស្សន៍ទៅ នាំឱ្យខ្មាសគេទាំងពូជ។ ណាមួយសម័យនេះជាសម័យកុំព្យូទ័រផង គ្មាននរណាមួយចង់បួសស្រាប់ មកបួសគ្មានអីសប្បាយ ឃើញតែគេនិយាយដើមទៀត។ កាលខ្ញុំនៅរៀនពុទ្ធិកវិទ្យាល័យ សម្ដេច ជួន ណាត ខ្ញុំតែងតែឮពាក្យរិះគន់តិះដៀលព្រះសង្ឃជាញឹកញាប់ ជាពិសេសពេលព្រឹក និងល្ងាច ក្រោយពីគេបានស្ដាប់ពតិមាន ឬអានកាសែត។ រឿងខ្លះគេបានភ្លេចបាត់ទៅហើយ តែពេលបានឃើញព្រះសង្ឃ ហាក់ដូចជារំលឹកគេនូវរឿងដែលភ្លេច ហើយញ៉ាំងគេឱ្យនិយាយអាក្រក់ តាមដែលគេចងចាំដោយមានព្រះសង្ឃជាកម្មបទ។ នៅព្រឹកមួយ ពេលខ្ញុំនិងមិត្តនិមន្តទៅរៀនតាមផ្លូវ ពេលនោះមានមនុស្សពីរបីនាក់គ្រាន់តែឃើញខ្ញុំនិងព្រះសង្ឃឯទៀតភ្លាម ក៏ស្រាប់តែនិយាយយ៉ាងឮៗថា "ពួកអាឯងបួសហើយ កុំធ្វើជើងកាង ជើងកោងវ៉ឺយ"។ ខ្ញុំនិងមិត្តមិនបាន



បង្អង់ឡើយ គ្រាន់តែពួកគាត់និយាយចប់ភ្លាម ក៏បន្ថែមល្បឿនលឿនជាមុន។ ខ្ញុំនិយាយលេងជាមួយមិត្តថា "បានបង្អែមកាត់ព្រឹកទើបតែឆាន់យាគូ ហើយអត់បង្អែមផង"។ ពេលព្រឹកនោះ ពតិមានស្ដីពីព្រះសង្ឃឈ្លោះគ្នា ហើយកាប់គ្នា ដេរពីរបីថ្នេរ។ តាមការសន្និដ្ឋានរបស់ខ្ញុំ ប្រហែលជាគាត់បានស្ដាប់ពតិមាននេះដែរហើយមើលទៅ។

ទម្លាប់ខ្មែរយើងច្រើនតែទម្លាក់កំហុសដាក់លើទីកន្លែង បើបុគ្គលណាមួយប្រព្រឹត្តខុសមានបារាជិកជាដើម គេមិនថាត្រឹមតែបុគ្គលនោះបារាជិកទេ តែគេថាវត្តនោះបារាជិកទៀត ហើយលែងនាំគ្នាទៅធ្វើបុណ្យទាននៅទីនោះ។ នេះជាការវិនិច្ឆ័យមួយអយុត្តិធមិបំផុតសម្រាប់ទីកន្លែង បើសិនជាទីកន្លែងមានចិត្តវិញ ម្ល៉េះរកមេធាវីប្ដឹងតវ៉ាមិនខាន។ ទង្វើនេះមិនត្រឹមត្រូវទាល់តែសោះ ចំពោះបច្ឆាជនដែលត្រូវទទួលមរតកអាក្រក់ បន្ដពីអ្នកជំនាន់មុនបន្សល់ទុកឱ្យ។ ឧទាហរណ៍ដូចជា វត្តណាដែលមានលោកបារាជិក ហើយមានព្រះសង្ឃទៅគង់នៅ ឬមានកុលបុត្របួសរៀនទីនោះ នឹងត្រូវបានទទួលពាក្យរិះគន់ ជាសំណងមកវិញមិនខាន។ ត្រង់នេះ វាផ្ទុយស្រឡះពីច្បាប់កម្មផល ដែលចែងថា អ្នកណាធ្វើ អ្នកនោះទទួល តែនេះបែរជាអ្នកធ្វើមុន ទុកផលដល់អ្នកក្រោយទទួលដែរ។ ដូច្នេះការកាត់ក្ដី

មិនសុក្រឹតទេ សូមពុទ្ធបរិស័ទពិចារណាឡើងវិញ ត្រង់ចំណុចនេះ។ បើអ្នកធ្វើខុស ដាក់ទោសអ្នកធ្វើខុសបានហើយ កុំទម្លាក់កំហុសដល់ទីកន្លែង និងពន្លកក្រោយទៀត។ ត្រង់ចំនុចនេះ ខ្ញុំយល់ថា ការដាក់កំហុសទៅលើទីកន្លែង គឺមិនសមស្របទេ គឺបើវត្ត ១ មានភិក្ខុត្រូវអាបត្តិបារាជិក គឺត្រូវតែបុគ្គលអ្នកប្រព្រឹត្តនោះឯង រីឯវត្តដែលជាទីកន្លែងគ្មានចិត្តវិញ្ញាណសម្រាប់ដឹងអ្វីទេ។ ដូច្នេះ វត្តនោះមិនត្រូវបារាជិកតាមភិក្ខុ ឬបុគ្គលនោះឡើយ។ ពុទ្ធបរិស័ទអាចធ្វើបុណ្យទានជាមួយព្រះសង្ឃក្នុងវត្តនោះបានតាមធម្មតា។ តើវត្តដែលជាទីកន្លែងចេះត្រូវបារាជិកមែនឬទេ? ឆ្លើយថា ទេ។ ដើម្បីយល់ឱ្យបានច្បាស់លាស់ក្នុងរឿងនេះ សូមឧបមាថា បើភិក្ខុ ១ អង្គ យកស្រីទៅលេងក្នុងស្រែមួយ តើស្រែនោះត្រូវបារាជិក ហើយម្ចាស់ស្រែនោះមិនអាចធ្វើការបង្កបង្កើនផលបានទៀតឬ? ឬត្រូវបោះបង់ស្រែនោះចោលដោយសារតែរឿងអាស្រូវកើតឡើងក្នុងទីនោះ? បើមានសត្វកណ្ដុរងាប់ក្នុងផ្ទះមួយ គេមិនដែលប្រើវិធីបោសសំអាតផ្ទះនោះ ដោយការដុតបំផ្លាញវាចោលឡើយ គឺគេគ្រាន់តែយកកណ្ដុរដែលងាប់ស្អុយនោះទៅចោលទៅបានហើយៗ យើងអាចរស់នៅ ឬធ្វើអ្វីៗនៅផ្ទះនោះបានតាមធម្មតា។

តាមពិតទៅ បញ្ហា ឬជម្លោះ (អធិករណៈ)[(៣៤)] កើតឡើងអាស្រ័យ មូលហេតុផ្សេងៗគ្នា។ ព្រះសម្មាសម្ពុទ្ធទ្រង់ចាត់អធិករណ៍ជាបួនប្រភេទ គឺ ÷



១- *វិវាទាធិករណៈ* ជម្លោះកើតឡើងអាស្រ័យទស្សនៈយល់ឃើញខុសគ្នា ឬខ្វែងគំនិតគ្នា។ អ្នកខ្លះថា នេះជាធម៌ នេះមិនមែនជាធម៌ នេះជាវិន័យ នេះមិនមែនជាវិន័យ នេះជាទោស នេះមិនមែនជាទោស ជាដើម។

២- *អនុវាទាធិករណៈ* ជម្លោះកើតឡើងដោយការចោទប្រកាន់គ្នា។ ភិក្ខុខ្លះត្រូវបានគេចោទដោយសីលវិបត្តិ (បារាជិក) ឬគរុកាបត្តិ (សង្ឃាទិសេស)។

៣- *អាបត្តាធិករណៈ* ជម្លោះកើតឡើងដោយការប្រព្រឹត្តិកន្លងនូវសិក្ខាបទណាមួយ ក្នុងចំណោមអាបត្តិទាំងប្រាំពីរកង។

៤- *កិច្ចាធិករណៈ* ជម្លោះកើតឡើងទាក់ទិននឹងសង្ឃកម្មមានអបលោកនកម្ម ញត្តិកម្មជាដើម។

ក្រោយពីចាត់អធិករណ៍ជាបួនក្រុមហើយ ព្រះបរមគ្រូទ្រង់បានបង្រៀនពីវិធីសាស្ត្រដោះស្រាយជម្លោះប្រាំពីរយ៉ាង ដែលស្មើនឹងភាសាបាលីថា "*សត្តាធិករណសមថៈ*"

ក- *សម្មុខាវិន័យ* ដោះស្រាយដោយនាំគូវិវាទ វត្ថុវិវាទ

នីតិវិធីវិវាទ និងភិក្ខុអ្នកដោះស្រាយវិវាទឱ្យបានព្រមគ្នាក្នុងទីចំពោះមុខសង្ឃ គណៈ បុគ្គល និងក្នុងទីចំពោះមុខធម៌វិន័យ ហើយកាត់សេចក្តីថាខុសឬត្រូវ ។

ខ- *សតិវិន័យ* ដោះស្រាយដោយសង្ឃ ឬគណៈធានាអះអាងថា ភិក្ខុហ្នឹងមិនមានកំហុសដូចការចោទទេ ព្រោះការចោទមិនមានមូលច្បាស់លាស់ ។

គ- *អមូឡ្ហវិន័យ* ដោះស្រាយដោយការធានារបស់សង្ឃ ឬគណៈ ឬពេទ្យចំពោះភិក្ខុដែលកើតជម្ងឺផ្លូវចិត្ត ឆ្កួតមិនមានសតិក្នុងទង្វើរបស់ខ្លួន ដោយមិនឱ្យអ្នកនោះមានកំហុសក្នុងពេលឆ្កួត ។

ឃ- *យេភុយ្យសិកា* ការយកមតិភាគច្រើន ជាអ្នកសម្រេចដោយរបៀបចាប់ស្លាក ។ របៀបនៃការចាប់ស្លាក ដំបូងត្រូវចាត់តាំងសលាភគ្គាហាបកៈ (អ្នកចែកស្លាក) ដែលប្រកបដោយអង្គ ៥ យ៉ាងគឺ ÷ មិនលំអៀងដោយសេចក្តីស្រឡាញ់ ដោយស្អប់ ដោយខ្លួនល្ងង់ខ្លៅ ដោយខ្លាចអំណាចគេ និងជាអ្នកដឹងស្លាកដែលគេបានចាប់ និងមិនបានចាប់ ។

## ការចាប់ស្លាកមាន ៣ ប្រភេទ

- *គូឡ្ហកៈ* ចាប់ស្លាកដោយបិទមុខ ឬរបៀបលាក់កំបាំង នេះចំពោះអធម្មវាទីមានគ្នាច្រើនជាង,



- *វិវដកៈ* ចាប់ស្លាកដោយបើកចំហ នេះចំពោះធម្មវាទីមានគ្នាច្រើនជាង,
- *សកណ្ណជប្បកៈ* ចាប់ស្លាកដោយរបៀបខ្សឹបប្រាប់ នេះចំពោះអ្នកចូលរួមច្រើនជាមនុស្សល្ងង់,

ង- *បដិញ្ញាតករណៈ* ដាក់ទោសដល់អ្នកដែលបង្កវិវាទតាមការដែលគេទទួលខុស ហើយប្តេជ្ញាថា នឹងមិនធ្វើអំពើនោះតទៅទៀត ។

ច- *តស្សបាបិយសិកាកម្មៈ* ដោះស្រាយដោយការដាក់ទោសឱ្យអ្នកនោះទទួលនូវសេចក្តីវិនាស ទៅតាមទង្វើរបស់ខ្លួន

ឆ- *តិណវត្ថារកៈ* ដោះស្រាយដោយឱ្យអ្នកទាំងសងខាងយល់គ្នា បំភ្លេចរឿងចាស់ចោល មិននឹកនាខុសត្រូវតទៅទៀត (ផ្សះផ្សាគ្នា) នេះចំពោះកំហុសស្រាល ឬតិចតួចដែលអាចអត់ឱនបាន ឧបមាដូចជា យកស្មៅទៅគ្របលើលាមកកុំឱ្យសាយភាយក្លិនស្អុយឡើង ។[៣៥]

## បណ្តាអធិករណ៍ទាំង ៤ យ៉ាងនេះ[៣៦]

- *វិវាទាធិករណ៍* រម្ងាប់ដោយ *សម្មុខាវិន័យ* និងយេភុ-យ្យសិកា

- អនុវិវាទាធិករណ៍ រម្ងាប់ដោយ សម្មុខាវិន័យ, សតិវិន័យ, អមូឡ្ហវិន័យ និង តស្សបាបិយសិកាកម្ម
- អាបត្តាធិករណ៍ រម្ងាប់ដោយ សម្មុខាវិន័យ, បដិញ្ញាតករណៈ និង តិណវត្ថារកៈ
- កិច្ចាធិករណ៍ រម្ងាប់ដោយ សម្មុខាវិន័យតែម៉្យាង។

បើតាមការសិក្សាព្រះវិន័យបិដក សម័យពុទ្ធកាល ក៏មានភិក្ខុប្រព្រឹត្តខុសច្រើនដែរ តែមិនឃើញថា ព្រះសម្មាសម្ពុទ្ធទ្រង់អនុញ្ញាតឱ្យចុះកាសែត ផ្សាយតាមវិទ្យុ ឬប្រាប់បរិស័ទទេ ប្រហែលជាសម័យកាលនោះ គ្មានបច្ចេកវិទ្យាទាំងអស់នោះ។ តែព្រះអង្គបានដោះស្រាយរាល់បញ្ហាបានយ៉ាងល្អឯក ព្រមទាំងបានបន្សល់ទុកនូវមធ្យោបាយនេះ ដល់ពុទ្ធបរិស័ទក្នុងការវិនិច្ឆ័យរកខុសត្រូវនៃអធិករណ៍។ ដូច្នេះយើងជាអ្នកដើរតាមព្រះពុទ្ធអង្គ គួរណាស់តែយកច្បាប់ទាំងនោះមកអនុវត្ត ប្រសើរជាងរឿងតូចបង្ខូចឱ្យជាធំ។ បើសិនជា បុគ្គលណាមួយប្រព្រឹត្តខុសដោយគរុទោស ឬលហុទោស ត្រូវតែដាក់កំហុសតាមទោសដែលខ្លួនប្រព្រឹត្ត បើត្រូវទោសស្រាល (អាបត្តិ ៥ កង មានថុល្លច្ច័យជាដើម) គួរឱ្យទេសនាវិធី បើត្រូវទោសធ្ងន់ សង្ឃាទិសេស គួរឱ្យវុដ្ឋានវិធី ឬបើត្រូវបារាជិកត្រូវធ្វើការប្ដេជ្ញាខ្លួនជាគ្រហស្ថ (សឹកចេញ)។



ជាថ្មីម្ដងទៀត ខ្ញុំសូមសំណូមពរ ដល់ជនអ្នករួមសាសនាជាទីគោរពទាំងអស់ បើមានករណីជាប់ពាក់ព័ន្ធនឹងពុទ្ធសាសនា កុំគប្បីចុះផ្សាយតាមទំព័រកាសែត អ៊ីនធឺណែត វិទ្យុ ទូរទស្សន៍ ធ្វើអ្វី ព្រោះកិច្ចទាំងអស់នេះ ជាភារៈកិច្ចរបស់សមាគមសង្ឃ និងក្រសួងធម្មការជាអ្នកដោះស្រាយ។

ជាទីបញ្ចប់នៃសំណេរនេះ ខ្ញុំសូមផ្ញើអត្ថបទនេះ ជូនចំពោះគណៈគ្រប់គ្រងសាលា លោកគ្រូ និងមិត្តទាំងអស់ដែលសិក្សានៅពុទ្ធិកវិទ្យាល័យ សម្ដេច ជួន ណាត ព្រមទាំងសប្បុរសជនដែលស្រឡាញ់រាប់អានព្រះពុទ្ធសាសនាដូចគ្នា ទាំងក្នុង និងក្រៅប្រទេស ហើយខ្ញុំសង្ឃឹមថាប្រធានអត្ថបទដ៏ខ្លីនេះ នឹងបានជាវិភាគទានជួយឱ្យព្រះពុទ្ធសាសនារីកចម្រើនរុងរឿង ក្នុងបិតុជាតិមាតុភូមិរបស់យើង និងទូទាំងពិភពលោក។ សូមឱ្យពិភពលោកទាំងមូលទទួលនូវសន្តិភាព តាមមាគ៌ាព្រះពុទ្ធសាសនា។

"គន្លឹះសម្រាប់ការអភិវឌ្ឍមនុស្ស គឺត្រូវមើលឃើញពួកគេធ្វើត្រូវ"

# មនុស្សជាអ្វី?

*ដោយសាមណេរ* **ផ្លិច មាស** (ថ្នាក់ឱ្យប្លូម)

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស។ (៣ដង) ខ្ញុំព្រះករុណាសូមឱនកាយវាចាចិត្តថ្វាយបង្គំ ចំពោះព្រះអរហន្តមុនី សម្មាសម្ពុទ្ធអង្គនោះដោយសេចក្ដីគោរព។

បន្ទាប់ពិនេះទៅ សូមបរិយាយអំពីមនុស្សដូចតទៅ ÷

ពាក្យថា "មនុស្ស" មកពី មន ធាតុ + ឧស្ស បច្ច័យ។ ដោយ មនៈ ប្រែថា ចិត្ត [អារម្មណំ ចិន្តេតីតិ = ចិត្តំ (ធម្មជាតំ), (ធម្មជាតណា) គិតនូវអារម្មណ៍ (ធម្មជាតនោះ) ឈ្មោះថា ចិត្ត][៣៧], វិញ្ញាណ [វិជានាតីតិ = វិញ្ញាណំ (ធម្មជាតំ), (ធម្មជាតណា) ដឹងនូវអារម្មណ៍ (ធម្មជាតនោះ) ឈ្មោះថា វិញ្ញាណ],[៣៨] ហទយៈ (ក្នុងព្រះអភិធម្ម) និង ឧស្ស ប្រែថា ខ្ពស់, ខ្ពង់ខ្ពស់, ថ្លៃថ្លា, ឧត្តម។[៣៩]

អត្ថន័យនៃ ពាក្យ ថា "មនុស្ស" ក្នុងទីនេះមាន ៣ យ៉ាងគឺ ÷

១- ជនអ្នកមានចិត្តខ្ពស់ សមដូចបទវិគ្គហៈថា "មនោ ឧស្សោ ឧស្សន្នោ អស្សាតិ = មនុស្សោ"។



២- ជនអ្នកដឹងនូវអំពើដែលមានប្រយោជន៍ និងអំពើមិនមានប្រយោជន៍ ដូចបទវិគ្គហៈថា "ហិតាហិតំ មនតិ ជានាតីតិ= មនុស្សោ"។[៤០]

៣- ជាអ្នកដឹងនូវហេតុគួរ និងហេតុមិនគួរ លោកឱ្យឈ្មោះថា "មនុស្ស" ឬ សត្វវិសេស ព្រោះមានបទវិគ្រោះថា "ការណាការណំ មនតិ ជានាតីតិ = មនុស្សោ (សត្តវិសេសោ)។[៤១]

ដូច្នេះ អត្តភាពជាមនុស្សដែលកើតឡើងដោយអំណាចកុសលកម្មទាំងឡាយ មានការធ្វើទាន រក្សាសីល ចម្រើនសមថវិបស្សនា ធ្វើតបសេចក្ដីល្អចំពោះអ្នកមានគុណ ការថ្វាយបង្គំព្រះរតនត្រៃជាចិត្តប្រកបដោយកុសលញាណសម្បយុត្ត ឬកុសលញាណវិប្បយុត្តក្ដី សុទ្ធតែជាកម្លាំងជំរុញឱ្យបានសម្បត្តិមនុស្ស។ មនុស្សនេះ ជាសត្វមានពូជពង្សដ៏ប្រសើរខ្ពង់ខ្ពស់ មានអានុភាពអាចញ៉ាំងខ្លួនឱ្យបានសម្រេចឋានៈផ្សេងៗដូចជា ព្រះពុទ្ធ បច្ចេកពុទ្ធ អគ្គសាវ័កពុទ្ធ អរហត្តបុគ្គល ឯតទគ្គបុគ្គល ពុទ្ធុបដ្ឋាក មគ្គផលថ្នាក់ទាប ថ្នាក់ខ្ពស់ សម្បត្តិអរិយបុថុជ្ជន សម្បត្តិស្ដេចចក្រពត្តិ សម្បត្តិទេវតា ឬសម្បត្តិ

ព្រះឥន្ទ-ព្រះព្រហ្មជាដើម ។ នេះគឺដោយសារអំណាចមហាបុញ្ញកិរិយា ជាអំពើបុណ្យកុសល ដែលខ្លួនខំកសាងពីមនុស្សជាតិនេះឯង ។

ហេតុនេះ យើងគ្រប់គ្នាត្រូវតែថែរក្សានាមញ្ញត្តិរបស់ខ្លួន ក្នុងឋានៈជាមនុស្សនេះឱ្យគង់វង្ស ឬខំធ្វើឱ្យប្រសើរថែមទៀត ជាការប្រពៃណាស់ បើមិនដល់ធម៌ថ្នាក់ទេវតា ព្រះឥន្ទ-ព្រះព្រហ្មទេ សូមកុំដុតបំផ្លាញ ពូជសន្តានខ្លួនឯង ឱ្យធ្លាក់ចុះមករកធម៌ថោកទាបរបស់សត្វតិរច្ឆាន ឬសត្វនរកប្រេតឡើយ ។ ព្រោះឱកាសដែលបានកំណើតជាមនុស្សពេញលេញនេះ ព្រះសម្មាសម្ពុទ្ធទ្រង់សម្តែងថា កម្រណាស់ ។

## ហេតុអ្វីបានជាមនុស្សហៅថាសត្វដែរ?

ព្រោះពាក្យសត្វ ឬសត្តប្រែឱ្យខ្លីថា "អ្នកជាប់ជំពាក់" (រូបាទីសុ សញ្ជតីតិ = សត្តោ) ។ តើជាប់ជំពាក់អ្វី? ។ បញ្ចកាមគុណេ សេវតីតិ =បញ្ចកាមគុណសេវី នរៈណាជាប់ជំពាក់ ឬសេពនូវកាមគុណប្រាំ គឺ÷ រូប សម្លេង ក្លិន រស ផោដ្ឋព្វៈ (របស់ដែលមកប៉ះផ្ទប់នឹងកាយ) នរៈនោះលោកហៅថា សត្វ។ ម្យ៉ាងទៀត នរណាជាប់ជំពាក់នឹងការកើត ចាស់ ឈឺ ស្លាប់ ឬជាប់ជំពាក់នឹងភព ៣ គឺៈ កាមភព



ភពអាស្រ័យកាម រូបភព ភពអាស្រ័យរូប អរូបភព ភពមិនអាស្រ័យរូប គឺអាស្រ័យត្រឹមតែនាមធម៌ នរៈនោះលោកហៅថា សត្វ ។

តាមធម្មតា មនុស្សយើងគ្រប់គ្នាសុទ្ធតែជាប់ជំពាក់ ឬអាស្រ័យនូវសភាវៈទាំងអម្បាលម៉ាន ដែលបានពោលហើយនោះដែរ ដូច្នេះមនុស្សក៏ជាសត្វដែរ ប៉ុន្តែជាសត្វមានចិត្តខ្ពស់ ជាសត្វស្គាល់ ខុសស្គាល់ត្រូវ ជាសត្វមានវិចារណញ្ញាណ ជាសត្វមានបញ្ញាខ្ពស់ ជាសត្វមានសង្គមយុត្តិធម៌ ជាសត្វមានសាសនា ជាសត្វមានភាសាប្រាស្រ័យទាក់ទងគ្នា ជាសត្វចេះរកវិធីរំដោះទុក្ខ និងជាសត្វអាចរកមាគ៌ាទៅកាន់ទីក្សេម ឋានបរមសុខ ពោលគឺព្រះនិព្វានបាន ។ ហេតុនេះហើយបានជាប្តូរពាក្យសត្វមកមនុស្សវិញ ។

តើមនុស្ស និងសត្វតិរច្ឆានមានសេចក្តីសម្គាល់ដូចម្តេច?

## គ្រឿងសម្គាល់សត្វតិរច្ឆានមានសញ្ញា ៣ គឺ

១- *អាហារសញ្ញា* ចេះស្វែងរកចំណីអាហារសម្រាប់ចិញ្ចឹមជីវិត ។

២- *កាមសញ្ញា* ចេះបន្តពូជ ចេះសម្រាក ឬចេះសប្បាយ

៣- **ភយសញ្ញា** ចេះភ័យខ្លាច ចេះរត់គេចពួនពីសត្រូវ ។

ចំណែកឯមនុស្សវិញមានសញ្ញា ៤ គឺបន្ថែម **ធម្មសញ្ញា** ចេះស្វែងរកគុណធម៌ មានប្រាជ្ញាស្គាល់ខុសត្រូវមួយទៀត ទើបទៅជាសត្វមានចិត្តខ្ពស់ជាងសត្វតិរច្ឆាន ។ តែបើមនុស្សមានត្រឹមតែសញ្ញា ៣ ដូចសត្វតិរច្ឆានដែរនោះ មិនមានអ្វីប្លែក ឬមិនមានអ្វីខ្ពស់ឡើយ ។ ដូច្នេះមនុស្សត្រូវតែស្វែងរកគុណធម៌ ត្រូវតែធ្វើអ្វីៗឱ្យខ្ពស់ ឱ្យប្រសើរឡើងជាលំដាប់ ទើបត្រូវតាមនិយមន័យរបស់ពាក្យថា "មនុស្ស" ។ បើដូច្នេះ មនុស្សណាមិនមានគុណធម៌ មនុស្សនោះមិនពេញជាមនុស្សទេ ។[(៤២)]

## មនុស្ស ៤ ប្រភេទ

មនុស្សនៅក្នុងពិភពលោកយើងនេះ មានច្រើនជាតិ ច្រើនសាសន៍ណាស់ ។ បើនិយាយពីរូបរាងកាយ ទ្រង់ទ្រាយបែបយើងនេះ ទោះជាតិសាសន៍ជាមួយគ្នាក្ដី ផ្សេងគ្នាក្ដី ឃើញថា សុទ្ធតែជាមនុស្សដូចគ្នាទាំងអស់ ប៉ុន្តែបើនិយាយពីការប្រព្រឹត្តិវិញ មនុស្សយើងមិនដូចគ្នាទេ ។ ដូច្នេះ ទើបលោកចែកមនុស្សជា ៤ ប្រភេទ ÷



១- **មនុស្សតិរច្ឆានោ** មនុស្សតិរច្ឆាន

២- **មនុស្សបេតោ** មនុស្សប្រេត

៣- **មនុស្សមនុស្សោ** មនុស្សជាមនុស្ស

៤- **មនុស្សទេវោ** មនុស្សជាទេវតា

តើមនុស្សតិរច្ឆាននោះដូចម្ដេច? ជាដំបូងយើងគប្បីសង្កេតមើលសត្វតិរច្ឆាន ។ ពាក្យ "តិរច្ឆាន" មកពី (តិរ + អញ្ជ= ច្ឆ) បូក និង យុ បច្ច័យ, ប្រែថា ទទឹង គឺឆ្អឹងខ្នងវាទទឹងផែនដី រីឯអំពើរបស់វាទទឹងនឹងសេចក្ដីចម្រើន ទំនាស់នឹងផ្លូវទៅរកសុខ សួគ៌ និងនិព្វាន ។ មួយទៀត ពាក្យ តិរច្ឆាន មកពី តិរ + ឆានៈ ដែលប្រែថា សត្វទៅក្នុងខាងក្រោម ។ ម្យ៉ាងវិញទៀត ពាក្យ តិរច្ឆាន ប្រែថា សត្វទៅទទឹង, ឬសត្វទៅក្នុងទីទទឹង, ដូចមានបទវិគ្រោះថា តិរយំ អញ្ចតីតិ = តិរច្ឆានោ ។ សត្វតិរច្ឆានគ្មានច្បាប់ទម្លាប់ទេ ប្រើកម្លាំងកាត់សេចក្ដី សត្វខ្លាំងធ្វើបាបសត្វខ្សោយ ជួបគ្នាគ្រហឹម ញញួរធ្មេញដាក់គ្នាក៏មាន ។ សត្វតិរច្ឆានមិនចេះសន្សំទ្រព្យសម្បត្តិទេ រកស៊ីតែមួយគែ ឬមួយពោះប៉ុណ្ណោះ គ្មានគម្រោងការអនាគតឡើយ ។ សត្វ

តិរច្ឆានមិនស្គាល់ហេតុផល មិនចេះប្រើសតិបញ្ញាដោះស្រាយបញ្ហាទេ ប្រើតែសភាវគតិពីកំណើតរបស់វា ដូច្នេះវាគ្មានការ ច្នៃប្រឌិត គ្មានការដកពិសោធអ្វីទាំងអស់ សត្វតិរច្ឆានមិនស្គាល់ ម៉ែ ឪ បង ប្អូន កូន ចៅ មីង មា ទេ វាអាចខាំ ឈ្លោះ ឬសេពមេថុនធម្ម ជាមួយគ្នាក៏បាន វាគ្មានភាពអៀនខ្មាស សូម្បីក្នុងទីសាធារណៈក៏អាចប្រព្រឹត្តបែបនោះបានដែរ សត្វតិរច្ឆានមិនចេះធ្វើបុណ្យទាន ឬរក្សាសីលទេ ។ ល ។ មនុស្សណាដែលមានរូបរាងកាយជាមនុស្ស តែការប្រព្រឹត្តិស្រដៀងគ្នានឹងលក្ខណៈខាងលើនេះ គប្បីជ្រាបថា មនុស្សនោះជាសត្វតិរច្ឆាន ( មនុស្សតិរច្ឆានោ) ។

មនុស្សបេតោ មនុស្សប្រេត តើដូចម្ដេច? យើងគប្បីដឹងលក្ខណៈប្រេត។ ប្រេតជាសត្វមួយមិនមានមុខរបរ មិនចេះធ្វើស្រែចំការអីទេ ចាំតែទទួលផលទាន ដែលអ្នកដទៃឧទ្ទិសឱ្យ ស៊ីតែខ្ជុះឈាម ស្លេស្ម៍ ឬលាមក មិនចេះឆ្អែតទេ ស្រេកឃ្លានជានិច្ច។ នេះជាលក្ខណៈរបស់ប្រេត។ ដូច្នេះ មនុស្សណាដែលមិនចូលចិត្តធ្វើការងារបង្កបង្កើនផលផ្ទាល់ខ្លួន ចូលចិត្តតែជញ្ជក់ឈាម អង្ក្បៀមឆ្អឹង សង្កត់



សង្កិនរឹបជាន់យកទ្រព្យសម្បត្តិអ្នកដទៃ មកធ្វើជាទ្រព្យសម្បត្តិរបស់ខ្លួន បំប៉ោងខ្លួនមិនចេះឆ្អែត មនុស្សនោះហៅថា មនុស្សបេ-តោ មនុស្សប្រេត ឬមនុស្សណាដែលខិតខំរកទ្រព្យសម្បត្តិផ្ទាល់ខ្លួនដែរ ប៉ុន្តែសូម្បីបានច្រើនយ៉ាងណាក៏ដោយ ក៏នៅតែស្រេកឃ្លានចង់បានមិនចេះចប់ មិនចេះស្កប់ចិត្ត មិនមានសេចក្ដីស្ងប់សុខសាន្តក្នុងជីវិតសោះ មនុស្សនោះលោកហៅថា មនុស្សបេតោ មនុស្សប្រេតដែរ។ មនុស្សខ្លះទៀតគ្មានទីជម្រកច្បាស់លាស់ ដេកតាមចិញ្ចើមថ្នល់ រកអាហារស៊ីតាមធុងសម្រាមដែលគេបោះចោល រងទុក្ខលំបាកវេទនាគ្មានថ្ងៃស្រាក មនុស្សប្រភេទនេះក៏ចាត់ចូលជាមនុស្សប្រេតដែរ ។

មនុស្សមនុស្សោ មនុស្សមនុស្ស តើដូចម្ដេច? ។ មនុស្សណាស្គាល់ហេតុផលខុសត្រូវ គុណ ទោស ប្រយោជន៍ និងមិនមែនជាប្រ-យោជន៍ វៀរចាកអំពើខុសឆ្គងទាំងឡាយ ហើយអនុវត្តតាមផ្លូវសុខចម្រើន ចេះប្រើសតិបញ្ញាគិតពិចារណា ដកការពិសោធន៍ ច្នៃប្រឌិតផលិតរបស់មានសារៈប្រយោជន៍ដល់សង្គមលោក ប្រឹងប្រែងស្វែង

រកទ្រព្យសម្បត្តិតាមសម្មាអាជីវោ និងចេះសន្សំទ្រព្យសម្បត្តិទុកតាមសមគួរ ដើម្បីការពារក្នុងគ្រាមានកិច្ចធុរៈបន្ទាន់កើតឡើងដោយមិនបានដឹងមុន ត្រូវមានចិត្ត មេត្តា ករុណា មិនកាចឃោរឃៅចេះអាណិតអាសូរជួយសង្គ្រោះរំដោះទុក្ខលំបាកអ្នកដទៃ និងធ្វើអ្វីៗក៏គោរពទៅតាមច្បាប់ទម្លាប់ ជាអ្នកមានមនុស្សធម៌ គឺសីល ៥ មិនបៀតបៀនជីវិតអ្នកដទៃ ដោយការកាប់សម្លាប់ ធ្វើឃាត ឬបាញ់ប្រហារជាដើម, មិនលួចប្លន់ ឬឆក់កណ្តៀតទ្រព្យសម្បត្តិអ្នកដទៃ, មិនប្រព្រឹត្តខុសកន្លងប្រពៃណី ប្តីប្រពន្ធ កូនចៅអ្នកដទៃ, មិនភូតកុហក បោកបញ្ឆោត ឬបោកប្រាស់អ្នកដទៃ, មិនផឹកទឹកស្រវឹងគ្រប់ប្រភេទ ឬសេពគ្រឿងញៀន ដែលជាហេតុនាំឱ្យមានសេចក្តីវិនាសដល់ខ្លួន និងក្លាយជាមនុស្សពោរពេញដោយសេចក្តីប្រមាទកាន់តែច្រើនឡើង ។ល។ មនុស្សមានសីលធម៌បែបនេះ លោកហៅថា មនុស្សមនុស្សោ មនុស្សមនុស្ស គឺមនុស្សទាំងរូបរាងកាយមនុស្សទាំងចិត្តគំនិត ពេញសមជាមនុស្សមែន ។

មនុស្សទេវោ មនុស្សទេវតា តើដូចម្តេច? ។



មនុស្សណាបានបដិបត្តិល្អ មានអត្តភាពជាមនុស្សពេញលក្ខ-ណៈគ្រប់សព្វហើយ ប៉ុន្តែ ជាអ្នកមានចិត្តខ្ពស់ជាងមនុស្សធម្មតា ខំ-បដិបត្តិឈានឡើងថែមទៀត គឺបណ្តុះចិត្តឱ្យមានកាន់តែច្រើនឡើងនូវទេវធម៌ និងកុសលធម៌ទាំងឡាយ មានហិរិ សេចក្តីខ្មាសអៀនចំពោះអំពើបាបអកុសលផ្សេងៗ មិនហ៊ានប៉ះពាល់ ដូចខ្មាសលាមកមានឱត្តប្បៈ សេចក្តីខ្លាចចំពោះអំពើបាបអកុសលនោះ វាផ្តល់ផលអាក្រក់ ទុក្ខលំបាកមកវិញ មិនហ៊ានធ្វើ មិនហ៊ានប្រព្រឹត្ត ដូចខ្លាចដុំដែកដុតយ៉ាងក្តៅក្រហមរន្ទាលច្រាលឆ្អៅដូច្នោះដែរ មិនដែលបង្កសេចក្តីទុក្ខលំបាក ក្តៅក្រហាយឱ្យដល់ជនដទៃ ឬសត្វដទៃណាឡើយ តែងមានចិត្តពោរពេញដោយព្រហ្មវិហារធម៌ មេត្តា ករុណាមុទិតា ឧបេក្ខា ចំពោះសព្វសត្វទាំងឡាយជានិច្ច ។ល។ មនុស្សនោះលោកហៅថា មនុស្សទេវោ មនុស្សទេវតា ។

យើងកើតមកជាមនុស្សគ្រប់គ្នា ត្រូវពិចារណាឱ្យហ្មត់ចត់ តើយើងជាមនុស្សប្រភេទណា បើយើងនៅក្នុងពីរប្រភេទខាងដើមនោះ មិនសមគួរទេ យើងគប្បីប្រឹងប្រែងលើកកម្ពស់ខ្លួនយើងឱ្យ

ខ្ពស់ឡើង មិនគួរបណ្តោយឱ្យស្ថិតនៅក្នុងឋានៈទាបដូច្នោះឡើយ ព្រោះមនុស្សជាសត្វប្រសើរវិសេស មានការវិវឌ្ឍទៅមុខជានិច្ច ។

**កំណាព្យ "មនុស្ស"**

មនុស្សក្នុងលោក មានច្រើនគរគោក រៀបរាប់មិនអស់
និយាយតាមក្បួន មានបួនប៉ុណ្ណោះ ចូរចាំទុកចុះ
កូនប្រុសស្រីអើយ ។
មួយមនុស្សតិរច្ឆាន ចិត្តពាលសាមាន្យ សន្តានឆ្គងឈ្លើយ
ជួបនឹងចាស់ទុំ វាយឫកព្រងើយ គ្មានគួរសមឡើយ
កូនអើយកុំត្រាប់ ។
ពួកនេះត្រេងត្រាង ច្រងេងច្រងាង អួតអាងចាក់កាប់
លួចឆក់ទ្រព្យធន ប្លន់កាប់សម្លាប់ មិនគោរពច្បាប់
និងប្រពៃណី ។
សប្បាយហ៊ឺហា បារីកញ្ឆា ល្បែងបៀរស្រាស្រី
មិនយល់កូនចៅ ឬប្រពន្ធប្តី នៃជនដទៃ
ដល់តិចឡើយណា ។
មិនស្គាល់បុណ្យទាន ធម៌អាថ៌មិនរៀន ចិត្តគ្មានមេត្តា



ចិត្តចង់សេពគប់ តែជនពាលា អ្នកប្រាជ្ញល្អជា
មិនចូលជិតឡើយ ។
ពីរមនុស្សប្រេត ស៊ីមិនចេះឆ្អែត រឹបជាន់មិនស្បើយ
យកទ្រព្យសម្បត្តិ គេធ្វើព្រងើយ គ្មានគិតតិចឡើយ
ដល់អ្នកក្រីក្រ ។
ប្រមូលបានច្រើន ទ្រព្យចេះតែកើន ចិត្តមិនត្រេកអរ
ចេះតែស្រេកឃ្លាន ចង់បានបន្ត គ្មានទឹកដល់ធម៌
សន្តោសសោះឡើយ ។
បីមនុស្សមនុស្ស បញ្ញាភ្លឺឆ្លុះ ស្គាល់ខុសត្រូវហើយ
ខំធ្វើការងារ មិនស្មៀមព្រងើយ បានទ្រព្យមកហើយ
លៃលកទុកដាក់ ។
ចាត់ចែងចាយវាយ សន្សំសំចៃ ការពារគ្រោះថ្នាក់
មានទ្រព្យសល់ខ្លះ គ្រាន់ជាពំនាក់ ពេលទុក្ខធុរៈ
យកទ្រព្យដោះស្រាយ ។
ស្គាល់បងស្គាល់ប្អូន ជីតាជីដូន ញាតិមិត្តជិតឆ្ងាយ

តែងជួយសង្គ្រោះ ទោះសម្លបាយ ទ្រព្យធនទាំងឡាយ
ចែកចាយគ្រប់គ្នា ។

មានមនុស្សធម៌ ចិត្តថ្លៃបវរ ជ្រះថ្លាសទ្ធា
រឿងបុណ្យកុសល មិនដែលរួញរា សាមគ្គីសាមគ្គា
នាំគ្នាកសាង ។

បួនមនុស្សទេវតា ប្រសើរថ្លៃថ្លា ទុកជាបែបយ៉ាង
ធ្វើល្អគ្រប់មុខ ទុកជាភស្តុតាង ហើយថែមទាំងសាង
គុណធម៌តទៀត ។

ខ្ពើមបាបខ្លាចបាប អំពើថោកទាប មិនយកខ្លួនបៀត
រឿងបុណ្យកុសល ខ្វាយខ្វល់ខំឆ្លៀត ធ្វើហើយធ្វើទៀត
មិនដែលជិនណាយ ។

មានចិត្តមេត្តា អាសូរករុណា មនុស្សសត្វទាំងឡាយ
តែងជួយសង្គ្រោះ រំដោះទុក្ខភ័យ បានសុខសប្បាយ
កាយចិត្តគ្រប់គ្នា ។

យើងជាមនុស្សពិត ស្ដាប់ធម៌ពិសិដ្ឋ ត្រូវពិចារណា



រំពឹងមើលខ្លួន នៃយើងរាល់គ្នា កែច្នៃយ៉ាងណា
ឱ្យបានខ្ពង់ខ្ពស់ ។

ឱ្យសមនឹងធម៌ សមនឹងកំណើត កើតមកជាមនុស្ស
កុំឱ្យថយថោក នាំឱ្យអប្បយស អាស្រូវកេរ្តិ៍ឈ្មោះ
កូនប្រុសស្រីអើយ ។[៤៣]

“ដរាបណាអំពើអាក្រក់មិនទាន់ហុចផលឱ្យ ដរាបនោះមនុស្សអាក្រក់ ឃើញអំពើអាក្រក់ថាល្អ, តែពេលណាអំពើអាក្រក់ហុចផលឱ្យ ពេលនោះមនុស្សអាក្រក់នឹងឃើញអំពើអាក្រក់ថា អាក្រក់ពិតមែន”។[៤៤]

# គោលព្រះពុទ្ធសាសនា ៣ យ៉ាង

*ដោយលោក* **ព្រំ ស៊ីណា** (ថ្នាក់បរិញ្ញាបត្រ)

ព្រះពុទ្ធសាសនា គឺជាព្រះធម៌ ពោលគឺ ជាពាក្យប្រៀនប្រដៅរបស់ព្រះអរហន្តសម្មាសម្ពុទ្ធ។ ព្រះសទ្ធម្ម ឬគោលព្រះពុទ្ធសាសនាមាន ៣ យ៉ាង សម្រាប់សិក្សារៀនសូត្រ និងប្រតិបត្តិ។ គោលព្រះពុទ្ធសាសនា[៤៥] ៣ យ៉ាងគឺ ÷

១. **បរិយត្តិ** គឺសិក្សាព្រះធម៌វិន័យ

២. **បដិបត្តិ** គឺចម្រើនធម៌ ដើម្បីសម្រេចនូវធម៌ដែលរំលត់កិលេស រំលត់ទុក្ខ

៣. **បដិវេធៈ** គឺដឹងច្បាស់នូវធម៌ដែលរំលត់កិលេស រំលត់ទុក្ខ

គោលព្រះពុទ្ធសាសនាទី១ "បរិយត្តិ" គឺការសិក្សារៀនសូត្រនូវគម្ពីរដីកា ឬព្រះពុទ្ធវចនៈ គឺព្រះត្រៃបិដកទាំងអស់។ ព្រះពុទ្ធវចនៈទាំងអស់ ហៅថា បរិយត្តិ បានដល់ សុត្តៈ គេយ្យៈ វេយ្យាករណ៍ គាថា ឧទាន ឥតិវុត្តកៈ ជាតក អព្ភូតធម៌ និង វេទល្លៈ[៤៦]។



*សុត្តៈ* គឺបានដល់ព្រះសូត្រផ្សេងៗ មានមង្គលសូត្រ ជាដើម។

*គេយ្យៈ* គឺព្រះសូត្រទាំងអស់ដែលមានគាថា មានសគាថវគ្គជាដើម។

*វេយ្យាករណ៍* គឺព្រះអភិធម្មបិដក ព្រះសូត្រដែលមិនមានគាថាបញ្ចូលជាមួយនឹងព្រះពុទ្ធវចនៈ ដែលមិនចាត់ចូលក្នុងអង្គ ៨។

*គាថា* គឺព្រះធម្មបទ ថេរគាថា ថេរីគាថា និងគាថាសុទ្ធៗ ដែលមិនមានឈ្មោះថា សូត្រក្នុងសុត្តនិបាត។

*ឧទាន* គឺព្រះសូត្រ ៨២ សូត្រដែលព្រះដ៏មានព្រះភាគទ្រង់ថ្លែងដោយសោមនស្សញាណ។

*ឥតិវុត្តកៈ* គឺព្រះសូត្រ ១១០ សូត្រដែលផ្តើមឡើងដោយពាក្យថា *វុត្តំ ហេតំ ភគវា* (ព្រះមានព្រះភាគទ្រង់ត្រាស់ហើយ)។

*ជាតក* គឺរឿងអតីតជាតិរបស់ព្រះមានព្រះភាគ និងព្រះសាវ័ក មានអបណ្ណជាតកជាដើម រួម ៥៥០ ជាតក។

*អព្ភូតធម៌* គឺព្រះសូត្រដែលប្រកបដោយអច្ឆរិយៈ អព្ភូតធម៌ (ធម៌ដែលក្រៃលែង ដោយគុណវិសេស ដែលគួរអស្ចារ្យ)។

វេទល្ល: គឺព្រះសូត្រដែលកាលណាសួរហើយ ក៏បាននូវសេចក្ដីដឹង និងសេចក្ដីត្រេកអរក្រៃលែងឡើងៗ មានចូឡវេទល្លសូត្រជាដើម ។

សុត្តៈ គេយ្យៈ ជាដើម គឺជា **បរិយត្តិសាសនា ឬ ជិនសាសនា**។ ព្រះពុទ្ធវចនៈទាំងអស់ចាត់ជាបិដក ៣ (ត្រៃបិដក) គឺព្រះវិន័យបិដក ព្រះសុត្តន្តបិដក និង ព្រះអភិធម្មបិដក ។

ព្រះវិន័យបិដក គឺជាគម្ពីរស្ដីពីច្បាប់ក្រឹត្យក្រម ដែលព្រះសម្មាសម្ពុទ្ធទ្រង់បញ្ញត្ត ទ្រង់អនុញ្ញាតទុកសម្រាប់ជាផ្លូវប្រតិបត្តិរបស់ភិក្ខុសង្ឃ និងឧបាសក ឧបាសិកា។ គម្ពីរព្រះវិន័យនេះ ជាកញ្ចក់ឆ្លុះមើលជីវប្រវត្តិព្រះសម្មាសម្ពុទ្ធ ក្នុងកាលដែលព្រះអង្គទ្រង់គង់ធរមាននៅឡើយ ព្រមទាំងហេតុការណ៍ផ្សេងៗនៅប្រទេសឥណ្ឌាសម័យព្រះពុទ្ធ ដូចជា ប្រវត្តិសាស្ត្រ ទំនៀមទម្លាប់ ការរចនា និងវិទ្យាសាស្ត្រផ្សេងៗ[៤៧] ។

សុត្តន្តបិដក គឺជាគម្ពីរដែលប្រមូលរួបរួមព្រះធម៌ទេសនា ពាក្យប្រៀនប្រដៅ និង និទានផ្សេងៗ និងព្រះសូត្រដែលព្រះសម្មាសម្ពុទ្ធ



ទ្រង់ត្រាស់ទេសនា ចំពោះបុគ្គល និងក្នុងសម័យផ្សេងៗ និងព្រះអរិយសាវ័ក មានព្រះសារីបុត្ត ព្រះមោគ្គលាន ព្រះអានន្ទ ជាដើមសម្ដែងផងដែរ។ ព្រះសូត្រ គឺជាខ្សែបន្ទាត់ដែលព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សម្ដែងទុក សម្រាប់ការប្រព្រឹត្តិព្រហ្មចរិយធម៌ ចម្រើន **សីល សមាធិ និង បញ្ញា**[៤៨] ។

ព្រះអភិធម្មបិដក ជាគម្ពីរស្ដីពីធម៌ មានអាថ៌ជ្រាលជ្រៅ ល្អិតសុខុមបំផុត បានដល់ទស្សនវិជ្ជាព្រះពុទ្ធសាសនា។ ព្រះអភិធម្មបិដកជាបរមត្ថទេសនា ស្ដីពី **ចិត្ត ចេតសិក រូប** និង **និព្វាន** ជាគោលវិជ្ជាសុទ្ធៗ សម្រាប់ការប្រតិបត្តិក្នុងជីវភាពរស់នៅប្រចាំថ្ងៃ មិនទាក់ទងដោយហេតុការណ៍ និងបុគ្គល[៤៩] ។

ព្រះត្រៃបិដក សង្គ្រោះចូលក្នុងបាវចនៈ ២ គឺ ព្រះសុត្តន្តបិដក និងព្រះអភិធម្មបិដក ចាត់ជា **ធម៌** ព្រះវិន័យបិដកចាត់ជា **វិន័យ**។

គោលព្រះពុទ្ធសាសនាទី ២ "**បដិបត្តិ**" គឺការប្រតិបត្តិ ការចម្រើនធម៌ ដើម្បីសម្រេចនូវធម៌ដែលរំលត់កិលេស រំលត់ទុក្ខ។ ធម៌ដែលត្រូវបដិបត្តិ បានដល់ **សម្មាបដិបទា** (សេចក្ដីប្រតិបត្តិដោយ

ប្រពៃ) អនុលោមប្បដិបទា (សេចក្តីប្រតិបត្តិដ៏សមគួរ)អបច្ចនិកប្បដិបទា (សេចក្តីប្រតិបត្តិមិនជាសឹកសត្រូវ) អន្វត្ថប្បដិបទា (សេចក្តីប្រតិបត្តិចំពោះប្រយោជន៍តាមលំដាប់) ធម្មានុធម្មប្បដិបទា (សេចក្តីប្រតិបត្តិធម៌ដ៏សមគួរដល់ធម៌)ពោលគឺ បំពេញសីលឱ្យបរិបូណ៌ (សីលេសុ បរិបូរិការិតា)ការគ្រប់គ្រងទ្វារក្នុងឥន្ទ្រីយ៍ទាំងឡាយ (ឥន្ទ្រិយសំវរៈ) ការដឹងប្រមាណក្នុងភោជន (ភោជនេមត្តញ្ញុតា) សេចក្តីប្រកបរឿយៗក្នុងការភ្ញាក់-រលឹក (ជាគរិយានុយោគ) សតិនិងសម្បជញ្ញៈ សតិប្បដ្ឋាន (ទីតាំងតម្កល់សតិ) ៤, សម្មប្បធាន (សេចក្តីព្យាយាមជាធំ)៤, ឥទ្ធិបាទ (គុណជាតិឱ្យដល់សេចក្តីសម្រេច) ៤, ឥន្ទ្រិយ៍ ៥, ពលៈ ៥, ពោជ្ឈង្គ៍ (អង្គនៃការត្រាស់ដឹង) ៧, អដ្ឋង្គិកមគ្គ (មគ្គមានអង្គ ៨)[៥០] ។

ម្យ៉ាងទៀត ធម៌ដែលត្រូវប្រតិបត្តិជាសំខាន់គឺ ពោធិបក្ខិយធម៌ ៣៧ ប្រការ ។

គោលព្រះពុទ្ធសាសនាទី ៣ "បដិវេធៈ" គឺដឹងច្បាស់នូវធម៌



ដែលរំលត់កិលេស រំលត់ទុក្ខបានដល់ មគ្គ ៤ ផល ៤ និង និព្វាន១ ដែលកើតឡើងនៅក្នុងចិត្តព្រះអរិយបុគ្គល ដែលបានកម្ចាត់បង់នូវកិលេស ។ ការស្តាប់ធម៌ដោយយកចិត្តទុកដាក់ជាលំដាប់ ប្រកបដោយសទ្ធាដ៏មុតមាំ និងបដិបត្តិចម្រើននូវធម៌ត្រឹមត្រូវ បានសម្រេចអរហត្តផល ។ ដូច្នេះ ការស្តាប់ព្រះធម៌ក្នុងគោលដៅអរហត្តតែមួយសម្រេចបានបញ្ញាកើតពីការស្តាប់ (សុតមយញាណ) ។ ការកើតឡើងរឿយៗនូវសុតមយញាណ អាចកម្ចាត់បង់នូវនីវរណធម៌ពីក្នុងចិត្ត ។ រីឯការបដិបត្តិធម៌ បន្ទាប់ពីការស្តាប់រឿយៗ សេចក្តីស្ងប់កើតឡើងរួមជាមួយសមាធិ (សុខក្ខណ៍សមថៈ) ហើយប្រសិនបើបន្តប្រតិបត្តិដោយត្រឹមត្រូវ បញ្ញាមើលឃើញធម្មជាតិតាមសភាវៈពិត (យថាភូតញាណទស្សនៈ) កើតឡើង នាំមកនូវសេចក្តីស្ងប់ និងសេចក្តីជ្រះថ្លា (សុខក្ខណ៍វិបស្សនា)[៥១] ។ ដូច្នេះការប្រតិបត្តិត្រឹមត្រូវនាំទៅដល់ថ្នាក់បដិវេធៈ គឺដឹងច្បាស់នូវព្រះធម៌ដែលរំលត់កិលេស រំលត់ទុក្ខ ដោយខ្លួនឯង ។

ការឃើញព្រះធម៌ថ្នាក់បដិវេធៈ គឺជាផលនៃការចម្រើនធម៌

ថ្នាក់បដិបត្តិ។ ឯការចម្រើនធម៌ថ្នាក់បដិបត្តិក៏ត្រូវអាស្រ័យបរិយត្តិ។ ហេតុនេះ បរិយត្តិគឺការសិក្សាព្រះធម៌វិន័យ ទើបជាសរណៈ ទើបជាទីពឹង ជាផ្លូវនាំទៅដល់ការសម្រេចព្រះពុទ្ធសាសនា គឺព្រះធម៌ថ្នាក់បដិបត្តិ និងថ្នាក់បដិវេធៈទៅជាលំដាប់ៗបាន[៥២]។

ព្រះធម៌របស់ព្រះសម្មាសម្ពុទ្ធ គឺជាប្រព័ន្ធសីលធម៌ និងទស្សនវិជ្ជា ដែលពន្យល់ពីមាគ៌ាតែមួយនៃការត្រាស់ដឹង មិនមែនជាមុខវិជ្ជា ដែលត្រូវសិក្សានៅតាមមហាវិទ្យាល័យសុទ្ធសាធទេ។

ពិតណាស់ គេត្រូវសិក្សាព្រះធម៌ ត្រូវប្រតិបត្តិថែមទៀត ហើយជាពិសេស ត្រូវធ្វើឱ្យជាក់ច្បាស់ដោយខ្លួនឯង។

ការគ្រាន់តែសិក្សាព្រះធម៌ មិនមានប្រយោជន៍ទេ បើគ្មានការប្រតិបត្តិពិតប្រាកដ។ ព្រះពុទ្ធទ្រង់សម្តែងថា ÷

"បុគ្គលជាពហុស្សូតមិនប្រតិបត្តិធម៌ គឺប្រៀបដូចជាផ្កាចាមានពណ៌ស្រស់ស្អាត តែគ្មានក្លិន។ អ្នកដែលមិនសិក្សាព្រះធម៌ ប្រៀបដូចមនុស្សខ្វាក់។ អ្នកដែលមិនប្រតិបត្តិធម៌ ប្រៀបដូចជាបណ្ណាល័យ"។[៥៣]



ដូច្នេះ យើងជាពុទ្ធសាសនិកគប្បីសិក្សា និងប្រតិបត្តិតាមគោលទាំង ៣ នៃព្រះពុទ្ធសាសនា។ ការគ្រាន់តែសិក្សា តែមិនប្រតិបត្តិតាមពុទ្ធឱវាទ មិនអាចធ្វើឱ្យជាក់ច្បាស់ក្នុងធម៌ មិនស្គាល់រសព្រះធម៌ ហើយការប្រតិបត្តិដោយមិនបានសិក្សាឱ្យយល់ជាមុន គឺជាដំណើរដ៏យឺតឆ្ពោះទៅកាន់គោលដៅ។ មានតែការសិក្សា (បរិយត្តិ) និងប្រតិបត្តិ (បដិបត្តិ) ទើបនាំឱ្យសម្រេចគោលដៅ ដែលជាគោលបំណងនៃព្រះពុទ្ធសាសនាក្នុងការរំដោះទុក្ខ ចេញចាកវដ្តសង្សារ ក៏ដូចជាគោលបំណងជីវិតរបស់មនុស្សលោកគ្រប់រូប។

# ការងារប្រាំប្រការដែលត្រូវបំពេញសន្សឹមៗ

*ដោយលោក* **ម៉ៅ ស៊ីថា** (ថ្នាក់អនុបណ្ឌិត)

នៅក្នុងលោកយើងនេះ មនុស្សទាំងឡាយមានការងារត្រូវធ្វើ គ្មាននរណាមួយ ដែលថា គ្មានការងារត្រូវធ្វើ ឬបំពេញនោះទេ លើកលែងតែព្រះអរហន្ត។

មានបញ្ហាចំនួនពីរដែលគួរធ្វើ គឺរឿងដែលគួរធ្វើរហ័ស និង រឿងដែលគួរធ្វើដោយសន្សឹមៗ ឬយឺតៗ។ រឿងដែលគួរធ្វើឱ្យរហ័ស នោះគឺៈ ការធ្វើទាន ការរក្សាសីល និងការធ្វើភាវនា ពោលគឺ សមថភាវនា និងវិបស្សនាភាវនាជាដើម។ ព្រះសម្មាសម្ពុទ្ធបរមគ្រូនៃយើង បានទ្រង់ត្រាស់សម្តែងថា "បញ្ហាទាំងអស់នេះត្រូវធ្វើ ចូរកុំពន្យារដល់ស្អែក ព្រោះថា ថ្ងៃស្អែកមិនប្រាកដថា អ្នកនៅមានជីវិតរស់នៅ ឬអត់"។ ព្រោះហេតុនោះ កុសលកម្មទាំងឡាយ គួរធ្វើឱ្យបានរហ័ស។

គ្រូខាងសីលធមិបានពន្យល់នូវបញ្ហា ឬរឿងរ៉ាវដែលគួរធ្វើឱ្យបានសន្សឹមៗទាំង ៥ យ៉ាងនោះគឺ ÷



១- សិនេ សិប្បំ ក្នុងការទទួលចំណេះដឹង និងការអប់រំ។

២- សិនេ ធនំ ក្នុងការទទួលទ្រព្យសម្បត្តិ និងធនធាន។

៣- សិនេ បព្វត មារុហំ ក្នុងការឡើងភ្នំ។

៤- សិនេ កាមញ្ច ក្នុងការស្វែងរកដៃគូជីវិត។

៥- សិនេ កោធញ្ច ក្នុងការបាត់បង់អារម្មណ៍។

១- បុគ្គលម្នាក់ៗ ដោយប្រាថ្នាចង់រៀនសូត្រឆាប់ៗ ព្យាយាមរៀនសូត្រមេរៀនទី២ មុនពេលខ្លួនចេះមេរៀនទី១ ឬឆ្លងកាត់មេ-រៀនទី១ ហើយរៀនមេរៀនទី៣ ឬមេរៀនទី៤ មុនឆ្លងកាត់មេ-រៀនទី២។ ជាលទ្ធផល បុគ្គលនោះនឹងជួបប្រទះការលំបាកលំបិនច្រើនប្រការ ក្នុងការសិក្សារៀនសូត្រមេរៀនទី៣ និងទី៤។ ដូច្នេះ គេប្រហែលក្លាយជាមិនមានអារម្មណ៍ ក្នុងការសិក្សារៀនសូត្រតទៅទៀត។

បុគ្គលម្នាក់ៗ ពេលប្រាថ្នាចង់សិក្សារៀនសូត្រ ព្យាយាមរៀនមេរៀនទី១ ឱ្យបានចេះចាំស្ទាត់ ហើយទន្ទេញរហូតចងចាំ បន្ទាប់មកទៀត បន្តទៅរៀននូវមេរៀនទី២ និងទី៣ ជាបណ្តើរៗ បន្ទាប់ពីបាន

ចងចាំនូវមេរៀនទី១ បានល្អហើយ។ មនុស្ស ឬបុគ្គលរូបនេះនឹងអាចមានសមត្ថភាពរៀន និងទទួលមេរៀនដទៃទៀត រហូតទទួលបានចាំសព្វគ្រប់ ព្រោះក្រោយពីចងចាំមេរៀនទី១ បានស្ទាត់ជំនាញហើយ។ ព្រោះហេតុដូច្នោះហើយ ទើបគ្រូខាងសីលធម៌បានពន្យល់ទុកមកថា ការទទួលបានការអប់រំ ចំណេះវិជ្ជា គួរតែធ្វើទៅដោយសន្សឹមៗ។

២- បុគ្គលម្នាក់ៗ ក្នុងការចង់បានទ្រព្យសម្បត្តិ និងធនធាន ដែលប្រាថ្នាចង់បានឱ្យរីកចម្រើនភ្លាមៗ ព្យាយាមពង្រីក និងបង្កើតការងារនានាទៀត ដោយមិនមានការវិនិយោគ ឬទ្រព្យសម្បត្តិជាមូលធន។ បុគ្គលរូបនេះ គឺគ្មានទាំងជំនាញគ្រប់ការងារនោះ និងមធ្យោបាយ ឬពិធីអនុវត្តការងារ។ ដូច្នេះ គ្មានការងារណាមួយទទួលបានជោគជ័យឡើយ ហើយនឹងទទួលបាននូវការខូចទឹកចិត្តទៀតផង។

ម៉្យាងវិញទៀត បើបុគ្គលរូបនោះ ពេលប្រាថ្នាចង់បានទ្រព្យសម្បត្តិ និងធនធាន ព្យាយាមធ្វើតែការងារមួយ ដែលការងារនោះ



ជាការងារជំនាញដោយសន្សឹមៗ ហើយមិនរញ្ជួយញាប់ញ័រការងារ នោះនឹងមានការរីកចម្រើន និងជោគជ័យ។ ដូច្នេះ បុគ្គលនោះនឹង ទទួលបានការរីកចម្រើន និងទទួលបានទ្រព្យសម្បត្តិ និងធនធាន។

ព្រោះហេតុដូច្នោះហើយ គ្រូខាងសីលធម៌បានពន្យល់ថា ការប្រាថ្នាចង់បានទ្រព្យធនធាន បុគ្គលនោះគួរធ្វើទៅដោយសន្សឹមៗ។

៣- បុគ្គលណាមួយឡើងភ្នំ ដែលមានកំពស់ ៤០០០ ឬ ៥០០០ ហ្វីត គួរកុំឡើងដោយប្រញាប់ប្រញាល់ពេក ព្រោះបុគ្គលនោះ នឹងឆាប់អស់កម្លាំងមុនពេលទៅដល់កំពូលភ្នំ ហើយមិនអាចធ្វើដំណើរបានទៀតទេ។ បុគ្គលឯណាឡើងភ្នំដ៏ខ្ពស់ដោយសន្សឹមៗ ហើយមានសតិស្មារតីទៅតាមកម្លាំងរបស់គេ បុគ្គលនោះនឹងឡើងទៅដល់កំពូលភ្នំនោះដោយល្អប្រពៃ។ ព្រោះហេតុដូច្នោះហើយ គ្រូខាងសីលធម៌បានពន្យល់ទុកមកថា បុគ្គលគួរឡើងភ្នំដោយសន្សឹមៗ។

៤- ក្នុងការស្វែងរកដៃគូជីវិត ដោយរហ័សរហួនពេក ហើយជ្រើសរើសដៃគូមិនស័ក្តិសម ដោយមិនបានគិតឱ្យបានជ្រៅជ្រះ និង

៥- គ្រប់ជ្រុងជ្រោយ ក្រោយពេលនោះ គេនឹងជួបប្រទះការលំបាកនានាក្នុងឥរិយាបថ និងមិនមានការឯកភាព និងសុភមង្គលឡើយ។

ធ្លាប់មានករណីជាច្រើនកើតឡើង ពេលដៃគូម្ខាងរត់ចោល ឬលាក់ខ្លួននៅថ្ងៃរៀបអាពាហ៍ពិពាហ៍។ ឪពុកម្តាយ និងបងប្អូនទាំងសងខាងបាត់បង់មុខមាត់ និងខ្មាសគេឯង។ ទ្រព្យសម្បត្តិដែលនៅថ្ងៃអាពាហ៍ពិពាហ៍នោះ ប្រែក្លាយជាគ្មានន័យទៅវិញ។ ដូច្នេះគ្រូខាងសីលធម៌បានណែនាំថា ការស្វែងរកដៃគូជីវិតក្នុងលោកនេះ គួរតែធ្វើទៅដោយសន្សឹមៗ។

មនុស្សម្នា ដែលរស់នៅក្នុងលោកនេះ ប្រាថ្នាចង់រស់នៅជាមួយប្រពន្ធ ឬភរិយាប្រកបដោយសីលធម៌ ក្នុងការជ្រើសរើសដើម្បីរស់នៅជាមួយគ្នា។ គ្រូខាងសីលធម៌បានពិពណ៌នាប្រាប់នូវលក្ខណៈប្រាំបីប្រការរបស់ភរិយា ប្រកបដោយសីលធម៌។ ប្រពន្ធ ឬភរិយាដែលប្រកបដោយលក្ខណៈល្អប្រាំបីប្រការនោះគឺ ÷

១- បុត្តេសុ ជននីវៈ ពេលអាហារ ធ្វើដូចជាម្តាយរៀបអាហារដ៏ល្អ និងឆ្ងាញ់ពិសារ។



២- មន្តេសុ ជននីវៈ ពេលស្លៀកពាក់ ធ្វើដូចជាម្តាយដែលរៀបចំសំលៀកបំពាក់ជាស្រេច។

៣- ចូឡូត្តាន ភគិនីវៈ មានភាពអៀនខ្មាស ដូចជាប្អូនស្រីទាក់ទងនឹងរឿងដែលមិនគួរឱ្យឃើញ ឬដឹង។

៤- កម្មេសុ បុត្តេសុ ទាសិវៈ ពេលមានកិច្ចការត្រូវធ្វើ បម្រើប្តីដោយគោរពដូចទាសី។

៥- សយេសុ មន្តិ ជាអ្នកប្រឹក្សាពេលមានវិបត្តិ។

៦- សយនេសុ ឈាមយេ រៀបចំកន្លែងឱ្យប្តីដេកដោយស្រួល

៧- រូបិសុ សុខា រៀបចំក្នុងផ្ទះ ឬក្រៅផ្ទះដោយស្អាតបាត។

៨- គុបិណោសុ ខន្តិនោ ពេលមានភាពខឹងសម្បា ត្រូវតែចេះអត់ធ្មត់។

ប្តីដែលរស់នៅជាមួយប្រពន្ធ ឬភរិយាដែលប្រកបដោយភាពសមរម្យ និងឯកភាពគ្នា ហើយប្រកបដោយលក្ខណៈ ៨ ប្រការខាងលើនេះ គឺជាប្រពន្ធល្អ ហើយមានភាពរីករាយទាំងផ្លូវកាយ និង

ផ្លូវចិត្ត។ យោងតាមព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សម្តែងនៅក្នុងឧប-និសយប្បច្ច័យ ក្នុងបដ្ឋានសូត្រថា÷

"បុគ្គលោបិ ឧបនិសយប្បច្ចយេន បច្ចយោ"

មានន័យថា ប្តីដែលរស់នៅជាមួយប្រពន្ធដែលមានលក្ខណៈល្អទាំងប្រាំបីប្រការនេះ ជាប្រពន្ធល្អ និងមានកុសលធម៌ថែមទៀត។ ម្យ៉ាងវិញទៀត ការរស់នៅជាមួយប្រពន្ធដ៏ល្អ និងស័ក្តិសមនេះ ស្វាមីនឹងបានបុណ្យកុសល ហើយជាងនេះទៅទៀត កុសលធម៌ទាំងនោះ នឹងបានជាឧបនិស្ស័យជួយគាំទ្រ ពេលខ្លួនជាស្វាមីបដិបត្តិវិបស្សនាធុរៈទៀតផង។

៥- បុគ្គលម្នាក់ៗ ជាធម្មតាខឹងភ្លាមៗ ដោយមិនបានថ្លឹងថ្លែង ពេលគេជួបប្រទះឱកាសបាត់បង់អារម្មណ៍។ បុគ្គលនោះក្លាយជាមានអំពើហិង្សា នៅក្នុងមារយាទ ឬឥរិយាបថ និងប្រើប្រាស់ពាក្យអសុរោះដាក់គ្នា។ ព្រោះតែមានសំដីគំរោះគំរើយដាក់គ្នា បុគ្គលរូបនោះនឹងបាត់បង់កេរ្តិ៍ឈ្មោះ។ មិត្តភ័ក្តិដែលធ្លាប់តែគោរពកោតក្រែង ក្លាយជាមានអារម្មណ៍មិនល្អ ហើយលែងរាប់អានគ្នាទៀតផង។



ព្រោះហេតុដូច្នោះហើយ គ្រូខាងសីលធម៌បានពន្យល់ និងប្រៀនប្រដៅថា បុគ្គលគួរទប់អារម្មណ៍ ពេលខឹងសម្បានរណាម្នាក់។

នៅមានប្រការបីយ៉ាងទៀត ដែលគួរធ្វើដោយសន្សឹមៗដែរ ពីព្រោះលំបាកជួសជុល ឬកែប្រែការងារនោះណាស់ ប្រសិនបើខុសហើយ។

១- រៀបអាពាហ៍ពិពាហ៍

២- កសាងវត្តអារាម (វិហារ)

៣- ចាក់សាក់ (លើខ្លួនមនុស្ស -រូបភាពផ្សេងៗ)

១- បុត្រធីតាទាំងឡាយណា ដែលមានឪពុកម្តាយល្អ មានការអៀនខ្មាស (ហិរិ) និងការភ័យខ្លាច (ឱត្តប្បៈ) ចង់រៀបការតែម្តងគត់ មិនចង់រៀបការច្រើនដងទេ។ ព្រោះហេតុដូច្នោះហើយ ការរៀបអាពាហ៍ពិពាហ៍ គួរតែធ្វើដោយសន្សឹមៗ ក្រោយពីបានគិតគូរយ៉ាងល្អិតល្អន់ និងសម្រេចចិត្តដោយប្រុងប្រយ័ត្នហើយ។

២- ក្នុងការកសាងវត្តអារាម និងការធ្វើ ឬកសាងព្រះពុទ្ធប្បដិមាសម្រាប់គោរពបូជា ត្រូវជ្រើសរើសទីកន្លែងដ៏សមរម្យ ហើយ

ព្រះពុទ្ធប្បដិមាទៀតសោត មើលទៅល្អគួរជាទីគោរពបូជា។

ប្រសិនបើទីកន្លែងជ្រើសរើសនោះ មិនសមរម្យ ហើយវត្តអារាម ឬព្រះពុទ្ធប្បដិមានោះ មិនមានភាពរុងរឿង ប្រជាជន ឬពុទ្ធបរិស័ទ នឹងមានទ្វេគ្រោះ ព្រោះគេមិនអាចរុះរើធ្វើម្ដងទៀតបាន។ ព្រោះហេតុដូច្នោះហើយ ការកសាងវត្តអារាម គេត្រូវតែគិតឱ្យបានហ្មត់ចត់ ហើយប្រុងប្រយ័ត្នបំផុត មុនពេលធ្វើ ឬចាប់កសាងឡើង។ មនុស្សវ័យក្មេង ដែលមានទម្លាប់ ចាក់សាក់លើដៃ, ជើង, ដើមទ្រូង ឬឆ្អឹងខ្នងរបស់គេ ដូចជារូបភាពឆ្មា ខ្លា និងខ្មោចបិសាច។ ពេលគេធំឡើង ហើយគេចង់លុបសាក់នោះចេញ។ ទោះបីជាយ៉ាងណាក៏ដោយ គេមិនអាចលុបបានងាយ ឬមិនអាចលុបបានទេ ព្រោះជាតិពុលបានចាក់ចូល ឬជ្រាបទៅក្នុងស្បែកអស់ពេលជាយូរមកហើយ។ ដូច្នេះ គេចាក់សាក់គួរតែគិតឱ្យបានហ្មត់ចត់ និងល្អិតល្អន់មុនពេលចាក់សាក់នោះ។(៥៤)

# គន្លឹះមូលដ្ឋានគ្រឹះដើម្បីជោគជ័យក្នុងវិថីជីវិត

*ដោយសាមណេរ* **ភាឡាន ម៉េងហុង** (ថ្នាក់ឌីប្លូម)

ពីមួយថ្ងៃទៅមួយថ្ងៃសេចក្តីប្រាថ្នារបស់មនុស្ស ចេះតែកើនឡើងជាលំដាប់។ សេចក្តីប្រាថ្នាសឹងតែគ្មានព្រំដែននេះ បានញាំញីផ្លូវចិត្តឱ្យអន្ទះអន្ទែង ពីព្រោះចង់បានចង់ឃើញនូវអ្វីដែលខ្លួនចង់បាន អ្នកខ្លះចង់បាននេះ អ្នកខ្លះចង់បាននោះ ហើយអ្នកខ្លះទៀតចង់ដឹងរឿងអាថ៌កំបាំងផ្សេងៗ។ ទោះបីជាមនុស្សមានចំណង់ចំណូលចិត្តខ្វែងគ្នាក៏ដោយ ក៏មានចំនុចស្របគ្នាទាំងអស់ដែរ ចំនុចដែលស្របគ្នានោះ ពោលគឺមនុស្សយើងចង់បាននូវសេចក្តីសុខ។ ដើម្បីទទួលបាននូវសេចក្តីសុខ មនុស្សម្នាក់ៗត្រូវតែមានសកម្មភាព លុះត្រាតែសកម្មភាពនោះទទួលបានជោគជ័យហើយ ទើបធ្វើឱ្យខ្លួនស្ងប់រម្ងាប់ផ្លូវចិត្ត និងសប្បាយរីករាយ។ នេះជារឿងធម្មតា ចរិតពីធម្មជាតិរបស់មនុស្សគ្រប់រូបតែងតែមានបំណងចង់សម្រេចអ្វីមួយ ឱ្យសមតាមសេចក្តីប្រាថ្នារបស់ខ្លួន ដោយសារជាប់ជំពាក់នឹងសេចក្តីចង់បានខ្លាំងពេក មិនដឹងជាដំបូងត្រូវចាប់ផ្តើមពីខាងណា អ្នកខ្លះបានត្រឹមតែអង្គុយគិតនឹកស្រមើស្រមៃ មិនព្រមបញ្ចេញសកម្មភាពសោះ ហើយអ្នកផ្សេងទៀតបានសង្វាតចូលប្រឡូកផ្សងព្រេងដែរ ប៉ុន្តែនៅ



ពេលជួបឧបសគ្គបន្តិចបន្តួច ក៏កើតសេចក្តីរារែកចិត្ត ឈប់បន្តសកម្មភាព។

ជាការពិតណាស់ ថ្វីត្បិតតែការស្រមើស្រមៃ និងបំណងប្រាថ្នាគឺជាចំនុចចាប់ផ្តើមក្នុងការសម្រេចអ្វីមួយជាផ្លែផ្កាក៏ដោយ ប៉ុន្តែបើខ្វះធាតុដទៃផ្សេផ្សំជាមួយហើយនោះ យើងមិនអាចធ្វើសេចក្តីស្រមើស្រមៃរបស់យើងឱ្យក្លាយជាការពិតបាននោះទេ។ អ៊ីចឹងហើយ ដើម្បីបោះជំហានឈានជើងចូលឱ្យបានទៅដល់គោលដៅ ម្នាក់ៗត្រូវតែអនុវត្តនូវអធិបតិធម៌ គឺសភាវៈជាធំក្នុងការងារ ឬ ហៅថាឥទ្ធិបាទធម៌ គឺគុណធម៌ ដូចជាជំហាននៃសេចក្តីសម្រេច មាន ៤ គឺៈ[៥៥]

១- **ឆន្ទៈ** មានសេចក្តីបំណងប្រាថ្នា ឬសេចក្តីពេញចិត្តក្នុងការងារដែលខ្លួនធ្វើ គឺបានដឹកនាំបំណងរបស់ខ្លួនទៅចងភ្ជាប់ក្នុងផលនៃការងារ។

២- **វិរិយៈ** ព្យាយាមធ្វើការងារដើម្បីសមិទ្ធិដែលខ្លួនបានចងភ្ជាប់

៣- **ចិត្តៈ** ផ្តោតចិត្តយ៉ាងខ្ជាប់ខ្ជួនក្នុងការងារ ដែលខ្លួនកំពុងធ្វើកំពុងប្រតិបត្តិ។

៤- **វិមំសា** ពិចារណាស្រាវជ្រាវរកហេតុផល នៃសេចក្តីពិតរបស់ការងារ។

ឆន្ទៈ, ឆន្ទៈ គឺជាកម្លាំងចិត្តដែលជំរុញឱ្យមនុស្សធ្វើអ្វីផ្សេងៗ

ហើយឆន្ទៈទៀតសោត ក៏ជាចំនុចចាប់ផ្តើមចំពោះបញ្ហាគ្រប់ប្រភេទ។ អ្នកសិក្សា អ្នកស្រាវជ្រាវរកហេតុផលផ្សេងៗ និងប្រកបការងារបានជោគជ័យ តែងតែមានឆន្ទៈភ្ជាប់នឹងខ្លួនជានិច្ច។ មួយវិញទៀតបុគ្គលដែលប្រកបដោយឆន្ទៈក្នុងការធ្វើអ្វីមួយ អ្នកនោះមុខជាពេញចិត្តសប្បាយរីករាយនឹងការងាររបស់ខ្លួនមិនខាន។ កាលដែលយើងមានចិត្តភក្តីភាពចំពោះការងារនេះឯង ជាមូលហេតុធ្វើឱ្យអារម្មណ៏របស់យើងនៅតែចង់បាន ចង់ឃើញវាមិនរលត់ទៅណាឆ្ងាយពីចិត្តរបស់យើងទេ ពីព្រោះមានអារម្មណ៏ជាស្នេហាស្រលាញ់វាហើយ។ ផ្ទុយទៅទៀត មនុស្សយើងពេលធ្វើអ្វីមួយទៅតាមការបង្គាប់បញ្ជារបស់គេដែលប្រកបដោយសេចក្តីមិនពេញចិត្ត កិច្ចការងារនោះៗ រមែងមិនដែលបានលទ្ធផលជាទីគាប់ចិត្តនោះទេ។ ហើយជួនកាល ក៏បណ្តាលឱ្យគ្រោះពីកិច្ចការងារនោះក៏មាន។ ចំពោះបញ្ហានេះមិនមែនពោលដៅលើតែកិច្ចការងារ និងការសិក្សារៀនសូត្រប៉ុណ្ណោះទេ សូម្បីតែការរៀបអាពាហ៏ពិពាហ៏រវាងបុរស និងស្ត្រីដែលព្រឹត្តិការណ៏យ៉ាងសំខាន់របស់មនុស្សម្នាក់ៗក្នុងឆាកជីវិត កាលបើខ្វះឆន្ទៈនេះហើយ មង្គលការនោះកម្រនិងបានដូចបំណងណាស់ តើអ្នកធ្លាប់បានឃើញផ្ទាល់ ឬឮតាមរយៈពត៌មាន កូនកំលោះរត់ចោលកូនក្រមុំៗ រត់ចោលកូនកំលោះផ្អើលពេញភូមិឬទេ?។ ដូច្នេះ



ហើយ មនុស្សម្នាក់ៗ មុននឹងឈានទៅដល់ចំនុចកំពូលរបស់ខ្លួន ត្រូវតែមានឆន្ទៈជាចាំបាច់ នៅពេលយើងចង់សម្រេចកិច្ចការអ្វីមួយមិនប្រកបដោយឆន្ទៈ ទោះបីជាយើងធ្វើអស់កាលយូរប៉ុន្មានក៏ដោយក៏មិនដូចសេចក្តីប្រាថ្នានោះឡើយ។ ឆន្ទៈក្នុងទីនេះ មិនមែនជាឆន្ទៈកាឡៃនោះទេ គឺជាឆន្ទៈដ៏ពិតប្រាកដ ឆន្ទៈដ៏ពិតប្រាកដនោះ ពោលគឺឆន្ទៈនៃកម្លាំងចិត្តប្រកបដោយចេតនា គ្មានការបង្ខិតបង្ខំ ឆន្ទៈណាពោរពេញទៅដោយការបង្ខិតបង្ខំនោះ គឺជាឆន្ទៈក្លែងក្លាយ។

**វិរិយៈ**, វិរិយៈ គឺជាសេចក្តីព្យាយាមគ្រប់ឧបសគ្គ ដោយមិនចុះចាញ់ងាយៗ។ កាលណាយើងមានឆន្ទៈក្នុងការសម្រេចធ្វើអ្វីមួយហើយ យើងត្រូវមានសេចក្តីព្យាយាមថែមទៀត សេចក្តីព្យាយាមជាធាតុមួយយ៉ាងសំខាន់ សម្រាប់ជួយជ្រោមជ្រែងយើងឱ្យបានឆាប់ទៅដល់គោលដៅ។ បុគ្គលឯណានីមួយ ទោះជាធ្វើអ្វីក៏ដោយ ប្រសិនបើខ្វះសេចក្តីព្យាយាមហើយនោះ ខ្លួនប្រាកដជាមិនបានសម្រេចនូវអ្វីដែលខ្លួនចង់សម្រេចឆាប់ៗនោះទេ។ មិនថាចំពោះការប្រកបកិច្ចការងារ ឬការសិក្សារៀនសូត្រ យើងទាំងអស់គ្នាត្រូវតែមានសេចក្តីព្យាយាម ពីព្រោះមានមនុស្សច្រើនណាស់បានឱ្យតម្លៃចំពោះសេចក្តីព្យាយាម រហូតដល់មានសុភាសិតបុរាណពោលថា "សេចក្តីព្យាយាមគង់បានសម្រេច ឱ្យតែការព្យាយាមនោះសមហេតុផល

ការព្យាយាមក្នុងផ្លូវត្រូវ។ កុំអាងបញ្ហាមើលងាយការព្យាយាម” ជាដើម។ មនុស្សមិនតិចទេមើលទៅ បន្ទាប់ពីខ្លួនមានបំណងចង់បានអ្វីមួយហើយ ក៏ចាប់ផ្តើមធ្វើកិច្ចការនោះ ប៉ុន្តែមិនសូវមានសេចក្តីព្យាយាមប៉ុន្មាននោះទេ។ កុំបណ្តោលឱ្យអ្វីមួយឃ្លាតឆ្ងាយផុតពីដៃអ្នក ប្រសិនបើអ្នកអាចឈោងចាប់បាន ប៉ុន្តែកុំព្យាយាមចង់បានអ្វីដែលហួសពីការឈោងដល់។ ជួនកាលមានគំនិតយល់ឃើញថា ស្រេចហើយតែព្រេងវាសនាកំណត់មកចុះ ព្រោះអីឃើញអ្នកខ្លះ គេមិនសូវជាខំប្រឹងប្រែងប៉ុន្មានផង ម្តេចគេសម្រេចបាននូវអ្វីដែលគេចង់បានដូចទៅនឹងអ្វីដែលយើងកំពុងចង់បានដែរ។ អ្នកមួយក្រុមទៀតមិនព្រមធ្វើអ្វីទាំងអស់ គិតតែអង្គុយបន់ស្រន់សូមឱ្យទេវតាជួយ សូមបញ្ជាក់ផងដែរថា កាលដែលបន់ស្រន់ដើម្បីឱ្យសម្រេចនូវវត្ថុបំណងអ្វីមួយ ដោយមិនព្រមបញ្ចេញសកម្មភាពគំនិតប្រាជ្ញ ឬកម្លាំងពលកម្ម សូម្បីតែឥន្ទ ព្រហ្ម យមយក្ស អារក្ស អ្នកតា ពាសពេញប្រទេសរហូតដល់ព្រះសម្មាសម្ពុទ្ធជាបរមគ្រូ ក៏មិនអាចជួយបានដែរ ទោះបីជាយើងអង្គុយបន់ស្រន់ រហូតទាល់តែបាក់ធ្មេញអស់ក៏ដោយ។ ការពិតលើសពីការពិតណាស់ទៅហើយ ដែលថា ការទទួលជោគជ័យ និងការទទួលបាននូវសេចក្តីសុខទុក្ខរបស់យើងគ្រប់គ្នា គឺបានមកពីការធ្វើកិច្ចការងារប្រកបដោយសេចក្តីព្យាយាមនេះឯង មិន-



មែនបានដោយសារអាទិទេពផ្តល់ឱ្យ ឬដោយអំពើបន់ស្រន់នោះទេ។ ជាពិសេសជាងនេះទៅទៀត សេចក្តីព្យាយាមនេះឯងដែលជាទម្ងន់ដៃដ៏ខ្លាំងសម្រាប់វាយបំបាក់នូវឧបសគ្គតូចធំ និងជាអ្នកតស៊ូយ៉ាងស្វិតស្វាញបំផុតក្នុងការស្ថាបនាវិថី ឆ្ពោះឈានទៅឆាប់យកនូវវត្ថុបំណងឱ្យស្ថិតនៅក្នុងរង្វង់កណ្តាប់ដៃរបស់យើងគ្រប់គ្នា។

**ចិត្តៈ, ចិត្តៈ** ក្នុងទីនេះជាអ្នកដើរតួយ៉ាងសំខាន់ក្នុងការស៊ើបអង្កេតចំពោះការងារដែលយើងកំពុងធ្វើ ឬកំពុងប្រតិបត្តិ ហើយអមដំណើរទៅជាមួយរហូត។ កាលបើយើងមានឆន្ទៈដ៏មុះមុត និងវិរិយភាពដ៏អង់អាចហើយ យើងត្រូវតែមានចិត្តមួយទៀត ដើម្បីឱ្យកិច្ចការងាររបស់យើងដំណើរការទៅយ៉ាងរលូន ។ក្នុងចំណោមមនុស្សមួយក្រុម នៅពេលកំពុងធ្វើអ្វីមួយ មើលទៅឃើញការបញ្ចេញកម្លាំងអស់ពីសមត្ថភាពស្មើគ្នា ការព្យាយាមទៀតសោត ក៏មានលក្ខណៈដូចគ្នា ប៉ុន្តែ ទីបំផុតលទ្ធផលការងារចេញមកមានសណ្ឋានទ្រង់ទ្រាយខុសគ្នា គួរឱ្យកត់សម្គាល់។ បញ្ហានេះគឺមកពីបុគ្គលដែលទទួលបានលទ្ធផលល្អនោះ ដោយសារតែគេមានចិត្តរង់ចាំឃ្លាំមើលគ្រប់វិនាទី ប្រកបដោយស្មារតីប្រុងប្រយ័ត្នបំផុត ចំពោះកិច្ចការងាររបស់គេ។ ចំណែកម្នាក់ទៀត បែរជាមិនបានលទ្ធផលល្អទៅវិញ នេះមកពី ខណៈពេលដែលគេកំពុងធ្វើការងារ ចិត្តរបស់គេមិនបាន

នៅជាមួយនឹងការងារ ឬថា មានការយកចិត្តទុកដាក់ដែរ ប៉ុន្តែមើលមិនបានគ្រប់ជ្រុងជ្រោយ។ មានបុគ្គលមួយចំនួនទៀត នៅពេលខ្លួនកំពុងធ្វើការ តែងតែមានការភិតភ័យព្រួយបារម្ភខ្លាំង ក្រែងការងារនោះមិនបានល្អ នេះក៏ជាមូលហេតុបណ្តាលឱ្យចិត្តរបស់បុគ្គលនោះមិននឹងន ចំពោះកិច្ចការងារនោះដែរ។ ទាំងនេះក៏ជាចំនុចសំខាន់មួយដែរ ដែលយើងមិនអាចខ្វះខាតបាន ដើម្បីជួយឱ្យយើងឆាប់ដល់គោលដៅ។ ធ្វើអ្វីក៏ដោយ ប្រសិនបើចង់ឆាប់ដល់គោលដៅ ចៀសវាងការបរាជ័យច្រើនដង ព្រមទាំងកុំឱ្យចំណាយពេលវេលាច្រើន និងការចំណាយកម្លាំងឥតប្រយោជន៍នោះ យើងត្រូវតែមានចិត្តជាប់ជាមួយការងារជានិច្ច ពេលណាយើងកំពុងធ្វើវា កុំឱ្យចិត្តឃ្លាតពីយើងឱ្យសោះ សូម្បីតែមួយវិនាទី ព្រោះអីបញ្ហាតូចតាចក៏បង្កឱ្យក្លាយទៅជារឿងធំបានដែរ។

*វិមំសៈ*, *វិមំសៈ*គឺជាការពិចារណាយ៉ាងហ្មត់ចត់បំផុត ចំពោះការងារដែលយើងបានធ្វើ។ ជាការពិតណាស់ កាលបើយើងមានឆន្ទៈជាចំនុចចាប់ផ្តើមហើយ បន្ទាប់មកយើងមានសេចក្តីព្យាយាម និងការយកចិត្តទុកដាក់ ចំពោះការងារយើងកំពុងធ្វើ ដែលជាធាតុយ៉ាងសំខាន់មិនអាចខ្វះបាន ប៉ុន្តែ វិមំសៈ ការពិចារណាទៅលើការ-ងាររឹងរឹតតែសំខាន់ទៅទៀត។ ការសិក្សារៀនសូត្រក្តី ការប្រកប



កិច្ចការផ្សេងៗក្តី ដើម្បីទទួលបាននូវសេចក្តីប្រាថ្នាឱ្យសមតាមបំ-ណងពិតនោះ យើងត្រូវតែមានការពិចារណាជាចំនុចចាំបាច់ ចំពោះអ្វីដែលយើងបានធ្វើកន្លងមក ក្នុងទិសដៅស្វែងរកហេតុផលឱ្យបានច្បាស់លាស់។ ជួនកាល យើងខំប្រឹងប្រែងធ្វើអ្វីមួយអស់ពិសមត្ថ-ភាពហើយ ទាស់ត្រង់តែថា មិនបានដូចផែនការណ៍គ្រោងទុកសោះ ពីព្រោះអីផ្លូវដែលយើងកំពុងដើរគឺជាផ្លូវខុស ដូច្នេះហើយទើបយើងមិនអាចទៅដល់គោលដៅបាន។ នៅពេលយើងពិចារណារកហេតុ-ផលឃើញហើយ យើងត្រូវស្វែងរកការបង្កើតវិធីសាស្ត្រសាជាថ្មី។ ទៅតាមផ្លូវនេះមិនដល់ យើងទៅតាមផ្លូវផ្សេងទៀត បើយើងនៅតែចចេសរឹងរូសធ្វើអ្វីដដែលៗ មិនព្រមបោះបង់គំនិតចាស់ចោល ទាំងដឹងខ្លួនថា វាមិនមែនជាវិធីសាស្ត្រល្អសម្រាប់ខ្លួននោះ ទោះបីជាយើងខំធ្វើរហូតដល់ទីបំផុត ក៏មិនបានសមប្រកបដូចសេចក្តីប្រាថ្នាឡើយ។ បើនៅតែធ្វើយ៉ាងនេះ នោះគឺជាការសម្តែងឱ្យឃើញពីភាពល្ងង់ខ្លៅរបស់ខ្លួនហើយ។ បុគ្គលដែលមានការពិចារណាអាចធ្វើឱ្យបុគ្គលដទៃកើតការងឿងឆ្ងល់ថា អ្នកខ្លះគេមានចំណេះដឹង និងសម-ត្ថភាពដូចបុគ្គលឯទៀតដែរ ហេតុអ្វីបានជាគេធ្វើមិនបាន?។ ឯរីបុគ្គលដែលគេដឹងថា ខ្លួនគេមានសមត្ថភាពគ្រប់គ្រាន់ បែរជាមិនព្រមបញ្ចេញសមត្ថភាពទៅវិញ។ នេះមកពីគេដឹងថា កាលៈទេសៈ

មិនអំណោយផលដល់គេ កាលដែលគេដឹងនេះ គឺមកពីការពិចារណាឃើញថា វាទៅមិនរួចនេះឯង។ វិមំសៈ ការពិចារណា គឺជាអ្នកឆក់ឱកាស ជាអ្នកបង្កើតឱកាស និងជាអ្នកផ្លាស់ប្តូរវារកវិធីសាស្ត្រប្លែកៗ ធ្វើយ៉ាងណាឱ្យឆាប់បានដល់គោលដៅលឿនបំផុត។ ហើយការពិចារណារកហេតុផលនេះទៀតសោត គឺជាមធ្យោបាយដ៏ស័ក្តិសិទ្ធិធ្វើឱ្យអនាគតល្អជាងបច្ចុប្បន្ន ធ្វើឱ្យបច្ចុប្បន្នល្អជាងអតីត។

ព្រះសម្មាសម្ពុទ្ធគឺជាអ្នកត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញាណដោយព្រះអង្គឯង ឥតមានគ្រូអាចារ្យណាប្រដៅព្រះអង្គឡើយ។ ព្រះអង្គបានញ៉ាំងសត្វលោកក្នុងវាលវដ្តសង្សារមហាធំធេងនេះ ឱ្យឆ្លងផុតត្រៃភពទាំងបី ព្រមទាំងបានបន្សល់ទុកនូវឱវាទល្អជាច្រើនសម្រាប់អនុជនជំនាន់ក្រោយ យកទៅប្រតិបត្តិដើម្បីទទួលបាននូវសេចក្តីសុខ ទាំងបច្ចុប្បន្នទាំងអនាគត ហើយទ្រឹស្តីនោះត្រូវបានពួកបស្ចិមប្រទេស និងប្រទេសលោកខាងលិចកំពុងតែចាប់អារម្មណ៍នាពេលបច្ចុប្បន្នផងដែរ។ កិត្តិនាមរបស់ព្រះអង្គបានល្បីរន្ទឺទូទៅសកលលោក ប្រទេសណាក៏ស្គាល់ដែរព្រះពុទ្ធសាសនា។ សមិទ្ធផលទាំងនេះ គឺបានមកពីការអនុវត្តឥទ្ធិបាទធម៌នេះឯង។ ពីព្រោះក្នុងចំណោមបារមីទាំង១០ ឬទាំង៣០ បើខ្វះវិរិយបារមីហើយ ព្រះអង្គក៏មិនអាចត្រាស់ដឹងជាព្រះបានដែរ ជាពិសេស គឺឆន្ទៈសេចក្តីប្រាថ្នា



របស់ព្រះអង្គឱ្យបានត្រាស់ជាព្រះពុទ្ធ កាលដែលនៅជាសុមេធៈតាបស។

អធិបតីធម៌នេះ មិនតែធ្វើឱ្យសម្រេចបានខាងលោកុត្តរធម៌នោះទេ ថែមទាំងធ្វើឱ្យសម្រេចបាននូវគោលបំណងខាងលោកិយធម៌ទៀតផង។ ទស្សនវិទូជាច្រើន ដែលបានលាតត្រដាងរឿងអាថ៌កំបាំងនៅក្នុងលោកយើង ហើយបានយកមកបង្ហាញឱ្យយើងបានភ្លឺភ្នែកគ្រប់គ្នាមកដល់បច្ចុប្បន្ននេះ ដូចជា តាលេះ (Thales), សូក្រាត (Soscate), ប្លាតុង (Platong), អារិស្តុត (Aristote), អាណាក់ស៊ីម៉ងឌ្រឺ (Anaximonder), ពិតាហ្គរ័ (Pythagore), អាណាក់ស៊ីម៉ែន (Anaximene), អ័ប៉េដូក (Empedole), កូពែកិនីក (Comperic), តូនប៊ី (Toynbee), ស្តិបហ្វិនសុន (Stephenson), រូសូ (Roussean), អូគូតុង (Augustecomte), ហ្គាលលីឡេ (Galilee), ប៉ាស្កាល់ (Pascal), ទេវីស្ត្រុះ (Levistrus), ស៊ូភីល (Sophiste), កាលម៉ាក (Karlmark), ហាត់ម៉ាន (Hartman), ប៊ីនេ (Binet), ស៊ីម៉ង (Simon), លោកអ៊ូម (Ohm), ម៉ាកូនី (Marconi), វ៉ូលហ្វ (Woolf), ប៉ាស្ទ័រ (Paster), កម៉ិត (Comette), ស្ពីណូសា (Spinoza), ចោនស្តាតមីល (John Stuart Mill), រូស៊ែល (Russell), អឺក្លីត (Eclide),

និង ឡូបាតឆេវគី (Lobartschewsky), ជាដើម។ ទស្សនវិទូ អ្នកវិទ្យាសាស្ត្រ បញ្ញវន្តដែលបានរៀបរាប់ឈ្មោះខាងលើនេះ សុទ្ធតែជាអ្នកបានអនុវត្តនូវឥទ្ធិបាទធម៌នេះគ្រប់ៗគ្នា ទើបអាចស្រាវជ្រាវអ្វីមួយឱ្យចេញជារូបរាងពិត្រប្រាកដ ដើម្បីភស្តុតាងជួយគាំទ្រទៅការអះអាងរបស់ខ្លួន ហើយបានបន្សំទុកនូវទ្រឹស្ដីប្លែកៗ ពីគ្នា។ អ្នកវិទ្យាសាស្ត្រខ្លះបានបន្សល់ទុកនូវក្បួនខ្នាតសម្រាប់ផលិតរថយន្ត និងសម្ភារៈប្រើប្រាស់ផ្សេងទៀតជាច្រើន ដើម្បីជួយសម្រួលក្នុងជីវភាពប្រចាំថ្ងៃឱ្យងាយស្រួល។

ពិតមែនតែទ្រឹស្ដីក្នុងព្រះពុទ្ធសាសនា(៥៦) យើងមិនបានឃើញក្បួនវិទ្យាសាស្ត្រ ដូចជាក្បួនធ្វើរថយន្ត អាកាសយាន និងក្បួនធ្វើវិទ្យុអគ្គីសនីជាដើមនោះមែន ប៉ុន្តែទ្រឹស្ដីព្រះពុទ្ធសាសនានេះឯង ជាប្រភពនៃវិទ្យាសាស្ត្រ នៃវឌ្ឍនធម៌ សីលធម៌ អារ្យធម៌ និងវប្បធម៌ក្នុងពិភពលោកទាំងមូល ដូចជាមុខវិទ្យា វត្ថុសិក្សាគ្រប់ផ្នែកទាំងអស់ក្នុងទ្រឹស្ដីវិទ្យាសាស្ត្រ សុទ្ធកើតមកពីពិភពអធិបតីធម៌នេះឯង។ ដើម្បីឱ្យរឹតតែច្បាស់ជាងនោះទៅទៀត ខ្ញុំសូមលើកយកទ្រឹស្ដីរបស់លោកអ៊ែនស្តែន (Ein Stein) ដែលជាអ្នកវិទ្យាសាស្ត្រផ្នែកខាងរូបវិទ្យា ដ៏ល្បីល្បាញម្នាក់មកបញ្ជាក់ ដូចតទៅនេះ លោកអ៊ែន ស្តែន បានពោលថា "ខ្ញុំគ្មានទេព្យកោសល្យអ្វីឡើយ មានតែការចង់



ដឹងតែប៉ុណ្ណោះ អ្វីដែលខ្ញុំធ្វើកើត ដោយសារតែខ្ញុំទ្រាំបានយូរជាមួយនឹងបញ្ហានោះឯង"។ យោងទៅតាមទ្រឹស្ដីខាងលើនេះ យើងអាចយល់បានយ៉ាងច្បាស់ចំនុចដែលលោកពោលថា មានតែការចង់ដឹងប៉ុណ្ណោះ នេះហើយជាតួនៃឆន្ទៈ ពីព្រោះជាការចង់ដឹងប្រកបដោយចេតនា មិនមានការបង្ខិតបង្ខំពីសំណាក់បុគ្គលណាមួយទេ។ ចំនុចមួយទៀត ដែលលោកពោលថា ដោយសារតែខ្ញុំទ្រាំបានយូរជាមួយនឹងបញ្ហានោះ នេះហើយគឺជាអត្តចរិតរបស់សេចក្ដីព្យាយាមយ៉ាងប្ដូរផ្ដាច់បំផុត។

ដូច្នេះហើយ យើងទាំងអស់គ្នាដែលជាអ្នកមានគម្រោងផែនការណ៍ក្នុងជីវិត ទាំងអ្នកចាប់ផ្ដើមអនុវត្ត ទាំងអ្នកកំពុងអនុវត្ត ត្រូវតែអនុវត្តឱ្យបានខ្ជាប់ខ្ជួននូវអធិបតីធម៌បួនប្រការនេះ ឱ្យបានគ្រប់ៗគ្នា។ ជាពិសេសយុវវ័យដែលជាសិស្សានុសិស្ស និងនិស្សិត កំពុងតែសិក្សារៀនសូត្រ និងជាអ្នកកំពុងស្រេកឃ្លាននូវចំណីអាហារចំណេះវិជ្ជា ដើម្បីទទួលបានទាំងបរិមាណ ទាំងគុណភាព យើងត្រូវតែអនុវត្តទៅតាមឥទ្ធិបាទធម៌ យើងមិនអាចមើលរំលងឥទ្ធិបាទធម៌នេះបានឡើយ។ ប្រសិនបើ ឥទ្ធិបាទធម៌បួនប្រការនេះសណ្ឋិតក្នុងដួងព្រលឹងវិញ្ញាណបុគ្គលណា បុគ្គលនោះលុះប្រាថ្នាចង់សម្រេចបាននូវអ្វីមួយ មុខជាសមប្រកបដូចក្ដីបំណងប្រាថ្នាពិតប្រាកដ។

# សាសនាគួរជឿ

*ដោយភិក្ខុ* **លាង សារ៉យ** (ថ្នាក់បរិញ្ញាបត្រ)

នៅពេលអ្នកវិទ្យាសាស្ត្រធ្វើការស្រាវជ្រាវ ទៅលើសាសនាផ្សេងៗ លទ្ធផលនោះតែងតែមានភាពជាអវិជ្ជមាន។ ទោះបីជាមានការបង្ហាញយ៉ាងនេះក៏ដោយ បន្ទាប់មកនៅក្នុងឆ្នាំ ២០០៤ ហើយនិងថ្មីៗនេះ ក្រុមអ្នកវិទ្យាសាស្ត្រជឿនលឿនដ៏ល្បីល្បាញក្នុងពិភពលោក ពួកគេបានធ្វើការស្រាវជ្រាវឈ្វេងយល់ ទៅលើព្រះពុទ្ធឱវាទនៃការអប់រំ តាមផ្លូវចិត្តក្នុងព្រះពុទ្ធសាសនា ជាលទ្ធផលនោះបានបង្ហាញផលជាវិជ្ជមាន ស្របនឹងទ្រឹស្តីអ្នកវិទ្យាសាស្ត្រដែរ។[(៥៧)] ដូច្នេះហើយអ្នកវិទ្យាសាស្ត្រទាំងនោះយល់ឃើញថា ពុទ្ធសាសនិកដែលប្រតិបត្តិ ឬអ្នកធ្វើសមាធិក្នុងទីកន្លែងស្ងប់ស្ងាត់ គឺនាំមកនូវសេចក្តីស្ងប់ចិត្ត ស្ងប់កាយ ជាងការប្រតិបត្តិក្នុងសាសនាដទៃផ្សេងៗទៀត។ នេះឃើញថា វាជារឿងគួរឱ្យអស់សំណើចណាស់មែនទេ សម្រាប់អ្នកដែលដើរតាមផ្លូវខុសមួយចំនួន គឺជនជាមិច្ឆាទិដ្ឋិបានគិត ហើយនិងនិយាយតៗមាត់ថា ព្រះពុទ្ធសាសនានាំមកនូវសេចក្តីទុក្ខតែម្យ៉ាង សម្រាប់ជីវិតមនុស្សសត្វក្នុងសាកលលោកយើងនេះ មិនត្រឹមតែប៉ុណ្ណោះទេ ថែមទាំងបានអះអាងថា អ្នកដែលជឿ និងគោរព



ប្រតិបត្តិព្រះពុទ្ធសាសនា គឺសុទ្ធតែអ្នកក្រីក្រ និងប្រទេសអ្នកក្រ។ ហេតុអ្វីបានជាពួកគេនិយាយបែបនេះ?។ បើតាមមតិរបស់ខ្ញុំសង្កេតឃើញថា ប្រទេសពួកលោកខាងលិចសុទ្ធតែជាប្រទេសជឿនលឿន និងជាប្រទេសមហាអំណាច រឺថាជាប្រទេសអ្នកមាន។ គ្រប់ប្រទេសទាំងអស់នោះ ពួកគេប្រតិបត្តិគោរពរាប់អានសាសនាក្រៅពីពុទ្ធសាសនា។ ហេតុនេះហើយបានជាពួកគេអះអាងថា ប្រទេសដែលកាន់សាសនាគ្រីស្ទ និងសាសនាដទៃទៀត សុទ្ធតែជាប្រទេសអ្នកមាន។ ត្រង់កន្លែងនេះហើយ ដែលខ្ញុំសូមដាស់សតិអារម្មណ៍ដល់ពុទ្ធសាសនិកទាំងអស់ កុំអាលជឿនូវពាក្យឃោសនា និងពាក្យល្បួងលួងលោម ឱ្យចូលសាសនារបស់ពួកគេ។ ខ្ញុំយល់ស្របថា ប្រទេសទាំងអស់នោះថា ជាប្រទេសអ្នកមាន និងប្រទេសមហាអំណាចពិតមែន ប៉ុន្តែ អ្នកមានខាងសីលធម៌ សម្បត្តិធម៌ ចរិយាធម៌ សុជីវធម៌ សីលធម៌ គោរពឱនលំទោន ឪពុកម្តាយ ចាស់ព្រឹទ្ធាចារ្យ គ្រូបាអាចារ្យ គ្រូឧបជ្ឈាយាចារ្យ បងប្អូន គឺមិនមានស្មើនឹងប្រទេសអ្នកកាន់ព្រះពុទ្ធសាសនាឡើយ។ ហេតុដូចម្តេចបានជាខ្ញុំហ៊ាននិយាយយ៉ាងនេះ?។ ព្រោះថា ពួកគេមិនបានយកឪពុកម្តាយជាធំ ឬថា ជាទីសក្ការៈ ជាអ្នកមានឧបការៈគុណទេ ផ្ទុយទៅវិញ ពួកគេគ្រាន់តែគិតថា ឪពុកម្តាយបង្កើតពួកគេមក ដោយសារតែសេចក្តី

សប្បាយកាមគុណរបស់ឪពុកម្ដាយតែប៉ុណ្ណោះ។ ពួកគេមិនបានយកចិត្តទុកដាក់ទៅបម្រើឪពុកម្ដាយ ចាស់ព្រឹទ្ធាចារ្យ គ្រូបាអាចារ្យ បងប្អូន ដូចជាប្រទេសអ្នកគោរពប្រតិបត្តិព្រះពុទ្ធសាសនាឡើយ តួយ៉ាងដូចជាប្រទេសកម្ពុជា ភូមា ឡាវ ថៃ ជាដើម។ លើសពីនេះទៅនេះ ពួកគេយកឪពុកម្ដាយដែលមានអាយុចាស់ ជរា ទៅដាក់ឱ្យរស់នៅក្នុងអគារសម្រាប់មនុស្សចាស់រង់ចាំតែសេចក្ដីស្លាប់ នៅកន្លែងនោះ។ ដោយឡែកឯកូនតូចៗវិញ ក៏គេមានអគារសម្រាប់ចិញ្ចឹមដាច់ដោយឡែកពីឪពុកម្ដាយដែរ កូនមិនបានជួបមុខម្ដាយឪពុកជារៀងរាល់ថ្ងៃ មានកូនខ្លះមិនបានស្គាល់ទាំងមុខឪពុកម្ដាយផង។ កត្តាទាំងនេះហើយ ដែលធ្វើឱ្យពួកគេធំធាត់ឡើង មិនជឿថា ឪពុកម្ដាយជាអ្នកមានគុណ។ ម្យ៉ាងទៀត ខ្ញុំសូមរំលឹកដល់ថា **ក្នុងនាមជាពុទ្ធបរិស័ទ** កុំអាលមានជំជឿ ទៅលើអ្វីមួយទាំងខ្វះការពិចារណា គឺជឿហួសហេតុ ជឿផ្កាប់មុខ។ ដោយហេតុថាបច្ចុប្បន្ននេះ ពុទ្ធបរិស័ទខ្មែរ ក្នុង និងក្រៅប្រទេសមានជំនឿជ្រុលនិយម ជំនឿងងឹតល្ងង់ នៅនិងទួលព្រះរាជា។ តាំងខ្ញុំបានបួសរៀនក្នុងព្រះពុទ្ធសាសនាជាច្រើនឆ្នាំមក ខ្ញុំមិនដែលឃើញក្បួនខ្នាតណាមួយថា ខ្លួនជាគ្រហស្ថភេទជាតាបសសោះ មានគុណធមិខ្ពស់ អាចបំបួសព្រះភិក្ខុសង្ឃបាន និងមានសិទ្ធិក្រាលគ្រងកឋិនបាន ទង្វើបែបនេះ ខ្ញុំមិនដែលឃើញ



ទាល់តែសោះ។ ខ្ញុំសូមបញ្ជាក់ថា ការបំបួសជាព្រះភិក្ខុសង្ឃ គឺមានការសូត្រញត្តិត្រឹមត្រូវតាមវិន័យកិច្ច បើមិនត្រឹមត្រូវតាមវិន័យកិច្ចនោះទេ កុំសង្ឃឹមថាឡើងជាព្រះភិក្ខុភាវៈ។ ផ្ទុយទៅវិញ វាគ្រាន់តែជាការលួចភេទ និងការបន្លំភេទប៉ុណ្ណោះ។ ត្រង់ចំណុចនេះ ពុទ្ធសាសនិកទាំងអស់គួរតែពិចារណាឱ្យមែនទែន ប្រយ័ត្នចាញ់បោកការឃោសនាអកុសល នាំខ្លួនខាតប្រយោជន៍ មុននឹងដាក់ជំនឿទៅលើ។ នៅស្រុកខ្មែរយើងកំពុងតែពេញនិយម មានជំនឿយ៉ាងខ្លាំងទៅលើស្រោចទឹក ទស្សន៍ទាយ ដាក់កថា ពាក់យន្ត គ្រូតូចគ្រូធំ ចុះមកពីភ្នំគូលែន។ គ្រូខ្លះរកបោកគេមិនសូវបាន ក៏តាំងខ្លួនឯងជាគ្រូមកពីព្រៃភ្នំ មកលក់វត្ថុស័ក្ដិសិទ្ធិ រូបចម្លាក់ព្រះ ពួកគេអួតថា មានបារមីពូកែ ព្រះចុះមកសណ្ឋិត ឥឡូវនេះ ខ្ញុំសូមលើកជាឧទាហរណ៍រឿងពិតមួយមកប្រាប់ កាលពីខ្ញុំរៀននៅឯស្រុកត្បូងឃ្មុំ មានតាចាស់ម្នាក់មកលក់រូបចម្លាក់ព្រះពុទ្ធឱ្យខ្ញុំ ហើយខ្ញុំមិនបានទិញពីគាត់ គាត់ក៏និយាយថា ខ្ញុំនេះមិនជឿព្រះទៅវិញ។ នេះបើពុទ្ធបរិស័ទណា ដែលបញ្ញាបានយល់ដឹងពីព្រះពុទ្ធវចនៈច្បាស់លាស់នោះ វាបែរជារឿងគួរឱ្យអស់សំណើច ហើយនិងរឿងចម្លែកមួយ។ អំពើទាំងនេះ គឺជាការយកសាសនា ជាការឃោសនា ជាការបោកប្រាស់ និងជាការរកស៊ីតែប៉ុណ្ណោះ។ ដោយឡែកពីនេះទៅទៀត សាសនាដទៃកំពុង

តែប្រើគ្រប់មធ្យោបាយ ដើម្បីទាក់ទាញពុទ្ធសាសនិកឱ្យចូលកាន់សាសនារបស់ខ្លួន មានតាំងពីប្រើទឹកលុយមកទាក់ទាញជាដើម។ ខ្លួនជាពុទ្ធសាសនិកគួរតែជ្រាប់ថា គ្មានសាសនាណាមួយដែលមានដំបូន្មាន និងទស្សនៈ ជឿកម្ម និងផលពិត១ មានពុទ្ធឱវាទដឹកនាំសត្វលោកទៅកាន់ទីរំលត់ទុក្ខ ពោលគឺ ព្រះនិព្វាន ដូចជាព្រះពុទ្ធ-សាសនាឡើយ។ បច្ចុប្បន្នឥឡូវនេះ ជាការពិតណាស់ ពួកអ្នកវិទ្យា-សាស្ត្រក៏ឯកភាពថា ព្រះពុទ្ធសាសនា គឺជាសាសនាមួយដែលបានដឹកនាំ នឹងកំពុងដឹកនាំមនុស្សសត្វទៅរកសេចក្តីសុខចម្រើន និងសន្តិភាពជូនប្រទេសជាតិ។ សំនួរចោទថា តើវាអាចទៅរួចទេ? ។

ពួកអ្នកវិទ្យាសាស្ត្រជាច្រើនបានធ្វើការរុករក តាមពុទ្ធវចនៈទៅឃើញថា ប្រព័ន្ធនៃខួរក្បាលមនុស្សយើងធ្វើការជាមួយនឹងប្រព័ន្ធផ្លូវចិត្ត។ លោកបណ្ឌិត **រីឆាត ដាវិតសិន (Dr. Richard Davidson)** នៃសាកលវិទ្យាល័យវិស្កនស៊ីន ឆ្លើយថា យោគីក្នុងព្រះពុទ្ធសាសនាអាចធ្វើឱ្យចិត្តស្ងប់បាន តាមការធ្វើសមាធិកម្មដ្ឋាន ចិត្តស្ងប់មិនត្រឹមតែកំពុងធ្វើសមាធិប៉ុណ្ណោះទេ ថែមទាំងស្ងប់ចិត្តបានល្អ បន្ទាប់ពីការធ្វើទៀតផង។ ទស្សនវិទូម្នាក់ទៀត នៃសាកលវិទ្យាល័យខាលីហ្វ័-នីញ៉ា មានមតិថា ការធ្វើសមាធិតាមបែបព្រះពុទ្ធសាសនា ធ្វើឱ្យបុគ្គលម្នាក់១អាចបែងចែកការភ័យខ្លាច និងកំហឹងចងពៀរបានដាច់



ស្រលះពីគ្នា។ នេះគឺជាផ្នែកដំបូងនៃការសិក្សាស្រាវជ្រាវលើចិត្ត-សាស្ត្ររបស់លោកបណ្ឌិត **ដានេល ហ្គូលេមេន (Dr. Daniel Goleman)** ជាអ្នកចិត្តសាស្ត្រម្នាក់ របស់អាមេរិចកាំងដ៏ល្បីល្បាញក្នុងលោក បានប្រកាសខ្លួនឯងថា ជាពុទ្ធសាសនិក។ [(៥៨)]

ការធ្វើសមាធិ ឬការហ្វឹកហាត់អប់រំចិត្ត គឺជាទិដ្ឋភាពមួយដ៏អស្ចារ្យនៃការប្រតិបត្តិរបស់ពុទ្ធសាសនិក។ ការធ្វើសមាធិមិនមែនត្រឹមតែធ្វើឱ្យចិត្តស្ងប់ស្ងាត់ប៉ុណ្ណោះទេ ថែមទាំងធ្វើឱ្យចិត្តយើងស្ងប់រម្ងាប់ចាកសេចក្តីលោភលន់ សេចក្តីក្រោធ សេចក្តីវង្វេង។ ពួកវាហ្នឹងហើយ ដែលជាប្រភពនៃសេចក្តីទុក្ខសោកសៅ និងសេចក្តីទុក្ខព្រួយចំបែង។ ទោះបីជាព្រះពុទ្ធវចនៈចាប់ផ្តើមពីសេចក្តីទុក្ខក៏ពិតមែន ប៉ុន្តែ ជាដំបូងគឺជាអរិយសច្ចៈ ហើយនិងជាទីបំផុតនោះ គឺការរលាស់ខ្លួនចេញពីសេចក្តីទុក្ខទាំងស្រុងដល់នូវឋានអមតៈ ពោលគឺព្រះនិព្វាន។ ដូច្នេះ ព្រះពុទ្ធវចនៈ មានន័យថា ជាការពន្យល់អំពីផ្លូវចាកចេញពីសេចក្តីទុក្ខសោក សម្រេចដល់សុខអមតៈចូលកាន់ព្រះនិព្វានពិត១។ បើយើងគិតថា ព្រះនិព្វានគឺជាឋានអមតៈ បរម-សុខ ដូច្នេះក៏ពិតមែនហើយ ប៉ុន្តែ ថាតើពុទ្ធសាសនិកគួរស្វែងរកព្រះនិព្វានតាមរបៀបណា? ។ ក្នុងលោកសន្និវាសយើងនេះ អ្វី១ទាំងអស់ គឺសុទ្ធតែមានសភាពផ្លាស់ប្តូរ និងសភាពមិនស្ថិតស្ថេរ មិន

ទៀងទាត់ ប្រព្រឹត្តទៅដោយ អនិច្ចំ ទុក្ខំ និងអនត្តា។ សេចក្ដីសុខអាចទៅរួច ប្រសិនបើ យើងមានបញ្ហាចាក់ធ្លុះ ហើយនិងឃើញការវិលកើត ចាស់ ឈឺ ស្លាប់ ទោសរបស់វដ្ដៈ ហើយខំប្រឹងប្រតិបត្តិតាមព្រះពុទ្ធវចនៈ។ ព្រះពុទ្ធសាសនាទូន្មានយើងឱ្យមានជំនាញជាក់ច្បាស់ក្នុងជីវិតប្រចាំថ្ងៃ។ ជំនាញទាំងនេះរួមមាន សីលធម៌ក្នុងការរស់នៅ និងការអប់រំចិត្តឱ្យស្ងប់ស្ងាត់ តាមទ្រឹស្ដីទូន្មានរបស់ព្រះសម្មាសម្ពុទ្ធទាំងអម្បាលនេះ នឹងនាំមកនូវសុភមង្គលក្នុងជីវិត។

សីលប្រាំដែលជាគ្រឿងដ៏ពិតប្រាកដនាំមកនូវសុខ សុភមង្គលសន្តិភាព និងវឌ្ឍនភាព ពីព្រោះថា ឋានសុខ ប្រកបដោយសេចក្តីមិនមានការកាប់សម្លាប់ មិនបំផ្លាញជីវិតមនុស្សសត្វ មិនមានការលួចប្លន់ មិនមានការនិយាយបោកប្រាស់ កុហកចាក់ដោត និងការសេពនូវគ្រឿងស្រវឹងលីលា គ្រឿងញៀនជាដើម។[៥៩] ហេតុនៃអកុសលធម៌ទាំងនេះហើយ ដែលជាអំពើអបាយមុខ នឹងនាំទៅកាន់ទុគតិពិភព។ កន្លែងណាដែលប្រកបទៅដោយការកាប់សម្លាប់ជាដើម កន្លែងនោះឯង នឹងជាកន្លែងប្រកបដោយភាពឈឺចាប់ ខ្លោចផ្សា និង ប្រកបដោយវិប្បដិសារីស្ដាយក្រោយក្នុងជីវិត នូវអ្វីៗដែលខ្លួនបានប្រព្រឹត្តកន្លងហួស។

យោងតាមការស្រាវជ្រាវលើសាសនាជាច្រើនកន្លងមក ឃើញ



ច្បាស់ថា មានតែពុទ្ធសាសនាមួយគត់ ដែលបានរួមចំណែកយ៉ាងសំខាន់ក្នុងសង្គមជាតិ ជួយបង្ហាត់បង្រៀន ប្រៀនប្រដៅអប់រំពន្យល់ណែនាំសាសនិករបស់ខ្លួនឱ្យប្រព្រឹត្តប្រតិបត្តិ ឱ្យបានសមរម្យត្រឹមត្រូវ ទៅតាមគន្លងប្រពៃណីសាសនាដ៏ល្អប្រសើររបស់ខ្លួនប៉ុណ្ណោះ។ ថែមទាំងជួយបណ្ដុះបណ្ដាល ធ្វើយ៉ាងណាដើម្បីឱ្យមនុស្សចេះស្រលាញ់អំពើល្អ អំពើជាកុសល ចេះជួយសង្គ្រោះគ្នាទៅវិញទៅមក ជាពិសេស ដល់ជនក្រីក្រលំបាកតោកយ៉ាក ដោយការឱ្យរបស់ប្រើប្រាស់ និងសម្ភារៈផ្សេងៗ មានដូចជាទីជម្រកជាដើម។

យាវទេវ អនត្ថាយ ញត្តំ ពាលស្ស ជាយតិ
ហន្តិ ពលស្ស សុក្កំសំ មុទ្ធមស្ស វិបាតយំ។
ចំណេះវិជ្ជាកើតឡើងដល់បុគ្គលពាល គ្រាន់តែដើម្បីសេចក្តី
វិនាសតែប៉ុណ្ណោះ ចំណេះវិជ្ជានោះរមែងញាំង ក្បាលគឺបញ្ញា
របស់គេឱ្យធ្លាក់ចុះ កម្ចាត់បង់នូវចំណែកនៃធម៌ស បានដល់
កុសលធម៌របស់បុគ្គលពាលនោះឯង។[៦០]

# លោកសណ្ឋានកថា

*ដោយសាមណេរ* **សុខ ឆាវ** ( ថ្នាក់បរិញ្ញាបត្រ )

តិណ្ណំ លោកានំ វសេសេនេវ អត្ថវណ្ណនា សង្ខេបតោ លោកសណ្ឋានកថាតិ វេទិតព្វាតិ ។

គ្រានេះ នឹងសម្តែងដំណើររឿង មានវិធីលោកសណ្ឋានជាដើម ។

ស. លោកមានផែនដី និងមនុស្សជាដើម អ្នកណាសាង?

ឆ. មិនមានអ្នកណាសាងទេ គឺកើតឡើងដោយសង្ខារ ។

ស. តើសង្ខារនោះ មានប៉ុន្មានប្រការ?

ឆ. សង្ខារមាន ២ ប្រការគឺ សង្ខារធម៌ ១ សង្ខារលោក ១។ សង្ខារធម៌ នោះចាត់ជា ៣ គឺៈ បុញ្ញាភិសង្ខារ បុណ្យកុសលដែលសត្វធ្វើដោយកាយវាចាចិត្ត ហើយតាក់តែងឱ្យផលនាំមកនូវសុខតាមកម្លាំង ១ អបុញ្ញាភិសង្ខារ អកុសលដែលសត្វសន្សំដោយកាយ វាចាចិត្ត ហើយតាក់តែងឱ្យផលនាំមកនូវទុក្ខតាមកម្លាំង ១ អនេញ្ជាភិសង្ខារ បានដល់អរូបឈានសមាបត្តិ ដែលសត្វចម្រើនឱ្យកើតឡើង ហើយតាក់តែងឱ្យផលទៅកើតក្នុងអរូបភព ១ ទាំង ៣ នេះ ឈ្មោះថា សង្ខារធម៌ ជាបច្ច័យតាក់តែងសត្វឱ្យកើតតាមកម្លាំង ។



សង្ខារលោកនោះ ចាត់ជា ២ ពួកគឺៈ ឧបាទិន្នកសង្ខារ សង្ខារដែលមានឧបាទានចូលទៅជិតកាន់យក បានដល់សត្វដែលមានចិត្តវិញ្ញាណ ១ អនុបាទិន្នកសង្ខារ សង្ខារដែលមិនមានឧបាទានចូលទៅជិតកាន់យក បានដល់សម្ភារៈដែលមិនមានចិត្តមិនមានវិញ្ញាណ មានដីថ្ម ក្រួសជាដើម ១ ។

ស. សង្ខារពួកណាជាអ្នកបង្កើតលោក?

ឆ. សង្ខារធម៌ ដែលជាកុសលជាអ្នកបង្កើតលោកឡើង ។

ស. សង្ខារដែលជាកុសល មានប៉ុន្មានប្រការ?

ឆ. មាន ៤ ប្រការគឺៈ កាមាវចរកុសល ១ រូបាវចរកុសល ១ អរូបាវចរកុសល ១ លោកុត្តរកុសល ១។

ស. សង្ខារធម៌ដែលជាកុសល ញ៉ាំងលោកឱ្យកើតឡើងនោះ ដូចម្តេច?

ឆ. ព្រះពោធិសត្វ ដែលប្រាថ្នាជាព្រះពុទ្ធ ព្រះបច្ចេកពុទ្ធជាដើម ដរាបដល់សាវ័ក សាវិកា និងបរមចក្រពត្តិក្សត្រា ព្រាហ្មណ៍ សេដ្ឋី កុដុម្ពីក៏ជាអវសាន កសាងពោធិញាណ បំពេញទាន រក្សាសីល ៥ សីល ៨ កម្មបថ ១០ ចម្រើនមេត្តាភាវនា ស្តាប់ព្រះធម៌ទេសនា ធ្វើពុទ្ធបូជា ធម្មបូជា និងសង្ឃបូជា ជាដើម កសាងសន្សំកងការកុសល អស់ជាតិជាអនេក ដោយអំណាចកុសលនៃ

អ្នកទាំងអស់នេះ ជាបុញ្ញនិធិសន្សំទុកមកក្នុងសន្តាន ជាបុញ្ញា-ភិសង្ខារ តាក់តែងឱ្យកើតលោក មានផែនដីជាដើម។

ស. ចក្រវាល (ចក្កវាឡ) នីមួយៗ ទំហំប៉ុន្មាន?

ឆ. បើវាស់ដោយវែងត្រង់ទៅ ១២៣.៤៥០ យោជន៍។

ស. ចក្រវាលនោះ មានសម្ភារៈអ្វីខ្លះ?

ឆ. មានភ្នំព្រះសុមេរុនៅកណ្តាល មានទ្វីបធំទាំង ៤ គឺ ជម្ពូទ្វីប ទទឹង ១ ម៉ឺនយោជន៍ ចំណែកព្រៃហិមពាន្ត ៣ ពាន់យោជន៍ ជាលំនៅនៃមនុស្ស ៣ ពាន់យោជន៍ ជាសមុទ្រ ៤ ពាន់យោជន៍ មានដើមព្រីងធំប្រចាំទ្វីប មនុស្សចិញ្ចឹមជីវិតដោយធ្វើស្រែ ជួញប្រែ ជាដើម។ ឧត្តរកុរោទ្វីបមានសណ្ឋាន ៤ ជ្រុង ទទឹង ៨០០០ យោជន៍ មានដើមកប្បព្រឹក្សប្រចាំទ្វីប មនុស្សអាស្រ័យដោយដើមកប្បព្រឹក្ស មិនបាច់ធ្វើស្រែកាប់ចំការ ជួញប្រែ មានរូបល្អៗ ទាំងប្រុស ទាំងស្រី មានសីល ៥ ដូចគ្នា ស្លាប់ហើយមិនទៅនរក ស្ត្រីមានគភ៌ គ្រប់កំណត់ ៧ ថ្ងៃ សម្រាលទារកចេញមក ក្មេងនោះជញ្ជក់តែម្រាមដៃគេ ៧ ថ្ងៃដើរបាន។ អមរគោយានីទ្វីប មានសណ្ឋានដូចព្រះច័ន្ទខែរនោច ទទឹង ៧០០០ យោជន៍ មានដើមក្ទម្ពរប្រចាំទ្វីប មានថ្មកែវភ្លើងឱ្យសម្រេចសេចក្តីប្រាថ្នាដល់មនុស្សទាំងពួង ពួកមនុស្សមានសីល ៥ ជានិច្ច ស្លាប់ហើយមិន



ទៅនរក។

បុព្វវិទេហទ្វីប ទទឹង ១ ម៉ឺនយោជន៍ មានសណ្ឋានដូចវង់ព្រះច័ន្ទ មានដើមច្រេសប្រចាំទ្វីប មានប្រាសាទកែវ ៧ ប្រការ កំពស់ ១៥ យោជន៍ អាចឱ្យសម្រេចសេចក្តីប្រាថ្នាដល់មនុស្សទាំងពួង។ មនុស្សទាំងអស់ជាអ្នកមានសីល ៥ មានអាយុ ១ ម៉ឺនឆ្នាំ លុះស្លាប់ហើយមិនទៅនរក។ មានទ្វីបតូចៗ ២០០០ ហើយនិងមានភ្នំ ចក្រវាលព័ទ្ធដោយជុំវិញ។

ស. ដីតាំងនៅលើរបស់អ្វី?

ឆ. ផែនដីនៅលើទឹកៗ តាំងនៅលើខ្យល់ ក្រោមខ្យល់ជាអជ្ឈតា-កាស ចន្លោះទទេ។

ស. ផែនដី-ទឹក និងខ្យល់ មានកម្រាស់ប៉ុន្មាន?

ឆ. ផែនដីមានកម្រាស់ ២៤ ០០០ យោជន៍។ ទឹកមានកម្រាស់ ៤ សែន ៨ ម៉ឺនយោជន៍។ ខ្យល់មានកម្រាស់ ៩៦០០០០ យោជន៍។

ស. កាលឱកាសលោកនឹងវិនាសនោះ តើដោយអាការៈដូចម្តេច?

ឆ. កាលឱកាសលោកនឹងវិនាសនោះ គឺវិនាសដោយភ្លើង មហា-មេឃតាំងឡើង បណ្តាលឱ្យភ្លៀងធ្លាក់ចុះទូទៅក្នុង ១ សែនកោដិចក្កវាឡ មនុស្សទាំងឡាយក៏នាំគ្នាសាបព្រោះស្រូវៗ ក៏ដុះលូតលាស់ឡើង មហាមេឃក៏បន្លឺសម្លេងដូចសម្លេងនៃសត្វលា

ហើយក៏រាំង បាត់ស្ងាត់ឈឹងទៅ លែងមានភ្លៀងធ្លាក់ចុះមកអស់សែននៃឆ្នាំដ៏ច្រើន ហើយទឹកក្នុងស្រះ ជ្រោះ ត្រពាំង បឹងបួក៏រីងអស់។ សត្វ និងមនុស្សទាំងឡាយ ដែលអាស្រ័យទឹកភ្លៀង និងទេវតាដែលអាស្រ័យនូវផ្កាឈើជាដើម ក៏នាំគ្នាច្យុតទៅកើតក្នុងព្រហ្មលោក។ ឯសត្វក្នុងអបាយភូមិមាននរកជាដើម ដែលមានកម្មដ៏ស្រាល អស់កម្មហើយ បានអាស្រ័យកុសលចាស់ជារបស់ដែលខ្លួនបានធ្វើទុក ក៏ច្យុតទៅកើតក្នុងព្រហ្មលោកទាំងអស់។

ស. ផែនដីកើតឡើងក្នុងទីណាមុន?

ឆ. កើតឡើងក្នុងមជ្ឈិមប្រទេសមុន។ ទីនោះជាទីដែលព្រះពុទ្ធអង្គចុះមកត្រាស់។

អធិប្បាយថា: មជ្ឈិមប្រទេសនោះ កាលនឹងវិនាសក៏វិនាសខាងក្រោយ កាលនឹងកើតឡើង ក៏កើតឡើងមុន។

កាលនឹងកើតឡើងនោះ មានគុម្ពឈូក ១ កើតឡើងមុនជាបុព្វនិមិត្ត ជាទីកំណត់ដឹងថា បើកប្បឯណាព្រះពុទ្ធមិនចុះមកត្រាស់ទេ គុម្ពឈូកនោះក៏មិនផ្កាឡើយ។ បើកប្បឯណាព្រះពុទ្ធអង្គចុះមកត្រាស់ ១-២-៣-៤ ឬ ៥ អង្គ ដូចក្នុងកប្បនេះ គុម្ពផ្កាឈូកក៏មានផ្កា ១-២-៣-៤ ឬ ៥ តាមចំនួនព្រះពុទ្ធអង្គ



ដែលនឹងចុះមកត្រាស់នោះ។

ស. តើព្រះពុទ្ធអង្គចុះមកត្រាស់គ្រប់តែកប្បទៅឬ?

ឆ. មិនចុះមកត្រាស់គ្រប់កប្បទេ ដ្បិតកប្បនោះមាន ២ គឺ:

១. **សុញ្ញកប្ប** សូន្យទទេ មិនមានព្រះពុទ្ធចុះមកត្រាស់

២. **អសុញ្ញកប្ប** មានព្រះពុទ្ធចុះមកត្រាស់។ អសុញ្ញកប្បចែកជា ៥ គឺ: **សារកប្ប** មានព្រះពុទ្ធ ១ អង្គចុះមកត្រាស់ ១ **មណ្ឌកប្ប** មានព្រះពុទ្ធ ២ អង្គចុះមកត្រាស់ ១ **វរកប្ប** មានព្រះពុទ្ធ ៣ អង្គចុះមកត្រាស់ ១ **សារមណ្ឌកប្ប** មានព្រះពុទ្ធ ៤ អង្គចុះមកត្រាស់ ១ **ភទ្ទកប្ប** មានព្រះពុទ្ធ ៥ អង្គចុះមកត្រាស់ ១។ ព្រោះហេតុនោះ ផ្កាឈូកទើបកើតច្រើនខ្លះ តិចខ្លះ តាមព្រះពុទ្ធអង្គ ដែលចុះមកត្រាស់។

ស. ក្នុងផ្កាឈូកនោះមានវត្ថុអ្វីខ្លះ?

ឆ. មានត្រៃចីវរកើតសម្រាប់បុណ្យ នៃព្រះពុទ្ធអង្គនៅក្នុងផ្កាឈូក ហេតុដូច្នោះ កាលផែនដីចម្រើនឡើងថ្មីៗ មានក្លិនដ៏ក្រអូបឡើងទៅដល់ព្រហ្មលោក។

ពេលនោះពួកមហាព្រហ្ម មួយអន្លើដោយព្រហ្មទាំងឡាយ

ក៏ចុះមកកាន់ផែនដី កាលបើមិនឃើញផ្កាឈូក ក៏សោយសោក តូចចិត្តថា **អដ្ឋោ វត ភោ លោកោ** ម្នាលគ្នាយើងដ៏ចម្រើន សត្វលោកនឹងងងឹតសាបសូន្យហើយ កាលបើបានឃើញផ្កាឈូក ក៏នាំគ្នាត្រេកអរ នាំនូវត្រៃចីវរទៅកាន់ព្រហ្មលោក។

វីព្រហ្មទាំងឡាយដ៏សេស ក៏ច្យុតមកកើតជាមនុស្ស មានរូបកាយបរិសុទ្ធល្អ ដោយគ្រឿងប្រដាប់ មានអានុភាពហោះទៅក្នុងអាកាសបាន មានរស្មីល្អភ្លឺផ្សាយចេញអំពីកាយ មានសីល ៥ បរិបូណ៌ មិនមានភេទប្រាកដជាស្រី ឬប្រុស មានបីតិជាអាហារ មានអាយុ ១ អសង្ខេយ្យឆ្នាំ។ គ្រាក្រោយមក មានសេចក្ដីប្រាថ្នា នឹងបរិភោគរសផែនដី ក៏ពូតជាពំនូតៗស៊ីជាអាហារ រស្មីក៏អន្តរធានបាត់ទៅ ត្រឡប់ឱ្យកើតជាងងឹត ពពួកមហាជនក៏ស្រែកយំបរិទេវនាការ ខ្សឹកខ្សួល។

គ្រានោះ សុរិយមណ្ឌល មានទទឹង និងបណ្ដោយ ៥០ យោជន៍ មានរស្មីរុងរឿង ដោយអាការៈដ៏ក្ដៅ ផុសឡើងមកអណ្ដែតនៅក្នុងអាកាស មានពន្លឺភ្លឺទូទៅក្នុងចក្រវាល មនុស្សទាំងឡាយឃើញហើយ ក៏រីករាយត្រេកអរ ទើបឱ្យឈ្មោះថា "ព្រះអាទិត្យ" រហូតមកដល់សព្វថ្ងៃនេះ ព្រោះភ្លឺរុងរឿងក្នុង



វេលាថ្ងៃ លុះដល់សម័យថ្ងៃល្ងាច ក៏ងងឹតអន្ធការ ពពួកមហាជនក៏តូចចិត្ត នាំគ្នាទួញយំបរិទេវនាការ។

កាលណោះ មានចន្ទមណ្ឌលប្រកបដោយវិមានប្រាក់ទទឹង និង បណ្ដោយ ៤៩ យោជន៍ កើតឡើង មានរស្មីរុងរឿង ក្នុងវេលាយប់ មនុស្សទាំងឡាយក៏ត្រេកអរ ទើបឱ្យឈ្មោះថា "ព្រះច័ន្ទ"។

កាលបើព្រះអាទិត្យ និងព្រះច័ន្ទកើតឡើងហើយនោះ ក៏បង្កើតឱ្យមានពពួកផ្កាយ ថ្ងៃ យប់ យាម ភ្នំព្រះសុមេរុ៍ មហាសមុទ្រ ជ្រោះជ្រោយ ទន្លេ បឹងត្រពាំង ស្ទឹង ថ្លុក និងព្រែកអូរផ្លូវទឹក ។ល។

ស. ភ្នំព្រះសុមេរុ៍ និងមហាសមុទ្រជាដើមនោះ កើតឡើងដោយអាការៈដូចម្ដេច?

ឆ. ភ្នំព្រះសុមេរុ៍ជាដើម កាលនឹងកើតឡើងនោះ ប្រៀបដូចជាបុគ្គល ដណ្ដាំបាយឱ្យពុះឡើងព្រមគ្នា ក៏បង្កើតជាពពុះខ្ពស់ខ្លះទាបខ្លះ ស្មើគ្នាខ្លះ។

ទីឯណាខ្ពស់ ក៏កើតជាភ្នំ ទីឯណាទាប ក៏កើតជាមហាសមុទ្រ ទន្លេ ស្ទឹង បឹងបួ ទីឯណាស្មើគ្នា ក៏បង្កើតជាទ្វីប។ ឯពពួកតារាផ្កាយនោះ អាចារ្យពួកខ្លះពោលថា កែវកំពូលវិមាននៃ

ទេវតា។

ស. កាលព្រះអាទិត្យ ព្រះច័ន្ទញ៉ាំងលោកឱ្យភ្លឺហើយ តទៅមុខទៀតនោះ មានហេតុដូចម្ដេចខ្លះ?

ឆ. មនុស្សទាំងឡាយនាំគ្នាត្រេកអរ ហើយនាំគ្នាបរិភោគរសផែនដី។ តាំងពីពេលនោះមក រាងកាយ ពណ៌សម្បុរ ទ្រង់ទ្រាយក៏ប្លែកៗគ្នា អាក្រក់ខ្លះ ល្អខ្លះ ហើយកើតមានទិដ្ឋិប្រកាន់ខ្លួនប្រាណផ្សេងៗ គ្រានោះរសផែនដីដែលក្រអូបផ្អែមជាអាហារក៏បាត់ទៅ កើតជារំកាច់ក្រាមដី មនុស្សទាំងឡាយក៏ស៊ីជាអាហារ។ លុះកន្លងយូរទៅ ក៏កើតមានទិដ្ឋិមានះច្រើនឡើង រំកាច់ក្រាមដីក៏បាត់ទៅ វល្លិប្រទាល ក៏កើតឡើង មនុស្សនាំគ្នាបរិភោគវល្លិៗក៏បាត់ទៅ កើតជាស្រូវសាលីសម្បុរស មិនមានអង្កាមកុណ្ឌក មានក្លិនក្រអូប ផ្លែជាអង្ករសរិត មនុស្សទាំងឡាយក៏នាំគ្នាបេះមកចំអិនបរិភោគ បើបេះវេលាព្រឹក លុះពេលល្ងាចក៏កើតឡើងដូចដើម។ សេចក្ដីថា ការចំអិនបាយដោយអង្ករនៃស្រូវសាលីនោះ ងាយណាស់ គឺបេះមក ដាក់ក្នុងភាជន៍ហើយ លើកឡើងតម្កល់លើផែនថ្មសីលា ក៏ឆ្អិនភ្លាម កាលឆ្អិនហើយមនុស្សនឹងបរិភោគមិនចាំបាច់រកម្ហូបមកផ្សំទេ នឹកចង់រសឆ្ងាញ់បែបណា អាហារក៏ឱ្យកើតរសឆ្ងាញ់បែបនោះ កាលបើ



ជនទាំងឡាយបរិភោគអាហារដ៏ជ្រោកជ្រាក ក៏បង្កើតជាមូត្រតូច អាចម៍នោមដ៏លាមកឡើងក្នុងពោះ មានមុខដំបៅជាប្រហោងឱ្យបញ្ចេញនូវមូត្រតូច បើជាតិមុនធ្លាប់កើតជាស្រី ក៏កើតភេទជាស្រី បើជាតិមុនធ្លាប់កើតជាប្រុស ក៏កើតភេទជាប្រុស។

កាលកើតឡើងប្រាកដជាស្រីជាប្រុសហើយ ក៏សំឡឹងមើលនូវគ្នានឹងគ្នាឱ្យកើតសេចក្ដីក្ដៅក្រហាយក្នុងកាមគុណ រាគៈក៏កើតឡើងយ៉ាងក្លាហាន ដរាបដល់សេពមេថុនធម្មជាទីបំផុត។ ពពួកមនុស្សធ្វើផ្ទះមិនបានធ្វើជញ្ជាំងបាំងបិទ ជនឯណាដែលក្រាស់ដោយរាគចរិតក៏សេពមេថុនក្នុងទីវាល មនុស្សដែលមានសេចក្ដីខ្មាសអៀនអន់ ក៏តិះដៀលថា យកដម្រាប់ដូចសត្វតិរច្ឆាន។ អំពីកាលណោះមក ក៏ធ្វើជញ្ជាំងបាំងបិទឱ្យជិត មានទ្វារបង្អួចសម្រាប់ បើកបិទដរាបមក កាលបើមនុស្សទាំងឡាយសង់ផ្ទះឡើងហើយ មនុស្សដែលខ្ជិលច្រអូស ក៏នាំគ្នាសន្សំស្រូវទុកច្រើនៗដោយសេចក្ដីលោភ។ តាំងពីថ្ងៃនោះមក ស្រូវសាលីក៏មានអង្កាមកុណ្ឌក ទៅច្រូតមកម្ដងក៏បាត់ទៅមិនកើតផលឡើងទៀតដូចអំពីមុន។ គ្រានោះ មនុស្សទាំងឡាយក៏បែងចែកខេត្តដែននៃស្រូវសាលីដល់គ្នា និងគ្នាជាចំណែកៗ មនុស្សមាន

ចិត្តជាអកុសលទៅលបលួចស្រូវសាលីរបស់អ្នកដទៃ លុះម្ចាស់របស់គេចាប់បាន ក៏ជេរប្រទេច ២-៣ ដង ហើយលែងទៅ ។

ដល់ពេលក្រោយមក ចាប់បានហើយវាយដំច្រំធាក់ ហើយលែងទៅ ។ កាលអទិន្នាទានកើតឡើងហើយ មុសាវាទ និយាយកុហកបញ្ឆោតនូវគ្នានឹងគ្នា ក៏កើតឡើង គ្រានោះមនុស្សទាំងឡាយ ក៏បាននូវសេចក្ដីក្ដៅក្រហាយច្រើនទើបសន្និបាតប្រជុំគ្នាពោលថា: គ្នាយើងទាំងពួង បានសេចក្ដីក្ដៅក្រហាយដូច្នេះ តើយើងត្រូវធ្វើដូចម្ដេច? កាលបើប្រឹក្សាគ្នាទៅ ក៏យើញព្រមគ្នាថា ព្រះបរមពោធិសត្វ ឋិតនៅក្នុងយុត្តិធម៌ គួរយើងទាំងឡាយលើកឡើងនូវព្រះពោធិសត្វឱ្យជាធំ ជាអ្នកប្រដៅដល់គ្នានឹងគ្នា។ កិរិយានៃព្រះពុទ្ធជាម្ចាស់នៃយើង ក្នុងខាងដើមភទ្ទកប្បនេះ ប្រកបដោយសីល ៥-៨ និងកម្មបថ ១០ ទើបទ្រង់ឱ្យឱវាទ ពាក្យប្រៀនប្រដៅ ដល់មហាជនជាច្រើន ព្រោះហេតុនោះមនុស្សទាំងឡាយ លើកព្រះបរមពោធិសត្វឡើងជាស្ដេចសម្មតិរាជ ឱ្យឋិតនៅក្នុងទីមានយសដ៏ធំ និងបានសង្កត់សង្កិននូវមនុស្សពាល ក៏ថ្វាយនូវអង្ករនៃស្រូវសាលីម្នាក់ៗកន្លះថាំង ។

តាមគម្ពីរធម្មសាសន៍ថា កាលព្រះបរមពោធិសត្វសោយរាជសម្បត្តិជាស្ដេចសម្មតិរាជ មានព្រះរាជឱរស ៤ ព្រះអង្គ។



ឱរសទាំង ៤ នេះ កាលចម្រើនធំឡើង ក៏បានសោយរាជសម្បត្តិក្នុងទ្វីបទាំង ៤ ។ ចំណែកព្រះរាជឱរសនៅក្នុងជម្ពូទ្វីបនេះមានព្រះរាជបុត្រ ១០ ព្រះអង្គ ទើបបែងជម្ពូទ្វីបនេះទៅជា ១១ ចំណែកឱ្យដល់ព្រះរាជឱរសមួយចំណែកៗមួយអង្គ លុះយូរមកព្រះរាជបុត្រទាំង ១០ នោះ មួយអង្គៗមានព្រះរាជបុត្រ ១០ ទៅទៀត ហើយក៏បែងជម្ពូទ្វីបជា ១០១ ចំណែក ចែកឱ្យមួយអង្គៗមួយចំណែក លុះយូរមកមានរូបរាងកាយ ភាសានិយាយក៏ផ្សេងៗទាំង ១០១ នោះមកដរាបដល់សព្វថ្ងៃនេះ ។

គ្រានោះមានមហាព្រហ្ម ១ អង្គ ឈ្មោះថា ព្រហ្មទេវ ច្យុតចុះមកកើតក្នុងត្រកូលអាមាត្រនៃស្ដេចសម្មតិរាជ លុះបានអាយុ ១៥ ឆ្នាំ ក៏បានទទួលរាជការជួសបិតា លុះយូរមក ឃើញជនទាំងឡាយ កើតវិវាទទាស់ទែងគ្នាជាច្រើន មានសេចក្ដីប្រាថ្នានឹងទំនុកបម្រុងដល់ក្សត្រនិងមហាជន ទើបទូលលាចេញបួសជាឫសីនៅក្នុងព្រៃហិមពាន្ត បានសម្រេចឈានអភិញ្ញាហោះទៅក្នុងអាកាសបាន លុះយូរមក ក៏មានសេចក្ដីស្រឡាញ់នាងកិន្នរីជាភរិយានៃវិជ្ជាធរ បានរួមអភិរម្យសមរស ស្មោះសរតាមប្រពៃណី ក៏ប្រសូត្របុត្រ ១ អង្គ នាម ភទ្ទកុមារ បុត្រទី ២ នាម មនោសារបយោរស ព្រហ្មទេវតាបសក៏ចិញ្ចឹមទុក។ លុះ

ភទ្ទកុមារធំឡើងក៏បួសជាឫសីបាន ឈានលោកីយ៍ហោះទៅកាន់ភ្នំចក្កវាឡ រៀនចេះចប់អស់ត្រៃវេទ អាគមមន្តវិជ្ជាទាំងពួងហើយ ត្រឡប់មកនាំមនោសារជាប្អូនទៅកាន់សំណាក់សម្មតិរាជ ថាយកគម្ពីរត្រៃវេទជាដើម ហើយក៏សឹកចេញមកធ្វើការរាជការ នឹងមនោសារជាប្អូន ស្តេចសម្មតិរាជទ្រង់តាំងមនោសារ ជាអ្នកពិភាក្សាសេចក្តីប្តឹងផ្តល់នៃពលរដ្ឋ មនោសារក៏កាត់សេចក្តីដោយយុត្តិធម៌។

គួរឱ្យកត់សម្គាល់ផងដែរថា មនោសារនេះហើយជាអ្នកនាំមក តាំងទុកជាគម្ពីរធម្មសាសន៍ សម្រាប់ពិភាក្សាកាត់សេចក្តីនិងការលក់ពិន័យ ក្នុងដំណើរគតិរបស់តុលាការ និងបទព្រះអយ្យកា សម្រាប់ក្សត្រដែលបានសោយរាជសម្បត្តិ។ មនោសារចាត់ចែងគម្ពីរធម្មសាសន៍នេះរួចហើយ ក៏នាំទៅថ្វាយសម្តេចព្រះសម្មតិរាជៗ ក៏លើកនូវគម្ពីរធម្មសាសន៍ និងបទអយ្យកាឡើងជាច្បាប់ សម្រាប់តុលាការ រហូតដល់សព្វថ្ងៃនេះ។[៦១]

# លក្ខណៈសំខាន់ ៤ យ៉ាង ក្នុងការយល់អំពីព្រះនិព្វាន

*ដោយភិក្ខុ* **ឈុំ ឆន** ( អនុបណ្ឌិតឆ្នាំបញ្ចប់)

និព្វានជាទុក្ខនិរោធ, និព្វានជាសច្ចៈឃើញដោយកម្រ ។ ការសម្ដែងអំពីព្រះនិព្វាន សរុបមកមាន ៤ បែប ÷

១- បែបបដិសេធ គឺមានន័យបញ្ជាក់ដល់ការលះ ការកម្ចាត់ ការដកចោលនូវភារៈដែលមិនល្អ និងមិនជាប្រយោជន៍ផ្សេងៗ ដែលជាចំណែកនៃវដ្ដៈ ដូចជា

ក្នុងបិដកលេខ ៣៦ ទំព័រ ១០៨ ព្រះសារីបុត្តឆ្លើយតបនិព្វានបញ្ហាចំពោះ ជម្ពុខាទកបរិព្វាជក ថា "យោ ខោ អាវុសោ រាគក្ខយោ ទោសក្ខយោ មោហក្ខយោ ឥទំ វុច្ចតិ និព្វានន្តិ" ។ ម្នាលអាវុសោ ការអស់រាគៈ ការអស់ទោសៈ ការអស់មោហៈ នេះហៅថា និព្វាន ។

ក្នុងបិដកលេខ ៣១ ទំព័រ ២៥៩ ព្រះមុសិលដ៏មានអាយុបានឆ្លើយតបបញ្ហារបស់ព្រះបវិដ្ឋដ៏មានអាយុថា ÷

ម្នាលអាវុសោបវិដ្ឋ វៀរចាកការជឿ វៀរចាកការពេញចិត្ត



វៀរចាកការស្ដាប់ឮតៗគ្នា វៀរចាកការត្រិះរិះដោយអាការៈ វៀរ-ចាកការយល់ឃើញ តាមការខិតខំពិនិត្យ ខ្ញុំព្រះករុណាក៏ដឹងយ៉ាងនោះ ឃើញយ៉ាងនោះថា "ភវនិរោធោ និព្វានន្តិ" ការរលត់ភពជា ព្រះនិព្វាន ។

ក្នុងបិដកលេខ ៣៤ ទំព័រ ៧៥ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលរាធៈ អ្នកទាំងឡាយចូរកម្ចាយចោល ឈូសចោលនូវរូប ចូរធ្វើឱ្យជារបស់លេងមិនកើត ចូរប្រតិបត្តិដើម្បីអស់ទៅនៃតណ្ហា ។

ចូរកម្ចាយចោល ឈូសចោល កម្ចាត់ចោលនូវវេទនា ។ល។ នូវសញ្ញា ។ល។ នូវសង្ខារទាំងឡាយ ។

ចូរកម្ចាយចោល ឈូសចោលនូវវិញ្ញាណ ចូរធ្វើឱ្យជារបស់លេងមិនកើត ចូរប្រតិបត្តិដើម្បីអស់ទៅនៃតណ្ហាយ៉ាងនោះឯង ។

**តណ្ហាក្ខយោ ហិ រាធ និព្វានន្តិ** ម្នាលរាធៈ ព្រោះថាការអស់ទៅនៃតណ្ហាឈ្មោះថា ព្រះនិព្វាន ។

ក្នុងបិដកលេខ ៣៥ ទំព័រ ៩៣ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់សម្ដែងថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាមួយមិនដឹងច្បាស់តាមពិតនូវការកើត ការរលត់ អានិសង្ស ទោស និង ការរលាស់ចេញនូវផស្សាយតនៈទាំង ៦ ទេ ភិក្ខុនោះឈ្មោះថា មិនបានប្រព្រឹត្តព្រហ្ម-ចរិយៈទេ ភិក្ខុនោះឈ្មោះថា ឆ្ងាយអំពីធម្មវិន័យនេះ ។

កាលបើព្រះមានព្រះភាគត្រាស់យ៉ាងនេះហើយ ភិក្ខុមួយរូបក៏ក្រាបទូលសួរព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គវិនាសចាកធម៌វិន័យនេះហើយ បពិត្រព្រះអង្គដ៏ចម្រើន ព្រោះខ្ញុំព្រះអង្គមិនទាន់ដឹងច្បាស់តាមពិតនូវការកើត ការរលត់អានិសង្ស ទោស និងការរលាស់ចេញនូវផស្សាយតនៈទាំង ៦ ឡើយ ។

ម្នាលភិក្ខុ អ្នកសម្គាល់នូវសេចក្តីនោះដូចម្តេច អ្នកពិចារណាឃើញនូវចក្ខុថា នោះជារបស់អញ នោះជាអញ នោះជាខ្លួនរបស់អញ ដូច្នេះឬ ។

ភិក្ខុ- មិនមែនឃើញដូច្នេះទេ ព្រះអង្គ ។

ព្រះពុទ្ធ- ម្នាលភិក្ខុប្រពៃហើយ ម្នាលភិក្ខុក្នុងរឿងនេះ អ្នកនឹងបានឃើញនូវចក្ខុនោះដោយបញ្ញាដ៏ប្រពៃតាមពិតយ៉ាងនេះថា នោះមិនមែនជារបស់អញ នោះមិនមែនជាអញ នោះមិនមែនជាខ្លួនរបស់អញឡើយ ឯសេវន្តោ ទុក្ខស្ស នោះឯងជាទីបំផុតនៃទុក្ខ ។

មានពាក្យហៅព្រះនិព្វានផុយគ្នាអំពីវដ្តៈដោយចំតែម្តង ដូចជាមានក្នុងព្រះសូត្រខាងក្រោមនេះជាដើម ។

ក្នុងបិដកលេខ ២១ ទំព័រ ១២៩ នៅក្នុងបាសរាសិសូត្រ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់សម្តែងថា ម្នាលភិក្ខុទាំងឡាយ ការស្វែងរកនេះមានពីរប្រការ គឺ ÷ ការស្វែងរកមិនប្រសើរ១ និងការស្វែងរក



ដ៏ប្រសើរ១ ។

ការស្វែងរកមិនប្រសើរ តើដូចម្តេច?

ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកមួយក្នុងលោកនេះ ខ្លួនឯងមានជាតិជាធម្មតាហើយ នៅស្វែងរករបស់ដែលមានជាតិជាធម្មតាថែមទៀត ។

ជរាជាធម្មតា ព្យាធិជាធម្មតា មរណៈជាធម្មតា ។ សេចក្តីសោកជាធម្មតា ។ សេចក្តីសៅហ្មងជាធម្មតា ។ ជរាធម៌ជាដើម ព្រះដ៏មានព្រះភាគទ្រង់ត្រាស់សម្តែងដូចជាតិធម៌ដែរ ។

ម្នាលភិក្ខុទាំងឡាយ នេះហៅថា ការស្វែងរកមិនប្រសើរ ។

ក្នុងទំព័រ ១៣២ ព្រះអង្គទ្រង់ត្រាស់សម្តែងថា ម្នាលភិក្ខុទាំង-ឡាយ ឯការស្វែងរកដ៏ប្រសើរ តើដូចម្តេច? ម្នាលភិក្ខុទាំងឡាយ ភិក្ខុពួកមួយក្នុងលោកនេះ ខ្លួនឯងមានជាតិជាធម្មតា ដឹងច្បាស់នូវទោសក្នុងជាតិធម៌ ហើយស្វែងរកនូវព្រះនិព្វានដែលមិនមានជាតិមិនមានធម៌ដទៃស្មើ ជាទីក្សេមចាកយោគៈ ។

ម្នាលភិក្ខុទាំងឡាយ នេះហៅថា ការស្វែងរកដ៏ប្រសើរ ។

ក្នុងបិដកលេខ ៣៦ ទំព័រ ៣៤៩ អសង្ខតវគ្គ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់សម្តែងព្រះនិព្វានថា ជាអសង្ខតធម៌ រួចហើយព្រះអង្គទ្រង់សម្តែងអំពីផ្លូវទៅកាន់អសង្ខតធម៌ (អសង្ខតគាមិមគ្គ) មាន

កាយគតាសតិ រហូតដល់ពោធិបក្ខិយធម៌ទាំង ៧ ពួក។

នៅក្នុងអសង្ខតវគ្គនេះ ព្រះអង្គទ្រង់សម្តែងឈ្មោះនិព្វានមានច្រើន គឺ ÷

១- អនតធម៌ - ធម៌មិនបង្អោនទៅ មិនត្រេកអរដោយកិលេសតណ្ហា។

២- អនាសវធម៌ - ធម៌មិនមានអាសវៈ ៤។

៣- សច្ចធម៌ - ធម៌ពិតដោយបរមត្ថសច្ចៈ។

៤- ចារធម៌ -ធម៌ដែលជាត្រើយនៃវដ្ដៈ។

៥- និបុណធម៌ - ធម៌ដ៏ល្អិតសុខុម។

៦- សុទុទ្ទសធម៌ - ធម៌ដែលសត្វឃើញដោយកម្រពេក។

៧- អជជ្ជរធម៌ - ធម៌ដែលមិនមានការចាស់គ្រាំគ្រា។

៨- ធុវធម៌ - ធម៌ដ៏ទៀងទាត់មាំទាំ។

៩- អបលោកិនធម៌ - ធម៌ដែលមិនមានសេចក្ដីវិនាសបែកធ្លាយ។

១០- អនិទស្សនធម៌ - ធម៌ដែលមើលមិនឃើញដោយចក្ខុវិញ្ញាណ។

១១- និប្បបញ្ចធម៌ - ធម៌ដែលមិនមានកិលេសជាគ្រឿងយឺតយូរ។



១២- សន្តធម៌ - ធម៌ស្ងប់។

១៣- អមតធម៌ - ធម៌ដែលមិនស្លាប់។

១៤- បណីតធម៌ - ធម៌ដ៏ប្រណីតថ្លៃថ្លា។

១៥- សិវធម៌ - ធម៌ដែលត្រជាក់ជាសុខសម្រាន្ត។

១៦- ខេមធម៌ - ធម៌ដ៏ក្សេមក្សាន្តប្រាសចាកនូវអន្តរាយ។

១៧- តណ្ហាក្ខយធម៌ - ធម៌ជាទីក្ស័យទៅនៃតណ្ហា។

១៨- អច្ឆរិយធម៌ - ធម៌ជាទីអស្ចារ្យ។

១៩- អព្ភូតធម៌ - ធម៌ដែលមិនធ្លាប់មាន មិនធ្លាប់ប្រាកដ ជាធម៌ចម្លែក។

២០- អនីតិកធម៌ - ធម៌ដែលមិនមានសេចក្ដីអន្តរាយ។

២១- និព្វានធម៌ - ធម៌មិនមានតណ្ហាជាគ្រឿងចាក់ស្រែះ។

២២- អព្យាបជ្ឈធម៌ - ធម៌មិនមានការបៀតបៀន។

២៣- វិរាគធម៌ - ធម៌ប្រាសចាកតម្រេក។

២៤- សុទ្ធិធម៌ - ធម៌ដ៏បរិសុទ្ធ។

២៥- មុត្តិធម៌ - ធម៌ជាទីផុតចាកកិលេស និងផុតចាកពីភពទាំង៣។

២៦- អនាលយធម៌ - ធម៌មិនមានអាល័យ ។

២៧- ទីបធម៌ - ធម៌ជាទីពឹង ។

២៨- លេណធម៌ - ធម៌ជាទីពួន ។

២៩- តាណធម៌ - ធម៌ជាទីដែលអាចការពារបាន ។

៣០- សរណធម៌ - ធម៌ជាទីរលឹក ។

៣១- បរាយនធម៌ - ធម៌ដែលជាទីទៅ ជាទីពឹងខាងមុខ ។

២. បែបឧបមា ពាក្យឧបមាច្រើនប្រើក្នុងការបរិយាយលក្ខណៈនៃបុគ្គលដែលបានសម្រេចនូវព្រះនិព្វាន គឺច្រើនជាងប្រើនៅក្នុងលក្ខណៈព្រះនិព្វានដោយត្រង់ ដូចជា៖

- ប្រៀបព្រះអរហន្តដូចគោនាំមុខហ្វូងគោ ហែលកាត់ក្រសែរទឹកឆ្លងដល់ត្រើយ (នៅក្នុងបិដកលេខ ២២ ចូលគោលសូត្រ) ។

- ដូចមនុស្សឆ្លងមហាសមុទ្រ ឬអន្លង់ទឹកធំដែលមានអន្តរាយច្រើន បានដល់ច្រាំងហើយ ឡើងឈរលើគោក (ក្នុងបិដកលេខ ៣៥ សមុទ្ទសូត្រ ព្រះអង្គសម្ដែងអំពីឆ្លងសមុទ្រ ចំណែកអាសីវិសសូត្រ ព្រះអង្គទ្រង់សម្ដែងអំពីឆ្លងអន្លង់ទឹកធំ) ។

- នឹងថា ទៅកើតទីណា ឬថា មិនកើតទេជាដើម សុទ្ធតែមិនត្រូវទាំងអស់ ដូចភ្លើងរលត់ទៅ នៅពេលដែលត្រូវរលត់ (បិដក



លេខ ៣៦ អានន្ទសូត្រ, បិដកលេខ ២៤ អគ្គិវច្ឆគោត្តសូត្រ) ។

- យ៉ាងណាក៏ដោយ ពាក្យឧបមាអំពីព្រះនិព្វាន ដោយត្រង់ក៏មានដែរ ដូចជា និព្វានប្រៀបដូចភូមិភាគដ៏រាបស្មើ គួរឱ្យរីករាយ (បិដកលេខ ៣៣ ទំព័រ ២៤៤ តិស្សសូត្រ) ។

- និព្វាន ដូចត្រើយនាយ មិនមានភ័យ (អាសីវិសបមសូត្រ ក្នុងបិដកលេខ ៣៥ ទំព័រ ៣៩៤) ។

- មានពាក្យហៅតាមបែបប្រៀបធៀបច្រើនទៀត ដូចជា អារោគ្យ (ការមិនមានរោគ) ទីប (កោះ, ទីដែលផុតភ័យ) លេន (គុហា, ទីសម្រាប់ពួន, ទីកំបាំងពីភ័យ) ជាដើម ។

៣. បែបបរិយាយលក្ខណៈដោយត្រង់ បែបនេះមានតិចកន្លែងទេ ក្នុងព្រះត្រៃបិដកនោះ ប៉ុន្តែ ជាទីចូលចិត្តនៃអ្នកសិក្សា អ្នកស្រាវជ្រាវដោយចំពោះអ្នកកាន់យកធម៌ព្រះពុទ្ធពិតៗ ជាអ្នកមានបញ្ញា ។ នឹងលើកយកមកប្រកបការសិក្សាពិចារណាដូចតទៅ៖

- ក្នុងបិដកលេខ ៥២ ទំព័រ ៣២០ ក្នុងវត្តជេតពន សម័យនោះឯងព្រះដ៏មានព្រះភាគទ្រង់ពន្យល់ភិក្ខុទាំងឡាយ ឱ្យយល់ច្បាស់ ឱ្យកាន់យក ឱ្យអាចហ៊ាន ឱ្យរីករាយ ដោយធម្មីកថា ប្រកបដោយព្រះនិព្វាន ។ ពួកភិក្ខុទាំងនោះបានធ្វើឱ្យជាប្រយោជន៍ ធ្វើទុកក្នុងចិត្ត

ប្រមូលមកនូវធម្មទេសនាទាំងអស់ ដោយចិត្តផ្ចង់ត្រចៀកស្តាប់ធម៌។

លំដាប់នោះព្រះដ៏មានព្រះភាគ ទ្រង់ជ្រាបច្បាស់នូវសេចក្តីនោះហើយ ទើបទ្រង់បន្លឺនូវឧទានក្នុងវេលានោះថា អត្ថិ ភិក្ខវេ តទាយតនំ យត្ថ នេវ បឋវី ន អាបោ ន តេជោ ន វាយោ ន អាកាសានញ្ចាយតនំ ន វិញ្ញាណញ្ចាយតនំ ន អាកិញ្ចញ្ញាយតនំ ន នេវសញ្ញានាសញ្ញាយតនំ នាយំ លោកោ ន បរលោកោ ន ឧភោ ចន្ទិម សុរិយា តមហំ ភិក្ខវេ នេវ អាគតឹ វទាមិ ន គតឹ ន ឋិតឹ ន ចុតឹ ន ឧបបត្តឹ អប្បតិដ្ឋំ អប្បវត្តំ អនារម្មណមេវ តំ ឯសេវន្តោ ទុក្ខស្សាតិ។

ម្នាលភិក្ខុទាំងឡាយ អាយតនៈនោះមានពិត (អាយតនៈនោះ) មិនមានបឋវី មិនមានអាបោ មិនមានតេជោ មិនមានវាយោ មិនមានអាកាសានញ្ចាយតនៈ មិនមានវិញ្ញាណញ្ចាយតនៈ មិនមានអាកិញ្ចញ្ញាយតនៈ មិនមាននេវសញ្ញានាសញ្ញាយតនៈ មិនមានលោកនេះ មិនមានបរលោក មិនមានដួងច័ន្ទ និងដួងអាទិត្យទាំងពីរ ។ល។

តថាគតពោលនូវ អាយតនៈនោះថា មិនមានការមក មិនមានការទៅ មិនមានការឈប់នៅ មិនមានចុតិ មិនមានឧបបត្តិ



អាយតនៈនោះ មិនមានទីតាំងនៅ មិនមានប្រព្រឹត្តទៅ ទាំងមិនមាននូវគ្រឿងតោង គឺអារម្មណ៍នោះឯងជាទីបំផុតនៃទុក្ខ។

ក្នុងបិដកលេខ ៥២ ដដែល ទំព័រ ៣២១ ព្រះអង្គទ្រង់សម្តែងនូវធម្មីកថា ទាក់ទងនឹងព្រះនិព្វាន ដល់ភិក្ខុទាំងឡាយដូចខាងដើមដែរ ហើយព្រះអង្គទ្រង់បន្លឺនូវឧទានជាគាថា ថា ទុទ្ទសំ អនត្តំ នាម ន ហិ សច្ចំ សុទស្សនំ បដិវិទ្ធា តណ្ហា ជានតោ បស្សតោ នត្ថិ កិញ្ចនន្តិ។ ធម្មតាអនតំ (ការមិនបង្អោនទៅរកភពគឺមិនមានតណ្ហា បានដល់ព្រះនិព្វាន បុគ្គលឃើញបានដោយកម្រ និព្វានសច្ចៈ មិនមែនសម្រាប់ឃើញបានដោយងាយឡើយ តណ្ហាដែលបុគ្គលបានត្រាស់ដឹងហើយ កិលេសជាគ្រឿងកង្វល់ រមែងមិនមានដល់អ្នកដឹង អ្នកឃើញ (នូវសច្ចៈនោះ)។

ព្រះពុទ្ធឧទានបន្តមកទៀតគឺៈ អត្ថិ ភិក្ខវេ អជាតំ អភូតំ អកតំ អសង្ខតំ នោ ចេ តំ ភិក្ខវេ អភវិស្ស អជាតំ អភូតំ អកតំ អសង្ខតំ ន យិធ ជាតស្ស ភូតស្ស កតស្ស សង្ខតស្ស និស្សរណំ បញ្ញាយេថ។ យស្មា ច ខោ ភិក្ខវេ អត្ថិ អជាតំ អភូតំ អកតំ អសង្ខតំ តស្មា ជាតស្ស ភូតស្ស កតស្ស សង្ខតស្ស និស្សរណំ បញ្ញាយតីតិ។

ម្នាលភិក្ខុទាំងឡាយ ព្រះនិព្វានឈ្មោះថា អជាតៈ (មិនកើត),

*អភូតៈ* (មិនប្រាកដ), *អកតៈ* (មិនធ្វើ), *អសង្ខតៈ* (មិនមានការតាក់តែង) រមែងមានដោយពិត ម្នាលភិក្ខុទាំងឡាយ ប្រសិនណាបើ ព្រះនិព្វាននោះ ឈ្មោះថា *អជាតៈ អភូតៈ អកតៈ អសង្ខតៈ* មិនមានទេ ការរលាស់ចេញនូវកិលេសដែលនាំឱ្យកើត នាំឱ្យប្រាកដ នាំឱ្យធ្វើ នាំឱ្យតាក់តែង ក៏មិនគប្បីមាននោះឡើយ ប៉ុន្តែ ព្រោះការមិនកើត ការមិនប្រាកដ ការមិនធ្វើ ការមិនតាក់តែងនោះមាន ដូច្នោះ ទើបការរួចផុតពីការកើត ការប្រាកដ ការធ្វើ ការតាក់តែងមានទៅ បានជាពិតប្រាកដមែន។

បិដកលេខ ១៥ ទំព័រ ២២០ នៅក្នុងកេវដ្ដសូត្រ ព្រះអង្គទ្រង់ត្រាស់សម្ដែងថា *វិញ្ញាណំ អនិទស្សនំ អនន្តំ សព្វតោ បភំ ឯត្ថ អាបោ ច បឋវី ច តេជោ វាយោ ន គាធតិ ឯត្ថ ទីឃញ្ច រស្សញ្ច អណុំ ថូលំ សុភាសុភំ ឯត្ថ នាមញ្ច រូបញ្ច អសេសំ ឧបរុជ្ឈតិ វិញ្ញាណស្ស និរោធេន ឯត្ថេតំ ឧបរុជ្ឈតីតិ*។

និព្វានដែលគប្បីដឹងច្បាស់ មិនមែនជារូប ដែលសម្រាប់ឃើញដោយចក្ខុឡើយ មិនមានទីបំផុត ភ្លឺស្វាងដោយប្រការទាំងពួង (ឬចូលទៅបានដោយកម្មដ្ឋានទាំងពួង)*បឋវី អាបោ តេជោ វាយោ* រមែងតាំងនៅមិនបានក្នុងព្រះនិព្វាននោះ។



ឧបាទាយរូប វែងខ្លីក្ដី ធំតូចក្ដី ស្អាតមិនស្អាតក្ដី រមែងតាំងនៅមិនបានក្នុងព្រះនិព្វាននោះ។

នាម និងរូបរមែងរលត់អស់ទៅ មិនមានសេសសល់នៅក្នុងព្រះនិព្វាននោះ នាម និងរូបនេះតែងរលត់ក្នុងព្រះនិព្វាននោះ ព្រោះរលត់ទៅនៃវិញ្ញាណ។

៤. *បែបវេវចនសព្ទ* គឺហៅទៅដោយគុណរបស់ព្រះនិព្វានដោយឈ្មោះផ្សេងៗ ដើម្បីសម្ដែងដល់គុណលក្ខណៈនៃព្រះនិព្វាននោះ ដូចពាក្យថា *សន្តំ* (ស្ងប់) *បណីតំ* (ប្រណីត, ឧត្តម) *ខេមំ* (ក្សេមក្សាន្ត) *អមតំ* (មិនស្លាប់) *សុទ្ធិ* (បរិសុទ្ធ) ។ល។

## ភាពនៃបុគ្គលដែលបានសម្រេចព្រះនិព្វាន

ភាពនៃបុគ្គលដែលបានសម្រេចនូវព្រះនិព្វាន អាចពុទ្ធបរិស័ទសិក្សាបានអំពីឈ្មោះដែលហៅ និងពាក្យដែលសម្ដែងនូវគុណលក្ខណៈរបស់អ្នកដែលបានសម្រេចព្រះនិព្វាននោះឯង ដូចជា *ព្រះអរហន្ត* (បុគ្គលគួរ ឬបុគ្គលឆ្ងាយចាកកិលេស), *ព្រះខីណាស្រព* (បុគ្គលអស់អាសវៈហើយ), *ព្រះអសេក្ខៈ* (បុគ្គលចប់ការសិក្សាហើយ ឬមិនត្រូវសិក្សា ឬបុគ្គល ប្រកបដោយអសេក្ខធម៌) *បរិក្ខីណភវសំយោជន* (បុគ្គលអស់ សំយោជនៈ

ដែលជាគ្រឿងចងក្នុងភព) **វុសិតព្រហ្មចរិយៈ** (បុគ្គលបានសម្រេចចប់សព្វគ្រប់នូវព្រហ្មចរិយ គឺអរិយមគ្គ ៨ ហើយ) **កតករណីយ** (បុគ្គលដែលត្រូវធ្វើស្រេចហើយ)។

សមណៈពិត (អ្នកស្ងប់រម្ងាប់នូវលោភៈ ទោសៈ មោហៈ អកុសល អំពីចិត្ត), ព្រាហ្មណ៍ពិត (អ្នកដែលបានបន្សាត់បង់នូវទាំងបុណ្យ ទាំងបាប), អរិយពិត (អ្នកដ៏ប្រសើរបំផុត ឬអ្នកឆ្ងាយអំពីសត្រូវ), វេទគូពិត (អ្នកចាក់ធ្លុះនូវអរិយសច្ចធម៌ ដោយមគ្គទាំង ៤)។

ការសិក្សាតាមឈ្មោះនៃបុគ្គល ដែលបានសម្រេចព្រះនិព្វាន ត្រូវពិចារណាភាវៈនៃបុគ្គលទាក់ទងទៅនឹងគោលធម៌ ដែលបានពោលហើយ ដូចជា អាសវៈ ៤, សិក្ខា ៣, អសេក្ខធម៌ ១០, សំយោជនៈ ១០, ព្រហ្មចរិយៈ គឺមគ្គមានអង្គ ៨ ជាដើម។

ជាបន្តទៅទៀតនេះ ជាការសិក្សាអំពីភាវៈ ៣ យ៉ាង គឺ៖ ភាវៈនៃបញ្ញា ១, ភាវៈនៃចិត្ត ១, និង ភាវៈនៃការប្រព្រឹត្តិក្នុងដំណើរជីវិត ១។

១. ភាវៈនៃបញ្ញា

លក្ខណៈសំខាន់ ដែលជាភូមិឋាននៃបញ្ញារបស់អ្នកបានសម្រេចព្រះនិព្វាន គឺការមើលឃើញរបស់ទាំងឡាយតាមដែលវាប្រព្រឹត្តទៅ



ឬឃើញតាមសេចក្ដីពិត មានឆឡង្គុបេក្ខា (ឧបេក្ខាប្រកបដោយ អង្គ ៦)។

បិដកលេខ ៣១ ទំព័រ ១៤១ ទុតិយអវិជ្ជាបច្ចយសូត្រ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សេចក្ដីចម្រូងចម្រាស់ សេចក្ដីប្រកាន់ ទទឹងទទែង សេចក្ដីប្រកាន់ឆ្វេងឆ្វាណានីមួយរបស់បុគ្គលនោះថា សង្ខារទាំងឡាយ ដូចម្ដេច មួយទៀតសង្ខារទាំងនេះ ជារបស់អ្នកណា ដូច្នេះក្ដី ថា សង្ខារទាំងឡាយដ៏ទៃ មួយទៀតសង្ខារទាំងនេះ ជារបស់បុគ្គលដទៃ ដូច្នេះក្ដី ថា ជីវិតនោះ គឺសរីរៈនោះ ដូច្នេះក្ដី ថាជីវិតដទៃ សរីរៈដទៃ ដូច្នេះក្ដី ធម្មជាតិទាំងអស់នោះ បុគ្គលនោះបានលះបង់ហើយ បានគាស់រំលើងឫសគល់អស់ហើយ បានធ្វើឱ្យនៅសល់តែទីនៅ ដូចជាទីនៅនៃដើមត្នោត ជាធម្មជាតិដល់នូវការមិនមានមែក មានភាពមិនកើតឡើងតទៅ ព្រោះការវិនាស និងការរលត់អស់ មិនមានសេសសល់នូវអវិជ្ជា។

បិដកលេខ ៤៧ ទំព័រ ១២៥

គ្រានោះ ភិក្ខុ ១ រូប បានចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយគង់អង្គុយក្នុងទីដ៏សមគួរ។ លុះភិក្ខុនោះ គង់អង្គុយក្នុងទីដ៏សមគួរហើយ បានក្រាបទូលសួរព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រដ៏ចម្រើន អ្វីជា

ហេតុ អ្វីជាបច្ច័យ ដែលនាំឱ្យវិចិកិច្ឆារបស់ព្រះអរិយសាវ័ក អ្នកមានសេចក្តីចេះដឹង មិនកើតឡើង ក្នុងអព្យាកតវត្ថុទាំងឡាយ ។

ព្រះដ៏មានព្រះភាគទ្រង់ត្រាស់តបថា ម្នាលភិក្ខុ វិចិកិច្ឆារបស់អរិយសាវ័ក អ្នកមានសេចក្តីចេះដឹង រមែងមិនកើតឡើង ក្នុងអព្យាកតវត្ថុទាំងឡាយ ព្រោះរលត់ទិដ្ឋិ។ (អព្យាកតវត្ថុ = សត្វស្លាប់ទៅ កើតទៀត សត្វស្លាប់ទៅ មិនកើតទៀត សត្វស្លាប់ទៅ កើតទៀតខ្លះ មិនកើតទៀតខ្លះ សត្វស្លាប់ទៅ កើតទៀតក៏មិនមែន មិនកើតទៀត ក៏មិនមែន) ។

ម្នាលភិក្ខុ បុថុជ្ជន អ្នកមិនចេះដឹង រមែងមិនដឹងច្បាស់នូវទិដ្ឋិ មិនដឹងច្បាស់នូវហេតុជាទីកើតឡើងនៃទិដ្ឋិ មិនដឹងច្បាស់នូវសេចក្តីរលត់ទៅនៃទិដ្ឋិ ទិដ្ឋិនោះ រមែងចម្រើនដល់បុថុជ្ជននោះ ៗមិនរួចចាកជាតិ ជរា មរណៈ សេចក្តីសោក សេចក្តីខ្សឹកខ្សួល ទុក្ខទោមនស្ស និងសេចក្តីចង្អៀតចង្អល់ឡើយ តថាគត ហៅថា រមែងមិនរួចចាកវដ្តទុក្ខ ។

បិដកលេខ ៣៣ ទំព័រ ៩៤ អនុធម្មសូត្រ ក្នុងក្រុងសាវត្ថី ក្នុងទីនោះឯង ព្រះដ៏មានព្រះភាគ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកប្រតិបត្តិធម៌ដ៏សមគួរតាមធម៌រមែងមាននូវអនុធម៌ (ធម៌ដ៏សមគួរ ឬធម៌អនុលោមតាមសេចក្តីពិត) នេះ គឺជាអ្នកពិចារណាឃើញអនត្តាក្នុងរូប ។ ក្នុងវេទនា ។ ក្នុងសញ្ញា ។ ក្នុងសង្ខារ ។ ជាអ្នកពិចារណាឃើញអនត្តាក្នុងវិញ្ញាណ ។



កាលបើភិក្ខុនោះ ពិចារណាឃើញអនត្តាក្នុងរូប វេទនា សញ្ញា សង្ខារ និងវិញ្ញាណ រមែងកំណត់ដឹងច្បាស់នូវ រូប វេទនា សញ្ញា សង្ខារ និងវិញ្ញាណ ។ កាលបើភិក្ខុនោះកំណត់ដឹងច្បាស់នូវ រូប វេទនា សញ្ញា សង្ខារ និងវិញ្ញាណ រមែងរួចស្រលះចាក រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ រួចស្រលះចាក ជាតិ ជរា មរណៈ សេចក្តី សោក សេចក្តីខ្សឹកខ្សួល សេចក្តីទុក្ខទោមនស្ស និងសេចក្តីចង្អៀត-ចង្អល់ចិត្ត តថាគតពោលថា បុគ្គលនោះរួចស្រលះចាកវដ្តទុក្ខ ។

## ២- ភាវៈនៃចិត្ត

ភាវៈនៃចិត្តដែលសំខាន់ គឺចិត្តរួចផុត ។ ភាវៈនេះ ជាផលដែលសម្រេចមកអំពីបញ្ញា គឺកាលបើបញ្ញាឃើញតាមសេចក្តីពិត ដឹងច្បាស់នូវសង្ខារនូវសង្ខារហើយ ចិត្តទើបរួចផុតអំពីអំណាចនៃការគ្របសង្កត់របស់កិលេស ។

ក្នុងបិដកលេខ ១៦ ទំព័រ ២៦០

ព្រះអង្គទ្រង់ត្រាស់ថា "*បញ្ញាបរិភាវិតំ ចិត្តំ សម្មទេវ អាសវេហិ វិមុច្ចតិ*" ចិត្តដែលអប់រំដោយបញ្ញាហើយ រមែងរួចស្រលះ

ដោយប្រពៃចាកអាសវៈទាំងឡាយ។

លក្ខណៈមួយផ្នែកទៀតនៃភាពជាឥស្សរៈរបស់ចិត្ត គឺការមិនធ្លាក់ចុះជាទាសៈរបស់អារម្មណ៍ ដែលអារម្មណ៍ជាទីតាំងនៃរាគៈ, ទោសៈ, មោហៈ នេះព្រោះមកអំពីចិត្តប្រាសចាកនូវរាគៈ ទោសៈ មោហៈ ហ្នឹងឯង។ ក្រៃលែងជាងនោះទៅទៀត គឺជាផលដែលសម្រេចបានមកអំពីការប្រាសចាករាគៈ ទោសៈ មោហៈ បានដល់ការដែលមិនភ័យខ្លាចតក់ស្លុត មិនញាប់ញ័រ។

ចិត្តដែលជាឥស្សរៈមានការរួចផុតស្រលះ រមែងមិនជាប់ក្នុងវត្ថុផ្សេងៗ ប្រៀបដូចជាស្លឹកឈូក ដែលមិនប្រឡាក់ផ្សើមដោយទឹក ឬផ្កាឈូកដែលកើតក្នុងទឹកភក់ ទឹកព្រាំ (ទឹកដូចប្រេងអណ្ដែតត្រា) តែស្អាតបរិសុទ្ធ មិនប្រឡាក់ទឹកភក់នោះៗ គឺមានការចាប់ផ្ដើមដោយមិនជាប់ក្នុងកាម រហូតដល់មិនជាប់ក្នុងបុណ្យ និងបាប មិនជាប់ក្នុងអារម្មណ៍ផ្សេងៗ។

បិដកលេខ ២៩ ទំព័រ ១០ (អរញ្ញសូត្រ)

ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ទៅនឹងទេវតាថា ពួកភិក្ខុនោះមិនសោកស្ដាយរបស់ដែលកន្លងទៅហើយ ទាំងមិនប្រាថ្នារបស់ដែលមិនទាន់មកដល់ គ្រាន់តែចិញ្ចឹមជីវិតដោយរបស់ជាបច្ចុប្បន្ន ហេតុនោះបានជាពណ៌សម្បុរកាយនៅតែផូរផង់បាន។



ពួកជនពាលតែងស្រពោនស្រពាប់ ដោយហេតុទាំងពីរនោះ គឺព្រោះសេចក្ដីប្រាថ្នានូវរបស់ដែលមិនទាន់មកដល់ និងសេចក្ដីអាលោះអាល័យ ចំពោះរបស់ដែលកន្លងទៅហើយ ដូចដើមបបុះខៀវស្រស់ដែលត្រូវគេច្រូតចោល។

មានចំណុចដែលគួរសង្កេត និងធ្វើការយល់ឱ្យជាពិសេសក្នុងសេចក្ដីនេះ គឺ "ការមិនអាល័យអតីតៈ និងមិនសង្ឃឹមអនាគត" ចាត់ចូលនៅក្នុងលក្ខណៈដែលជាភាវៈនៃចិត្ត មិនមែនលក្ខណៈដែលជាភាវៈនៃបញ្ញាទេ។ ដូច្នេះហើយ ទើបមិនបានសំដៅសេចក្ដីថាព្រះអរហន្តមិនប្រើបញ្ញា ពិចារណាការងារខាងមុខ និងមិនប្រើនូវប្រយោជន៍អំពីការដឹងអតីតៈនោះឡើយ។ ផ្ទុយមកវិញ ព្រោះព្រះអរហន្តមានភាវៈនៃចិត្តដែលផុតស្រលះ មិនជាប់ជំពាក់ចំពោះអតីតៈ និងអនាគតមកប្រើជាប្រយោជន៍ ខាងផ្នែកបញ្ញាបានពេញទី។

យើងសង្កេតឃើញ ការងាររបស់ព្រះសម្មាសម្ពុទ្ធទាក់ទងនឹងអតីតៈ អនាគត ដែលជាផ្នែកនៃបញ្ញាញាណ ដូចជា**បុព្វេនិវាសានុស្សតិញ្ញាណ** (ញាណរលឹកដឹងជាតិមុន) **ចុតូបបាតញ្ញាណ** (ញាណដឹងចុតិបដិសន្ធិ) **អតីតំ សញ្ញាណ** (ញាណដឹងអតីតៈ) **អនាគតំ សញ្ញាណ** (ញាណដឹងអនាគត) ព្រមទាំងការដែល

ព្រះអរហន្ត នឹងធ្វើនូវកិច្ចការណា១ ច្រើនតែរំពឹងគិត ដើម្បីអនុគ្រោះដល់ពពួកជនជំនាន់ក្រោយ ។

លក្ខណៈផ្លូវចិត្តដែលផុតស្រលះ គឺមិនកង្វល់ ប្រាសចាកភ័យ ស្ងប់ប្រណីត សុខ មិនមានសោក ក្សេម ថ្លា ត្រជាក់ ឆ្អែត មិនស្រេកឃ្លាន។ គ្រប់ឥរិយាបថ គឺមានចិត្តប្រព្រឹត្តទៅស្រាល ទំនេរ ស្រលះស្វាង មិនមានរោគ ។

## ៣- ភារៈខាងការប្រព្រឹត្តិ ឬដំណើរជីវិត

ក្នុងផ្នែកនៃការប្រព្រឹត្តិទូទៅ ដែលហៅថា សីល មានការពោលសម្តែងក្នុងលក្ខណៈនៃអ្នកដែលបានសម្រេចនិព្វានហើយ មិនជាសូវច្រើនឡើយ ទាំងនេះព្រោះតាមគោលនៃសីលសិក្ខានោះ ព្រះអរិយបុគ្គលរមែងជាអ្នកមានសីល ដោយសម្បូរហើយ តាំងតែពីថ្នាក់សោតាបន្នទៅម្ល៉េះ។ បុគ្គលជាព្រះអរហន្តមិនមានសេសសល់នៅភាពទ្រុស្តសីល ឬការប្រព្រឹត្តិទុច្ចរិតឡើយ ។

ចំណុចដែលគួរពិចារណាក្នុងទីនេះ គឺចំពោះត្រឹមតែថា តើព្រះអរហន្តមានដំណើរជីវិតយ៉ាងណា ប្រកបកិច្ចការអ្វី ក្នុងរូបភាពបែបណា ។

ប្រការជាដំបូង ព្រះអរហន្ត ជាអ្នកអស់កម្មដែលជាអភិសង្ខារ



ការធ្វើអ្វី១របស់លោក មិនជាកម្មស ឬកម្មខ្មៅតទៅទៀតឡើយ គឺគ្រាន់តែជាកិរិយាប៉ុណ្ណោះ ។

ដែលថាអស់កម្មនោះ សំដៅដល់ការមិនធ្វើកម្មផ្សេង១ ដោយមានអវិជ្ជា តណ្ហា ឧបាទាន គ្របសង្កត់ តែជាការធ្វើដោយចិត្ត ដែលជាឥស្សរៈ មានបញ្ញាដឹងច្បាស់ តាមហេតុផល ឈប់ធ្វើការបែបយ៉ាងបុថុជ្ជន ផ្លាស់មកជាធ្វើតាមបែបអរិយជា គឺមិនធ្វើការដោយសេចក្តីប្រកាន់មាំ ក្នុងសភាពល្អ ឬអាក្រក់ ទាក់ទងនឹងខ្លួនឯង ផលប្រយោជន៏របស់ខ្លួន ដែលត្រូវបានយ៉ាងនេះ ឬយ៉ាងនោះឡើយ ។

ព្រះអរហន្តធ្វើការតាមវត្ថុបំណងនៃការងារនោះ១ តាមហេតុផលនៃរឿងនោះ១ ដូច្នេះ ទើបជាការធ្វើដែលអណ្តែតផុត ពីបុញ្ញកម្មទៅទៀត ឯចំណែកបាបកម្ម មិនចាំបាច់ពោលឡើយ ព្រោះអស់លោភៈ មោហៈ ដែលជាហេតុប្បច្ច័យ ក្នុងសេចក្តីអាក្រក់នោះ១ហើយ ។

- **វិជ្ជា** - ការដឹងច្បាស់នូវសភាវៈ ដែលធ្វើឱ្យកិលេសមានទីតាំងអាស្រ័យ ។

- **វិមុត្តិ** - ការដែលចិត្តរួចផុតស្រលះពីគ្រឿងជាប់ជំពាក់ ។

- **ករុណា** - សភាពអាណិតរបស់ចិត្ត ទៅតាមសេចក្តីទុក្ខរបស់សត្វលោក ហើយត្រូវជួយឱ្យមានទីពឹងដល់សត្វលោកនោះ១ ។

*វិជ្ជា វិមុត្តិ* និង*ករុណា* មានសភាពផ្ទុយទាំងស្រុងអំពី *អវិជ្ជា តណ្ហា* និង*ឧបាទាន*។ បុគ្គលដែលបានសម្រេចដល់ព្រះនិព្វាន បានលះ *អវិជ្ជា តណ្ហា* និង*ឧបាទាន* ហើយមានកម្លាំងបញ្ញា និងករុណាជំរុញឱ្យធ្វើការងារជាប្រយោជន៍ ប្រកបដោយគុណដ៏ក្រៃលែង។

បុគ្គលដែលបានសម្រេចដល់ព្រះនិព្វានហើយ មិនមានទឹករំពឹងរកប្រយោជន៍អ្វីឱ្យដល់ខ្លួនឯងទៀតឡើយ មានតែធ្វើប្រយោជន៍ ឱ្យដល់អ្នកដទៃប៉ុណ្ណោះ ជាការបំពេញកិច្ចនៃករុណាបានពេញទី។

ព្រះអរហន្តមានគុណបទ គឺពាក្យសម្តែងនូវគុណលក្ខណៈថា *កតករណីយ* ប្រែថា មានកិច្ចដែលត្រូវធ្វើ បានធ្វើស្រេចហើយ គឺធ្វើកិច្ចដែលជាប្រយោជន៍របស់ខ្លួន (*សោឡសកិច្ច = កិច្ច* ១៦) រួចជាស្រេចហើយ ហ្នឹងឯង។

កាលបើព្រះអរហន្តធ្វើប្រយោជន៍របស់ខ្លួនស្រេចហើយ ក៏ជាបុគ្គលមាន *អត្តហិតសម្បត្តិ* (ដល់ព្រមដោយបរិបូរនូវប្រយោជន៍ខ្លួន) ម្ល៉ោះហើយ លោកមានតែបរទត្ថ គឺប្រយោជន៍អ្នកដទៃប៉ុណ្ណោះដែលធ្វើ។

ព្រះអរហន្តមានដំណើរជីវិតដែលនៅសល់នោះ ដោយបរហិតបដិបត្តិ (បដិបត្តិដើម្បីប្រយោជន៍អ្នកដទៃ)។ ព្រះអរហន្តមានគុណ



លក្ខណៈជាសព្វមិត្ត (ជាមិត្តនឹងសត្វលោកទាំងអស់គ្នា) ឬ *សព្វភូតានុកម្បកៈ* (ជាអ្នកអនុគ្រោះនូវប្រយោជន៍ឱ្យដល់សព្វសត្វ)។

ប្រយោជន៍ដែលអនុគ្រោះឱ្យសព្វសត្វ គឺជាខ្លឹមសារនៃជីវិត ជាការចម្រើនខាងបញ្ញា ព្រមដោយគុណធម៌ដទៃទៀត ដែលដោះស្រាយបាននូវបញ្ហាក្នុងជីវិត បានរួចផុតពីអំណាចនៃការគ្របសង្កត់របស់អវិជ្ជា តណ្ហា និងឧបាទាន។

ភារៈនៃបញ្ញា ភារៈនៃចិត្ត និងភារៈខាងការប្រព្រឹត្តិ ឬដំណើរជីវិតនៃអ្នកដែលបានសម្រេចនូវព្រះនិព្វាន ដូចដែលបានពោលមកហើយ រួមនៅចំនុចទាំង ៣ គឺ៖ ១. បញ្ញា ដែលហៅថា វិជ្ជា, ២. ការរួចផុតជាឥស្សរៈ ដែលហៅថា វិមុត្តិ, ៣. ករុណា ដែលជាកំលាំងក្នុងការផ្សាយនូវប្រាជ្ញាញាណចេញទៅ ធ្វើឱ្យអ្នកដទៃបាននូវវិជ្ជា និងដល់នូវវិមុត្តិផងដែរ។

ដែលនៅជាបុថុជ្ជន ប្រៀបដូចជា មនុស្សជាប់ចំណង ឯវិជ្ជាដូចជាកាំបិតកាត់នូវចំណងនោះ វិមុត្តិដូចជាការរួចផុតពីចំណង ហើយក៏មានឥស្សរៈ សេរីភាព ករុណាដូចកាលដែលអស់នូវភាពក្រវល់ក្រវាយ ក្តៅក្រហាយនឹងរឿងខ្លួនឯង ហើយក៏មើលចេញទៅឃើញអ្នកដទៃជាប់ចំណង ម្ល៉ោះហើយ លោកមានតែការងារជួយស្រាយនូវចំណងឱ្យអ្នកដទៃប៉ុណ្ណោះ។

## ពាក្យហៅឈ្មោះព្រះនិព្វាន

១- អកណ្ហាសុក្កៈ - មិនខ្មៅ មិនស (មិនមានវណ្ណៈ មិនជាបុណ្យ មិនជាបាប,

២- អកតៈ - មិនមានអ្នកណាសាង,

៣- អកិញ្ចនៈ - មិនមានកង្វល់,

៤- អកុតោភយៈ- មិនមានភ័យអំពីទីណា,

៥- អច្ចុតៈ - មិនឃ្លាត មិនចាកចេញ,

៦- អច្ឆរិយៈ - អស្ចារ្យ,

៧- អជរៈ - មិនចាស់ មិនគ្រាំគ្រា,

៨- អជាតៈ - មិនកើត

៩- អនតៈ - មិនបង្អោនទៅ មិនមានតណ្ហា,

១០- អនន្តៈ - មិនមានទីបំផុត,

១១- អនាឡានៈ - មិនមានការប្រកាន់មាំ,

១២- អនាបរៈ - មិនមានដទៃទៀត, ប្រសើរបំផុត,

១៣- អនាលយៈ - មិនមានអាល័យ,

១៤- អនាសវៈ - មិនមានអាសវៈ,

១៥- អនិទស្សនៈ - មិនឃើញដោយភ្នែក,



១៦- អនីតិកៈ - ប្រាសចាកពីការវិនាសអន្តរាយ,

១៧- អនុត្តរៈ - មិនមានអ្វីដទៃខ្ពង់ខ្ពស់ក្រៃលែងជាង,

១៨- អបលោកិតៈ - មិនបែកធ្លាយ,

១៩- អភយៈ - មិនមានភ័យ,

២០- អមតៈ - មិនស្លាប់,

២១- អមោសធម្មៈ - ជាធម៌មិនកុហក,

២២- អព្ភុតៈ- មិនធ្លាប់មាន, គួរអស្ចារ្យ,

២៣- អព្យាធិ - មិនមានរោគបៀតបៀន,

២៤- អព្យាបជ្ឈៈ - មិនមានការបៀតបៀន,

២៥- អសង្កិលិដ្ឋៈ - មិនសៅហ្មង,

២៦- អសង្កុប្បៈ - មិនកម្រើកញាប់ញ័រ,

២៧- អសង្ខតៈ - មិនមានការតាក់តែង,

២៨- អសំហិរៈ - មិនរសេមរសាម,

២៩- អសោកៈ - មិនមានសោក,

៣០- អារោគ្យៈ - មិនមានរោគ,

៣១- ឥស្សរិយៈ - ភាពជាធំក្នុងខ្លួនឯង,

៣២- ខេមៈ - ក្សេម, ផុតចាកភ័យ,

៣៣- **តណ្ហាក្ខយៈ** - ការអស់តណ្ហា,

៣៤- **តាណៈ** - ទីជ្រកពួន,

៣៥- **ឌីបៈ** - កោះ ឬទីពឹង ។ល។

ខ្ញុំសូមឧទ្ទិសអត្ថបទ សម្តែងអំពីព្រះនិព្វាន ដែលបានដកស្រង់ចេញពីព្រះត្រៃបិដកសុទ្ធសាធនេះ ដល់សហធម្មិកទាំងអស់ ដែលចូលចិត្តសិក្សានៅក្នុងព្រះពុទ្ធវចនៈ។ ខ្ញុំសង្ឃឹមថា អត្ថបទនេះ នឹងជួយជាគំនិតខ្លះៗ សម្រាប់អស់លោក ក្នុងការឈ្វេងយល់អំពីព្រះ-និព្វានពិតៗ ដែលសម្តែងចេញអំពីព្រះឱស្ឋរបស់ព្រះពុទ្ធជាម្ចាស់ និងព្រះអរហន្តទាំងឡាយ ដែលគ្រប់អង្គរំលត់ខន្ធចូលកាន់ព្រះនិព្វានហើយ។

# នវទស្សនៈ

*ដោយភិក្ខុ* **សឿង ទុទ្ធី** ( អនុបណ្ឌិតឆ្នាំបញ្ចប់)

កាលខ្ញុំនៅពីក្មេង អាយុប្រហែល ៧ ឬ ៨ ឆ្នាំ ខ្ញុំមិនដឹងអ្វីទាំងអស់។ ខ្ញុំកើតក្នុងត្រកូលអ្នកស្រែដែលលំបាក ហើយគ្មានសំលៀកបំពាក់សមរម្យសម្រាប់ទៅរៀនសូត្រដូចគេម្តងណាឡើយ។ ឪពុកម្តាយរបស់ខ្ញុំពុំមែនជាអ្នកចេះដឹងទេ។ ម្តាយរបស់ខ្ញុំ គាត់មិនចេះមើលអក្សរ សូម្បីតែ ក ខ ក៏គាត់អានមិនរួចដែរ។ ដូច្នេះខ្ញុំកើតមកឥតមានបញ្ញាវៃឆ្លាត ដូចកុមារដទៃទេ។ ខ្ញុំត្រូវបានអវិជ្ជាបិទបាំងរូបរិត តាំងពីកំណើតមក សូម្បីតែមានវ័យធំបន្តិច ហើយក្តីក៏ខ្ញុំឆ្ងល់នូវអ្វីដែលមិនគួរឆ្ងល់។ ថ្ងៃមួយខ្ញុំបានឮមីក្រូគេចាក់ភ្លេងបុណ្យសពតាចាស់ម្នាក់ដែលបានស្លាប់នៅជិតផ្ទះរបស់ខ្ញុំ។ ខ្ញុំសួរឪពុករបស់ខ្ញុំថា "គេធ្វើអីហ្នឹងឪ?" ឪពុករបស់ខ្ញុំបានប្រាប់ខ្ញុំថា "គេធ្វើបុណ្យសពមនុស្សស្លាប់"។ ខ្ញុំសួរគាត់ទៀតថា "ហេតុអ្វីបានជាគាត់ស្លាប់?" ឪពុកខ្ញុំប្រាប់ថា "មកពីគាត់ចាស់ ទើបស្លាប់ហ្នឹងណ៎"។ ពេលនោះ ខ្ញុំសប្បាយចិត្តណាស់ ព្រោះខ្ញុំគិតថា "ខ្ញុំជាក្មេងមិនចេះស្លាប់ឡើយ"។

ថ្ងៃមួយជាខាងក្រោយមកទៀត នៅទីរួមស្រុករបស់ខ្ញុំ ( ស្រុកកំពង់រោទិ៍) មានការសម្តែងល្ខោន។ ឪពុកខ្ញុំសួរថា "តើកូន



ឯងចង់ទៅមើលល្ខោនឬអត់?" ខ្ញុំសួរគាត់ថា "តើល្ខោននោះដូចម៉េចឪ?" គាត់ប្រាប់ខ្ញុំថា រឿងល្ខោនហ្នឹងមានស្តេច និងមានយក្សទៀតផង ល្អមើលណាស់! ខ្ញុំសួរគាត់ថា "តើស្តេចដូចម៉េចឪ?" ខ្ញុំនៅតូចខ្ញុំមិនដែលឃើញស្តេចទេ សូម្បីតែរូបថត ក៏មិនដែលឃើញដែរ។ ពេលសួរដូចនេះ ឪពុកខ្ញុំប្រាប់ថា "ស្តេចគឺមនុស្សយើងហ្នឹង គ្រាន់តែមានបុណ្យស័ក្តិខ្ពស់ មានសំលៀកបំពាក់ល្អខុសពីមនុស្សធម្មតា។ "ចុះយក្ស ដូចម៉េចដែរឪ?" ខ្ញុំសួរគាត់ទៀត។ គាត់ប្រាប់ថា "យក្សគឺរាងដូចមនុស្សយើង តែមានមាឌធំ និងមានមុខមាត់គួរឱ្យខ្លាចហើយគាត់ប្រាប់ថា គាត់ក៏មិនដែលឃើញយក្សមែនទែនដែរ គឺឃើញតែយក្សក្នុងរឿងល្ខោនប៉ុណ្ណោះ។ តើពិភពលោកនេះប្រៀបដូចជាឆាកល្ខោន ដូចលោកសេកស្ពៀរ៍ថាមែនឬ? ខ្ញុំមិនយល់ទេ! លុះដល់ពេលបានចូលរៀននៅសាលា ខ្ញុំបានឃើញអ្វីៗជាច្រើន ប៉ុន្តែខ្ញុំនៅតែមិនទាន់ចេះ នូវអ្វីដែលគ្រូបង្រៀន។ ខ្ញុំមិនមែនជាសិស្សពូកែដូចគេទេ ពេលរៀនក្នុងថ្នាក់ ជារឿយៗខ្ញុំមិនដែលគេចផុតពីការស្តីបន្ទោសឬរំពាត់ ឬការគក់វាយដោយដៃ និងមួលស្លឹកត្រចៀក ពីសំណាក់លោកគ្រូ អ្នកគ្រូឡើយ។ ខ្ញុំមិនយល់មេរៀនដែលរៀនក្នុងថ្នាក់ទេស្ទើរតែគ្រប់មុខវិជ្ជាទាំងអស់។ ក្នុងជីវិតពិតរបស់ខ្ញុំៗ មានសេចក្តីសង្ឃឹមតិចតួចណាស់ ក្នុងការសិក្សារៀនសូត្រ។ កាលនៅជាសិស្ស

សាលា ខ្ញុំគិតប្រុងរត់ចោល សាលារៀនជាច្រើនដង ដោយខ្មាសមិត្តរួមថ្នាក់ និងអ្នកដទៃ ព្រោះត្រូវរំពាត់ញយពេក។

ការដែលខ្ញុំត្រូវរំពាត់ ឬគ្រូវាយនោះ គឺមិនមែនមកពីខ្ញុំជាសិស្សខិលខូចអ្វីទេ គឺមកពីខ្ញុំល្ងង់តែម្ដង។ ខ្ញុំមិនដែលឃើញមនុស្សល្ងង់ ត្រូវបានគេយកសម្ដីមកបោះពុម្ពជាសៀវភៅទេ។ ពេលដែលខ្ញុំបានឃើញដំបូង ខ្ញុំអស់សំណើច តែដល់បានអានទៅ ខ្ញុំស្ងើចសរសើរវិញ។ តាមធម្មតា មនុស្សមិនបានទទួលការអប់រំត្រូវបានគេហៅថាមនុស្សល្ងង់ ឬមនុស្សអវិជ្ជា។

ព្រះតេជគុណ **ក្វង ឈិន** (Kuang Ch'in) (1892-1986) ជនជាតិចិន បួសក្នុងពុទ្ធសាសនាមហាយានមួយជីវិត។ ឈ្មោះរបស់លោកបានត្រូវគេចុះក្នុងជីវប្រវត្តិថា ជាមនុស្សមិនបានទទួលការអប់រំពីសាលា ជាអនក្ខរជន។ ប៉ុន្តែ ក្នុងភ្នួសរបស់លោកៗបានខិតខំរៀនសូត្រ និងប្រតិបត្តិតាមផ្លូវពុទ្ធសាសនា ហើយពាក្យទូន្មានរបស់លោកត្រូវបានគេយកមកបោះពុម្ពជាសៀវភៅ ដែលគួរឱ្យចាប់អារម្មណ៍។ ចំពោះខ្លួនខ្ញុំវិញ ពេលខ្លះខ្ញុំក៏អស់សំណើចចំពោះខ្លួនឯងដែរ ព្រោះខ្ញុំមិនចេះនូវអ្វីដែលគេចេះ។ ប៉ុន្តែ ខ្ញុំហាក់ដូចជាចម្លែកក្នុងចិត្តខ្លួនឯងថា ហេតុអ្វីបានជាខ្ញុំចាំព្រឹត្តិការណ៍ជីវិត រហូតដល់សព្វថ្ងៃ មិនភ្លេចសោះ ទោះបីបានបួសជិត ២០ ឆ្នាំ ហើយក៏



ដោយ។

ការចាំព្រឹត្តិការណ៍ជីវិត ដោយរឿងរ៉ាវជាបទពិសោធន៍ផ្ទាល់មួយអន្លើដោយការអានសៀវភៅជាច្រើនបន្ថែមផង ធ្វើឱ្យខ្ញុំចេះវិភាគ និងគិតពីបញ្ហាជីវិតខ្លួនឯង និងអ្នកដទៃក្នុងសង្គមបានកើនឡើងជាលំដាប់។ ការគិតនោះ កើតចេញជាទស្សនៈថ្មី។ ខ្ញុំបានកត់ត្រាទុក ក្នុងសៀវភៅជានិច្ច។ ពេលនេះ ខ្ញុំសូមលើកយកទស្សនៈដែលខ្ញុំបង្កើតឡើង មកសរសេរដាក់ក្នុងសៀវភៅ "ប្រជុំកម្រងអត្ថបទស្ដីអំពីព្រះពុទ្ធសាសនា" របស់សមាគមសមណនិស្សិតខ្មែរ ទីក្រុងយ៉ាំងហ្គូន សហភាពមីយ៉ាន់ម៉ា ដើម្បីចែកជូនជាគតិលោក និងគតិធម៌ ដល់មិត្តអ្នកអាន កំសាន្តដួងចិត្ត និងទុកដូចជាម្ហូបសម្រាប់ប៉ូវខួរក្បាលមួយមុខផងដែរ។ ខ្ញុំសូមអភ័យទោសជាមុន និងសូមកុំឱ្យមានបាប ប្រសិនបើទស្សនៈដែលទើបតែប្រសូតិចេញមកនេះមានការខុសឆ្គងត្រង់កន្លែងណាមួយនោះ។ ទស្សនៈដែលខ្ញុំលើកយកមកបង្ហាញជូនមិត្តអ្នកអាននៅពេលនេះ មានដូចខាងក្រោម ÷

## មនុស្ស និងការសិក្សា

- អ្នកត្រូវធ្វើជាកូនក្មេង នៅពេលដែលអ្នកចាប់ផ្ដើមរៀនភាសាថ្មីមួយទៀត។
- ចូរអ្នកខំប្រឹងរៀនសូត្រ ដើម្បីឱ្យដឹងថាខ្លួនអ្នកថាយ៉ាងម៉េច។

- ចូរអ្នកទម្លាប់អានសៀវភៅល្អៗ រាល់ថ្ងៃទៅ ប្រហែល ១០ ឆ្នាំ ផ្លាយ អ្នកនឹងបានដឹងថា អ្នកអាចក្លាយជាអ្នកប្រាជ្ញមួយរូប។

## មនុស្ស និងការចេះដឹង

- ការចេះដឹងនូវព្រះធម៌ គឺជាការចេះដឹង ក្នុងចំណោមការចេះដឹងដ៏ប្រសើរបំផុតទាំងឡាយ។
- ខ្ញុំមិនអាចមានអំនួតចំពោះចំណេះដឹងបានទេ ព្រោះអ្វីដែលខ្ញុំចេះ គឺជាអ្វីដែលគេចេះរួចហើយ។
- គ្មានអ្វីមួយដែលបុគ្គលដទៃបានដឹង ហើយវាមិនត្រូវបានដឹងដោយព្រះសម្មាសម្ពុទ្ធឡើយ។
- បើចង់ចេះចង់ដឹងថាតើ ទស្សនៈនេះជាធម្មៈ ជាអធម្មៈ ឬជាសទ្ធម្មៈ គឺត្រូវពិនិត្យផ្ទៀងផ្ទាត់ មើលក្នុងគម្ពីរព្រះត្រៃបិដក។

## មនុស្ស និងការងារ

- បើអ្នកធ្វើការងារលំបាកពេលនេះបាន អ្នកនឹងអាចធ្វើការងារលំបាកក្រោយៗទៀតបាន ដោយគ្មានបារម្ភ ឬភ័យខ្លាចអ្វីឡើយ។
- អ្វីដែលមនុស្សធ្វើមិនកើតនោះគ្មានទេ តែអ្វីដែលមនុស្សធ្វើមិនទាន់កើតមាន។

## មនុស្ស និងការអភិវឌ្ឍទូទៅ

- ពិភពលោកឥឡូវនេះកាន់តែចាស់ ដូច្នេះយើងទាំងអស់គ្នាពួតដៃ



គ្នាធ្វើឱ្យពិភពលោកនេះថ្មីឡើងវិញ។

## មនុស្ស និងសេចក្តីត្រូវការ

- អ្វីដែលខ្ញុំត្រូវការ គឺមិនមែនអ្នកទេ ខ្ញុំគ្រាន់តែត្រូវការអ្វីមួយពីអ្នក។
- ខ្ញុំមិនមែនជាមនុស្សផឹកទឹកដោះ រហូតទាល់តែមេគោអស់ទឹកដោះនោះឡើយ។

## អ្នកចេះ និងអ្នកល្ងង់

- ពេលខ្ញុំនៅល្ងង់ ខ្ញុំស្រឡាញ់អ្នកចេះ ពេលខ្ញុំចេះខ្ញុំស្រឡាញ់អ្នកល្ងង់។

## អ្នកប្រាជ្ញ និងមនុស្សធម្មតា

- បុគ្គលជាអ្នកប្រាជ្ញទាំងឡាយ រមែងមានចរិតលក្ខណៈ សមត្ថភាព និងសកម្មភាពខុសពីមនុស្សធម្មតា។ ដូច្នេះ ត្រូវតែថែរក្សាជីវិតអ្នកប្រាជ្ញ ទោះស្ថិតនៅក្នុងស្ថានភាពបែបណាក៏ដោយ ព្រោះប្រទេសដែលរីកចម្រើន គឺប្រទេសដែលសម្បូរដោយអ្នកប្រាជ្ញ។ ប្រទេសដែលសត្រូវមិនហ៊ានមើលងាយ គឺប្រទេសដែលមានអ្នកប្រាជ្ញ។

## មនុស្ស និងអាកាសធាតុ

- បើមនុស្សល្អ អាកាសធាតុក៏ល្អ បើអាកាសធាតុល្អ មនុស្សក៏ល្អ។

## មនុស្ស និងការសន្យា

- គេធ្វើឱ្យខកខានការសន្យាស្ទើរតែរាល់ដង ដូច្នេះខ្ញុំមិនចង់សន្យាអ្វីឡើយ។

## មនុស្ស និងសេចក្តីស្នេហា

- មុនដំបូងបុរសលោមស្ត្រី ក្រោយមកស្ត្រីលោមបុរសវិញ។
- ខ្ញុំមិនអាចស្រឡាញ់អ្នកបានទេ ប្រសិនបើអ្នកមិនដឹងនូវអ្វីដែលខ្ញុំស្រឡាញ់។

## មនុស្ស និងភាតព្វកិច្ចជាតិសាសនា

- ខ្ញុំមិនរឹងមាំក៏ដោយសារអ្នកដទៃ ហើយអ្នកដទៃមិនរឹងមាំក៏ដោយសារខ្ញុំ។
- ខ្លាចចាញ់គេហួសហេតុពេក ក៏នៅតែចាញ់គេ ចង់ឈ្នះគេហួសហេតុពេក ក៏នៅតែចាញ់គេ។ ដូច្នេះ ដើម្បីជាតិសាសនាបានរស់ត្រូវគិតអ្វីៗឱ្យបានគ្រប់ជ្រុងជ្រោយ មុនពេលសម្រេចធ្វើអ្វីមួយ ឬត្រូវ ហ៊ានលះបង់ ប្រសិនបើស្ថានភាពតម្រូវឱ្យមានការលះបង់។
- ភាសិតខ្មែរថា "ពេលស្រុកមានសង្គ្រាម គេត្រូវការអ្នកក្លាហាន ពេលស្រុកសាន្តត្រាណ គេត្រូវការអ្នកចេះ"។ ប៉ុន្តែតាមទស្សនៈ



ខ្ញុំៗ យល់ថា គប្បីត្រូវការបុគ្គលទាំងពីរពួកខាងលើគ្រប់កាល ព្រោះយើងមិនដឹង ថាសត្រូវនឹងមកឈ្លានពានស្រុកភូមិ ឬប្រទេសយើងនៅពេលណា។ ម្យ៉ាងទៀត បើមានអ្នកចេះ ហើយក្លាហាន គឺរឹតតែប្រសើរ។

## មនុស្ស និងការរស់នៅក្នុងសង្គម

- មួយជីវិតខ្ញុំៗ មិនចង់រស់នៅជាមួយ មនុស្សគ្មានសីលធម៌ ១ មនុស្សគ្មានចំណេះដឹង ១ មនុស្សចេះដឹងតែមានទំនោរផ្លូវចិត្តទុច្ចរិត ១ មនុស្សខ្ជិល ១ មនុស្សមិនយល់ចិត្តខ្ញុំ ១ និងមនុស្សដែលបដិសេធនូវឆន្ទៈរបស់ខ្ញុំ ១ ។

## មនុស្ស និងតណ្ហារបស់មនុស្ស

- ពិភពលោកនេះសុទ្ធតែមានសេចក្តីស្រេកឃ្លានដូចគ្នា គ្រាន់តែសេចក្តីស្រេកឃ្លាននោះខុសគ្នា។
- យើងមិនអាចបំបាត់សេចក្តីស្រេកឃ្លាន ដោយការបរិភោគអាហារក្នុងសុបិន្តបានទេ។
- ដរាបណាអ្នកព្យាយាមបំពេញចិត្តនូវអ្វីៗគ្រប់យ៉ាងក្នុងលោក អ្វីៗគ្រប់យ៉ាងនោះ នឹងធ្វើឱ្យអ្នកលំបាកចិត្តជារៀងរហូត។

## មនុស្ស និងទោសនៃកាមគុណ

- ការចាក់ទឹកអាស៊ីតដាក់គ្នាព្រោះរឿងកាមគុណ គឺជាបាបកម្មក្នុង

វដ្តសង្សារ ។

➢ ការត្រេកត្រអាលនឹងកាមគុណ ដោយខ្វះសតិសម្បជញ្ញៈគ្រប់-គ្រង ធ្វើឱ្យមនុស្សក្បាលធំ ក្លាយជាមនុស្សក្បាលតូច ។

## មនុស្ស និងការញៀន

➢ ការញៀនបារី ម្លូស្លា កញ្ឆា អាភៀន និងគ្រឿងញៀនផ្សេងៗ គឺជាការពិបាកលះបង់ ការលះបង់កិលេស គឺ លោភៈ ទោសៈ និង មោហៈ គឺពិបាកជាងរាប់លានដង ។ ការលះបង់ទាំងនេះអាចធ្វើទៅបាន គឺអាស្រ័យលើការតាំងចិត្តរបស់មនុស្ស និងបរិស្ថានដែលមានអំណោយផល ។

## មនុស្ស និងអំពើល្អ

➢ រាល់ទង្វើល្អទាំងអស់របស់បុគ្គល ពុំមែនសុទ្ធតែល្អនោះទេ ។

➢ រាល់ទង្វើល្អទាំងអស់គ្មានកំណត់កាលទេ ប៉ុន្តែរាល់ទង្វើល្អទាំងអស់សុទ្ធតែធ្វើក្នុងកាល ។

## មនុស្ស និងការលះបង់

➢ ក្នុងចំណោមបុគ្គលដែលមានការលះបង់ ព្រះពុទ្ធគឺជាបុគ្គលដែលមានការលះបង់ខ្ពស់បំផុតក្នុងលោក ។

## មនុស្ស និងវណ្ណៈក្នុងសង្គម

➢ ការប្រកាន់វណ្ណៈ គឺជារឿងឆ្កួតលីលាមួយ ។



➢ មិនមែនអំណាច មិនមែនយសស័ក្តិ មិនមែនទ្រព្យសម្បត្តិ មិនមែនជាតិកំណើត មិនមែនត្រកូល និងមិនមែនរូបសម្រស់ទេ បុគ្គលដែលបរិបូណ៌ដោយចំណេះដឹង បញ្ញា និងការប្រព្រឹត្តចរិយាមារយាទល្អត្រឹមត្រូវ គឺជាបុគ្គលដែលខ្ពង់ខ្ពស់ជាងគេបង្អស់ ក្នុងចំណោមមនុស្ស និងទេវតាទាំងឡាយ ។

## មនុស្ស និងពិភពលោក

➢ ពិភពលោកតែងតែមានបញ្ហា ប្រសិនបើពិភពលោកគ្មានបញ្ហាទេ គេមិនឱ្យឈ្មោះថា ពិភពលោកឡើយ ។

➢ ក្នុងលោកនេះ មានសេចក្តីទុក្ខច្រើនណាស់ បើអ្នកដឹងដូច្នេះហើយ គួរស្វែងរកផ្លូវដើម្បីរំដោះចេញពីទុក្ខនោះចុះ ។

➢ រាល់សេចក្តីទុក្ខ ឬបញ្ហាទាំងឡាយក្នុងលោក ពុំអាចត្រូវបានកំ-ចាត់បង់ដោយទស្សនៈជាទ្រឹស្តីសុទ្ធសាធទេ ។ វាត្រូវបានកំចាត់បង់តាមវិធីសាស្ត្រដ៏ត្រឹមត្រូវនោះ បានដល់ការប្រតិបត្តិតាមអរិយមគ្គអង្គ ៨ ដូចដែលព្រះសម្មាសម្ពុទ្ធទ្រង់បានសម្តែងទុក ។

## មនុស្ស និងអនត្តាធម៌

➢ តើអាចឱ្យខ្ញុំនិយាយថា អ្នកសំខាន់ចំពោះខ្ញុំដូចម្តេចទៅ បើខ្លួនខ្ញុំមិនសំខាន់សម្រាប់ខ្លួនខ្ញុំផង ។

## មរតករបស់មនុស្សសត្វ

➢ កើតចាស់ ឈឺ ស្លាប់ គឺជាមរតករបស់មនុស្សសត្វគ្រប់រូប ដែលបានកើតមកក្នុងលោកនេះ តែយ៉ាងណាក៏ដោយ ការកើតជាមនុស្ស គឺជាពរមួយដ៏ប្រសើរ ។

## ចិត្ត ចេតសិក រូប និព្វាន

➢ អ្វីដែលមិនប្រែប្រួលឱ្យឈ្មោះថា បរមត្ថធម៌ ហើយអ្វីៗដែលប្រែប្រួលក៏ឱ្យឈ្មោះថា បរមត្ថធម៌ ដែរ ។

## មនុស្ស និងធម៌

➢ មនុស្សទាំងអស់សុទ្ធតែមានធម៌ក្នុងខ្លួន គ្រាន់តែមនុស្សខ្លះមិនបានដឹងថា ក្នុងខ្លួនគេមានធម៌ប៉ុណ្ណោះ ។

## មនុស្ស និងសច្ចធម៌

➢ អ្នកប្រហែលជាច្រឡំជាមួយសច្ចធម៌ ប៉ុន្តែសច្ចធម៌ពុំដែលច្រឡំជាមួយអ្នកឡើយ ។

## មនុស្ស និងសេចក្តីសុខ

➢ ជីវិតមានសេចក្តីសុខ គឺជីវិតប្រកបដោយចំណេះដឹងនិងសីលធម៌

➢ ជីវិតមានសេចក្តីសុខ គឺជីវិតប្រកបដោយគុណធម៌និងការធ្វើអំពើល្អ

➢ ជីវិតមានសេចក្តីសុខគឺជីវិតប្រកបដោយសុខភាពល្អនិងទ្រព្យសម្បត្តិ

➢ ជីវិតមានសេចក្តីសុខពិតប្រាកដ គឺជីវិតប្រកបដោយធម៌ ។

# សេចក្តីសន្និដ្ឋានរួម

ប្រជុំអត្ថបទស្តីអំពីព្រះពុទ្ធសាសនា ដែលបានសរសេររៀបរាប់មកខាងលើទាំងអស់នេះ សុទ្ធតែជាកម្រងអត្ថបទដែលមានខ្លឹមសារ និងសារប្រយោជន៍ដល់សង្គមខ្មែរយើង ព្រោះបានសរសេរឡើងផ្អែកតាមទ្រឹស្តីពុទ្ធសាសនាជាគោល ដូចដែលព្រះសម្មាសម្ពុទ្ធទ្រង់បានសម្តែងផង និងផ្អែកតាមគតិលោកខ្លះផង ដែលឆ្លុះបញ្ចាំងពីទិដ្ឋភាពជាក់ស្តែងរបស់សង្គម និងសាសនាពិតៗ។

ដូច្នេះ ដើម្បីធ្វើឱ្យប្រទេសជាតិ និងសាសនារបស់យើងបានរីកចម្រើន យើងត្រូវខិតខំសិក្សារៀនសូត្រ ទាំងវិជ្ជាផ្លូវលោក ទាំងវិជ្ជាផ្លូវធម៌ និងសិប្បៈផ្សេងៗទៀត ដូចជា វិទ្យាសាស្ត្រ បច្ចេកវិទ្យា ទស្សនវិជ្ជា នយោបាយ សេដ្ឋកិច្ច គ្រប់គ្រង ជាដើម។ យើងគប្បីសិក្សាស្រូបយកទាំងចំណេះដឹង និងចំណេះធ្វើ ដើម្បីយកមកអភិវឌ្ឍប្រទេសជាតិ និងសាសនាយើងឱ្យបានថ្កុំថ្កើងរុងរឿងជាលំដាប់ ហើយយើងត្រូវមានមនសិការចំពោះជាតិ សាសនាពិតប្រាកដគ្រប់ៗគ្នា។ ធ្វើដូចនេះ សត្រូវ ឬជាតិដទៃពុំហ៊ានមើលងាយយើងឡើយ។

ពុទ្ធសាសនា ជាធាតុសំខាន់មួយ ក្នុងចំណោមធាតុសំខាន់ទាំងឡាយរបស់ជាតិខ្មែរយើងលើគ្រប់វិស័យ។ សូមសំណូមពរឱ្យខ្មែរទាំងបព្វជិត ទាំងគ្រហស្ថ ទាំងអ្នកដឹកនាំ និងប្រជារាស្ត្រ ឬប្រជា-



ពលរដ្ឋគប្បីយកចិត្តទុកដាក់រៀនយកវិជ្ជាពុទ្ធសាសនា ឱ្យបានស៊ីជម្រៅ ហើយយកពុទ្ធិវិជ្ជានេះ ទៅអនុវត្តក្នុងការងារជាអាជីពរបស់ខ្លួន ទាំងផ្នែកសាសនា នយោបាយ ការទូត សេដ្ឋកិច្ច គ្រប់គ្រង និងរបរជំនួញផ្សេងៗ តាមត្រូវការ។

ការយកវិជ្ជាពុទ្ធសាសនាទៅប្រតិបត្តិ ប្រកបជាមួយវិស័យផ្សេងៗទៀត ពុំមែនជារឿងអាក្រក់ទេ ផ្ទុយទៅវិញ គឺជារឿងល្អសម្រាប់យើងទាំងអស់គ្នា និងពិភពលោកទាំងមូលផងដែរ។ ជាពិសេស អ្នកដឹកនាំប្រទេស និងប្រជាពលរដ្ឋ គប្បីប្រឹក្សាជាមួយបព្វជិត ឬព្រះសង្ឃ ជាអ្នកបានសិក្សារៀនសូត្រចេះដឹង ដើម្បីដោះស្រាយបញ្ហាផ្សេងៗ ក្នុងដំណើរជីវិត ទាំងវិបត្តិគ្រួសារ ឬវិបត្តិប្រទេសជាតិក្តី គឺជាប្រការដែលល្អបំផុត ក្នុងទង្វើបែបនេះ។

**ពុទ្ធសាសនំ ចិរំ តិដ្ឋតុ។**

*សូមឲ្យព្រះពុទ្ធសាសនាឋិតនៅជារៀងរហូត។*

# សួនកំណាព្យ

## យុវជន និង សង្គម (បទបថ្យាវត្ត)

យុវជនទាំងអស់ជាក្តីសង្ឃឹម    ជាស្នាមញញឹមជាតិខេមរា
វាសនាប្រទេសពឹងអ្នកហើយណា    សូមអ្នកមេត្តាជួយត្រាប្រណី ។
ត្រូវខំរៀនសូត្រតស៊ូឃ្មាតខ្មី    សែនល្អប្រពៃព្យាយាមប្រឹងប្រែង
សំបូរអ្នកចេះជាតិមិនចំបែង    បរទេសស្ញប់ស្ញែងកេរ្តិ៍ឈ្មោះល្បីល្បាញ ។
វប្បធម៌កេរដំណែលជាតិពីដូនតា    ស្អាតស្អំថ្លៃថ្លាឧត្តមថ្កើងថ្កាន
យុវជនទាំងអស់គ្រប់ៗប្រាណ    រក្សាឱ្យបានមានក្នុងលោកិយ ។
ទំនៀមទម្លាប់និងប្រពៃណី    ដ៏ល្អប្រពៃរឹងប៉ឹងមាំមួន
មិនត្រូវបំភ្លេចវប្បធម៌ខ្លួន    ការពារខ្ជាប់ខ្ជួនកុំឱ្យបាត់បង់ ។
ចរិតស្លូតបូតប្លូកពារមទម    ចរិយាសមរម្យសុភាពរាបសា
ត្រូវចេះគោរពមាតាបិតា    ឃើញគ្រូអាចារ្យចេះគួរសម ។
កាយវិកាទន់ភ្លន់ហត្ថាប្រណម្យ    ព្រមទាំងលាយឡំស្នាមញញឹមផង
ហើយចេះកោតក្រែងត្រកូលរាមច្បង    វាចាអញហងគប្បីកុំប្រើ ។
សេពគប់ប្រយ័ត្នប៉ះបាបមិត្ត    ដែលមានគំនិតមិនស្មោះគេចកែ
នាំគ្នាដើរលេងពាលាអាវ៉ាសែ    អារម្មណ៍ប្រួលប្រែគិតតែសប្បាយ ។
ជាហេតុធ្វើខ្លួនឱ្យអន្តរាយ    គួរចៀសឱ្យឆ្ងាយកុំយកខ្លួនបៀត
នាំឱ្យខូចខ្លួនសីលធម៌ឃ្លាឃ្លាត    កើតរឿងព្រោងព្រាតដាក់គ្រួសារ ។



នាំគ្នាកាប់ចាក់បងតូចធំ    បង្កើតជាក្រុមវាយដំប្រហារ
ដើរលេងជម្លោះគ្មានក្រែងរអា    បង្កបញ្ហាដល់ការឈឺចាប់ ។
ជួនកាលក៏មានឈានដល់ការស្លាប់    បើមានប្រញាប់បោះបង់គំនិត
អំពើអាក្រក់ចូលអប់រំចិត្ត    មិនត្រូវប្រព្រឹត្តនាំកើតទុក្ខព្រួយ ។
គ្រឿងញៀនមានមេតាំងហ្វេតាមីន    និងហេរ៉ូអ៊ីនរួមមានយ៉ាម៉ា
បើជក់ទៅហើយនាំអន់បញ្ញា    ខាតបង់ថវិកាទាំងពេលវេលា ។
ចុកគាំងសាច់ដុំប្រកាច់វេទនា    ញ័រខ្លួនគ្រាំគ្រាឆាប់អាក់អន់ចិត្ត
ដោះស្រាយបញ្ហាខ្វះខាតគំនិត    បាត់បង់ការគិតបាត់ភាពម្ចាស់ការ ។
ភ្លើតភ្លើនភ្លេចខ្លួនសប្បាយហ៊ឺហា    សំលេងឡូឡានាំគ្នាស្រែកហ៊ោ
ជាពួកជាក្រុមបង្ហោះម៉ូតូ    សង្គមផ្លាស់ប្តូរតាមដងវិថី ។
រំខានដំណើរដល់អ្នកដទៃ    ទុយិសអប្រិយអាក្រក់ពេកក្រៃ
កើតចលាចលរញ៉េរញ៉ៃ    អនាធិបតេយ្យសង្គមស្អប់ខ្ពើម ។
មន្តស្នេហ៍ផ្អែមល្ហែមបង្កប់អត្ថន័យ    លួងលោមយុវវ័យគិតតែសប្បាយ
តែងបន្សល់ទុកនូវភាពសោកស្តាយ    ធុញថប់ជិនណាយក្នុងការសិក្សា ។
កើតទុក្ខក្រៀមក្រំខ្លោចចិត្តឈឺផ្សា    គ្មានមនសិការចំពោះរៀនសូត្រ
ប្រែប្រួលចរិតសុភាពស្លូតបូត    ជួនកាលរហូតដល់ការខូចចិត្ត ។
កាលមានស្នេហាក្នុងយុវវ័យ    មិនត្រូវគិតខ្លីនាំគ្នារួមភេទ
នាំឆ្លងកាមរោគកើតជម្ងឺអេដស៍    ព្រោះគ្មានថ្នាំពេទ្យណាព្យាបាលបាន ។
អង់ទីគ័រចុះខ្សោយនៅក្នុងប្រាណ    មានពេលរំខានជម្ងឺពូតផ្តុំ
ពិសេសជម្ងឺឱកាសនិយម    ចូលមកប្រជុំទន្ទ្រានរាងកាយ ។

រាប់អានសេពគប់កល្យាណមិត្ត ប្រសប់យកចិត្តពេលមានកិច្ចការ
ជួយផ្ដល់យោបល់ដោះស្រាយបញ្ហា ចេះយកអាសាទឹកចិត្តស្មោះស ។
មានតែទូន្មានឱ្យប្រព្រឹត្តល្អ ជួយគ្នាគ្រាក្រអាសន្នអបលក្ខណ៍
ហើយមិនចោលគ្នាគ្រប់ឧបសគ្គ នៅពេលខណៈមានទុក្ខធុរៈ ។
ទាន់ខ្លួននៅក្មេងរៀនសូត្រប៉ុនប៉ង មានគោលបំណងលក្ខន្តិកៈ
សិក្សាពុះពាស៊ូទ្រាំលំបាក ដើម្បីឋានៈនិងកិច្ចការងារ ។
ត្រូវខំសន្សំចំណេះវិជ្ជា កុំឱ្យវេលាកន្លងផុតណា
ជាលទ្ធផលនៃការសិក្សា ដល់ត្រើយសុខាអនាគតភ្លឺស្វាង ។

( សាមណេរ **ភាឡាន ម៉េងហុង** )



## **តណ្ហាទាសៈ** ( បទកាកគតិ )

មិនថាជាអ្វី ទាំងប្រុសទាំងស្រី នៅក្នុងលោកា
ជាបុថុជ្ជន ទាសករតណ្ហា គ្រប់តែរូបា
គ្រប់គ្នាទាំងអស់ ។

ខំធ្វើអ្វីៗ តស៊ូឃ្មាតខ្មី ស្មើរគ្មានចន្លោះ
ជូនសើចសប្បាយ ជូនសោះកក្រោះ ពេលនឹកស្រណោះ
ក្នុងនាមទាសករ ។

វាលវដ្ដសង្សារ ពាំនាំសត្តា មិនងាយកម្រ
ហែលឆ្លងត្រៃភព លុះអំពើល្អ ធ្វើចិត្តស្មោះស
ទើបងាយឆ្លងបាន ។

ឱមហិច្ឆតា សេចក្ដីប្រាថ្នា មិនងាយស្រាកស្រាន្ត
ចំណង់ចងចិត្ត កើតក្ដីរំខាន ប្រមាណមិនបាន
ធ្លាក់ជ្រោះតណ្ហា ។

បងធំអវិជ្ជា នាំឱ្យវេទនា បង្កឈឺផ្សា
ជាឪពុកម្ដាយ របស់តណ្ហា បង្កបង្ការ
ផលិតសុខទុក្ខ ។

ទុក្ខក្នុងផ្លូវចិត្ត ដានតាមជាប់ស្អិត មិនដែលស្រណុក
គ្រប់វិនាទី តែងតែឈឺចុក អង្គុយសំកុក

កម្រស្រស់ស្រាយ ។

ឈឺចាប់ពើតផ្សា ពេលរងទុក្ខា ផ្នែកខាងផ្លូវកាយ
មុខក្រៀមស្រពោន មិនដែលសប្បាយ ធ្លាប់តែក្អាកក្អាយ
រសាត់គ្មានសល់ ។

នេះជារឿងពិត គ្រប់តែជីវិត ត្រូវតប់ប្រមល់
ធម្មជាតិតាក់តែង មិនដែលនឹងថ្កល់ រសាប់រសល់
តែងតែប្រួលប្រែ ។

មានសើចមានយំ មានក្មេងចាស់ទុំ មានព្រួយត្អូញត្អែរ
នេះរឿងជីវិត ពិតមិនអាចកែ គ្រប់រូបត្រូវតែ
ពិចារណា ។

ឱ្យធ្វើម្តេចទៅ ស្ថានភាពតម្រូវ មនុស្សក្នុងការ
មិនអាចគេចផុត តណ្ហាឡើយណា វាលែងតែថា
ជាព្រះអរហន្ត ។

សេចក្តីចង់បាន មិនចេះស្រាកស្រាន្ត មិនងាយឆ្អែតឆ្អន់
អ្នកខ្លះមិនខំ គិតតែបន់ស្រន់ សង្កិតសង្កន់
នាំចិត្តលំបាក ។

ជីវភាពរស់នៅ ធម្មជាតិតម្រូវ ជួបនឹងឧបសគ្គ



ជូននាំឱ្យល្អ ខ្លះរឿងអបលក្ខណ៍ ដុនដាបតោកយ៉ាក
វេទនាឯកា ។

ជ្រុងមួយនៃទុក្ខ ត្រូវប្រឈមមុខ នឹងរឿងស្នេហា
សំលេងខ្សឹកខ្សួល លាយទឹកនេត្រា ជួនមិនត្រូវការ
ជីវិតខ្លួនឯង ។

ទុក្ខជាប់រហូត មិនងាយរបូត តែងតែចំបែង
មុខក្រៀមស្រពោន សោយសោកសង្រេង រៀបចំតាក់តែង
ឱ្យក្តៅក្នុងចិត្ត ។

គិតឃើញបែកឆ្វេង ស្មារតីវង្វេង បាត់បង់គំនិត
នាំឱ្យគិតខ្លី ឈានដល់ប្រព្រឹត្ត ផ្តាច់បង់ជីវិត
ខ្លួនឯងឱ្យក្ស័យ ។

ចិត្តតែងប្រមូល ដង្ហើមចេញចូល កើតក្តីស្រមៃ
នឹកឃើញរឿងចាស់ សែនអាក្រក់ក្រៃ ស្រមោលចង្រៃ
មិនងាយបំភ្លេច ។

កុសលអកុសល លទ្ធផលតែងផល តាមតែទិចនិក
ប្រព្រឹត្តកម្មណា ទោះច្រើនឬតិច បុណ្យនោះមិនភ្លេច
រូបយើងឡើយណា ។

គ្រប់គ្នាទាំងអស់ កុំភ្លេចឱ្យសោះ ត្រង់ផ្សងសច្ចា

ពេលធ្វើកុសល ឱ្យផុតតណ្ហា ផុតវដ្តសង្សារ
បានសុខស្រួលពិត ។
ធ្វើអំពើល្អ ទឹកចិត្តស្មោះស ខំតោងឱ្យស្អិត
ទានសីលភាវនា អំពើសុចរិត បោះបង់គំនិត
ល្បែងបួនប្រការ ។
ត្រូវខំប្រព្រឹត្ត ជម្រះផ្លូវចិត្ត កុសលផងណា
គ្រប់ពេលវេលា អនុវត្តធម៌អាថ៌ ទទួលផលា
ដល់ឋានផុតទុក្ខ ។

(សាមណេរ **ភាឡាន ម៉េងហុង**)



## គុណធម៌របស់ពុកម៉ែ (បទពាក្យ ៧)

រដូវកាលបានឈានមកដល់ ចិត្តខ្ញុំខ្វាយខ្វល់ព្រោះស្រមៃ
សញ្ជប់សញ្ជឹងទាំងយប់ថ្ងៃ ស្លាបប៉ាកកាក្នុងដៃចាំជួយចារ ។
ដោយហេតុតែចិត្តគិតមមៃ នឹកចង់លកលៃរឿងធម៌អាថ៌
ជាចំណងដៃជូនខេមរា គ្រាន់អានសិក្សាពេលទំនេរ ។
សព្វថ្ងៃនេះក្នុងពិភពលោក មានរឿងស្មោកគ្រោកហួសគ្មាន់គ្មេរ
សីលធម៌ធ្លាក់ចុះចិត្តវៀចវេរ ស្រុកយើងស្រុកគេដូចតែគ្នា ។
មាតាបិតាខ្វះគុណធម៌ បង្កើតកូនមកក៏មិនពុះពារ
ចិញ្ចឹមថ្នាក់ថ្នមតាមមាគ៌ា ដែលព្រះភគវាបានចែងទុក ។
គុណធម៌ប្រាំប្រការល្អឯក ព្រះពុទ្ធបានចែកដល់ម៉ែពុក
ដើម្បីបានល្អនៅគ្រប់ស្រុក នឹងឈប់សំកុកដោយសារបុត្រ ។
ទី១ ឪពុកម្ដាយគ្រប់រូប ត្រូវចេះលៃលកដាក់កំណត់
ហាមកូនប្រុសស្រីឱ្យគេចផុត អំពើខុសបទគ្រប់ប្រការ ។
អំពើទុច្ចរិតទាំងឡាយ ទោះតាមផ្លូវកាយឬវាចា
ដែលនាំទោសពៀរដល់បុត្រា នឹងក្រុមគ្រួសារថ្ងៃខាងមុខ ។
ធ្វើឱ្យសង្គមចលាចល វឹកវរច្របល់មិនបានសុខ
ញាតិមិត្តគ្រប់គ្នាក៏រងទុក្ខ ចិត្តក្ដៅគគុកគ្រប់ៗប្រាណ ។
ឪពុកម្ដាយក្នុងលោកគ្រប់គ្នា ត្រូវតែពុះពារហាមឱ្យបាន

កូនប្រុសកូនស្រីពីភូមិឋាន    ចិត្តខ្មៅសាមាន្យដ៏អប្រិយ ។
ដើរលេងពាលាអាវ៉ាសែ    ភ្លេចចំការស្រែគោក្របី
មិនស្តាប់វាចាពុកម៉ែស្តី    ចិត្តងប់នឹងស្រីល្បែងស៊ីសង ។
សេពគប់បាបមិត្តចិត្តឫស្យា    ហ៊ានវាយប្រហារញាតិប្អូនបង
បងតូចបងធំហ៊ោអឹងកង    កាប់គុនចាប់ចងឈាមពាសដី ។
សេពគ្រឿងញៀនអាភៀនកញ្ឆា    ផឹកស៊ីស្រីស្រាជីវិតខ្លី
ចាក់កាប់សម្លាប់គ្មានប្រណី    ទាំងប្រុសទាំងស្រីដូចតែគ្នា ។
តុលាការកោះហៅស្ទើររាល់ថ្ងៃ    បង់ប្រាក់ពិន័យម៉ែវេទនា
លក់អស់កេរអាករជ្រូកមាន់ទា    ដើម្បីធានាកូនឫស្យា ។
ឥឡូវនេះសម័យទំនើប    កូនចៅរំភើបបុណ្យសង្សារ
ឈ្លោះប្រកែកគ្នាព្រោះស្នេហា    ចាក់កាប់ប្រហារមិនទុកស្នែក ។
ទង្វើនេះគួរឱ្យអនិច្ចំ    ពុកម៉ែដេកភាំងគិតសង្វេគ
វប្បធម៌បរទេសចូលជ្រៀតជ្រែក    កូនខ្មែរលែងត្រេកវប្បធម៌ខ្លួន ។
ស្នេហាអូនបងត្រកងបី    តាមដងវិថីឬតាមសួន
កូលាបមួយទងជូននីមនួន    ទោះបីបង់ខ្លួនក៏មិនស្តាយ ។
ទង្វើនេះមិននាំចម្រើន    ពុកម៉ែត្រូវក្រើនកូនទាំងឡាយ
ឱ្យបង្វៀរចេញចាកអបាយ    ជាផ្លូវអន្តរាយដល់សង្គម ។
ទី២ ឪពុកម្តាយគ្រប់រូប    ត្រូវចេះលៃលកស្តីអប់រំ



កូនប្រុសស្រីឱ្យបានសមរម្យ    ចរិតរមទមសុភាពរាបសា ។
ឱ្យស្គាល់ខុសស្គាល់ត្រូវទោសគុណ    ចេះបំពេញបុណ្យដ៏ថ្លៃថ្លា
ចេះគោរពចាស់ព្រឹទ្ធាចារ្យ    លោកយាយលោកតាញាតិប្រុសស្រី ។
ឱ្យចេះគោរពថ្វាយបង្គំ    ពុកម៉ែចាស់ទុំដោយភក្តី
ព្រមទាំងរតនៈកែវទាំងបី    ដែលនាំសិរីឱ្យគ្រួសារ ។
ឱ្យចេះស្រឡាញ់ជាតិមាតុភូមិ    វប្បធម៌ឧត្តមនិងសាសនា
ជាកេរដំណែលពីដូនតា    បីបាច់រក្សាឱ្យគង់វង្ស ។
ឱ្យចេះស្រឡាញ់ការសិក្សា    ខិតខំឧស្សាហ៍នឹងមិនល្ងង់
បញ្ញាមានពិតចិត្តថ្លាយង់    គ្រួសារឧត្តុង្គឧត្តមក្រៃ ។
ឱ្យចេះដឹងគុណឪពុកម្តាយ    អ្នកផ្តល់រូបកាយខ្លួននោះនៃ
ព្រោះលោកជាព្រះដ៏ប្រពៃ    ចិញ្ចឹមថ្នមបីតាំងពីក្មេង ។
លោកគឺជាគ្រូដំបូងគេ    ដែលស្រែកបំពេឱ្យកូនគេង
បង្ហាត់បង្រៀនឱ្យចេះលេង    ឱ្យចេះស្តីស្តែងហៅម៉ែពុក ។
អប់រំកូនឱ្យចេះធ្វើទាន    សម្រាប់ជាស្ពានឆ្លងផុតទុក្ខ
ដល់ក្មេងកំព្រាគ្មានម៉ែពុក    ត្រូវការទំនុកស្រែកក្លែងៗ ។
រីឯការសេពគប់មិត្តភក្តិ    ម៉ែត្រូវបញ្ជាក់ឪប្រាប់ស្តែង
សេពគប់បណ្ឌិតផុតចំបែង    បណ្ឌិតនោះឯងនាំសុខា ។
គប់ប្រាជ្ញនាំប្រាណឱ្យបានសុខ    គប់ពាលនាំទុក្ខចិត្តសោកា

គប់ប្រាជ្ញនាំប្រាណឱ្យថ្លៃថ្លា    គប់ពាលឫស្យាជីវិតថោក ។
ដូច្នេះឪពុកម្ដាយគ្រប់ប្រាណ    ចូរចាំឱ្យបានហើយលៃលក
នាំបុត្រប្រុសស្រីឱ្យទៅរក    កាន់ទីជម្រកសុខក្សេមក្សាន្ត ។
ពោលគឺធ្វើតែអំពើល្អ    មានចិត្តស្មោះសគ្រប់សន្ដាន
ដែលបានរស់នៅក្នុងភូមិឋាន    ដោយចិត្តប្រោសប្រាណតរៀងទៅ ។
ទី៣ ពុកម៉ែគ្រប់អាត្មា    ត្រូវតែសច្ចានាំកូនចៅ
ឱ្យរួចផុតពីភាពល្ងង់ខ្លៅ    ដែលមាននិតនៅក្នុងកាយា ។
ដោយនាំបុត្រប្រុសស្រីឆ្ពោះទៅ    កាន់ទីគោលដៅគឺសាលា
ឱ្យគាត់បានរៀនបានសិក្សា    អក្សរអក្ខរាបូកគុណចែក ។
ឱ្យគាត់រៀនអានរៀនសរសេរ    រៀនគិតគ្មាន់គ្មេររៀនវែកញែក
ចាប់ផ្ដើមពីថ្ងៃនេះកុំចាំស្អែក    នាំចិត្តរារែកខ្វាសសាលា ។
កូនពេញវ័យដល់ពេលរៀនសូត្រ    ពុកម៉ែត្រូវស្រូតឱ្យឆាប់រ៉ា
ដឹកដៃកូនស្ងួនចរយាត្រា    ឆ្ពោះទៅសាលាដោយភក្ដី ។
ឱ្យកូនរៀនពីថ្នាក់បឋម    ដល់ថ្នាក់ឧត្ដមវិទ្យាល័យ
មិនថាកូនប្រុសឬកូនស្រី    ត្រូវតែលកលៃឱ្យស្មើគ្នា ។
ត្រូវលះបង់ទំនៀមចាស់    វិលប្រែប្ដូរផ្លាស់យកមាគ៌ា
កូនប្រុសស្រីមានសិទ្ធស្មើគ្នា    ទទួលយកវិជ្ជាដាក់ក្នុងប្រាណ ។
កាលណាបើកូនមានវិជ្ជា    ពុកម៉ែគ្រប់គ្នារស់សុខសាន្ត



មិនលំបាកជេរស្ដីរុញច្រាន    ឱ្យកូនកល្យាណដើរផ្លូវត្រូវ ។
វីសង្គមជាតិក៏សប្បាយ    មិនមានខ្វល់ខ្វាយរឿងអាស្រូវ
ពីបងតូចធំនៅតាមផ្លូវ    ដែលចាំស្ទាក់ហៅវាយឆក់ប្លន់ ។
គ្រប់ក្រុមគ្រួសារមុខស្រស់ស្រាយ    សើចហ៊ោក្អាកក្អាយតាមតំបន់
លែងអង្គុយសំកុកស្រែកបន់ស្រន់    ខ្លាចមានអាសន្នដល់បុត្រភ្ញា ។
ម្យ៉ាងទៀតបើកូនមានចំណេះ    អាចប្រើតម្រិះធ្វើការងារ
ចិញ្ចឹមជីវិតបានគ្រប់គ្រា    ជីវភាពធូរធារុងរឿងឡើង ។
ថែមទាំងអាចជួយលើមុខមាត់    គ្រួសារកម្សត់ឱ្យថ្កុំថ្កើង
ឱ្យចៀសផុតពីការរើសអើង    ញាតិមិត្តចុះឡើងសឹងរាល់ថ្ងៃ ។
សង្គមជាតិសំបូរធនធាន    មនុស្សអ្នកមានសីលវិន័យ
អភិវឌ្ឍឆាប់រហ័សក្រៃ    នៅគ្រប់វិស័យគួរមោទនៈ ។
បរទេសកោតស្ញប់ស្ញែង    គេនាំគ្នាថ្លែងសរសើរជាក់
វឹងប្រទេសអបលក្ខណ៍    នៅជុំវិញអ្នកមិនហ៊ានបៀត ។
ការសិក្សាពិតជាសំខាន់    ពុកម៉ែគ្រប់ប្រាណត្រូវលៃឆ្លៀត
ត្រូវឱ្យកូនរៀនហើយរៀនទៀត    កុំបីរវាទគាត់ឡើយណា ។
"ទំពាំងស្នងឫស្សី" ពាក្យបុរាណ    ដែលលោកទូន្មានបុត្រធីតា
ឱ្យខិតខំប្រឹងប្រែងសិក្សា    ព្រោះជាវាសនាប្រទេសជាតិ ។
ពេលព្រឹទ្ធាចារ្យស្លាប់អស់ទៅ    កូនចៅរស់នៅតទៅទៀត

ជួយប្រឹងប្រែងអភិវឌ្ឍជាតិ　　រុងរឿងព្រោងព្រាតដូចសួគ៌ា ។
ទី៤ ឪពុកម្ដាយទាំងឡាយ　　ត្រូវគិតវែងឆ្ងាយគ្រប់វេលា
បើកូនប្រុសស្រីចង់មានគ្នា　　ស្វាមីភរិយាសម្រាប់ជីវិត ។
ត្រូវបំពេញតាមតម្រូវការ　　តែត្រូវពិចារណាឱ្យល្អន់ល្អិត
មុនថ្ងៃមង្គលខិតមកជិត　　គប្បីពិនិត្យឱ្យហ្មត់ចត់ ។
ត្រូវពិនិត្យពីក្រុមគ្រួសារ　　ពង្សាវតាឱ្យប្រាកដ
ខ្លាចក្រែងមានភាពភ្លាំងភ្លាត់　　នាំឱ្យប្រាសព្រាត់ថ្ងៃខាងមុខ ។
មើលពីចរិយាការប្រព្រឹត្តិ　　ជាមួយញាតិមិត្តម្ដាយឪពុក
ចេះស្គាល់ខ្ពស់ទាបដឹងសុខទុក្ខ　　យកចិត្តទំនុកថែរក្សា ។
ប៉ុន្តែសម័យទំនើបនេះ　　កូនប្រុសស្រីចេះមានស្នេហា
តាំងពីនៅក្នុងវ័យសិក្សា　　ពាក្យពេចន៍ចចារស្នេហ៍អូនបង ។
សម័យប្រល័យកេរបុរាណ　　ពុកម៉ែគ្រប់ប្រាណចូរចាំចង
ពីបុរាណកូនដើរតាមគន្លង　　ពុកម៉ែផ្គូផ្គងជាគូគាប់ ។
មិនប្រកែកប្រឆាំងតវ៉ា　　ដាក់ជោគវាសនាតាមទម្លាប់
ពេលខ្លះក៏មានព្រេងភ័ព្វ　　ជួនខ្លះក៏ងាប់ចោលរោងការ ។
រីឯសម័យទំនើបវិញ　　ពុកម៉ែទោម្នេញទ្រូងពើតផ្សា
ខំប្រឹងរត់តាមបុត្រធីតា　　ស្មើរសូន្យសង្ខារចាកលោកីយ៍ ។
កូនជាអ្នកបញ្ជាពុកម៉ែ　　ឱ្យដើរហាមហែធ្វើសាក្សី



ក្នុងការជ្រើសរើសប្រពន្ធប្ដី　　តាមតែហឫទ័យរបស់ខ្លួន ។
ទោះអាក្រក់ល្អដូចម្ដេចម្ដា　　គ្មានសិទ្ធតវ៉ានឹងកូនស្ងួន
ពុកម៉ែស៊ូទ្រាំតាមនឹមនួន　　ទោះត្រូវប្រឈួនក៏មិនថា ។
នេះហើយចិត្តកូនសម័យថ្មី　　ចេះច្នៃលកលៃតាមចិន្ដា
រិះរកគូគាប់រួមស្នេហា　　សម្រាប់វាសនាអនាគត ។
តែពុកម៉ែត្រូវយល់ព្រមផង　　ទើបមិនផ្គាំផ្គងហើយគត់មុត
ជីវិតរស់នៅបរិសុទ្ធ　　ឧត្តមបំផុតក្នុងលោកា ។
ទី៥ ក្រោយពីរៀបកូនរួច　　ពុកម៉ែត្រូវគួចគិតគ្រប់អាត្មា
ពីទ្រព្យសម្បត្តិក្នុងគេហា　　ដែលខ្លួនរក្សានៅសព្វថ្ងៃ ។
ត្រូវតែចែកដល់បុត្រធីតា　　នូវទ្រព្យភោគ្គាទាំងនោះនៃ
តាមលទ្ធភាពខ្លួនអាចលកលៃ　　មានគោក្របីជ្រូកមាន់ទា ។
ដីស្រែចំការច្បារដំណាំ　　ចែកចាយកូនដាំពេលក្រគ្រា
ដើម្បីឱ្យផុតក្ដីវេទនា　　ចិញ្ចឹមគ្នីគ្នារស់សុខសាន្ត ។
នេះហើយជាគុណធមិពុកម៉ែ　　សម្រាប់មើលថែកូនគ្រប់ប្រាណ
ដើម្បីឱ្យកូនបានថ្កើងថ្កាន　　រស់នៅសុខសាន្តតរៀងទៅ ។

ភិក្ខុ **ស៊ុយ សុវណ្ណ**

## **ល្បែងបួនប្រការ** (បទកាកគតិ)

ល្បែងបួនប្រការ ទីមួយនោះណា ជាអ្នកលេងស្រី
ប្រការទីពីរ ផឹកស៊ីនោះនៃ សុរាមេរ័យ
វិនាសទ្រព្យជាក់ ។
ប្រការទីបី ភាសាបាលី អក្ខធុត្តៈ
អ្នកលេងល្បែងភ្នាល់ ឥតខ្វល់អស់ប្រាក់ អស់ទាំងមិត្រភក្តិ
វិនាសជាក់ស្តែង ។
វិទីបួនណា បាបមិត្តា ព្រះពុទ្ធសម្តែង
គប់មិត្រអាក្រក់ អស់លក្ខណ៍ស្តែងៗ ព្រះពុទ្ធទ្រង់ចែង
ឱ្យចៀសវាង៉ា ។
ឱជាតិខេមរា រិះក្នុងអាត្មា នូវល្បែងនានា
ចៀសវាងឱ្យបាន ទើបប្រាណសុខា ល្បែងបួនប្រការ
ត្រូវចៀសឱ្យផុត ។

(ភិក្ខុ **ចា៉ន ភាគ**)



## **សន្តានចិត្តម៉ែ** (បទកាកគតិ)

អហឹរីខ្ញុំ លើកហត្ថបង្គំ គុណកែវទាំងបី
ព្រះពុទ្ធព្រះធម៌ បវរប្រពៃ ព្រះសង្ឃថ្លាថ្លៃ
ជាស្រែឧត្តម ។
សូមចម្រើនពរ ខ្មែរពូជអង្គរ យាយតាពូអ៊ំ
បងប្អូនប្រុសស្រី ដោយក្តីភិរម្យ ដែលនៅជួបជុំ
ក្នុងក្រៅប្រទេស ។
ទោះរស់ទីណា យើងជនខេមរា មិនគប្បីធ្វេស
ប្រមាថមើលងាយ ឫកវាយចចេស នាំមានដៀលត្មះ
ពីជនទាំងឡាយ ។
ជាពិសេសនោះ ពុកម៉ែទាំងអស់ ត្រូវតែខ្វល់ខ្វាយ
ត្រិះគិតគ្នាន់គ្នេរ រិះរេឧបាយ រកផ្លូវនាយអាយ
ទូន្មានកូនចៅ ។
កូនចៅប្រុសស្រី ចិត្តនៅក្មេងខ្ចី ហាស្តីឆ្អិនឆៅ
ជាមួយចាស់ទុំ ពូអ៊ំញាតិផៅ ទាំងក្នុងទាំងក្រៅ
គេហដ្ឋានខ្លួន ។
កាយវិការឆ្គង មើលខុសទំនង ទៅនឹងច្បាប់ក្បួន

ដើរលេងប៉ោឡៃ ចិត្តប្រែផ្ទួនៗ ចងចិត្តគុំកួន
នាំទុក្ខចូលផ្ទះ ។
សេពគប់មិត្តភ័ក្តិ ជួបមិត្តអបលក្ខណ៍ ឱ្យម៉ែឈាមស្ទះ
ទឹកភ្នែកម៉ែស្រក់ ទ្រូងម៉ែស្ទើរប្រេះ តើកម្មអ្វីចេះ
ធ្លាក់លើម៉ែថ្លៃ ។
តាមពិតរឿងនេះ បើយើងត្រិះរិះ និងវិនិច្ឆ័យ
កម្មនេះជាកម្ម របស់ម៉ែថ្លៃ ដែលខ្វះវិន័យ
ប្រៀនប្រដៅកូន ។
តាមក្បួនតម្រា ម៉ែគ្រប់រូបា ត្រូវតែក្រាបលួន
រក្សាថ្នាក់ថ្នម បីបមឱបកូន ដែលបានមកយោន
កំណើតក្នុងផ្ទៃ ។
ព្រហ្មវិហារ ដែលម៉ែគ្រប់គ្នា មានក្នុងហឫទ័យ
មេត្តាកើតមាន ដល់បុត្រប្រុសស្រី ចាប់តាំងពីថ្ងៃ
កូនក្នុងផ្ទៃម៉ែ ។
ម៉ែសែនអាណិត អាសូរកូនពិត ទន្ទឹងចាំខែ
ចង់ឃើញកូនណាស់ រិះគិតឥតល្ហែ តើមុខកូនម៉ែ
ស្រស់បស់យ៉ាងណា ។
ពេលខែមកដល់ ចិត្តម៉ែរែងខ្វល់ ខ្លាចក្ស័យមរណា



ពេលឆ្លងទន្លេ ម៉ែចុកពើតផ្សា ស្ទើរក្ស័យជីវា
ចាកចោលលោកីយ៍ ។
ឆ្លងផុតដល់ត្រើយ ទ្រូងម៉ែបានស្បើយ ពីគ្រោះអប្រិយ
សម្រែកកូនតូច ប្រៀបដូចតន្ត្រី មានចិត្តអភ័យ
ផុសក្នុងចិត្តម៉ែ ។
ករុណាធមិ ដ៏ល្អបវរ បានចេញជាផ្លែ
ករុណាកូនពិត តាំងចិត្តមើលថែ បីបមបំពេ
លុះដល់ក្ស័យប្រាណ ។
ពេលកូនដឹងក្តី ចេះនិយាយស្តី ហៅពុកម៉ែបាន
ចិត្តម៉ែរីងរឹត អាណិតប្រោសប្រាណ ដល់បុត្រកល្យាណ
គ្មានអ្វីប្រៀបផ្ទឹម ។
មុទិតាធមិ ដ៏សែនបវរ រីកស្រស់ពព្រឹម
បីដូចសន្សើម ធ្លាក់ពេលព្រលឹម ឱ្យផ្កាញញឹម
ជាទីមេត្រី ។
ពាក្យពេចន៍ទន់ភ្លន់ ប្រៀបបានទឹកមន្ត ប្រស់បុត្រពិសី
ប្រក់ព្រំស្រោចស្រព ឱ្យមានសិរី លុះធំពេញវ័យ
ក្លាយជាកូនល្អ ។
ទឹកចិត្តស្លូតបូត ប្រឹងប្រែងរៀនសូត្រ ដោយចិត្តស្មោះស

វិជ្ជាផ្លូវលោក យោកដល់ផ្លូវធម៌ ជីវិតបវរ
នាក្នុងលោកា ។
ចុងក្រោយម៉ែថ្លៃ មានធម៌ប្រពៃ ហៅឧបេក្ខា
ដុះចេញពីចិត្ត ជិតក្នុងឱរា សម្រាប់បុត្រា
រស់នៅសុខសាន្ត ។
ម៉ែស្រឡាញ់កូន ទោះបងឬប្អូន លុះថ្ងៃអវសាន
ស្មើៗអង្គារ ស្ងួនភ្ងាកល្យាណ គ្មានចិត្តសាមាន្យ
ដាក់បុត្រណាឡើយ ។
ទោះអាក្រក់ល្អ ចិត្តម៉ែស្មោះស ចំពោះត្រាណត្រើយ
ម៉ែស៊ូរ៉ាប់រង គ្មានពេលល្ហែល្ហើយ ឱះឱបុត្រអើយ
ចូរចាំទុកចុះ ។
នេះជាសេចក្តី ដែលម៉ែលកលៃ ដល់បុត្រស្រីប្រុស
កូនអើយចូរចាំ ចំណាំដោយស្មោះ ចាំទុកដល់លុះ
ថ្ងៃមរណា ។
ម៉ែកូនប្រឹងណាស់ ដង្ហើមស្ទើរស្ទះ ក្ស័យចោលជីវ៉ា
ពេលខ្លះគ្មានស៊ី ក៏ម៉ែមិនថា ឱ្យតែបុត្រា
បានពេញក្រពះ ។
នេះជាសន្តានចិត្ត ដែលមានពិតៗ ក្នុងនាមជាព្រះ



កន្លោងនៃកូន ស៊ូលូនបម្រះ ទោះជួបប្រទះ
ទុក្ខសោកយ៉ាងណា ។
ដូច្នេះម៉ែសូម អង្វរមាសម៉ុម កូនគ្រប់អាត្មា
ធ្វើតែកម្មល្អ ពោលស្តីសច្ចា និងគិតចិន្តា
តែកិច្ចការល្អ ។
ទោះនៅទីណា កូនអើយសច្ចា ត្រូវមានសីលធម៌
មកដាក់ក្នុងខ្លួន ជីវិតបវរ ទោះមានឬក្រ
ញាតិមិត្តស្រឡាញ់ ។

(ភិក្ខុ **ស៊ុយ សុវណ្ណា**)

# យោងសេចក្ត


១-ប. ធម្ម. ភាគ ៣, ទំព័រ ២៦៤

២-ប. ធម្ម. ភាគ ៣, ទំព័រ ១៤៩

៣-ព្រះតេជគុណបណ្ឌិត ក. ស្រី ធម្មានន្ទ, *ខ្លឹមសារជីវិត*, ទំព័រ ១១៦-១២១

៤- ទី. បា. បិដកលេខ ១៩, ទំព័រ ៦៩

៥- ព្រះមហា ព្រំ ឪ, *ព្រះពុទ្ធសាសនាកថា*, ទំព័រ ក

៦- អាគត. ទំព័រ ៧៩

៧- អាគត. ទំព័រ ៨០-៨១

៨- លោកគ្រូ ប៊ុត សាវង្ស, *ព្រះពុទ្ធសាសនា-ខ្លឹមសារគួរយល់ដឹង*, ទំព័រ ៣៣

៩- លោក គីម ចាន់ណា, *ប្រាជ្ញាជីវិត*, ទំព័រ ៨៤

១០- ព្រះមហា ព្រំ ឪ, *ព្រះពុទ្ធសាសនាកថា*, ទំព័រ ៩០

១១- អាគត. ទំព័រ ៨១-៨២

១២- ភិក្ខុធម្មបាល ខៀវ ជុំ, *ជីវិតឈ្នះលោក*, ទំព័រ ២៨០-២៨១

១៣- អង្គ. តិក. បិដកលេខ ៤១, ទំព័រ ២១៦

១៤- ព្រះវិរិយបណ្ឌិតោ ប៉ាង ខាត់, *ព្រះពុទ្ធសាសនាដូចម្តេច?*, ទំព័រ ........

១៥- អង្គ. អដ្ឋក., ទំព័រ ២៥៥

១៦- ព្រះធម្មវរោត្តម តុង ឈួន, *ឧបករណ៍ធម្មវិភាគ និង គហិ-បដិបត្តិ*, ទំព័រ ៣៦២

១៧- សាស្ត្រាចារ្យ អៀង សាយ, *មេកាព្យ*, ទំព័រ ៣

១៨- ព្រះធម្មវរោត្តម តុង ឈួន, *ឧបករណ៍ធម្មវិភាគ និង គហិ-បដិបត្តិ*, ទំព័រ ៣៦២

១៩- អាគត. ទំព័រ ៣៦៤

២០- សាស្ត្រាចារ្យ អៀង សាយ, *មេកាព្យ*, ទំព័រ ១០៦

២១- អាគត. ទំព័រ ៦៧

២២- ព្រះធម្មវរោត្តម តុង ឈួន, *ឧបករណ៍ធម្មវិភាគ និង គហិ-បដិបត្តិ*, ទំព័រ ៣៦៤

២៣- អាគត. ទំព័រ ៣៦៤-៣៦៥

២៤- ព្រះពោធិវង្ស ហួត តាត, *ធម្មសង្គហៈ*, ទំព័រ ៩៥-៩៦

២៥- ព្រះធម្មវរោត្តម តុង ឈួន, *ឧបករណ៍ធម្មវិភាគ និង គហិ-បដិបត្តិ*, ទំព័រ ៣៦៥

២៦- ព្រះពោធិវង្ស ហួត តាត, *ធម្មសង្គហៈ*, ទំព័រ ៩៧-៩៨

២៧- ព្រះធម្មវរោត្តម តុង ឈួន, *ឧបករណ៍ធម្មវិភាគ និង គហិ-បដិបត្តិ*, ទំព័រ ៣៦៦

២៨- សាស្ត្រាចារ្យ អៀង សាយ, *មេកាព្យ*, ទំព័រ ៩៩

២៩- សាស្ត្រាចារ្យ ឥន្ទ ឱមសាម៉េង, *ប្រវត្តិទស្សនៈ សាសនា សីលធម៌ នយោបាយ*, ទំព័រ ១៧៧-១៧៨

៣០- អាគត. ទំព័រ ១៧៨

៣១- អាគត. ទំព័រ ១៧៨

៣២- Ven. Dr. K. Sri Dhammananda, "*Buddhist Principles for Human Dignity*", ប្រែសម្រួលជាខេមរភាសាជាស្នាដៃ សាមណេរ ជិន ម៉ៅ, ទំព័រ ៣-១០

៣៣- ព្រះតេជគុណ បណ្ឌិត ហុក សាវណ្ណ, *តួនាទីរបស់ព្រះសង្ឃក្នុងសង្គមខ្មែរ*, ទំព័រ ៥០

៣៤- វិនយ. ចុល្ល., ទំព័រ ៥៩

៣៥- អាគត. ទំព័រ ៣-៥២

៣៦- អាគត. ទំព័រ ៨០-១២២

៣៧- ប. ធម្ម. ភាគ ៣, ទំព័រ ២៨១

៣៨- ព្រះគ្រូមុនីសោភ័ណ, *អភិធម្មត្ថសង្គហៈពិស្តារ សំនួរ-ចម្លើយ*, ទំព័រ ៤០

៣៩- ប. ធម្ម. ភាគ ៣, ទំព័រ ៣៩

៤០- ប. ធម្ម. ភាគ ៣, ទំព័រ ២៥០

៤១- ព្រះពុទ្ធវង្ស សេខ នាង, *បាលីវេយ្យាករណ៍*, ទំព័រ ២៤២

៤២- ព្រះភិក្ខុ ឥន្ទប្បញ្ញោ ងិន ភេន, *គូដៃនៃមនុស្ស*, ទំព័រ ២

៤៣- អាគត. ទំព័រ ៣៨-៤៣

៤៤- ព្រះមហា យិន នឿន, *គាថាធម្មបទ*, ទំព័រ ១៨៩

៤៥- វិនយ. អ. ទំព័រ ១៤៣

៤៦- ខុ. មហា. ទំព័រ ២៧២

៤៧- ព្រះភិក្ខុ ប៉ាង ខាត់, *មហាវណ្ណកម្ម*, ទំព័រ ១១៥

៤៨- Mahasi Sayadaw, *Fundamentals of Vipassana Meditation*, ទំព័រ ១៣

៤៩- ព្រះភិក្ខុ ប៉ាង ខាត់, *មហាវណ្ណកម្ម*, ទំព័រ ១១៦

៥០- ខុ. មហា. ទំព័រ ២៧២

៥១- U Ko Lay and U Tin Lwin, *The Great Chronicle of Buddhas CD*

៥២- សុចិន្ត បរិហារវនខេត្ត, *បរមត្ថធម៌សង្ខេប ចិត្តសង្ខេប និង*

*ភាគបន្ថែម*, ទំព័រ ១៦

៥៣- Narada Maha Thera, *The Buddha and His Teachings*, ទំព័រ VII-VIII

៥៤- Ven. Kundalabhivamsa, *Ethical Knowledge for Modern Youth*, ប្រែសម្រួលជាខេមរភាសាជាស្នាដៃ លោក ម៉ៅ ស៊ីថា

៥៥- ព្រះភិក្ខុ ធម្មបាល ខៀវ ជុំ, *ជីវិតតស៊ូ*, ទំព័រទី ៣០

៥៦- ព្រះភិក្ខុ សុង ស៊ីវ, *ពុទ្ធសាសនា និងវិទ្យាសាស្ត្រ*, ទំព័រ ១០១

៥៧- Liow B., How to Develop Happiness in Daily Living, ទំព័រ ៥

៥៨- អាគត. ទំព័រ ៥-៦

៥៩- អាគត. ទំព័រ ៦

៦០- ខុ. ធ., ទំព័រ ៣៦

៦១- មហាបរិយត្តិ ឧត្តមវិជ្ជា កៅ សុវណ្ណ, *វិវិធម្មសង្គហៈ*, ទំព័រ ៨០-១០១

# គន្ថនិទ្ទេស


១. ក្រុមជំនុំព្រះត្រៃបិដក, *វិន័យបិដក ចុល្លវគ្គ ទុតិយភាគ សមថក្ខន្ធកៈ* បិដកលេខ ១០, បោះពុម្ពដោយ វិទ្យាស្ថានពុទ្ធ-សាសនបណ្ឌិត្យ, ភ្នំពេញ, ព. ស. ២៥០១

២. ក្រុមជំនុំព្រះត្រៃបិដក, *សុត្តន្តបិដក ទីឃនិកាយ បាដិកវគ្គ* បិដកលេខ ១៩, បោះពុម្ពដោយវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ, ព.ស. ២៤៩២

៣. ក្រុមជំនុំព្រះត្រៃបិដក, *សុត្តន្តបិដក អង្គុត្តរនិកាយ តិកនិបាត ទុតិយបណ្ណាសក មហាវគ្គ* បិដកលេខ ៤១, ទំព័រ ២១៦, បោះពុម្ពដោយ វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ, ព. ស. ២៤៩២

៤. ក្រុមជំនុំព្រះត្រៃបិដក, *សុត្តន្តបិដក អង្គុត្តរនិកាយ អដ្ឋកនិបាត នវមភាគ*, ទំព័រ ២៥៥ បោះពុម្ពដោយ វិទ្យាស្ថានពុទ្ធសាសន-បណ្ឌិត្យ, ភ្នំពេញ, ព. ស. ២៤៩២

៥. ក្រុមជំនុំព្រះត្រៃបិដក, *សុត្តន្តបិដក ខុទ្ទកនិកាយ ធម្មបទ ពាលវគ្គ* បិដកលេខ ៥២, បោះពុម្ព ដោយវិទ្យាស្ថានពុទ្ធ-សាសនបណ្ឌិត្យ, ភ្នំពេញ, ព. ស. ២៤៩២

៦. ក្រុមជំនុំព្រះត្រៃបិដក, *សុត្តន្តបិដក ខុទ្ទកនិកាយ មហានិទ្ទេស បឋមភាគ* បិដកលេខ ៦៤, បោះពុម្ព ដោយវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ, ព. ស. ២៤៩២

៧. Kundalabhivamsa Venerable Sayadaw, *Ethical Knowledge for Modern Youth*, បោះពុម្ពដោយ Saddhammaramsi Meditation Centre, Yangon, Myanmar, ប្រែសម្រួលជាខេមរៈភាសាដោយលោក ម៉ៅ ស៊ីថា និស្សិតថ្នាក់អនុបណ្ឌិត ពុទ្ធសាសនានៃសាកលវិទ្យាល័យពុទ្ធសាសនាទូតថេរវាទអន្តជាតិ ។

៨. ខាត់ ប៉ាង ព្រះភិក្ខុ, *មហាវណ្ណកម្ម*, ប្រមូលរៀបរៀងដោយ មហាបរិយត្តិ ឧត្តមវិជ្ជា កៅ ឈឹន, បោះពុម្ព ដោយរោងពុម្ពវត្តភ្នំ, ភ្នំពេញ, ឆ្នាំ ១៩៧០

៩. ខាត់ ប៉ាង ព្រះវីរិយបណ្ឌិតោ, *ព្រះពុទ្ធសាសនាដូចម្ដេច?*, ទំព័រ.....

១០. ចាន់ណា គឹម លោក, (ប្រែ និងរៀបរៀង), *ប្រាជ្ញាជីវិត*, បោះពុម្ពលើកទី ២ ដោយ សមាគមអ្នកនិពន្ធខ្មែរ នៅរោងពុម្ពឥន្ទ្រីយ៍មាស, ភ្នំពេញ, ឆ្នាំ ២០០៨

១១. ជុំ ខៀវ ព្រះភិក្ខុ ធម្មបាល, *ជីវិតឈ្នះលោក*, បោះពុម្ពដោយ គណៈធម្មទាន, ភ្នំពេញ, ឆ្នាំ ព. ស. ២៥១៣ គ.ស. ១៩៦៩

១២. ជុំ ខៀវ ព្រះភិក្ខុ ធម្មបាល, *ជីវិតតស៊ូ*, បោះពុម្ពផ្សាយលើកទី១ ដោយបណ្ណាគារត្រៃរតន៍, ភ្នំពេញ, ព.ស. ២៥៤៨, គ. ស. ២០០៤

១៣. ឈួន តុង ព្រះធម្មវរោត្តម, *ឧបករណ៍ធម្មវិភាគ និងគហិបដិបត្តិ* ឆ្នាំ ព. ស. ២៥០៨ គ. ស. ១៩៦៦

១៤. ឌី ព្រំ ព្រះមហា, *ព្រះពុទ្ធសាសនកថា*, បោះពុម្ព ដោយរោងពុម្ពវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ, ឆ្នាំ ព. ស. ២៥៥១ គ.ស. ២០០៧

១៥. តាត ហួត ព្រះពោធិវ័ង្ស, *ធម្មសង្គហៈ*, បោះពុម្ពដោយ រោងពុម្ពគឹមសេង, ភ្នំពេញ, ឆ្នាំ ព. ស. ២៥០១ គ. ស. ១៩៥០, ចម្លងដោយ បណ្ណាគារត្រៃរតន៍

១៦. តួរ កិម, ព្រះគ្រូសិរីសោភ័ណ, *បទានុក្រមធម្មបទ* ភាគ៣, បោះពុម្ពដោយ រោងពុម្ព មិត្តភាព កម្ពុជា-ជប៉ុន, ភ្នំពេញ, ឆ្នាំ ព. ស. ២៥៣៨ គ. ស. ១៩៩៤

១៧. Dhammananda K. Sri Dr, "*ខ្លឹមសារជីវិត*" ប្រែសម្រួលជាភាសាខ្មែរដោយ ភិក្ខុ ស៊ុយ សុវណ្ណ, បោះពុម្ពឆ្នាំ ២០០៩

១៨. Dhammananda K. Sri Dr, *Buddhist Principles for*

*Human Dignity*, បោះពុម្ពលើកទី ១ ដោយ Buddhist Missionary Society, ម៉ាឡេស៊ី, ឆ្នាំ ១៩៩៦, បោះពុម្ពឡើងវិញដោយ The Corporate Body of the Buddha Education Foundation, តៃវ៉ាន់, ឆ្នាំ ១៩៩៨

១៩. នាង សេខ ព្រះពុទ្ធវង្ស, *បាលីវេយ្យាករណ៍*, បោះពុម្ពលើកទី ៨ ដោយ វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ, ឆ្នាំ គ. ស. ២៤៩៧ គ. ស. ១៩៥៤

២០. នាង សេខ ព្រះគ្រូមុនីសោភ័ណ, *អភិធម្មត្ថសង្គហៈពិស្តារ សំនួរ-ចម្លើយ*, បោះពុម្ពដោយរោងពុម្ព វិថីប៉ាស្ទ័រ, ភ្នំពេញ, ឆ្នាំ ព. ស. ២៤៩៧ គ. ស. ១៩៥៤

២១. Narada Maha Thera, *The Buddha and His Teachings*, បោះពុម្ពដោយ The Corporate Body of the Buddha Educational Foundation, តៃវ៉ាន់, ឆ្នាំ ២០០៩

២៣. នឿន យិន ព្រះមហា, *គាថាធម្មបទ*, (ប្រែ), បោះពុម្ពលើកទី ១ ដោយ MITR SIAM PRESS, បាងកក, ឆ្នាំ ព. ស. ២៥៣៤ គ.ស. ១៩៩១

២៤. បរិហារវនខេត្ត សុចិន្ត, *បរមត្ថធមិសង្ខេប ចិត្តសង្ខេប និង ភាគបន្ថែម*, ប្រែសម្រួលជាខេមរភាសាដោយ ធម្មាចារ្យ រស់ សុផាត, បោះពុម្ពដោយមូលនិធិសិក្សា និង ផ្សព្វផ្សាយព្រះពុទ្ធ-សាសនា, បាងកក, ឆ្នាំ ១៩៩៤

២៥. ភេន ង៉ិន ព្រះភិក្ខុ ឥន្ទប្បញ្ញោ, *គូដៃនៃមនុស្ស*, បោះពុម្ពនៅ វត្តពោធិវង្ស, ប្រទេសបារាំង, ឆ្នាំ ១៩៩៩

២៦. Mahasi Sayadaw, *Fundamentals of Vipassana Meditation*, បកប្រែជាភាសាអង់គ្លេស ដោយ U Maung Tha Noe, បោះពុម្ពដោយ The Corporate Body of the Buddha Education Foundation, តៃវ៉ាន់, ឆ្នាំ ២០០៨

២៧. Lay Ko U and Lwin Tin U, *The Great Chronicle of Buddhas CD*, រចនាដោយ Technology នៃសាកល-វិទ្យាល័យពុទ្ធសាសនាទូតថេរវាទអន្តរជាតិ, កំណែទី ១, យ៉ាំងហ្គូន

២៨. Liow B., *How to Develop Happiness in Daily Living*, Setiakawan, Selangor ឆ្នាំ ២០០៥

២៩. សាយ អៀង, សាស្ត្រាចារ្យនៅវិទ្យាស្ថានជាតិគរុកោសល្យ, *មេកាព្យ*, ឆ្នាំ ព. ស. ២៥០៩ គ. ស. ១៩៦៦

៣០. សាវង្ស ប៊ុត លោកគ្រូ, *ព្រះពុទ្ធសាសនា-ខ្លឹមសារគួរយល់ដឹង* , បោះពុម្ពដោយ The Corporate Body of the Buddha

Educational Foundation, តៃវ៉ាន់, ឆ្នាំ ២00៣

៣១.សាវណ្ណ ហុក ព្រះតេជគុណបណ្ឌិត, *តួនាទីរបស់ព្រះសង្ឃក្នុងសង្គមខ្មែរ*, ឆ្នាំ គ. ស. ២៥៥២ គ. ស. ២00៨

៣២.ស៊ីវ សុង ព្រះភិក្ខុ, *ពុទ្ធសាសនា និងវិទ្យាសាស្ត្រ*, បោះពុម្ពផ្សាយលើកទី ២ ដោយបណ្ណាគារ យាយតាធមិ, ភ្នំពេញ, ព.ស. ២៥១៦, គ.ស. ១៩៧២

៣៣. សុវណ្ណ កៅ មហាបរិយត្តិ ឧត្តមវិជ្ជា, *វិវិធម្មសង្គហៈ*, បោះពុម្ព ដោយបណ្ណាគារមូលមិត្ត, ភ្នំពេញ, ឆ្នាំ ១៩៧0

៣៤.វិទ្យាស្ថានស្រាវជ្រាវវិបស្សនា, *វិនយ អដ្ឋកថា បាចិត្តិយអដ្ឋកថា*, រៀបចំដោយវិទ្យាស្ថានស្រាវជ្រាវវិបស្សនា, កំណែ ៤.0.0.១៥, ញ៉ូដេលី

៣៥.ឱមសាម៉េង ឥន្ទ លោក, *ប្រវត្តិទស្សនៈ សាសនា សីលធមិនយោបាយ*, បោះពុម្ពឆ្នាំ ២00៥

## គណៈកម្មការត្រួតពិនិត្យ និងកែសម្រួល

-ភិក្ខុ **សឿង វុឌ្ឍី** ថ្នាក់អនុបណ្ឌិត

-ភិក្ខុ **ឈុំ ឆន** ថ្នាក់អនុបណ្ឌិត

-ភិក្ខុ **អ៊ុំ សត្ថា** ថ្នាក់បរិញ្ញាបត្រ

-ភិក្ខុ **មួន វិចិត្រ** ថ្នាក់បរិញ្ញាបត្រ

-ភិក្ខុ **ថ៉ាន ភាគ** ថ្នាក់ឱប្លម

-ភិក្ខុ **ថ៉ា ច័ន្ទប៊ិន់** ថ្នាក់ឱប្លម

-ភិក្ខុ **ឡេង ប៊ុននាង** ថ្នាក់ឱប្លម

-សាមណេរ **ថុង ត្រាកន** ថ្នាក់ឱប្លម

-សាមណេរ **ឌិន ម៉ៅ** ថ្នាក់ឱប្លម

-លោក **ម៉ៅ ស៊ីថា** ថ្នាក់អនុបណ្ឌិត

## គណៈកម្មការវាយកុំព្យូទ័រ

-ភិក្ខុ **ព្រហ្ម សំណាង** ថ្នាក់បរិញ្ញាបត្រ

-ភិក្ខុ **លាង សារ៉យ** ថ្នាក់បរិញ្ញាបត្រ

-ភិក្ខុ **ស៊ុយ សុវណ្ណ** ថ្នាក់បរិញ្ញាបត្រ

-សាមណេរ **សុខ ធាវី** ថ្នាក់បរិញ្ញាបត្រ

-សាមណេរ **ឆ្លិច មាស** ថ្នាក់ឱប្លម

-សាមណេរ **ភាឡាន ម៉េងហុង** ថ្នាក់ឱប្លម

-លោក **ព្រំ ស៊ីណា** ថ្នាក់បរិញ្ញាបត្រ

**រចនាក្រុបដោយ**

ភិក្ខុ **ស៊ុយ សុវណ្ណ**


**អាសយដ្ឋាន**

**សមណនិស្សិតខ្មែរ**

Khmer Buddhist Student Monks
The International Theravada Buddhist Missionary
University (I.T.B.M.U), Dhammapala Hill, P.O,
Mayangone Township, Yangon, Myanmar
E-mail: info.ksma@gmail.com
Website: http://info-ksma.ning.com
http://info-ksma.blogspot.com